វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១៣-១៤

## ការអភិវឌ្ឍសម្រាប់ទាំងអស់គ្នា ចីរភាព និងអភិបាលកិច្ច នៅកម្ពុជា





ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន វបសអ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១៣-១៤

*Annual Development Review*
*2013 - 2014*

ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១៤

ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជា ខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ CDRI មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

CDRI ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

**© រក្សាសិទ្ធិឆ្នាំ២០១៤ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាអេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN-10: 99950–52–89-8

**សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១៣-២០១៤**
*Annual Development Review 2013-14*
ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១៤

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ ទូរស័ព្ទ៖ (៨៥៥២៣) ៨៨១៣៨៤, ៨៨១៧០១, ៨៨១៩១៦, ៨៨៣៦០៣
🖶 ទូរសារ៖ (៨៥៥២៣) ៨៨០៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ-ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយ៖ ខេង-សេង
បោះពុម្ពនៅប្រទេសកម្ពុជា ដោយ Invent Cambodia

# មាតិកា


បញ្ជីអក្សរកាត់ ........ x

១. ការអភិវឌ្ឍសម្រាប់គ្រប់គ្នា ចីរភាព និងអភិបាលកិច្ចនៅកម្ពុជា៖ និន្នាការ ឧបសគ្គ និងបញ្ហាប្រឈម ........ 1

១. សេចក្តីផ្តើម ........ 1

២.កំណើននិងភាពក្រីក្រ ........ 2

៣. សុខភាព និងការអប់រំ ........ 3

៤. ការផ្លាស់ប្តូរក្នុងកសិកម្ម ........ 5

៥. ចីរភាព៖ ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន ........ 6

៦. អភិបាលកិច្ច៖ វិមជ្ឈការតាមបែបប្រជាធិបតេយ្យ ........ 8

៧. សេចក្តីសន្និដ្ឋាន ........ 9

បញ្ជីគន្ថនិទ្ទេស ........ 10

២. កម្ពុជា និងតំបន់ជុំវិញ - បញ្ហាប្រឈម និងជម្រើស ........ 11

១. សេចក្តីផ្តើម៖ កម្ពុជា និងតំបន់ជុំវិញ - "ពេលវេលាគួរឲ្យចាប់អារម្មណ៍"11

២. កម្ពុជា និង តំបន់ជុំវិញ៖ បរិបទគោលនយោបាយ ........ 13

៣. ពាណិជ្ជកម្មសេរី និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់៖ ឱកាស និង បញ្ហាប្រឈម សម្រាប់កម្ពុជា ........ 14

៣.១ ការរីកដុះដាលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកម្លាំងជំរុញ ........ 14

៣.២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទូទាំងតំបន់សំខាន់ៗ ........ 15

៣.៣ ឱកាស និងបញ្ហាប្រឈមសម្រាប់កម្ពុជា ........ 16

៤. កម្ពុជា និងតំបន់ជុំវិញនាពេលអនាគត - បញ្ហាប្រឈម និងជម្រើស "ការតភ្ជាប់"៖ តើវាមានន័យដូចម្តេចសម្រាប់កម្ពុជានៅក្នុងមហាអនុតំបន់ទន្លេមេគង្គ អាស៊ាន អាស៊ីបូព៌ា និងលើសពីនេះទៀត? ........ 18

៤.១ បង្រួមគម្លាតអភិវឌ្ឍន៍ (NDG) ក្នុងអាស៊ាន ........ 19

៤.២ ចលនាពលកម្ម ........ 19

៤.៣ សំណួរផ្នែកគោលនយោបាយមួយចំនួនសម្រាប់កម្ពុជា និងតំបន់ជុំវិញ ........ 20

ឯកសារយោង ........ 22

**៣. ការវាយតម្លៃពីភាពអំណោយផលដល់ជនក្រីក្រនៃកំណើនសេដ្ឋកិច្ច ការថែទាំសុខភាព និងការអប់រំនៅកម្ពុជា ..... 23**
១. សេចក្តីផ្តើម ..... 23
២. ក្របខ័ណ្ឌវិភាគ និងវិធីសាស្ត្រស្រាវជ្រាវ ..... 24
៣. ទិន្នន័យ ..... 25
៤. ការពិពណ៌នាស្ថិតិសង្ខេប: ចំណាយប្រើប្រាស់ និង ចំណាយមិនប្រើប្រាស់ ..... 25
៥. ភាពបានជាប្រយោជន៍ដល់ទាំងអស់គ្នា៖ កំណើនជួយទ្រទ្រង់ដល់ជនក្រីក្រ ..... 29
៥.១ ចំណាយប្រើប្រាស់ ..... 29
៥.២ ចំណាយមិនប្រើប្រាស់ ( non-consumption )៖ សុខភាព និងការអប់រំ ..... 30
៦. ការសន្និដ្ឋាន និងអនុសាសន៍ ..... 33
ឯកសារយោង ..... 35

**៤. យុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែមសម្រាប់កុមារ៖ ការវាយតម្លៃពីឥទ្ធិពលយុទ្ធនាការ ទៅលើទម្លាប់នៃការផ្តល់អាហារទៅឲ្យកុមារ ..... 36**
១. សេចក្តីផ្តើម ..... 36
២. វិធីសាស្ត្រ និងក្របខណ្ឌវិភាគ ..... 37
៣. លទ្ធផលស្រាវជ្រាវ ..... 38
៣.១ ការរំលឹកពី សាររបស់ CFC ការយល់ដឹង/ ចំណេះដឹង និងការយកចិត្តទុកដាក់ . 39
៣.២ ការទទួលយក និងភាពសមស្របនៃសារ ..... 39
៣.៣ ការអនុវត្ត ..... 40
៤. ការពិភាក្សា ..... 40
៥. សេចក្តីសន្និដ្ឋាន និងការរៀនសូត្របាន ..... 42
បញ្ជីគន្ធនិទ្ទេស ..... 43

**៥. ចំណាយសាធារណៈលើការអប់រំសម្រាប់គ្រប់គ្នានៅកម្ពុជា៖ ការវិភាគពីទំហំអត្ថប្រយោជន៍១ ..... 44**
១. សេចក្តីផ្តើម ..... 44
២. ការសិក្សាលើឯកសារពាក់ព័ន្ធនានា ..... 45
៣. ទិន្នន័យ និង វិធីសាស្ត្រស្រាវជ្រាវ ..... 46
៣.១. ទិន្នន័យ ..... 46
៣.២. ការវិភាគទំហំអត្ថប្រយោជន៍ ..... 46
៣.៣. ការវិភាគទំហំអត្ថប្រយោជន៍ទទួលបានពីឯកតាបន្ថែម ..... 47
៤. លទ្ធផលសិក្សាជាក់ស្តែង ..... 48
៥. សេចក្តីសន្និដ្ឋាន និងគោលនយោបាយពាក់ព័ន្ធ ..... 52

ឯកសារយោង ..... 53

**៦. អាទិភាពគោលនយោបាយដើម្បីបង្កើនទិន្នផល និងផលស្រូវនៅកម្ពុជា ..... 55**
១. សេចក្តីផ្តើម ..... 55
២. ចំណាយខ្ពស់លើធាតុចូលកសិកម្ម ..... 55
៣. ការចែកចាយកម្មសិទ្ធិដីធ្លីដោយគ្មានប្រសិទ្ធភាព និងសមធម៌ ..... 57
៤. ឧបសគ្គជាលក្ខណៈរចនាសម្ព័ន្ធនៃទីផ្សារស្រូវអង្ករបស់កសិករតូចតាច ..... 58
៥. ការជ្រៀតចូលទៅក្នុងទីផ្សារអង្ករពិភពលោក ..... 59
៦. គោលនយោបាយនាបច្ចុប្បន្ន និងទៅអនាគត ..... 61
ឯកសារយោង ..... 62

**៧. ឧស្សាហកម្មជីនៅកម្ពុជាៈ និន្នាការ បញ្ហាប្រឈម និងឱកាស ..... 63**
១. សេចក្តីផ្តើម ..... 63
២. រចនាសម្ព័ន្ធឧស្សាហកម្មជី ..... 63
២.១. សាវតារ ..... 63
២.២. និន្នាការនៃការផ្គត់ផ្គង់ ..... 64
២.៣. តួនាទីរដ្ឋាភិបាល ..... 64
២.៤. រចនាសម្ព័ន្ធឧស្សាហកម្មជី ..... 64
២.៥. អង្គភាពនាំចូល ..... 65
៣. បញ្ហាចោទខាងផ្នែកតម្រូវការ ..... 65
៣.១. និន្នាការនៃការប្រើប្រាស់ ..... 65
៣.២. ការប្រើប្រាស់តាមមុខដំណាំ ..... 66
៣.៣. ឧបសគ្គចម្បងៗប៉ះពាល់ដល់ការប្រើប្រាស់ជី ..... 66
៤. បញ្ហាចោទខាងផ្នែកផ្គត់ផ្គង់ ..... 67
៤.១. ខ្សែចង្វាក់ផ្គត់ផ្គង់ជី ..... 67
៤.២. ប្រព័ន្ធបទបញ្ញត្តិច្បាប់ ..... 67
៤.៣. ឧបសគ្គសំខាន់ៗប៉ះពាល់ការផ្គត់ផ្គង់ជី ..... 68
៥. ផ្លូវដើរទៅមុខ ..... 68
ឯកសារយោង ..... 70

**៨. ឥទ្ធិពលសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅលើផលិតកម្មស្រូវៈ ភស្តុតាងផ្អែកលើទិន្នន័យបានពីអង្កេតជាបន្តបន្ទាប់ ក្នុងប្រាំបួនភូមិ នៅកម្ពុជា ..... 71**
១. សេចក្តីផ្តើម ..... 71
២. ការពិនិត្យលើឯកសារពាក់ព័ន្ធ ..... 71

៣. សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅកម្ពុជា ..... 72
៤. ទិន្នន័យ ..... 73
៤.១. ប្រភពទិន្នន័យ ..... 73
៤.២. ស្ថិតិបែបពណ៌នាសម្រាប់អង្កេតដំបូង និងចុងបញ្ចប់ ..... 73
៥. វិធីសាស្ត្រគណនា ..... 74
៦. ការគណនាជាក់ស្តែង ..... 74
៧. សន្និដ្ឋាន ..... 75
ឯកសារយោង ..... 77

**៩. ការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ សមត្ថភាពបន្សាំ និងអភិបាលកិច្ចធនធានទឹកក្នុងអាងទន្លេសាប ..... 78**
១. សេចក្តីផ្តើម ..... 78
១.១. ការប្រែប្រួលអាកាសធាតុ នៅប្រទេសកម្ពុជា និងនៅអាងទន្លេសាប ..... 78
១.២. គោលបំណង និងសំណួរស្រាវជ្រាវ ..... 79
១.៣. ទស្សនទាននៃការប្រែប្រួលអាកាសធាតុ និងសមាសភាគនៃភាពងាយរងគ្រោះ 79
២. វិធីសាស្ត្រស្រាវជ្រាវ ..... 80
៣. លទ្ធផល ..... 81
៣.១. ការប្រែបរួលអាកាសធាតុ៖ និន្នាការ និងផលប៉ះពាល់ ..... 81
៣.២. សមត្ថភាពបន្សាំ ..... 84
៣.៣. វិបាក ចំពោះអភិបាលកិច្ចធនធានទឹក ..... 85
៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..... 86
ឯកសារយោង ..... 88

**១០. ការធ្វើឲ្យវិស័យទេសចរណ៍នៅកម្ពុជាមានភាពបៃតង: សក្តានុពល ឧបសគ្គ និងជម្រើសគោលនយោបាយ១ ..... 89**
១. សេចក្តីផ្តើម ..... 89
២. សក្តានុពលសម្រាប់ទេសចរណ៍ធម្មជាតិនៅកម្ពុជា ..... 93
២.១. ទេសចរណ៍ប្រកបដោយនិរន្តរភាព ..... 93
២.២. អេកូទេសចរណ៍ ..... 93
២.៣. ទេសចរណ៍បៃតង ..... 94
២.៤. សក្តានុពលអេកូទេសចរណ៍ និង ទេសចរណ៍បៃតងនៅកម្ពុជា ..... 94
៣. ការធ្វើឲ្យវិស័យទេសចរណ៍កម្ពុជាមានភាពបៃតង: ឧបសគ្គ និងតម្រូវការ ..... 96
៣.១ ការកាត់បន្ថយកាបូន និងកត្តាគំរាមកំហែងទៅលើវិស័យទេសចរណ៍កម្ពុជា ..... 98

៣.២ វិស័យទេសចរណ៍ និងការប្រែប្រួលអាកាសធាតុ ........ 98
៣.៣ ឥទ្ធិពលនៃការរីកចម្រើនវិស័យទេសចរណ៍ទៅលើធនធានធម្មជាតិ ........ 99
៤. គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល៖ ជម្រើសគោលនយោបាយថ្មីៗ និងគម្រោងជំនួយរបស់រដ្ឋ ........ 100
៥. សេចក្តីសន្និដ្ឋាន ........ 103
ឯកសារយោង ........ 106

**១១. ឥទ្ធិពលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ទៅលើលទ្ធិប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន៖ ទស្សនៈពីភូមិវិទ្យានយោបាយផ្អែកលើការសិក្សាពីគម្រោងបោះព្រំទន្លេសាប ........ 109**
១. ក្របខ័ណ្ឌនៃការវិភាគ ........ 109
២. វិធីសាស្ត្រស្រាវជ្រាវ និងករណីសិក្សា ........ 110
៣. លទ្ធផលរកឃើញ ........ 110
៣.១ ការបង្កើតផែនទី និងគណនេយ្យភាព ........ 110
៣.២ ការបោះបង្គោលព្រំ និងគណនេយ្យភាព ........ 111
៣.៣ តម្រូវការរបស់ប្រជាជន ការតំណាង និងការឆ្លើយតប ........ 112
៤. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន ........ 112
បញ្ជីគន្ថនិទ្ទេស ........ 113

**១២. ទំនាក់ទំនងរវាងក្រុមប្រឹក្សា ស្រុក/ក្រុង/ខ័ណ្ឌ នឹងឃុំ/សង្កាត់៖ ភាពតំណាង និងគណនេយ្យភាព ក្នុងអភិបាលកិច្ចមូលដ្ឋាន ........ 114**
១.សេចក្តីផ្តើម ........ 114
២. ទិដ្ឋភាពទូទៅនៃកំណែទម្រង់នៅកម្ពុជា ........ 115
៣. លទ្ធផលស្រាវជ្រាវ ........ 117
៣.១ គណនេយ្យភាពនៅក្នុង DMK ........ 117
៣.២ ឃុំ/សង្កាត់ និង ស្រុក/ខ័ណ្ឌ/ក្រុង៖ អ្នកតំណាងមានគណនេយ្យភាពឬទេ? ........ 120
៤. សេចក្តីសន្និដ្ឋាន ........ 120
ឯកសារយោង ........ 122

**បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន វបសអ ........ 124**

# បញ្ជីតារាង និងរូបភាព

**ជំពូក ៣**

តារាង ១៖ កម្រិតចាប់ប្រែប្រួលសំខាន់ៗ បានយកមកប្រើសម្រាប់វាយតម្លៃលើកំណើនទ្រទ្រង់ជនក្រីក្រ ... 25
តារាង ២៖ មេគុណ Gini ប៉ាន់ស្មាន នៃ វិសមភាពចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់, តាមឆ្នាំ ... 27
តារាង ៣៖ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារអាយុក្រោមប្រាំឆ្នាំ គិតតាមក្រុមបញ្ចភាគ (z-score) ... 27
តារាង ៤៖ សុខភាពគ្រួសារនិងការអប់រំ គិតតាមស្ថានភាពទ្រព្យធន ឆ្នាំ២០០៥-១០ (z-score) ... 28
តារាង ៥៖ ឥទ្ធិពលនៃកំណើន និងវិសមភាព ទៅលើភាពក្រីក្រ ... 29
តារាង ៦៖ ឥទ្ធិពលនៃកំណើន និងវិសមភាព ទៅលើភាពក្រីក្រផ្នែកសុខភាព ... 31
តារាង ៧៖ ឥទ្ធិពលនៃកំណើន និងវិសមភាព ទៅលើភាពក្រីក្រផ្នែកអប់រំ ... 32

រូបភាព ១៖ ខ្សែកោងដង់ស៊ីតេចំណាយប្រើប្រាស់ពិតប្រចាំថ្ងៃក្នុងមនុស្សម្នាក់ ... 26
រូបភាព ២៖ អត្រាកំណើនសមមូលនៃភាពក្រីក្រ (PEGR) សម្រាប់ចំនួនជនក្រីក្រ $\alpha = 0$ ... 30

**ជំពូក ៥**

តារាង ១៖ អត្រានៃការចូលរួម និងចំណែកនៃចំណាយសាធារណៈ (%) ... 48
តារាង ២៖ អត្ថប្រយោជន៍ទទួលបានពីឯកតាបន្ថែម ... 50
តារាង ៣៖ អត្រាសិស្សចូលរៀន និងការបែងចែកចំណាយសាធារណៈតាមតំបន់ភូមិសាស្ត្រ (%) ... 51

រូបភាព ១៖ ខ្សែកោងតំណាងឲ្យចំណាយរបស់រដ្ឋាភិបាល និង គំរូប្រៀបធៀបពីរ ... 47
រូបភាព ២៖ ខ្សែកោងតំណាងឲ្យចំណាយសាធារណៈលើវិស័យអប់រំក្នុងឆ្នាំ២០១១ ... 49

ឧបសម្ព័ន្ធ ១៖ រចនាសម្ព័ន្ធអប់រំនៅកម្ពុជា ... 54
ឧបសម្ព័ន្ធ ២៖ លក្ខណៈជឿនលឿននៃចំណាយសាធារណៈលើវិស័យអប់រំ នៅឆ្នាំ២០០៤ និង២០០៩ ... 54

**ជំពូក ៦**

តារាង ១៖ ខ្សែចង្វាក់តម្លៃអង្ករនៅរដូវវស្សា និងរដូវប្រាំង នៅខេត្តតាកែវ, ខែកុម្ភៈ ២០១២ 58
តារាង ២៖ សមត្ថភាពរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា ... 60

រូបភាព ១៖ កម្មសិទ្ធិដីធ្លីក្នុងវិស័យកសិកម្មចំពោះគ្រួសារជនបទនៅកម្ពុជា ... 58

## ជំពូក ៧


តារាង ១៖ ផលិតកម្មស្រូវ បែងចែកតាមប្រភេទក្រុមគ្រួសារ និងឆ្នាំ.......... 73
តារាង ២៖ លទ្ធផលវាយតម្លៃដោយប្រើវិធីសាស្រ្ត DD (ការប្រៀបធៀបរវាងទិន្នផលជាមធ្យមនៃក្រុមរងប្រព្រឹត្តកម្ម នឹងក្រុមសម្រាប់ប្រៀបធៀប) គណនាដោយប្រើកម្មវិធី STATA.......... 75

រូបភាព ១៖ និន្នាការក្នុងការប្រើប្រាស់ជី ឆ្នាំ២០០៧-២០១១ (តោន).......... 65


## ជំពូក ៩


រូបភាព ១៖ ទំនាក់ទំនងរវាងសមាសភាគផ្សេងៗ នៃភាពងាយរងគ្រោះ.......... 80
រូបភាព ២៖ ប្រភេទនិងទំហំនៃការខូចខាត បណ្តាលមកពីគ្រោះធម្មជាតិ ក្នុងខេត្តកំពង់ធំ.....81
រូបភាព ៣៖ ប្រភេទនិងទំហំនៃការខូចខាត បណ្តាលមកពីគ្រោះធម្មជាតិ ក្នុងខេត្តពោធិ៍សាត់82
រូបភាព ៤៖ ប្រភេទនិងទំហំនៃការខូចខាត បណ្តាលមកពីគ្រោះធម្មជាតិ ក្នុងខេត្តកំពង់ឆ្នាំង 83


## ជំពូក ១០


តារាង ១៖ ការរួមចំណែករបស់វិស័យទេសចរណ៍ក្នុងការបង្កើតប្រាក់ចំណូល និងការងារក្នុងឆ្នាំ២០១២.......... 90
តារាង ២៖ ទីផ្សារធំៗទាំង ៥ របស់វិស័យទេសចរណ៍កម្ពុជាពីឆ្នាំ២០០៥ ដល់ ២០១២.... 90
តារាង ៣៖ ព័ត៌មានទេសចរណ៍នានា..........91

តារាង ៤៖ សង្ខេបអំពីកាលានុវត្តភាព និង ហានិភ័យនានា.......... 103


## ជំពូក ១២


តារាង ១៖ គំនូរបង្ហាញរចនាសម្ព័ន្ធរដ្ឋបាលរបស់រដ្ឋាភិបាល..........116

# បញ្ជីអក្សរកាត់

ផសស ផលិតផលក្នុងស្រុកសរុប
AIC ក្រុមហ៊ុនធាតុចូលកសិកម្ម ( Agricultural Inputs Company )
ASEAN សមាគមអាស៊ាន ( Association of Southeast Asian Nations )
CBET សហគមន៍អេកូទេសចរណ៍ ( Community-based ecotourism )
CDRI វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( Cambodia Development Resource Institute )
CFM យន្តការហិរញ្ញប្បទានកាបូន ( Carbon finance mechanisms )
CIF ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ( Climate Investment Funds )
CPA តំបន់ការពារសហគមន៍ ( Community protected area )
CSES អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ( Cambodia Socio-Economic Survey )
EIA ការវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាន ( Environmental Impact Assessments )
GMS មហាអនុតំបន់មេគង្គ Greater Mekong Sub-region
GTZ កិច្ចសហការពីអង្គការអាល្លឺម៉ង់ ( German Technical Cooperation Agency )
IFPRI វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ ( International Food Policy Research Institute )
JICA ទីភ្នាក់ងារសហប្រត្តិបត្តិការអន្តរជាតិ ជប៉ុន ( Japan International Cooperation Agency )
MAFF ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( Ministry of Agriculture, Forestry and Fisheries )
MDT ដំណើរផ្លូវស្វែងយល់ពីទន្លេមេគង្គ ( Mekong Discovery Trail )
MFI គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ( Microfinance Institutions )
NAADS ឥទ្ធិពលនៃកម្មវិធីសេវាប្រឹក្សាផ្នែកកសិកម្មជាតិរបស់ប្រទេសអ៊ូហ្គង់ដា ( National Agricultural Advisory Services )
OECD អង្គការសហប្រត្តិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ ( Organisation for Economic Co-operation and Development )
PATA សមាគមន៍ធ្វើដំណើរអាស៊ីប៉ាស៊ីហ្វិក ( Pacific Asia Travel Association )
Sida ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែ ( Swedish International Development Cooperation Agency )
UNEP កម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ ( United Nations Environment )
USAID ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ( United States of America International Aid )
WCS សង្គមអភិរក្សសត្វព្រៃ ( Wildlife Conservation Society )
WEF អង្គការវេទិកាសេដ្ឋកិច្ចពិភពលោក ( World Economic Forum )
WWF មូលិធិសត្វព្រៃពិភពលោក ( World Wildlife Foundation )

-១-

# ការអភិវឌ្ឍសម្រាប់គ្រប់គ្នា ចីរភាព និងអភិបាលកិច្ច នៅកម្ពុជាៈ និន្នាការ ឧបសគ្គ និងបញ្ហាប្រឈម

*ដោយ Srinivasa Madhur*[9]

## ១. សេចក្តីផ្តើម

កម្ពុជាកំពុងមានការផ្លាស់ប្តូរយ៉ាងលឿនទាំងក្នុងផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ។ ដោយមានកំណើន ផសស ប្រចាំឆ្នាំជាមធ្យម ៧,៧% ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាកំពុងឈានឡើង ពីឋានៈជាប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ សង្គមមួយដែលបានបែកខ្ញែកដោយសារសង្គ្រាមស៊ីវិលអូសបន្លាយ និងការបៀតបៀនពីខាងក្រៅក្នុងទសវត្សរ៍ ១៩៧០ និង ១៩៨០ កំពុងបង្ហាញនូវការរួបរួមគ្នាក្នុងសង្គម និងសាមគ្គីភាពដ៏រឹងមាំ។ ប្រទេសដែលកាលពីពីរទសវត្សរ៍មុនមានភាពក្រីក្រច្រើនពាសពេញ, ស្ថានភាពដុនដាបផ្នែកសុខាភិបាល និងអនក្ខរកម្មកម្រិតខ្ពស់នោះ ឥឡូវនេះ បែរជាអាចកាត់បន្ថយភាពក្រីក្រពុំរ៉ែអស់ជាងពាក់កណ្តាល, រីកលូតលាស់យ៉ាងខ្លាំងផ្នែកសុខាភិបាល និងសឹងតែសម្រេចបានការអប់រំកម្រិតបឋមសិក្សាជាសាកល។ ប្រទេសកម្ពុជាបានធ្វើការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច និងសង្គម ទន្ទឹមគ្នានឹងការចាប់ផ្តើមដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម និងវិសហមជ្ឈការជំរុញឡើងដោយកម្លាំងខាងក្នុង នូវទម្រង់រដ្ឋាភិបាល។ ដោយបានទទួលស្គាល់នូវសមិទ្ធផលអភិវឌ្ឍន៍ទាំងនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបញ្ចូលកម្ពុជា ទៅក្នុងតារាងប្រទេសមានចំណូលទាប "ពោរពេញដោយថាមពល" ដែលសេដ្ឋកិច្ចបានចាប់ផ្តើមស្ទុះឡើងក្នុងទសវត្សរ៍១៩៩០ (IMF 2013)។

សូចនាករនាពេលបច្ចុប្បន្នបង្ហាញថា ទោះបីមានការជាប់គាំងផ្នែកនយោបាយក្រោយការបោះឆ្នោតជាតិកាលពីខែកក្កដា ២០១៣ ក្តី ក៏កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ ទំនងមានប្រហែល ៧% ដែលស្រដៀងគ្នានឹងកំណើនប្រចាំឆ្នាំ ពីឆ្នាំ ២០១១-២០១៣ (ADB 2013; IMF 2013; World Bank 2014)។ ដោយសារគណនីចរន្តទទួលមូលនិធិយ៉ាងច្រើនពីជំនួយពីខាងក្រៅ និងវិនិយោគផ្ទាល់ពីបរទេស ហើយអតិផរណាប្រចាំឆ្នាំនៅមានកម្រិតជាមធ្យម ៥% ក្នុងប៉ុន្មានខែចុងក្រោយនេះ ដូច្នេះកំណើនក្នុងពេលខាងមុខហាក់ពុំមានហានិភ័យផ្នែកម៉ាក្រូហិរញ្ញវត្ថុទេ ថ្វីបើកំណើនយ៉ាងលឿននៃឥណទានធនាគារក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បង្ហាញពីតម្រូវការវិធានការប្រយ័ត្នប្រយែងផ្នែកគោលនយោបាយក្តី (Heng 2014)។ ប្រសិនបើកម្ពុជាអាចរក្សាសន្ទុះកំណើនបច្ចុប្បន្ន រហូតដល់ឆ្នាំ២០១៨ នោះ កម្ពុជានឹងចូលទៅក្នុងក្រុមប្រទេសទាំង១៦ ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងមានចីរភាព គិតតាំងពីក្រោយសង្គ្រាមលោកលើកទី២ មក (គឺ មានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ៧%ឬច្រើនជាងនេះក្នុងរយៈពេលប្រហែល២៥ឆ្នាំ) ដោយឡែកប្រទេសវៀតណាមហាក់សម្រេចបានលទ្ធផលនេះនៅឆ្នាំ២០១១ (CGD 2008; Madhur and Menon 2014)។

[9] Srinivasa Madhur ជានាយកផ្នែកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI ។

ថ្វីបើកន្លងមក កម្ពុជាសម្រេចបានលទ្ធផលគួរឲ្យកោតសរសើរក្តី ប៉ុន្តែកម្ពុជានៅមានរបៀបវារៈអភិវឌ្ឍន៍ត្រូវអនុវត្តជាច្រើនទៀត មានជាអាទិ៍ ការរក្សានូវកំណើនខ្លាំងក្លា, ការធានាឲ្យកំណើនហុចផលដល់គ្រប់គ្នាក្នុងសង្គម, ការធានាថា កំណើននិងការអភិវឌ្ឍនៅតែរក្សាបាននូវចីរភាពនៃបរិស្ថាន, និង ការពង្រឹងអភិបាលកិច្ច និងស្ថាប័នសាធារណៈសម្រាប់ការអភិវឌ្ឍ (CDRI 2013; World Bank 2013;CDRI 2014)។

នៅពេលមានអាទិភាពថ្មីៗកំពុងផុសឡើងនៅក្នុង របៀបវារៈអភិវឌ្ឍន៍របស់កម្ពុជាបែបនេះ កម្រងឯកសារនៅក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១៣-១៤ នេះ ធ្វើការពិនិត្យពីនិន្នាការដំណើការ និងបញ្ហាប្រឈមនានា នៅក្នុងវិស័យជាប់ទាក់ទងគ្នាបីគឺ ការអភិវឌ្ឍសម្រាប់គ្រប់គ្នា ចីរភាពនៃបរិស្ថាន និង អភិបាលកិច្ចនៃការអភិវឌ្ឍ។ ជំពូកសេចក្តីផ្តើមនេះ បូកសរុប និងធ្វើសំយោគនូវជំពូកទាំង១២ ដែលស្ថិតក្រោមប្រធានបទតែមួយ។ បញ្ហាទាក់ទងនឹងការអភិវឌ្ឍមានពិភាក្សាក្នុងផ្នែកផ្សេងៗ គឺ កំណើននិងភាពក្រីក្រ (ផ្នែកទី២) សុខភាពនិងការអប់រំ (ផ្នែកទី៣) និងការផ្លាស់ប្តូរក្នុងកសិកម្ម (ផ្នែកទី៤)។ ផ្នែកទី៥ ពិភាក្សាអំពី បញ្ហាចីរភាពបរិស្ថាន, ផ្នែកទី៦ អំពីអភិបាលកិច្ច ហើយផ្នែកទី៧ ជាសេចក្តីសន្និដ្ឋានសង្ខេប។

## ២.កំណើននិងភាពក្រីក្រ

កម្ពុជាជាប្រទេសតូច មានសេដ្ឋកិច្ចបើកចំហខ្លាំង និងស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីប៉ូព៉ាដ៏មានសន្ទុះ។ កម្ពុជាក៏ជាសមាជិកក្នុងកិច្ចផ្តួចផ្តើមធ្វើសហប្រតិបត្តិការ និងសមាហរណកម្មសំខាន់ៗជាច្រើននៅក្នុងតំបន់ និងអនុតំបន់ដែរ។ ទោះបីមានសេដ្ឋកិច្ចបើកចំហ និងទីតាំងភូមិសាស្ត្រអំណោយផលដូច្នេះក្តី ក៏កម្ពុជាមិនទាន់ធ្វើសមាហរណកម្មសេដ្ឋកិច្ចបានល្អទេ ជាពិសេសសជាមួយប្រទេសជិតខាងខ្លួន ឬ នៅក្នុង "រោងចក្រអាស៊ី" ជារួម។

លោក Hing and Strange (ជំពូក ២) បានដាក់កំណើន និងដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជានៅក្នុងបរិបទតំបន់។ អ្នកនិពន្ធវែកញែកថា កម្ពុជាមានសក្តានុពលធំសម្បើមដើម្បីទទួលបានផលចំណេញពី ការផ្តួចផ្តើមសមាហរណកម្មមួយចំនួនដែលកំពុងដំណើរការ ដូចជា ការផ្តួចផ្តើមសម្រាប់មហាអនុតំបន់មេគង្គ (GMS) សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP)។ ដើម្បីឲ្យអត្ថប្រយោជន៍ជាសក្តានុពលនៃការផ្តួចផ្តើមធ្វើសមាហរណកម្មកម្រិតអនុតំបន់ តំបន់ និងអន្តរតំបន់នេះក្លាយជាការពិត កម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមជាច្រើន។ Hing and Strange បានផ្តល់អាទិភាពលើបីចំណុចគឺ ការពង្រឹងភាពតភ្ជាប់ជាមួយប្រទេសជិតខាង (តាមរយៈ ការតភ្ជាប់កាន់តែល្អ តាមផ្លូវថ្នល់ ផ្លូវដែក ការដឹកជញ្ជូនតាមផ្លូវសមុទ្រនិងអាកាស), ធ្វើឲ្យសាមញ្ញនូវប្រព័ន្ធភស្តុភារបម្រើពាណិជ្ជកម្ម (តាមរយៈ តម្លាភាពកាន់តែល្អក្នុងនីតិវិធីផ្នែកភស្តុភារ, ការកាត់បន្ថយកម្រៃក្រៅផ្លូវការទារយកដោយពួកមន្ត្រីនៅតាមព្រំដែន, ការធ្វើសមាហរណកម្មសេវាភស្តុភារបម្រើពាណិជ្ជកម្មរបស់កម្ពុជា ជាមួយប្រទេសជិតខាង) និងកសាងជំនាញរបស់មូលធនមនុស្សនៅកម្ពុជា (តាមរយៈ ការកែលំអលទ្ធភាពទទួលបានសេវាថែទាំសុខភាព និងការអប់រំ និងគោលនយោបាយ ចំណាកស្រុកកម្លាំងពលកម្មកាន់តែបើកទូលាយ តែមានការគ្រប់គ្រងល្អ ដែលជាចំណែកមួយនៃការត្រៀមរៀបចំសម្រាប់ AEC នាពេលខាងមុខ)។

ជំពូក ៣ វិភាគពីនិន្នាការក្នុងកំណើនអំណោយផលដល់ជនក្រីក្រនៅកម្ពុជា និងសូចនាករសុខភាព និងការអប់រំមួយចំនួន។ ដោយប្រើប្រាស់ទិន្នន័យបានពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) Rath and Lun បានរកឃើញថា កំណើននៅកម្ពុជាពីឆ្នាំ២០០៤ ដល់ ២០១១ ជារួមមានភាពអំណោយផលបង្គួរដល់ជនក្រីក្រ។ ភាពអំណោយផលនេះបានកើនឡើងចាប់តាំងពីឆ្នាំ២០០៧ មក ដោយសារវិសមភាពក្នុងចំណាយប្រើប្រាស់បានធ្លាក់ចុះ គឺផ្ទុយពីកំណើនវិសមភាពកាលពីឆ្នាំ២០០៤ ដល់ ២០០៧។ ជាទូទៅលទ្ធផលទាំងនេះ វាស្របនឹងការប៉ាន់ស្មានថ្មីៗរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) និងធនាគារពិភពលោក ដែលបង្ហាញពីការថយចុះយ៉ាងច្រើននូវភាពក្រីក្រតាំងពីឆ្នាំ២០០៧ មក (MOP 2012; World Bank 2013)។ ដោយប្រើទិន្នន័យបានពីអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) អ្នកនិពន្ធបានពង្រីកការវាស់វែងភាពអំណោយផលដល់ជនក្រីក្រ ទៅដល់ផ្នែកពីរទៀតនៃការអភិវឌ្ឍធនធានមនុស្ស ពោលគឺ សុខភាព និងការអប់រំ។ Rath and Lun បានរកឃើញថា ភាពអំណោយផលដល់ជនក្រីក្រផ្នែកសុខភាពកុមារ (វាយតម្លៃតាម ភាពក្រិន ភាពស្គមស្គាំង និងភាពមិនគ្រប់ទម្ងន់) បានធ្លាក់ចុះពីឆ្នាំ២០០៥ ដល់ ២០១១ បើធៀបនឹងនិន្នាការពីឆ្នាំ២០០០ ដល់ ២០០៥។ លទ្ធផលមានស្រដៀងគ្នាដែរសម្រាប់ការអប់រំ (វាស់វែងតាម ចំនួនឆ្នាំសិក្សាជាមធ្យម(mean)) ដែលបានធ្លាក់ចុះពីឆ្នាំ២០០០ ដល់ ២០០៥ បើធៀបនឹង ៥ឆ្នាំមុននោះទៀត។ សរុបមក អ្នកនិពន្ធបានណែនាំឲ្យប្រយ័ត្នថា ទោះបីមានការធ្លាក់ចុះខ្លាំងនូវអាត្រាភាពក្រីក្រចាប់ពីឆ្នាំ២០០៧ មកក្តី ក៏ប្រជាជនក្រីក្រដែលនៅសល់ និងប្រជាជនស្ថិតលើខ្សែបន្ទាត់ភាពក្រីក្រតែបន្តិចបន្តួចនោះ គឺងាយរងគ្រោះជាខ្លាំង បើសិនមានការប៉ះពាល់អវិជ្ជមានទោះតិចតួចក្តីដល់ប្រាក់ចំណូល។

## ៣. សុខភាព និងការអប់រំ

សុខភាពនិងការអប់រំគឺជាធាតុផ្សំ និងជាកត្តាកំណត់នៃការអភិវឌ្ឍ។ សង្គមមួយដែលមានសុខភាពមាំទាំ និងការអប់រំ អាចផ្តល់ឲ្យប្រទេសជាតិនូវពលករមានផលិតភាពល្អសម្រាប់ជួយជំរុញកំណើនសេដ្ឋកិច្ច។ សុខភាពល្អ និងការអប់រំល្អ ក៏ជាបំណងប្រាថ្នារបស់មនុស្សគ្រប់គ្នាដែរ។ ក្នុងបរិបទនេះ ជំពូក ៤ និង ជំពូក ៥ ពិនិត្យលើទិដ្ឋភាពជាក់លាក់មួយចំនួននៃសុខភាព និងការអប់រំនៅកម្ពុជា។

ជំពូក ៤ ពិនិត្យលើ បញ្ហាអាហាររូបត្ថម្ភកុមារ ដែលជាប់ទាក់ទងនឹងកត្តាជាច្រើន ដូចជារបៀបរបបផ្តល់អាហារដល់ទារក ជាដើម។ រដ្ឋាភិបាលបានចាប់អនុវត្តគំនិតផ្តួចផ្តើមជាច្រើនសំដៅកែលំអ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ដូចជា យុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែម (CFC) ជាដើម។ យុទ្ធនាការនេះ បានចាប់ផ្តើមក្នុងខែមេសា ២០១២ និងបានប្រើប្រាស់ទូរទស្សន៍ (តាមលំនាំការផ្សាយពាណិជ្ជកម្មដោយមានផ្តល់ព័ត៌មានជាច្រើន) ពិព័រណ៍សុខភាពដោយមានការចម្អិនអាហារបង្ហាញជាក់ស្តែង ការចុះសាកសួរប្រជាជនតាមផ្ទះ ការប្រជុំតាមក្រុម ដើម្បីផ្សព្វផ្សាយពីផលប្រយោជន៍ គ្រឿងផ្សំ របៀបចម្អិន និងរបបផ្តល់អាហារសម្បូរជីវជាតិ សម្រាប់កុមារមានអាយុពី ៦ ទៅ ២៤ខែ។ កម្មវិធីនេះផ្តោតលើ មាតា និងអ្នកថែទាំកុមារនានា។ ការវាយតម្លៃជាដំបូងដោយ Chea, Nou and Ros បានសន្និដ្ឋានថា ក្នុងរយៈពេលយ៉ាងខ្លីបន្ទាប់ពីបានចាប់អនុវត្ត CFC បានជួយលើកកម្ពស់ការយល់ដឹងរបស់មាតា និងអ្នកថែទាំកុមារ ហើយភាគច្រើនបានអនុវត្តតាមការណែនាំអំពីអាហារសម្រាប់ទារកនេះ។ ទោះយ៉ាងនេះក្តី អ្នកនិពន្ធបានបញ្ជាក់ថា

មិនទាន់មានសញ្ញាអ្វីច្បាស់ទេថា ក្រុមគោលដៅនឹងរក្សារបបផ្តល់អាហារបែបនេះ ក្នុងរយៈពេលវែង។ ការផ្គត់ផ្គង់អគ្គិសនីបានតិចនៅឡើយនៅតាមជនបទ និងឧបសគ្គផ្សេងទៀត បានរារាំងការបញ្ជូនសារនៃយុទ្ធនាការឲ្យបានទៅដល់មាតានិងអ្នកថែទាំទារកនៅតាមជនបទ និងតំបន់ដាច់ស្រយាល តាមរយៈទូរទស្សន៍ដែលជាប្រព័ន្ធផ្សព្វផ្សាយមានប្រសិទ្ធភាពបំផុតនាពេលបច្ចុប្បន្ន។ អ្នកនិពន្ធបានផ្តល់មតិថា ការបន្តយុទ្ធនាការពិតជាមានប្រយោជន៍ ប៉ុន្តែក៏ត្រូវធានាថាក្រុមគោលដៅមិនគ្រាន់តែបានទទួល និងអនុវត្តតាមរបៀបរបបផ្តល់អាហារល្អប្រសើរដល់កុមារនោះទេ គឺថែមទាំងរក្សារបៀបអនុវត្តល្អនេះក្នុងពេលយូរអង្វែងទៀតផង។

ជំពូក ៥ ពិនិត្យលើធាតុសំខាន់ៗនៃការអភិវឌ្ឍសម្រាប់គ្រប់គ្នា ភាពអំណោយផលដល់ជនក្រីក្រនៃចំណាយសាធារណៈលើការអប់រំ។ Tong and Phay បានប្រើការវិភាគពីទំហំអត្ថប្រយោជន៍-(Benefit-incidence analysis: BIA) ដើម្បី វាយតម្លៃភាពអំណោយផលដល់ជនក្រីក្រនៃចំណាយសាធារណៈលើវិស័យអប់រំនាពេលបច្ចុប្បន្ន និង គន់គូរពីទំហំអត្ថប្រយោជន៍ដែលគ្រួសារស្ថិតក្នុងក្រុមមានកម្រិតប្រាក់ចំណូលខុសៗគ្នា អាចទទួលបានពីកំណើនស្មើភាពគ្នានៃចំណាយសាធារណៈ ក្នុងការអប់រំទាំងបីកម្រិត គឺ បឋមសិក្សា (ថ្នាក់ទី១-៦) មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) និងមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២)។ លទ្ធផលវិភាគបង្ហាញថា ចំណាយសាធារណៈនាពេលបច្ចុប្បន្នទៅលើការអប់រំកម្រិតបឋមសិក្សា ជាទូទៅ វាអំណោយផលដល់ជនក្រីក្រ ព្រោះគ្រួសារក្រីក្រទទួលបានអត្ថប្រយោជន៍ច្រើនជាងគ្រួសារធូរធារ អំពីចំណាយទាំងអស់នេះ។ រីឯលទ្ធផលសម្រាប់ចំណាយលើមធ្យមសិក្សាបឋមភូមិមិនសូវល្អដូច្នេះទេ ប៉ុន្តែក៏នៅតែអំណោយផលជាងដល់ជនក្រីក្រដែរ។ ចំពោះចំណាយលើមធ្យមសិក្សាទុតិយភូមិវិញ គឺមិនសូវច្បាស់លាស់ទេ។ ពិតហើយ គេអាចសន្និដ្ឋានបានថា ការពង្រីកចំណាយសាធារណៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ វាផ្តល់អត្ថប្រយោជន៍ដល់គ្រួសារមានជីវភាពមធ្យម ជាងគ្រួសារក្រីក្របំផុត ឬធូរធារបំផុត។ ហេតុផលមួយក្នុងរឿងនេះគឺ សម្រាប់គ្រួសារក្រីក្រ បន្ទុកចំណាយនៃការបញ្ជូនកូនទៅសាលារៀនវាខ្ពស់ខ្លាំងពេក ចំណែកឯសម្រាប់គ្រួសារធូរធារវិញ គេចូលចិត្តបញ្ជូនកូនទៅសាលាឯកជនជាជាងសាលារដ្ឋ។ អ្នកនិពន្ធផ្តល់មតិថា ជម្រើសគោលនយោបាយដើម្បីបង្កើនភាពអំណោយផលដល់ជនក្រីក្រនៃចំណាយលើការអប់រំគឺ គួរគិតគូរលៃចែកឡើងវិញនូវថវិកាអប់រំនាពេលបច្ចុប្បន្ន ដូចជា ការបែងចែកចំនួនភាគរយថវិកាច្រើនជាងមុនសម្រាប់កម្រិតបឋមសិក្សា និងពីព្រោះ វាបង្កើនភាពអំណោយផលដល់ជនក្រីក្រនៃចំណាយសាធារណៈ។ ប៉ុន្តែសម្រាប់មធ្យមសិក្សាទុតិយភូមិវិញ ចំណាយសាធារណៈដែលមានស្រាប់គួរតម្រង់ទិសឲ្យបានល្អជាងមុន ដើម្បីផ្តល់អត្ថប្រយោជន៍ ដល់គ្រួសារក្រីក្រ ជាពិសេសនៅតំបន់ជនបទ។ ចំណុចនេះអាចធ្វើទៅបានតាមរយៈ ការផ្ទេរសាច់ប្រាក់មានលក្ខខណ្ឌសម្រាប់ជនក្រីក្រ, អន្តរាគមន៍ជាសម្ភារៈ (ដូចជាកម្មវិធីផ្តល់អាហារនៅសាលារៀន) ឬក៏ការផ្តល់ជំនួយគាំទ្រដល់ការសិក្សាសម្រាប់ជនក្រីក្រនៅតាមជនបទ ជាដើម។

## ៤. ការផ្លាស់ប្តូរក្នុងកសិកម្ម

ការផ្លាស់ប្តូរក្នុងកសិកម្មមានសក្តានុពលធំធេងដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កំណើនសម្រាប់គ្រប់គ្នា។ កសិកម្មនៅកម្ពុជាមានការផ្លាស់ប្តូរយ៉ាងលឿនក្នុងពីរបីទសវត្សរ៍កន្លងមកនេះ ដោយមានកំណើនយ៉ាងខ្លាំងទាំងក្នុងទិន្នផល និងផលិតកម្ម។ ផ្អែកលើជោគជ័យនេះ កម្ពុជាមានសក្តានុពលធំធេងដើម្បីបង្កើនផលិតភាពថែមទៀត។ ហើយការថយចុះចំនួនភាគរយពលករបម្រើការងារក្នុងវិស័យកសិកម្ម នឹងបញ្ចេញកម្លាំងពលកម្មអតិរេកសម្រាប់ការពង្រីកឧស្សាហកម្ម និងពិពិធកម្មសេដ្ឋកិច្ច។ គឺក្នុងបរិបទនេះហើយ ដែល ជំពូក ៦, ៧ និង ៨ ពិនិត្យពីបញ្ហាប្រឈម និងជម្រើសគោលនយោបាយនានា សម្រាប់ការបង្កើនទិន្នផលកសិកម្ម។

ស្រូវអង្ករមានចំណែកជិតដល់ ៤០% នៃតម្លៃបន្ថែមផ្នែកកសិកម្មរបស់កម្ពុជា ក្នុងឆ្នាំ២០១០ (NIS 2011)។ ដូច្នេះ ការបង្កើនទិន្នផលស្រូវជាកត្តាចាំបាច់ សម្រាប់ឲ្យមានការផ្លាស់ប្តូរលឿនក្នុងកសិកម្ម។ ក្នុងជំពូក ៦ លោក Theng and Flower បានពិនិត្យពី អាទិភាពគោលនយោបាយដ៏ចាំបាច់ៗដើម្បីសម្រេចកិច្ចការនេះ។ កសិករដាំស្រូវភាគច្រើននៅកម្ពុជា មានដីដាំដុះតូច។ បន្ទាប់ពីបានវិភាគល្អិតល្អន់ពីឧបសគ្គ ដែលកសិករតូចតាចត្រូវប្រឈមមុខក្នុងការបង្កើនទិន្នផល Theng and Flower រកឃើញថា គុណភាពពូជស្រូវអន់ ចំណាយខ្ពស់លើធាតុចូល (ដោយសារទីផ្សារជីគ្មានប្រសិទ្ធភាព) ការបែងចែកមិនប្រកបដោយសមធម៌នូវដីកសិកម្ម និងកង្វះព័ត៌មានអំពីទីផ្សារស្រូវអង្ករ គឺជាឧបសគ្គចម្បងដែលរារាំងដល់ការបង្កើនទិន្នផល និងផលិតកម្មស្រូវអង្ករនៅកម្ពុជា។ ដើម្បីកាត់បន្ថយឧបសគ្គទាំងនេះ អ្នកស្រាវជ្រាវ បានផ្តល់មតិឲ្យធ្វើសមាហរណកម្មតាមខ្សែបញ្ឈរកាន់តែប្រសើរលើផលិតកម្មតាមរយៈ ការផ្គត់ផ្គង់យ៉ាងទៀងទាត់នូវគ្រាប់ពូជមានគុណភាពល្អ, ការផ្តល់សេវាប្រឹក្សាយោបល់បានទាន់ពេល, ការផ្តល់ប្រាក់កម្ចីសម្រាប់វិនិយោគកម្រិតកសិដ្ឋាន, ការបន្ធូរបន្ថយការរឹតត្បឹតសព្វថ្ងៃលើការនាំចូលជី និងការពង្រឹងអនុវត្តច្បាប់គ្រប់គ្រងគុណភាពជី។ ការផ្តល់យោបល់ផ្សេងទៀត រួមមាន ការលើកកម្ពស់ទំនាក់ទំនងតាមខ្សែផ្តេករវាងអង្គការកសិករ និងក្រុមហ៊ុនចុះកិច្ចសន្យាធ្វើកសិកម្ម និង វិធានការផ្តល់កម្មសិទ្ធិដីកសិកម្មដល់កសិករម្ចាស់ដីតូចៗ។ ដើម្បីឲ្យគោលនយោបាយទាំងនេះផ្តល់ផលប្រយោជន៍បានច្រើនជាអតិបរមា អ្នកនិពន្ធបានបញ្ជាក់ពី តម្រូវការឲ្យមានការសម្របសម្រួលកាន់តែល្អរវាងក្រសួង និងស្ថាប័នរដ្ឋជាប់ពាក់ព័ន្ធ ដើម្បីឲ្យកសិករតូចតាចអាចបានប្រើប្រាស់សេវាកសិកម្មឧបត្ថម្ភដោយរដ្ឋាភិបាល តាមរយៈសេវាកម្មច្រកចេញចូលតែមួយរបស់រដ្ឋាភិបាល។

ក្នុងជំពូក ៧ Theng and Khiev បានផ្តោតជាសំខាន់លើ ទីផ្សារជី និងមធ្យោបាយធានាថាវាមានគុណភាពសម្រាប់កែលំអផលិតភាពកសិកម្ម។ ទីផ្សារជីនៅកម្ពុជា ជាទីផ្សារសេរី និងគ្មានគោលនយោបាយសម្រាប់ការពារ ឬអនុគ្រោះដល់រោងចក្រផលិតជីក្នុងស្រុកទេ ដោយរដ្ឋាភិបាលអនុញ្ញាតឲ្យអ្នកផ្គត់ផ្គង់ជីប្រកួតប្រជែងគ្នាលើថ្លៃ និងគុណភាព នៅគ្រប់កម្រិតនៃខ្សែចង្វាក់ផ្គត់ផ្គង់។ ការផ្គត់ផ្គង់ជីបានកើនឡើងយ៉ាងលឿន ដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការ។ ផលចំណេញទៅអនាគតក្នុងផលិតកម្មដំណាំ រំពឹងថាទទួលបានភាគច្រើនពីកំណើនទិន្នផល ហើយជីដើរតួនាទីយ៉ាងសំខាន់នៅក្នុងនោះ។ តាមការវិភាគពីឧបសគ្គរារាំងប្រសិទ្ធភាពទីផ្សារជីនៅកម្ពុជា អ្នកនិពន្ធផ្តល់មតិឲ្យធ្វើកំណែទម្រង់បីយ៉ាង គឺ ធ្វើឲ្យសាមញ្ញនូវបទបញ្ញត្តិ និងនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល, លុបបំបាត់ការកម្រិតចំនួនតោនលើអ្នកនាំចូល, និង ពង្រីកការស្រាវជ្រាវវិទ្យាសាស្ត្រ និងសេវា

សាធារណៈផ្សព្វផ្សាយបច្ចេកទេសកសិកម្ម តាមការបង្កើនចំណាយសាធារណៈដើម្បីកែលំអប្រសិទ្ធភាពប្រើប្រាស់ជីរបស់កសិករ។ វិធានការទាំងនេះអាចជួយបានច្រើនណាស់ក្នុងការបង្កើនទិន្នផលកសិកម្ម ពីព្រោះបរិមាណ និងប្រសិទ្ធភាពនៃការប្រើប្រាស់ជីក្នុងកសិកម្មនៅកម្ពុជាវានៅទាបជាខ្លាំងបើធៀបនឹងប្រទេសជិតខាង។

ជំពូក ៨ ផ្តោតលើ ការវិភាគពីតួនាទីនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម (ដូចជាការជ្រើសរើសពូជ, ជីគីមី និងការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ, ការគ្រប់គ្រងទឹក, ការធ្វើជីកំប៉ុស, និងវិធីដាំដុះ) ដើម្បីជួយសម្រួលដល់ការអនុវត្តរបៀបធ្វើកសិកម្មល្អៗ និងបង្កើនទិន្នផលកសិកម្ម។ មកទល់សព្វថ្ងៃ ការសិក្សាតិចតួចដែលបានព្យាយាមបកស្រាយពីឥទ្ធិពលនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្មទៅលើទិន្នផលកសិកម្មនៅកម្ពុជា។ ដោយប្រើប្រាស់ទិន្នន័យលើច្រើនឆ្នាំ បានពីអង្កេតធ្វើឡើងដោយ CDRI ក្នុងឆ្នាំ ២០០៨ និង ២០១១ ក្នុង ៩ភូមិ ស្ថិតក្នុងតំបន់ភូមិសាស្ត្របួនធំៗ គឺ តំបន់ទំនាបទន្លេមេគង្គ តំបន់ទំនាបទន្លេសាប តំបន់ខ្ពង់រាប និងតំបន់ឆ្នេរ រួមផ្សំនឹងវិធីសាស្ត្រស្ថិតិជាច្រើនប្រភេទផងនោះ អ្នកនិពន្ធ Keo and Theng បានស្រាវជ្រាវឃើញថាសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ជះឥទ្ធិពលជាវិជ្ជមានទៅលើទិន្នផលស្រូវ។ ប៉ុន្តែដោយសារចំណុចខ្វះខាតខ្លះក្នុងទិន្នន័យ,ការលំបាកវាស់វែងឲ្យបានត្រឹមត្រូវនូវប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម, បញ្ហាកសិករអនុវត្តតែមួយភាគនៃបច្ចេកទេស/គំនិតថ្មៃប្រឌិតថ្មីខាងកសិកម្ម, និងការរំលងចោលនូវឥទ្ធិពលខ្លះនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅក្នុងទិន្នន័យអង្កេតទើបនាំឲ្យឥទ្ធិពលនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលបានសង្កេតឃើញ មិនមានសារៈសំខាន់ខាងស្ថិតិទេ។ លទ្ធផលបែបនេះឃើញមានជាទូទៅនៅក្នុង ការសិក្សាស្រដៀងគ្នាដែលបានធ្វើឡើងនៅប្រទេសផ្សេងទៀត។ ដោយការសិក្សាបែបនេះទើបមានអនុវត្តនៅក្នុងបរិបទកម្ពុជា អ្នកនិពន្ធបានបញ្ជាក់ថា ត្រូវមានភស្តុតាងច្រើនថែមទៀត ទើបអាចវាយតម្លៃបានត្រឹមត្រូវ។

## ៥. ចីរភាព៖ ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន

កម្ពុជាងាយរងគ្រោះជាខ្លាំងដោយសារ ឥទ្ធិពលអាក្រក់នៃការប្រែប្រួលអាកាសធាតុ។ កម្ពុជាមានបឹងទន្លេសាប និងទន្លេមេគង្គ ដែលតភ្ជាប់គ្នាដោយទន្លេសាប ដែលមានរបបជលសាស្ត្រតែមួយខុសគេគឺទិសដៅទឹកហូរផ្លាស់ប្តូរអាស្រ័យលើកម្ពស់ទឹកនៅក្នុងទន្លេមេគង្គ (ហូរពីទន្លេមេគង្គទៅបឹងទន្លេសាបក្នុងរដូវវស្សា និងពីបឹងទន្លេសាប ទៅទន្លេមេគង្គវិញនៅដើមរដូវប្រាំង)។ ភាពងាយរងគ្រោះដោយទឹកជំនន់ដោយសារលក្ខណៈភូមិសាស្ត្រ គួបផ្សំនឹងការប្រែប្រួលអាកាសធាតុ និងកង្វះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសមស្របនៅតាមជនបទ ធ្វើឲ្យទឹកជំនន់ និងគ្រោះរាំងស្ងួតជះឥទ្ធិពលកាន់តែធ្ងន់ធ្ងរឡើងទៅលើប្រជាជន ដែលពឹងផ្អែកលើធនធានធម្មជាតិនៃបឹងទន្លេសាប (CDRI 2013)។ ម្យ៉ាងទៀត ការអភិវឌ្ឍសេដ្ឋកិច្ច និងកំណើនប្រជាជននៅក្នុងពីរបីទសវត្សរ៍ចុងក្រោយនេះ បានធ្វើឲ្យការបំភាយឧស្ម័នផ្ទះកញ្ចក់កើនឡើងយ៉ាងខ្លាំង ដោយសារសកម្មភាពកសិកម្ម និងឧស្សាហកម្ម។ ទោះបីការបំភាយឧស្ម័ននេះគិតជាចំនួនតោន នៅមានតិចណាស់ក្តី ក៏គួរមានការឆ្លើយតបយ៉ាងឆាប់រហ័សចំពោះការគំរាមកំហែងនេះ។ ដោយហេតុនេះ ជំពូក ៩ និង ១០ បានផ្តោតលើបញ្ហាចីរភាពនៃបរិស្ថាន ដោយពិនិត្យលើប្រធានបទដ៏សំខាន់ពីរ គឺ អភិបាលកិច្ចទឹកនៅបឹងទន្លេសាប និង លទ្ធភាពកាត់បន្ថយដានកាបូននៃវិស័យទេសចរណ៍នៅកម្ពុជា។

ជំពូក ៩ លោក Chem and Kim បានពិនិត្យពីផលប៉ះពាល់គួបផ្សំគ្នានៃការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរក្នុងប្រព័ន្ធធម្មជាតិបង្កឡើងដោយសកម្មភាពមនុស្ស (ដូចជា ការកាប់បំផ្លាញព្រៃឈើ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ) ទៅលើធនធានទឹក និងអភិបាលកិច្ចទឹកនៅក្នុងអាងបឹងទន្លេសាប។ ដោយពឹងផ្អែកជាសំខាន់លើវិធីសាស្រ្តមានការចូលរួម តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ឃុំ នៅខេត្តកំពង់ធំ ពោធិ៍សាត់ និងកំពង់ឆ្នាំង, អ្នកស្រាវជ្រាវបានរកឃើញតំបន់ងាយជួបគ្រោះមហន្តរាយនៅក្នុងអាង និងបានវាយតម្លៃពីប្រភេទ ភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃគ្រោះធម្មជាតិ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ អាចចែកចេញជាបួនក្រុម គឺ ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និង ជំងឺឆ្លងរាលដាល។ គ្រោះធម្មជាតិទាំងនេះកើតឡើងនៅតំបន់អាងស្ទើររៀងរាល់ឆ្នាំ នៅពីរទសវត្សរ៍កន្លងមកនេះ លើកលែងតែក្នុងឆ្នាំ២០០៣ និង ២០០៨ ហើយគេយល់ថា វាកាន់តែញឹកញាប់ និងកាន់តែខ្លាំងឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ប្រជាជននៅតាមមូលដ្ឋានយល់ថា ទឹកជំនន់មានលក្ខណៈញឹកញាប់ និងធ្ងន់ធ្ងរជាងគ្រោះធម្មជាតិផ្សេងទៀតដែលបង្កដោយការប្រែប្រួលអាកាសធាតុ ហើយបន្ទាប់មកគឺគ្រោះរាំងស្ងួត។ ដោយមូលហេតុនេះ អ្នកនិពន្ធបានផ្តល់មតិពីតម្រូវការ (១)ណែនាំបច្ចេកទេសកសិកម្មថ្មីៗដែលជួយឲ្យកសិករអាចសម្របខ្លួនទៅនឹង ការកើតមានកាន់តែញឹកញាប់នូវ រយៈពេលមានភ្លៀងធ្លាក់ច្រើនពេក ឬតិចពេក (ពីព្រោះការប្រែប្រួលអាកាសធាតុ បានធ្វើឲ្យប្រែប្រួលរបបទឹកភ្លៀង) (២)កសាងយន្តការនិងផែនការប្រកបដោយប្រសិទ្ធភាពសម្រាប់ត្រៀមទប់ទល់គ្រោះមហន្តរាយ,ចាត់វិធានការឆ្លើយតប និងដំណើរការរើបឡើងវិញ (៣)លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វានៅតាមភូមិ និងឃុំ (៤)សម្របសម្រួលផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅកម្រិត ឃុំ ស្រុក និងខេត្ត (៥)ផ្តោតកិច្ចប្រឹងប្រែងបន្សាំខ្លួន និងសង្គ្រោះបន្ទាន់សម្រាប់ជួយដល់ប្រជាជនក្រីក្របំផុត និងងាយរងគ្រោះបំផុត។

ក្នុងជំពូក ១០ អ្នកនិពន្ធវិភាគពីផលប៉ះពាល់ផ្នែកបរិស្ថាននៃកំណើនវិស័យទេសចរណ៍យ៉ាងលឿន និងផ្តល់មតិពីវិធីធ្វើឲ្យកំណើននោះជួយពង្រឹងចីរភាពបរិស្ថានបន្ថែមទៀត។ អ្នកនិពន្ធបានរំលឹកថា ចំនួនភ្ញៀវទេសចរជាតិនិងអន្តរជាតិ, សណ្ឋាគារ រមណីយដ្ឋាន ក្រុមហ៊ុនអាកាសចរណ៍ផ្សេងៗដែលផ្តល់ការហោះហើរមកកាន់និងនៅក្នុងប្រទេសកម្ពុជា ព្រមទាំងសេវាកម្មទេសចរណ៍ពាក់ព័ន្ធផ្សេងទៀត កំពុងរីកដុះដាលយ៉ាងលឿន និងអាចដាក់សម្ពាធយ៉ាងខ្លាំងទៅលើធនធានក្នុងស្រុក ដូចជា ថាមពល ឥន្ធនៈហ្វូស៊ីល ទឹក ស្បៀងអាហារ និងដីធ្លី។ ផលប៉ះពាល់បន្ទាប់បន្សំនៃការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍ (ដូចជា ការថយចុះធនធានធម្មជាតិ និងកំណើនដានកាបូន) ត្រូវតែគ្រប់គ្រងឲ្យបាន ប្រសិនបើចង់ឲ្យឧស្សាហកម្មទេសចរណ៍នៅកម្ពុជាមានចីរភាព។ អាទិភាពនានា រួមមាន វិធានការបង្កើនប្រសិទ្ធភាពប្រើប្រាស់ថាមពលនៅតាមសណ្ឋាគារ "បៃតង", ការពង្រីក ថាមពលកកើតឡើងវិញ ជាពិសេស ថាមពលព្រះអាទិត្យ, ការរៀបចំតំបន់ទេសចរណ៍ឲ្យសម្បូរបែប, ការកែលំអបទបញ្ញត្តិឧស្សាហកម្ម និងការកសាងយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយមួយដើម្បីលើកកម្ពស់ឧស្សាហកម្មទេសចរណ៍ ដែលជួយរក្សាបរិស្ថាន។ ជាសំណាងល្អ កម្ពុជាមានសក្តានុពលធំធេងក្នុងការធ្វើពិពិធកម្មវិស័យទេសចរណ៍ ក្រៅពីតំបន់ជាបេតិកភណ្ឌពិភពលោក ដើម្បីធ្វើឲ្យសម្ពាធលើបរិស្ថាននៅជុំវិញតំបន់ទាំងនោះ ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ កម្ពុជាក៏មានលទ្ធភាពធំធេងក្នុងការអភិវឌ្ឍវិស័យអេកូទេសចរណ៍ដែរ ដែលអាចជំរុញកំណើន បង្កើតការងារ ហើយជួយការពារធនធានធម្មជាតិ

ដូចជា ព្រៃ ទឹក និងសត្វព្រៃ។ នាបច្ចុប្បន្ន ការអភិវឌ្ឍវិស័យនេះនៅកម្ពុជា នៅយឺតយ៉ាវជាងប្រទេសជិតខាង ដូច្នេះនៅមានសកម្មភាពជាច្រើនទៀតដែលកម្ពុជាត្រូវអនុវត្ត។

## ៦. អភិបាលកិច្ចៈ វិមជ្ឈការតាមបែបប្រជាធិបតេយ្យ

កម្មវិធីវិមជ្ឈការតាមបែបប្រជាធិបតេយ្យនៅកម្ពុជា បានផ្តល់លទ្ធផលចម្រុះ។ កម្មវិធីនេះបានជួយបង្កើតរបបនយោបាយពហុបក្ស តាមរយៈការបង្កើតឲ្យមានក្រុមប្រឹក្សាមូលដ្ឋានពហុបក្សដែលប្រជាជនបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់។ ទោះយ៉ាងនេះក្តី វិមជ្ឈការនយោបាយមិនមែនសុទ្ធតែមានគួបផ្សំដោយវិមជ្ឈការស៊ីជម្រៅផ្នែកកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុនោះទេ។បញ្ហានេះបានរាំងរាំងដល់រដ្ឋអំណាចថ្នាក់ក្រោមជាតិ ក្នុងការដើរតួនាទីឲ្យបានធំដុំក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច (CDRI 2013)។ នៅក្នុងបរិបទនេះ ជំពូក ១១ បានផ្តោតលើឥទ្ធិពលនៃកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ (D&D) ទៅលើ "ប្រជាធិបតេយ្យភាវូបនីយកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្ត" នៅថ្នាក់ក្រោមជាតិ ទាក់ទងនឹង គណនេយ្យភាព ការតំណាង និងការឆ្លើយតប។ ចំណែកឯ ជំពូក ១២ ពិនិត្យពីទំនាក់ទំនង និងអន្តរកម្មរវាងស្រទាប់ពីរនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺ អាជ្ញាធរស្រុកនិងក្រុមប្រឹក្សាឃុំ។

ក្នុងជំពូក ១១ Kim and Hort បង្ហាញនូវករណីសិក្សាមួយស្តីពី គម្រោងបោះព្រំប្រទល់ទន្លេសាប (TSDP)។ គម្រោង TSDP ដែលបានអនុវត្តចាប់ពីពាក់កណ្តាលឆ្នាំ២០១០ ដល់ឆ្នាំ ២០១១ នេះ បានអនុវត្តឡើងដើម្បីទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើបន្តទៀតនៅតំបន់បឹងទន្លេសាប ដោយមិនបំពានលើសិទ្ធិកសិករមូលដ្ឋានក្នុងការប្រើប្រាស់ដីស្រែរបស់ពួកគេ។ គម្រោងនេះមានបំណងកំណត់ព្រំប្រទល់ជាក់លាក់មួយរវាងព្រៃលិចទឹក (រក្សាទុកជាតំបន់ព្រៃការពារ) និងតំបន់ដាំដុះស្រូវឡើងទឹក (ដែលកសិករមានសិទ្ធិប្រើប្រាស់សម្រាប់ការដាំដុះ)។ ដោយប្រើឯកសារទាក់ទងនឹង គម្រោង TSDP នេះ និងលទ្ធផលបានពីសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល កសិករមូលដ្ឋាន និងមេគំនិតមួយចំនួន អ្នកនិពន្ធ Kim and Hort បានវាយតម្លៃលើ "ដំណើរការប្រជាធិបតេយ្យ" នៃការអនុវត្តគម្រោង TSDP។ ផ្អែកលើភស្តុតាងផ្សេងៗជាច្រើន អ្នកនិពន្ធបានសន្និដ្ឋានថា គំនិតផ្តួចផ្តើមនេះ ជាដំណើរការពីលើទៅក្រោមច្បាស់លាស់មួយ ដែលមន្ត្រីរដ្ឋាភិបាលកណ្តាលបានកំណត់ព្រំដែនអនុវត្តដល់ថ្នាក់ក្រោម។ ប្រជាពលរដ្ឋមូលដ្ឋាន និងអ្នកតំណាងជាប់ឆ្នោតមានការបង្ហាញគណនេយ្យភាពចំពោះខ្លួន ការតំណាង ឬការឆ្លើយតបតិចតួច ក្នុងការអនុវត្តគម្រោង TSDP។ អាជ្ញាធរមូលដ្ឋានតែងត្រូវបានផាត់ចេញពីគម្រោង ដោយភ្នាក់ងារ TSDP ដែលថ្នាក់ក្រសួងបានចាត់តាំង ហើយមិនមានអ្នកតំណាងនៃអាជ្ញាធរមូលដ្ឋាននៅកម្រិតណាមួយ បានចេញមុខមកតំណាងផលប្រយោជន៍របស់ កសិករដាំស្រូវលិចទឹកនៅតាមមូលដ្ឋានដែលបានរងគ្រោះធ្ងន់ធ្ងរពីការផ្តួចផ្តើមអនុវត្តគម្រោងនេះឡើយ។ Kim and Hort បានសន្និដ្ឋានថា "... កំណែទម្រង់អភិបាលកិច្ចមិនមានឥទ្ធិពលល្អគួរឲ្យកត់សម្គាល់ទេក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ហើយគណនេយ្យភាព ការតំណាង និងការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាជន គឺត្រូវបានជំនួសដោយការគោរពតាមបញ្ជាពីថ្នាក់លើមកថ្នាក់ក្រោម"។

ក្នុងជំពូក ១២ លោក Chheat បានប្រើប្រាស់ទិន្នន័យ និងព័ត៌មានបានពីអង្កេតធ្វើឡើងដោយ CDRI ស្តីពី តួនាទី និងទំនួលខុសត្រូវនៃស្រទាប់ផ្សេងៗគ្នានៃរដ្ឋអំណាចថ្នាក់ក្រោមជាតិ (Chheat

*et al.* 2011) និងសម្ភាសន៍ថ្មីៗជាបន្ថែមទៀត ដើម្បីកំណត់ពី អន្តរទំនាក់ទំនងរវាងកម្រិតឃុំ/សង្កាត់ (CS) នឹង ស្រុក/ក្រុង/ខណ្ឌ (DMK)។ ការសន្និដ្ឋានដ៏សំខាន់មួយ គឺ អន្តរកម្មរវាងស្រទាប់ទាំងពីររបស់រដ្ឋាភិបាលទាក់ទងនឹង តួនាទី ការតំណាង និងគណនេយ្យភាព បានជួបបញ្ហាដោយសារកង្វះការយល់ដឹងទូទៅអំពី ខ្សែបន្ទាត់ព្រំដែនគណនេយ្យភាពរវាងពួកគេ។ អាជ្ញាធរ DMK ភាគច្រើនគិតថា ពួកគេទទួលខុសត្រូវចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចខ្លួន រីឯក្រុមប្រឹក្សាឃុំ/សង្កាត់ភាគច្រើន ដែលជាតំណាងជ្រើសតាំងដោយការបោះឆ្នោតផ្ទាល់ពីសំណាក់ប្រជាជន រំពឹងថា មន្ត្រី DMK ត្រូវមានគណនេយ្យភាពចំពោះខ្លួនជាចម្បង គឺមិនមែនចំពោះប្រជាជនអ្នកបោះឆ្នោតនោះទេ។ ដោយសារការយល់ច្រឡំនេះ CS និង DMK មិនអាចសម្របសម្រួលសូម្បីលើតួនាទីខ្លះៗដែលពួកគេត្រូវបំពេញ ក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ។ ចំណុចនេះ បង្ហាញពីតម្រូវការជាបន្ទាន់នូវ ការកំណត់តួនាទី ទំនួលខុសត្រូវ និងគណនេយ្យភាព របស់ពួកគេនីមួយៗ។ ម្យ៉ាងទៀត រដ្ឋអំណាចថ្នាក់ក្រោមជាតិទាំងពីរស្រទាប់នេះ ក៏ត្រូវការធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីកសាងសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍជាទូទៅ។

## ៧. សេចក្តីសន្និដ្ឋាន

សរុបមក ជំពូកនានាដូចតទៅនេះ បានទទួលស្គាល់ពីសមិទ្ធផលដ៏ធំធេងដែលកម្ពុជាសម្រេចបានក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅនេះ និងបញ្ជាក់ពីជំហានបន្ទាប់ និងមធ្យោបាយផ្សេងៗ ដើម្បីកំណត់នូវរបៀបវារៈអភិវឌ្ឍន៍ដែលនៅសេសសល់ត្រូវអនុវត្តបន្តទៀត។ ឯកសារនេះ គូសបញ្ជាក់ពីតម្រូវការៈ

- ធ្វើសមាហរណកម្មប្រទេសកម្ពុជា ជាមួយនឹងប្រទេសជិតខាង (ការតភ្ជាប់កាន់តែល្អ, សេវាភស្តុភារបម្រើពាណិជ្ជកម្មកាន់តែប្រសើរ, និងរបៀបរបបធ្វើជំនួញងាយស្រួល សម្រាប់វិនិយោគិន)
- កាត់បន្ថយភាពងាយរងគ្រោះនៃក្រុមប្រជាជនក្រីក្រ និងជិតក្រីក្រ (លទ្ធភាពប្រើប្រាស់សេវាសាធារណៈមូលដ្ឋានកាន់តែប្រសើរ និងកម្មវិធីគាំពារសង្គមរឹងមាំល្អ)
- (អន្តរាគមន៍មានចំណាយតិច និងប្រសិទ្ធភាពខ្ពស់ ដូចជា កម្មវិធីយុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែមសម្រាប់កុមារ ជាដើម)
- លើកកម្ពស់លក្ខណៈសម្រាប់គ្រប់គ្នានៃចំណាយលើការអប់រំសាធារណៈ (គិតគូរពីការផ្ទេរសម្ភារៈ ឬ ថវិកាដោយមានលក្ខខណ្ឌ និងចំគោលដៅ)
- បង្កើនទិន្នផលកសិកម្ម (ផ្គត់ផ្គង់គ្រាប់ពូជគុណភាពល្អ, ទីផ្សារជីកាន់តែមានប្រសិទ្ធភាព និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មកាន់តែប្រសើរ)
- ធានាចីរភាពផ្នែកបរិស្ថាន (សមត្ថភាពកាន់តែប្រសើរក្នុងការសម្របខ្លួននឹងការប្រែប្រួលអាកាសធាតុ/គ្រោះធម្មជាតិ និងការយកចិត្តទុកដាក់កាន់តែខ្លាំងលើកំណើនសេដ្ឋកិច្ចបៃតង)
- ពង្រឹងវិមជ្ឈការ (វិមជ្ឈការកាន់តែច្រើនផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល និងការកសាងសមត្ថភាពនៅមូលដ្ឋាន)។

## បញ្ជីឯកសារយោង


ADB, Asian Development Bank (2013), *Asian Development Outlook 2013: Asia's Energy Challenge* (Manila: ADB)

CDRI, Cambodia Development Resource Institute (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities,* (Phnom Penh: CDRI)

CDRI (2014), ASEAN 2030 Phase II: *Growing Together for Economic Prosperity "Cambodia Background Paper*, Working Paper Series No. 90 (Phnom Penh: Cambodia Development Resource Institute)" Jan/Susan/Kimsun, How can this be without authors? Are there no authors for this WP? Plsclarify.

CGD, Commission on Growth and Development (2008), *The Growth Report. Strategies for Sustained Growth and Inclusive Development* (Washington DC: World Bank)

Chheat S., Lun P., Kim S., Heng S., Sok S. and Chhoun N. (2011), *"A Baseline Survey of Sub-national Government: Towards a Better Understanding of Decentralisation and Deconcentration in Cambodia"*, Special Report 12 (Phnom Penh: CDRI)

HengDyna (2014), *"Cambodia: Managing Risks for Growth", presentation at the Annual Meeting of the Cambodia Economic Association,* Phnom Penh, 19 January

IMF, International Monetary Fund (2013), *World Economic Outlook* (Washington, DC: IMF)

Madhur, Srinivasa and JayantMenon(2014), *"Growth, Development and Inclusion in the Greater Mekong Subregion: An Assessment*", in CDRI (2014) Inclusive Development in the GMS - An Assessment (Phnom Penh: CDRI)

MOP, Ministry of Planning (2012), *Annual Progress Report* (Phnom Penh: CDRI)

World Bank (2013), *Where Have All the Poor Gone?*(Washington, DC:World Bank)

World Bank (2014),*Global Economic Prospects*, Volume 8, January (Washington DC: World Bank)

-២-

# កម្ពុជា និងតំបន់ជុំវិញ - បញ្ហាប្រឈម និងជម្រើស

*ដោយ ហ៊ីង វុត្ថា និង ឡារី ស្រ្តេនូ* [១]

## ១. សេចក្តីផ្តើម៖ កម្ពុជា និងតំបន់ជុំវិញ - "ពេលវេលាគួរឲ្យចាប់អារម្មណ៍"

នៅពាក់កណ្តាលខែធ្នូ ឆ្នាំ២០១៣ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដឹកនាំគណៈប្រតិភូរដ្ឋាភិបាល ទៅចូលរួមក្នុងការប្រជុំកំពូលអបអរសាទរខួប ៤០ឆ្នាំ នៃទំនាក់ទំនងអាស៊ាន-ជប៉ុន និងកិច្ចប្រជុំកំពូលមេគង្គ-ជប៉ុន លើកទី៥ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។ បន្ទាប់មក សម្តេចបានធ្វើទស្សនកិច្ចការងារទ្វេភាគីជាផ្លូវការមួយនៅប្រទេសជប៉ុន។ កម្មវិធីនៅទីក្រុងតូក្យូ ជាព្រឹត្តិការណ៍ចុងក្រោយនៃកិច្ចប្រជុំកំពូល និងការរៀបចំនានាក្នុងតំបន់ និងអនុតំបន់ក្នុងឆ្នាំ២០១៣ ដែលបង្ហាញនូវការចូលពាក់ព័ន្ធរបស់កម្ពុជា នៅក្នុងសមាគមផ្លូវការផ្សេងៗ និងយន្តការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ដ៏សំខាន់ៗ ដូចជា មហាអនុតំបន់មេគង្គ, សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងវេទិកាតំបន់អាស៊ាន ស្តីពីបញ្ហាសន្តិសុខ, អាស៊ានបូក៣ (ចិន, ជប៉ុន និង កូរ៉េខាងត្បូង), អាស៊ានបូក៦ (ឥណ្ឌា, អូស្ត្រាលី និង ញូហ្ស៊ីឡែន), កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (អាស៊ានបូក៦, រុស្ស៊ី និង សហរដ្ឋអាមេរិក) និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីអាស៊ានផ្សេងៗ។ ម៉្យាងទៀត ក៏មានគំនិតផ្តួចផ្តើមសហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ចុងក្រោយបំផុតស្តីពី ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដែលផ្អែកលើ សមាជិកភាពក្នុងអាស៊ានបូក៦។ ទស្សនកិច្ចនៅទីក្រុងតូក្យូនេះ ក៏ស្ថិតនៅចុងឆ្នាំមួយ ពោរពេញដោយភាពតានតឹងក្នុងតំបន់ និងឆ្លងកាត់ព្រំដែន លើបញ្ហាអធិបតេយ្យភាពជាតិ និងដែនដី ទាក់ទងនឹងប្រទេសមានអំណាចតូចធំក្នុងតំបន់។

មុនពេលចេញទៅជប៉ុន សម្តេចនាយករដ្ឋមន្ត្រី បានសម្តែងក្តីបារម្ភលើភាពតានតឹងរវាងជប៉ុន និង ចិន (Cambodia Daily 5 December 2013)។ សម្តេចបានអំពាវនាវឲ្យប្រទេសទាំងពីរមានការអត់ធ្មត់ និងកើនរំលឹកពី "ផលប៉ះពាល់ធ្ងន់ធ្ងរ និងមិនអាចនឹកស្មានដល់" សម្រាប់តំបន់ទាំងមូល ប្រសិនបើពួកគេធ្វើសកម្មភាពមិនប្រកបដោយទំនួលខុសត្រូវ។ សម្តេចបានសង្កត់ធ្ងន់ថា កម្ពុជាជាមិត្តល្អរបស់ប្រទេសទាំងពីរ និងបានលើកទៀតថា ជម្លោះ ឬការប្រឈមមុខណាមួយរវាងប្រទេសទាំងពីរ នឹងមានផលប៉ះពាល់អវិជ្ជមានដល់ជំនួយអភិវឌ្ឍន៍ ពាណិជ្ជកម្ម និងវិនិយោគសម្រាប់ប្រទេសលូតលាស់តិចជាងគេនានាដែលជាសមាជិកអាស៊ាន។ សម្តេចបានលើកទឹកចិត្តឲ្យអាស៊ានដើរតួនាទីសម្របសម្រួលក្នុងការជំរុញកិច្ចសន្ទនា ជាពិសេស អាស៊ានបូក៣ (ចិន ជប៉ុន និង កូរ៉េខាងត្បូង) ដែលកន្លងមកគឺជា យន្តការដ៏សំខាន់បំផុតសម្រាប់អាស៊ាន និងជាយាន្តសម្រាប់ការធ្វើសហប្រតិបត្តិការក្នុងតំបន់ និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ីបូព៌ា។

ទស្សនកិច្ចនៅជប៉ុន បានហុចលទ្ធផលជាការផ្តល់កម្ចីថ្មីៗនិងច្រើនៗ ពីប្រទេសជប៉ុន និងការប្តេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកការពារជាតិ និងការកសាងភាពជាដៃគូជាយុទ្ធ

---

[១] ហ៊ីង វុត្ថា ជាអ្នកស្រាវជ្រាវ និង ឡារី ស្រ្តេនូ ជានាយកប្រតិបត្តិ នៅវិទ្យាស្ថាន CDRI ។

សាស្ត្រ។ មន្ត្រីជាន់ខ្ពស់ក្នុងស្រុក និងអ្នកជំនាញការផ្នែកនយោបាយការបរទេស បានលើកថា "ចលនារីតចំណងសហប្រតិបត្តិការជាមួយជប៉ុននេះ មិនមែនជាសញ្ញាបង្ហាញថា កម្ពុជាឃានមួយជំហានចេញពីប្រទេសចិនដែលជាសម្ព័ន្ធមិត្តសំខាន់បំផុត និងវិនិយោគិនធំបំផុតរបស់ខ្លួននោះទេ" (Phnom Penh Post 18 December 2013)។

មតិរបស់សម្តេចនាយករដ្ឋមន្ត្រី និងការវិភាគរបស់ជំនាញការ និងប្រព័ន្ធផ្សព្វផ្សាយជុំវិញបញ្ហាដូចខាងលើ បានបង្ហាញពីទ្វេគ្រោះ ដែលប្រទេសតូចៗតែងតែមានសារៈសំខាន់ជាយុទ្ធសាស្ត្រត្រូវប្រឈមមុខ ដោយសារភាពតានតឹងក្នុងតំបន់វានៅតែក្តៅគំ ហើយជួនកាលពុះកញ្ជ្រោលឡើងទៀត ក្នុងពេញមួយឆ្នាំ២០១៣។ ជម្លោះទាំងនេះផ្តោតជាសំខាន់លើបញ្ហាដែនដី និងអធិបតេយ្យភាពដែលអូសបន្លាយជាយូរមកហើយ នៅដែនសមុទ្រចិនភាគខាងត្បូង និងភាគខាងកើត និងជាប់ពាក់ព័ន្ធដល់ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងច្បាប់ដ៏ស្មុគស្មាញនៃការដណ្តើមកោះ និងដែនសមុទ្រ។ ធនធានធម្មជាតិជាសក្តានុពលនៅក្នុងតំបន់ជម្លោះទាំងនេះ ស្ថិតក្រោមការអះអាងទាមទារពីប្រទេស ចិន ជប៉ុន កូរ៉េខាងត្បូង និង សមាជិកអាស៊ានខ្លះ។ ជម្លោះនេះក៏បង្ហាញផងដែរពី នយោបាយនៃប្រទេសមានអំណាចក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងអាស៊ីបូព៌ាជាពិសេសការប្រកួតប្រជែងក្នុងតំបន់រវាង ចិន និង សហរដ្ឋអាមេរិក និងរវាងប្រទេសនានាក្នុងតំបន់ដែលមានសម្ព័ន្ធភាពជិតស្និទ្ធជាមួយប្រទេសធំទាំងពីរ។

ទំនាក់ទំនងស្មុគស្មាញ និងមិនសូវជិតស្និទ្ធរវាងជប៉ុន និងកូរ៉េខាងត្បូង អាចប៉ះពាល់ដល់ការជឿនលឿន និងសមិទ្ធលទ្ធភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចិន-ជប៉ុន-កូរ៉េ ហើយអាចរាំងស្ទះដល់គោលដៅនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ចនៅតំបន់អាស៊ីបូព៌ា (Madhur 2013)។ ក្នុងពេលជាមួយគ្នា យន្តការសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងតំបន់ថ្មីៗ ដែលមានមហិច្ឆតាខ្ពស់ និងអាចមានការគងគ្នា និង ភាពប្រកួតប្រជែង គឺមាន ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) និង ភាពជាដៃគូឆ្លងកាត់តំបន់ប៉ាស៊ីហ្វិក (TPP) ក៏ធ្វើឲ្យទំនាក់ទំនងក្នុងតំបន់កាន់តែស្មុគស្មាញឡើងដែរ។ ប្រទេសសមាជិកអាស៊ានមួយចំនួន បានចូលរួមក្នុងយន្តការទាំងពីរនេះ រីឯប្រទេសចិនមានតួនាទីក្នុងយន្តការមួយ (RCEP) និងកំពុងគិតគូរចាប់យកតួនាទីក្នុងយន្តការមួយទៀត (TPP)។ RCEP នៅតែជាអាទិភាពមួយសម្រាប់កម្ពុជាដែលមានអាស៊ានជាមូលដ្ឋានសំខាន់របស់ខ្លួន ហើយ ចិន កូរ៉េខាងត្បូង និង ជប៉ុន ក៏ចូលរួមក្នុងនោះដែរ។ ការប្តេជ្ញាចិត្តជារួមនៃ RCEP ក្នុងការភ្ជិតគម្លាតផ្នែកអភិវឌ្ឍន៍តាមរយៈ សហប្រតិបត្តិការក្នុងតំបន់ និងជំនួយសម្រាប់ប្រទេសលូតលាស់តិចជាងគេដែលជាសមាជិកខ្លួន ធ្វើឲ្យ RCEP កាន់តែមានលក្ខណៈទាក់ទាញខ្លាំងឡើង។ ទោះយ៉ាងនេះក្តី ប្រសិនបើប្រទេសចិន សម្រេចចិត្តចូលរួមក្នុង TPP នោះ កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ នឹងមានការផ្លាស់ប្តូរខ្លាំងម្តងទៀត។

នៅខែវិច្ឆិកា ឆ្នាំ២០១៣ តុលាការអន្តរជាតិ (ICJ) បានចេញសេចក្តីសម្រេចពីជម្លោះរវាងកម្ពុជា និងថៃ លើភាពជាម្ចាស់កម្មសិទ្ធិប្រាសាទព្រះវិហារ និងដែនដីជាប់នឹងប្រាសាទ។ សាលក្រមបានបញ្ជាក់គាំទ្រលើសេចក្តីសម្រេចរបស់តុលាការអន្តរជាតិក្នុងឆ្នាំ១៩៦២ ដែលដាក់ប្រាសាទព្រះវិហារ និងតំបន់ជំរាលនៃប្រាសាទ ជាកម្មសិទ្ធិរបស់កម្ពុជា។ ទោះបីជាប្រទេសថៃមិនទាន់ទទួលស្គាល់ជាផ្លូវការនូវសេចក្តីសម្រេចចិត្តនេះក្តីក៏មិនទាន់មានធ្វើសកម្មភាពអ្វីទៀតទេដោយរដ្ឋាភិបាលប្រទេសទាំងពីរបាននិងកំពុងព្យាយាមកាត់បន្ថយ ភាពតានតឹងផុសពីអារម្មណ៍ជាតិនិយមនេះ។

ម៉្យាងទៀត ហាក់ពុំអាចមានដំណោះស្រាយឆាប់ទេសម្រាប់ ភាពទ័លច្រកផ្នែកនយោបាយរបស់ថៃ ដែលបង្កើតជាក្ដីបារម្ភពី រលកជាតិនិយមថៃបោកបក់មួយលើកទៀតមកលើ ប្រាសាទព្រះវិហារ ។

នៅមហាអនុតំបន់មេគង្គ (GMS) ការសាងសង់ទំនប់វារីអគ្គិសនីលើទន្លេ និងដៃទន្លេមេគង្គ (តំបន់ ខ្សែទឹកខាងលើនៅប្រទេសចិន និង តំបន់ខ្សែទឹកខាងក្រោមនៅប្រទេសមីយ៉ាន់មា ឡាវ និងកម្ពុជា) បន្តបង្កនូវក្ដីបារម្ភ។ ភាពតានតឹងកាន់តែខ្លាំងទាក់ទងនឹង ផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន នៃទំនប់ទាំងនេះ ដែលនឹងគួបផ្សំជាមួយផលវិបាកបណ្ដាលពីការប្រែប្រួលអាកាសធាតុ ហើយធ្វើឲ្យ លំហូរទឹក ទឹកជំនន់ និងវដ្ដកសិកម្ម នៃប្រព័ន្ធទន្លេសាប និងទន្លេមេគង្គ, ការនេសាទ និងជីវភាពរស់នៅ ជាពិសេសសម្រាប់កម្ពុជា និងវៀតណាម មានការប្រែប្រួលយ៉ាងធ្ងន់ធ្ងរ។ យន្តការអន្តររដ្ឋាភិបាលទន់ខ្សោយ ក្នុងការចរចារកដំណោះស្រាយដែលភាគីទាំងសងខាងអាចទទួលយកបាន និងកង្វះពីឆន្ទៈនយោបាយក្នុងការស្វែងរកដំណោះស្រាយរួមសម្រាប់ GMS នឹងធ្វើឲ្យភាពតានតឹងនេះកាន់តែធ្ងន់ធ្ងរឡើង។

នៅដើមខែធ្នូ ទីភ្នាក់ងារសារព័ត៌មានផ្លូវការ Xinhua របស់ចិន បានចេញផ្សាយអត្ថបទមួយ អំពី ចម្លើយតបរបស់រដ្ឋាភិបាលកម្ពុជាចំពោះការរីកវរផ្នែកនយោបាយ ហើយអំពាវនាវឲ្យមានកំណែទម្រង់ស៊ីជម្រៅ និងសំខាន់ៗនៅកម្ពុជា ក្នុង ៥ឆ្នាំខាងមុខ (Xinhua News Agency 4 December 2013)។ ការអំពាវនាវឲ្យមាន ចម្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ពីសំណាក់រដ្ឋាភិបាល និងថ្នាក់ដឹកនាំកម្ពុជា ចំពោះការមិនយល់ស្របនឹងលទ្ធផលនៃការបោះឆ្នោតជាតិកាលពីខែកក្កដា និងឲ្យមានកំណែទម្រង់កាន់តែស៊ីជម្រៅនោះ ហាក់បង្ហាញពីក្ដីបារម្ភរបស់ប្រទេសចិនថា អស្ថិរភាពនៅកម្ពុជានឹងជះឥទ្ធិពលអាក្រក់ទៅលើសេដ្ឋកិច្ច និងផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់ចិន ទាំងនៅកម្ពុជា GMS អាស៊ាន និង ប្រទេសនានានៅអាស៊ីបូព៌ា។ ដោយឡែក ប្រទេសចិនពឹងផ្អែកលើកម្ពុជា និងសមាជិកអាស៊ានខ្លះទៀត ឲ្យដើរតួនាទីជួយទ្រទ្រង់ដល់វិធីសាស្ត្ររបស់ចិន ក្នុងការដោះស្រាយទំនាស់នៅដែនសមុទ្រចិនភាគខាងត្បូង ដោយសន្សឹមៗនិងមានភាពជាក់ស្ដែង។ ចំណងមិត្តភាពកម្ពុជា-ចិនមានការវិវត្តគួរឲ្យភ្ញាក់ផ្អើល ដោយបច្ចុប្បន្ន ប្រទេសចិនជាដៃគូពាណិជ្ជកម្ម វិនិយោគិន និងអ្នកផ្ដល់ជំនួយអភិវឌ្ឍន៍លំដាប់ទី១ របស់កម្ពុជា ហើយអន្តរជាតិគេមើលឃើញថា ប្រទេសទាំងពីរមានទំនាក់ទំនងជាយុទ្ធសាស្ត្រជិតស្និទ្ធជាខ្លាំង។

## ២. កម្ពុជា និង តំបន់ជុំវិញ៖ បរិបទគោលនយោបាយ

រដ្ឋាភិបាលកម្ពុជាបានចេញផ្សាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣សម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅខែកញ្ញា ឆ្នាំ២០១៣ បន្ទាប់ពីការបោះឆ្នោតជាតិនៅ ខែកក្កដា។ ឯកសារនេះផ្ដល់នូវ ក្របខ័ណ្ឌគោលនយោបាយ សម្រាប់អាណត្តិ ៥ឆ្នាំថ្មីរបស់រដ្ឋាភិបាល ហើយក្លាយជា មូលដ្ឋានសម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៤-១៨។ យុទ្ធសាស្ត្រនេះ គឺជា ផែនការមួយសម្រាប់ "លើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារ បែងចែកផលនៃកំណើនប្រកបដោយសមធម៌ និងធានាប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធាន"។ យុទ្ធសាស្ត្រនេះ ផ្ដោតលើអាទិភាពបួនគឺ៖ ការអភិវឌ្ឍធនធានមនុស្ស ដើម្បីធានាបាននូវភាពប្រកួតប្រជែងក្នុងទីផ្សារការងារ ក្នុងតំបន់មួយ ដែលមានការបើកចំហកាន់តែខ្លាំងឡើង, ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និង ការកែលំអគ្រឿងសម្រួលការធ្វើពាណិជ្ជកម្ម ដើម្បីធានាថា "ការតភ្ជាប់" នៅក្នុងប្រទេស ក្នុងតំបន់ និងក្នុងសកលលោក, ការអភិវឌ្ឍ

និងការបង្កើតតម្លៃបន្ថែម ថែមទៀតក្នុងវិស័យកសិកម្ម និង ការពង្រឹងអភិបាលកិច្ច និង សមត្ថភាពរបស់ស្ថាប័នសាធារណៈ ដើម្បីប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនិង បរិយាកាសវិនិយោគ។

ផ្នែកមួយនៃ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ចែងពី ការពង្រីកសមាហរណកម្មរបស់កម្ពុជា ចូលទៅក្នុងតំបន់ និងពិភពលោក។ គោលដៅនេះអាចសម្រេចបាន តាមការចូលរួមក្នុងក្របខ័ណ្ឌសហប្រតិបត្តិការកម្រិតអនុតំបន់ តំបន់ និងអន្តរជាតិ ដោយការចូលជាសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការដទៃទៀត។ ផ្នែកនេះចែងថាៈ

> ដំណើរការប្រទេសកម្ពុជាធ្វើសមាហរណកម្មទៅក្នុង សហគមន៍ក្នុងតំបន់ និង ពិភពលោក នឹងកាន់តែស៊ីជម្រៅឡើង ជាពិសេស តាមការចូលរួមនៅក្នុង សហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលនឹងប្រសូតឡើងនៅឆ្នាំ២០១៥ និងតាមកិច្ចប្រឹងប្រែងខ្លាំងក្លាបំផុត ក្នុងការប្រើប្រាស់ឱកាសឲ្យមានប្រសិទ្ធភាព និងបរិយាកាសអំណោយផលល្អផុសចេញពីសមាហរណកម្មក្នុងតំបន់ ដើម្បីឲ្យកម្ពុជាទទួលបានអត្ថប្រយោជន៍ច្រើនជាអតិបរមា និងជាសំខាន់ តាមការភ្ជាប់ទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ ក៏ដូចជាបណ្តាញផលិតកម្មក្នុងតំបន់ និងខ្សែចង្វាក់បង្កើតតម្លៃបន្ថែមក្នុងពិភពលោក។

ការប្តេជ្ញាចិត្តអនុវត្តគោលនយោបាយដ៏ទូលំទូលាយទាំងនេះ ហាក់ដូចជាច្បាស់លាស់ហើយ ប៉ុន្តែមិនបានឆ្លុះបញ្ចាំងពី លក្ខណៈស្មុគស្មាញ និង ភាពមិនប្រាកដប្រជានៅកម្ពុជា និងប្រទេសជិតខាងក្នុងតំបន់អាស៊ីនេះទេ។ ម្យ៉ាងទៀតក៏ពុំមានការផ្តោតលើ បញ្ហាប្រឈម និងជម្រើសមួយចំនួនដែល កម្ពុជានឹងត្រូវជួប ក៏ដូចជា អង្គការនិងយន្តការកម្រិតអនុតំបន់និងតំបន់ដែលកម្ពុជាបានចូលរួម ដូចជា មហាអនុតំបន់មេគង្គ (GMS), អាស៊ាន, អាស៊ានបូក៣, អាស៊ានបូក៦, និង RCEP នោះដែរ។

## ៣. ពាណិជ្ជកម្មសេរី និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ៈ ឱកាស និង បញ្ហាប្រឈមសម្រាប់កម្ពុជា

### ៣.១ ការរីកដុះដាលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកម្លាំងជំរុញ

តំបន់អាស៊ីមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងការបង្កើតយ៉ាងផុសផុលមិនធ្លាប់មានពីមុនមកនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs)។ នៅខែមករា ឆ្នាំ២០១៣ តំបន់អាស៊ី បានចូលរួមក្នុង ២៥៧ FTAs ក្នុងនេះមាន ១៣២ បានចុះហត្ថលេខារួច (១០៩ បានចូលជាធរមានហើយ), ៧៥ កំពុងចរចាគ្នា និង ៥០ ទើបបានដាក់ស្នើឡើង (ADB 2013:50)។ កត្តានាំឲ្យរីកដុះដាល FTAs រួមមាន ទំនាក់ទំនងសេដ្ឋកិច្ចកាន់តែច្រើន និងការពឹងផ្អែកលើគ្នាចុះឡើង ដែលជំរុញឡើងដោយ កម្លាំងទីផ្សារនៃការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែន វិនិយោគផ្ទាល់ពីបរទេស (FDI) និង ហិរញ្ញវត្ថុ។ ជោគជ័យនៃសមាហរណកម្មសេដ្ឋកិច្ចក្នុងសហភាពអឺរ៉ុប (EU) និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាមេរិកខាងជើង (NAFTA) និងក្តីបារម្ភពីការផុសឡើងនៃ ប្លុកអឺរ៉ុប និង អាមេរិកខាងជើង ដែលរើសអើងប្រឆាំងនឹងអ្នកនាំចេញ និង វិនិយោគិននៅអាស៊ី បានផ្តល់នូវមេរៀនដ៏ល្អ (Kawai 2008, Chia 2010)។ កំណើន FTAs ក៏ជំរុញឡើងដោយ ការផ្លាស់ប្តូររបស់ប្រទេសនីមួយៗក្នុងគោលនយោបាយពាណិជ្ជកម្ម ដើម្បីឆ្លើយ

តបនឹង ដំណើរការយឺតយ៉ាវនៃ របៀបវារៈអភិវឌ្ឍន៍ទីក្រុងដូហា (DDA) របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO's) និងនិន្នាការតំបន់និយមដ៏ចំហនៅក្នុង កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក (APEC) (ប្រទេសភាគច្រើននៅអាស៊ីបានប្រើប្រាស់ក្របខ័ណ្ឌពហុភាគីទាំងពីរនេះ ដើម្បីធ្វើសេរីភាវូបនីយកម្មគោលនយោបាយពាណិជ្ជកម្មរបស់ខ្លួន)។

## ៣.២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទូទាំងតំបន់សំខាន់ៗ

**សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)៖** សហគមន៍សេដ្ឋកិច្ចអាស៊ាន បានទទួលការអនុម័តដោយ មេដឹកនាំអាស៊ាន ក្នុងកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០០៣ នៅកោះបាលី ដើម្បីឆ្លើយតបនឹងកំណើនល្បឿនសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និង បញ្ហាប្រឈមផ្សេងៗនៃសកលភាវូបនីយកម្ម។ ថ្ងៃកំណត់ព្រមព្រៀងគ្នាពីដំបូងគឺឆ្នាំ២០២០ តែក្រោយមកបានពន្យាពេលដល់ឆ្នាំ ២០១៥។ សហគមន៍សេដ្ឋកិច្ចអាស៊ាន ជាការបង្រួបបង្រួម និងពង្រីកក្របខ័ណ្ឌផ្សេងៗដែលមានស្រាប់ដូចជា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA), កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម (AFAS), និង តំបន់វិនិយោគអាស៊ាន (AIA)។ គោលបំណង គឺដើម្បីបង្កើត អង្គការតំបន់មួយដែលមានសរសរគ្រឹះបួន គឺ៖ (១) ទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ (២) តំបន់សេដ្ឋកិច្ចមានការប្រកួតប្រជែងខ្ពស់ (៣) តំបន់អភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និង (៤) តំបន់បានធ្វើសមាហរណកម្ម យ៉ាងពេញលេញចូលជាមួយនឹងសេដ្ឋកិច្ចសកល។

**កិច្ចព្រមព្រៀង អាស៊ានបូក៖** អាស៊ានបានបន្តគាំទ្រ ការបង្កើតក្របខណ្ឌអាស៊ានបូក១ ហើយ បច្ចុប្បន្នបានបញ្ចប់ ការផ្តល់សច្ចាប័ន FTAs ជាមួយ អូស្ត្រាលី និង ញូវហ្សេឡែន, ចិន, ឥណ្ឌា, ជប៉ុន, និង សាធារណរដ្ឋកូរ៉េ។ ដំណើរការនេះ ជាក់ស្តែងបានធ្វើឲ្យ អាស៊ាន ក្លាយជាតំបន់ស្នូលមួយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ FTAs នៃអាស៊ានបូក១ ទាំងអស់ សុទ្ធតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយគេតែងហៅថា FTAs បូក និង WTO បូក (Chia 2010) ពីព្រោះវាវិកធំហួសពី សេរីភាវូបនីយកម្មពាណិជ្ជកម្មលើទំនិញ ហើយឈានទៅគ្របដណ្តប់លើ ពាណិជ្ជកម្មលើសេវាកម្ម និង ការវិនិយោគ, ការសម្របសម្រួលពាណិជ្ជកម្ម និងវិនិយោគ, លទ្ធកម្មរបស់រដ្ឋាភិបាល, កម្មសិទ្ធិបញ្ញា, គោលនយោបាយលើការប្រកួតប្រជែង, និង សហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសច្រើនបែបយ៉ាង។ កិច្ចព្រមព្រៀងក៏មានរួមបញ្ចូលផងដែរនូវ របៀបរបបចាត់ចែងពិសេស និងខុសពីគ្នា, ភាពបត់បែន, និង ការកសាងសមត្ថភាពសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) (Chia 2010)។ សំខាន់បំផុតគឺ អាស៊ាន បានកសាងបណ្តាញ FTA មួយ (FTA អាស៊ាន+១) នៅទូទាំងអាស៊ីដ៏ធំទូលាយ ដោយអាស៊ានខ្លួនឯងក្លាយជាតំបន់ស្នូល។ ប៉ុន្តែទាំងអស់នេះមានគុណវិបត្តិមួយ គឺ FTA អាស៊ាន+១ មានច្រើនបែបនេះ បង្កើតបានជា "មីមួយចាន" ដែលជាស្ថានភាពមួយរំខានដល់អាជីវកម្មនានាក្នុងការប្រើប្រាស់ប្រព័ន្ធអនុគ្រោះផ្សេងៗ (Fukunaga and Isono ២០១៣)។

**ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP)៖** RCEP ត្រូវបានបង្កើតឡើងដោយមេដឹកនាំអាស៊ានបូក៦ ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ នៅទីក្រុងភ្នំពេញ ក្នុងខែវិច្ឆិកា ២០១២។ ជាទូទៅគេឃើញចលនានេះថាជា យុទ្ធសាស្ត្រអាស៊ាន ដើម្បីប្រកួតប្រជែងជាមួយនឹងការផ្តួចផ្តើមធ្វើ FTA ពីរនៅទូទាំងតំបន់ គឺ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ីបូព៌ា (EAFTA) រវាងអាស៊ាន នឹង CJK (ចិន, ជប៉ុន, កូរ៉េ) ដែលជាសំណើមានការជំរុញខ្លាំងពីចិននិងកូរ៉េ និង ភាព

ជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយនៅអាស៊ីបូព៌ា (CEPEA) រវាងអាស៊ាន និងដៃគូទាំង ៦ របស់ខ្លួន (CJK ឥណ្ឌា អូស្ត្រាលី និង ញូវហ្សេឡែន)។ ការបង្កើត RCEP នេះក៏ក្នុងបំណងកាត់បន្ថយស្ថានភាព "មីមួយចាន" នោះដែរ។ RCEP ក៏សំដៅ បង្កើនការចូលរួមក្នុងខ្សែចង្វាក់ ផលិតកម្មតាមរយៈ "ការបង្គរទុក" និងដើម្បីឆ្លើយតបនឹង ហេតុផលខាងសេដ្ឋកិច្ចនយោបាយថា អាស៊ានត្រូវ "លើកស្ទួយផលប្រយោជន៍របស់ខ្លួន" នៅក្នុង FTA ធំៗ ដើម្បីប្រកួតប្រជែងជាមួយនឹងកិច្ចព្រមព្រៀងផ្សេងទៀត ដូចជា ភាពជាដៃគូឆ្លងកាត់តំបន់ប៉ាស៊ីហ្វិក (TPP) និង FTA ជាមួយចិន ជប៉ុន កូរ៉េខាងត្បូង។ ការចរចាបានធ្វើឡើងស្របតាម គោលការណ៍ណែនាំចំនួន ៨[១] ដោយបានចាប់ផ្តើមនៅឆ្នាំ២០១៣ ហើយរំពឹងថានឹងចប់សព្វគ្រប់នៅឆ្នាំ២០១៥។ ប្រសិនបើអនុវត្តទៅបាន RCEP នឹងក្លាយជាប្លុកពាណិជ្ជកម្មដ៏ធំបំផុតក្នុងពិភពលោក ដោយមាន ទីផ្សារធ្វើសមាហរណកម្មចូលគ្នាមានមនុស្សជាង ៣,៤៣ាន់លាននាក់ (ប្រមាណ ៤៩%នៃចំនួនប្រជាជនសរុបក្នុងពិភពលោក) និងមាន ផសស គួបចូលគ្នាទំហំ ២១,៤ពាន់ពាន់លានដុល្លារ ឬ ប្រមាណ មួយភាគបីនៃ ផសស បច្ចុប្បន្នរបស់ពិភពលោក (ADB 2013:14)។ គេរំពឹងថា កិច្ចព្រមព្រៀង ទៅអនាគត នឹងផ្តល់នូវ កំណើនប្រាក់ចំណូលគួរឲ្យកត់សំគាល់ដល់ជិត ៦៤៤៣ាន់លានដុល្លារ នៅឆ្នាំ២០២៥ ឬស្មើនឹង 0,៦% នៃ ផសស ពិភពលោក (Petri *et al* 2012)។

**ភាពជាដៃគូឆ្លងកាត់តំបន់ប៉ាស៊ីហ្វិក (TPP)៖** កិច្ចព្រមព្រៀង TPP ដែលពីដំបូងគេហៅថា ភាពជាដៃគូសេដ្ឋកិច្ចយុទ្ធសាស្ត្រឆ្លងកាត់តំបន់ប៉ាស៊ីហ្វិក ត្រូវបានចុះហត្ថលេខានៅឆ្នាំ២០០៥ ដោយ ប្រ៊ុយណេ ឈីលី ញូវហ្សេឡែន និងសិង្ហបុរី ហើយឥឡូវនេះបានពង្រីកទៅកាន់ ១២ប្រទេសទៀត មានជាអាទិ៍ អូស្ត្រាលី កាណាដា ម៉ាឡេស៊ី ម៉ិកស៊ិក ប៉េរូ សហរដ្ឋអាមេរិក វៀតណាម និងក្នុងពេលឆាប់ៗនេះនៅជប៉ុនផងដែរ។ កិច្ចព្រមព្រៀងនេះ តំណាងឱ្យទីផ្សារមានមនុស្ស ៧៩២ លាននាក់ មាន ផសស គួបគ្នាចំនួន ២៦,៥ពាន់ពាន់លានដុល្លារ (៣២% នៃ ផសស ពិភពលោក) និងពាណិជ្ជកម្មសរុប ៩,៤ពាន់លានដុល្លារ ឬ ២៦% នៃពាណិជ្ជកម្មពិភពលោក (Choi and Lee 2013)។ បែបបទ TPP គឺ "WTO-បូក" ដែលគ្របដណ្តប់លើច្រើនវិស័យ រួមមាន សេរីភាវូបនីយកម្មពាណិជ្ជកម្មលើទំនិញ សេវាកម្ម វិនិយោគ កម្មសិទ្ធិបញ្ញា (IPRs), ការការពារបរិស្ថាន, ពលកម្ម, សេវាហិរញ្ញវត្ថុ, របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងបញ្ហាខាងបទប្បញ្ញត្តិច្បាប់ផ្សេងទៀត។

## ៣.៣ ឱកាស និងបញ្ហាប្រឈមសម្រាប់កម្ពុជា

ការរីកដុះដាល FTAs នៅក្នុងតំបន់ ផ្តល់នូវឱកាសល្អ និងបញ្ហាប្រឈមដល់កម្ពុជា។ ឱកាសល្អគឺ ផលចំណេញខាងសេដ្ឋកិច្ច និងសុខុមាលភាពដែលទទួលបានពីការចូលរួមក្នុង FTAs។ លទ្ធផលពិសោធន៍មើលរបស់ Itakura (2013) បង្ហាញថា AEC នឹងបង្កើន ផសស ពិតរបស់

[១] មាតិកាសង្ខេបនៃគោលការណ៍ណែនាំសម្រាប់ការចរចា RCEP រួមមាន៖ (1) វាលូនគ្នាជាមួយនឹង WTO (2) មានការរីកចម្រើនគួរឱ្យកត់សម្គាល់ធៀបនឹង FTAs ដែលមានស្រាប់នៃ អាស៊ានបូក១ (3) ការសម្របសម្រួលពាណិជ្ជកម្ម និងវិនិយោគ (4) ភាពបត់បែន សម្រាប់ឆ្លើយតបនឹង កម្រិតខុសគ្នានៃការអភិវឌ្ឍរបស់បណ្តាប្រទេសចូលរួម (5) មិនត្រូវលំបាកជាង FTAs ទ្វេភាគី/ពហុភាគី ដែលមានស្រាប់នោះទេ (6) មានលក្ខខណ្ឌចូលជាសមាជិកបើកចំហ ដើម្បីអនុញ្ញាតឲ្យមានការចូលរួមពីដៃគូក្នុង FTA ណាមួយរបស់អាស៊ាន ដែលមិនបានចូលរួមក្នុងការចរចា RCEP និងដៃគូសេដ្ឋកិច្ចផ្សេងទៀត បន្ទាប់ពីការចរចា RCEP នេះចប់អស់ (7) ការផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព និង (8) ការចរចាស្របគ្នាលើជំពូកផ្សេងទៀត។

កម្ពុជា ៤,៤ ឯកតាភាគរយ ហើយ FTAs ទូទាំងតំបន់ ដូចជា អាស៊ានបូក៣ និង អាស៊ានបូក៦ នឹងមានផលប៉ះពាល់កាន់តែធំ ដោយជួយឲ្យ ផសស ពិតមានកំណើន ៦,៤២% និង ៦,៤៤% រៀងគ្នា។ ក្នុងចំណោម FTAs នៃអាស៊ានបូក១ គឺ FTAs អាស៊ាន-ចិន ដែលនឹងមានផលប៉ះពាល់ខ្លាំងបំផុតលើសេដ្ឋកិច្ចកម្ពុជា ដោយ ផសស ពិតនឹងកើនឡើង ៨,៣%។ លទ្ធផលក៏បង្ហាញដែរថា ផលចំណេញខាងសេដ្ឋកិច្ច នឹងទទួលបានពី កំណើនទំហំពាណិជ្ជកម្មអន្តរជាតិ ព្រោះមានរបាំងតិចតួចចំពោះពាណិជ្ជកម្មទំនិញ និងសេវាកម្ម និងពីកំណើនវិនិយោគរបស់វិនិយោគិនទាំងក្នុងស្រុក និងបរទេស។

Hing (2013) និង Strange *et al.* (2013) ក៏សន្និដ្ឋានស្រដៀងគ្នានេះដែរអំពី ឱកាសល្អដែលកម្ពុជាទទួលបានពី FTAs ដោយវែកញែកថា ក្រៅពីការរក្សាស្ថិរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច សហប្រតិបត្តិការក្នុងតំបន់ក៏អាច ជំរុញការតភ្ជាប់រូបវន្ត បង្កើនលទ្ធភាពបានប្រើប្រាស់ទីផ្សារ ធនធាន និងទុនវិនិយោគក្នុងតំបន់, បង្កើនការចូលរួមក្នុងបណ្តាញផលិតកម្មក្នុងតំបន់, បង្កើនល្បឿនកំណែទម្រង់ក្នុងស្រុកដ៏ចាំបាច់ ហើយធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធ្វើអាជីវកម្ម និងវិនិយោគ។ ទាំងអស់នេះនឹងរួមចំណែកជួយបង្កើនផលិតភាព បង្កើតការងារ និងជំរុញកំណើនសេដ្ឋកិច្ច។ អ្នកនិពន្ធសន្និដ្ឋានថា កម្ពុជាមានផលប្រយោជន៍នឹងទៅឱ្យហួសពី AEC ហើយក្លាយជាចំណែកមួយនៃពាណិជ្ជកម្មសេរី និងសហគមន៍សេដ្ឋកិច្ចទូទាំងអាស៊ីប៉ូព៌ា ដែលអាចជួយបង្រួម ឬ ភ្ជិតគម្លាតអភិវឌ្ឍន៍ក្នុងតំបន់អាស៊ីប៉ូព៌ា តាមរយៈវិធីសាស្ត្រមានការសម្របសម្រួលល្អមួយនៃសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសមាហរណកម្មក្នុងតំបន់។

បញ្ហាប្រឈមសម្រាប់ FTAs ក្នុងតំបន់ មានច្បាប់ គំរូ និងកម្រិតផ្សេងគ្នានៃសេរីភាវូបនីយកម្ម។ ទី១ អាស៊ានអាចបាត់បង់ "ភាពពាក់ព័ន្ធល្អ និង ភាពជាស្នូល" របស់ខ្លួន ដែលជាលទ្ធផលនៃអស្ថិរភាពនយោបាយនៅក្នុងរដ្ឋជាសមាជិកអាស៊ានមួយចំនួន ភាពតានតឹងរវាងរដ្ឋទាំងនេះលើបញ្ហាព្រំដែន ការគ្មានឆន្ទៈដោះស្រាយបញ្ហារសើបនានា និងការផុសឡើងនូវការប្រកួតប្រជែងរវាងការផ្តួចផ្តើមធ្វើសហប្រតិបត្តិការក្នុងតំបន់ ដូចជា CKJ និង TPP ជាដើម។ ការវិវត្តបែបនេះមិនសូវផ្តល់ផលប្រយោជន៍ដល់កម្ពុជាទេ ព្រោះវាកាត់បន្ថយការពាក់ព័ន្ធល្អរបស់កម្ពុជាក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ដែលកំពុងលូតលាស់យ៉ាងលឿន។ ទី២ គំនិតផ្តួចផ្តើមមួយសំណុំយ៉ាងស្មុគស្មាញ ដើម្បីជំរុញ "ការតភ្ជាប់" និង អន្តរកម្មសេដ្ឋកិច្ចកាន់តែច្រើននៅក្នុងតំបន់ក៏ជាបញ្ហាប្រឈមមួយដែរសម្រាប់សមត្ថភាពស្ថាប័ន និងវិស័យឯកជននៅកម្ពុជា។ ស្ថាប័នសាធារណៈភាគច្រើននៅកម្ពុជា ខ្វះខាតហិរញ្ញវត្ថុនិងធនធានមនុស្ស មានការសម្របសម្រួលតាមខ្សែបញ្ឈរនិងខ្សែដេកមិនបានល្អស្មើគ្នា និងពុំមានការលើកទឹកចិត្តគ្រប់គ្រាន់ឲ្យបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព។ ដំណើរការសមាហរណកម្មក្នុងតំបន់ដែលស្មុគស្មាញ និងមានច្រើនស្រទាប់ នឹងធ្វើឲ្យកម្ពុជាជួបបញ្ហាធំក្នុងការសម្របសម្រួល ហើយមិនសូវមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងសហប្រតិបត្តិការក្នុងតំបន់។

សម្រាប់ការធ្វើអាជីវកម្ម ទោះបីមានយន្តការថ្នាក់ជាតិសម្រាប់ការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋាភិបាលនឹងវិស័យឯកជនក្តី ក៏ការចូលរួមរបស់វិស័យឯកជនក្នុងដំណើរការអាស៊ាន មិនបានស្មើដៃគ្នាទេ និងនៅខ្វះការយល់ដឹងអំពីអត្ថប្រយោជន៍ និងឱកាសនៃ FTAs និងសមាហរណកម្មក្នុងតំបន់ (Chan & Strange 2012, Strange et al. 2013)។ វិធាន និង និតិវិធីមួយសំណុំដ៏ស្មុគស្មាញនេះ ក៏ក្លាយជាបន្ទុក និងបង្កការច្របូកច្របល់ ដល់អាជីវកម្ម

នានាដែរ។ អង្កេតលើ ៦០ក្រុមហ៊ុនបង្ហាញថា មានក្រុមហ៊ុន ២០% បានស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានលើទំនិញ (ATIGA), ១៦,៧% បានស្នើនៅក្រោម FTA អាស៊ាន-ចិន និង ៣,៣% ក្រោម FTA អាស៊ាន-កូរ៉េ (Fukunaga 2013)។ អាជីវកម្មភាគច្រើនណាស់ បានលើកពីកង្វះព័ត៌មានថាជាមូលហេតុសំខាន់ដែលពួកគេមិនបានប្រើ FTA។

## ៤. កម្ពុជា និងតំបន់ជុំវិញនាពេលអនាគត - បញ្ហាប្រឈម និងជម្រើស

ក្នុងការកំណត់ផែនការទៅអនាគតរបស់ខ្លួននៅក្នុងតំបន់ ដោយយោងតាមឱកាសល្អជាច្រើនដែលទទួលបានពី សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និង សមាហរណកម្មនិងសហប្រតិបត្តិការកាន់តែធំទូលាយនៅអាស៊ីបូព៌ា កម្ពុជាក៏ជួបបញ្ហាប្រឈមចម្បងៗ និងជម្រើសមួយចំនួនដែរ។

### "ការតភ្ជាប់"៖ តើវាមានន័យដូចម្តេចសម្រាប់កម្ពុជានៅក្នុងមហាអនុតំបន់ទន្លេមេគង្គ អាស៊ាន អាស៊ីបូព៌ា និងលើសពីនេះទៀត?

ការសិក្សារបស់ CDRI រួមមាន CDRI (2013), Strange *et al.* (2013), និង Hing (2013) បានបង្ហាញថា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា គឺនៅយឺតយ៉ាវជាងប្រទេសអាស៊ានដែលនៅជិតខាង។ របាយការណ៍ស្តីពីការប្រកួតប្រជែងសកលឆ្នាំ២០១១ បានធ្វើចំណាត់ថ្នាក់ហេដ្ឋារចនាសម្ព័ន្ធទូទៅរបស់កម្ពុជា នៅលេខរៀង ១១៤ ដោយមានពិន្ទុ ២,៧០ គឺ នៅទាប បើធៀបនឹងពិន្ទុជាមធ្យម ៤,៣៥ សម្រាប់អាស៊ាន[២] ទាំងមូល។ សន្ទស្សន៍លទ្ធផលផ្នែកភស្តុភាររបស់ធនាគារពិភពលោក (Logistics Performance Index: LPI) ឆ្នាំ២០១២[៣] បានធ្វើចំណាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀង ១០១ ក្នុងចំណោម ១៥៥ប្រទេស ធៀបនឹង វៀតណាម (៥៣) និង ថៃ (៣៨)។ លទ្ធផលមិនល្អនេះ បណ្តាលជាសំខាន់មកពីបញ្ហាចម្បងពីរ គឺ ទី១ កង្វះតម្លាភាពក្នុងការយកកម្រៃ (ភាគច្រើនជាកម្រៃក្រៅផ្លូវការ) ដែលបានលាក់បំបាំងនូវ បន្ទុកចំណាយពិតនៃសេវាភស្តុភារមានតម្លៃខ្ពស់បែបនេះ។ ទី២ កង្វះការធ្វើសមាហរណកម្មសេវាភស្តុភារ ជាមួយប្រទេសជិតខាង ក៏នាំឱ្យមានបន្ទុកចំណាយខ្ពស់ កង្វះសមត្ថភាព និងការយឺតយ៉ាវដែរ (Clark and Sok 2013)។

ដើម្បីបង្កើនការតភ្ជាប់ដែលសំខាន់បំផុតសម្រាប់ ជោគជ័យនៃសមាហរណកម្មក្នុងតំបន់និងអនុតំបន់ ប្រទេសកម្ពុជាគួរធ្វើវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមាន ផ្លូវ ស្ពាន ផ្លូវដែក អាកាសយានដ្ឋាន និងការផលិតថាមពល។ ត្រូវយកចិត្តទុកដាក់ខ្លាំងដែរទៅលើ ហេដ្ឋារចនាសម្ព័ន្ធ "ទន់" និង ប្រសិទ្ធភាពផ្នែកភស្តុភាពតាមរយៈ ការលុបបំបាត់វប្បធម៌ និងការអនុវត្តយកកម្រៃក្រៅផ្លូវការ, កំណែទម្រង់ និងទំនើបភាវូបនីយកម្មគយ, ការចែករំលែក និងផ្សព្វផ្សាយព័ត៌មានកាន់តែធំទូលាយ, ការប្រកួតប្រជែងកាន់តែខ្លាំងក្លាក្នុងការដឹកជញ្ជូនតាមផ្លូវគោក កំពង់ផែ និងតាមអាកាស, ការបង្កើនលទ្ធភាពទទួលបានព័ត៌មានអំពីកិច្ចព្រមព្រៀងអន្តរជាតិ, ការលើកកម្ពស់សមត្ថភាពដឹកជញ្ជូន និងសេវាផ្នែកភស្តុភារ, និង ការធ្វើសមាហរណកម្មសេវាដឹកជញ្ជូនតាមផ្លូវគោកទៅក្នុងទីផ្សារតំបន់ (Clark and Sok 2013, Hing 2013)។ ជាការចាំបាច់ដែរដែលត្រូវ

---

2 គេបានដកប្រទេសឡាវ និងមីយ៉ាន់ម៉ា ចេញ ព្រោះរកទិន្នន័យមិនបាន។

3 យកបាននៅថ្ងៃទី ១៣ មករា ២០១៤ នៅ http://lpisurvey.worldbank.org/។

តភ្ជាប់ដោយផ្ទាល់នូវ យុទ្ធសាស្ត្រជំនួយអភិវឌ្ឍន៍ អាទិភាព និងធនធាននានា ទៅនឹងសមាហរណកម្មក្នុងតំបន់ និងអនុតំបន់, ពាណិជ្ជកម្ម និងវិនិយោគផ្ទៃក្នុងតំបន់, ហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់សម្រាប់ការតភ្ជាប់, ការអភិវឌ្ឍវិស័យឯកជន, និងការកសាង និងកំណែទម្រង់ស្ថាប័នជាតិ។ ការលើកកម្ពស់ ការតភ្ជាប់រវាងប្រជាជននឹងប្រជាជន តាមរយៈ បណ្តាញអប់រំ និងគម្រោងអាហារូបករណ៍, ចលនាពលកម្មជំនាញ និងពាក់កណ្តាលជំនាញដោយមានបទបញ្ញត្តិច្បាប់គ្រប់គ្រងយ៉ាងល្អ, និងលំហូរវប្បធម៌ប្រជាប្រិយ ក៏នឹងបង្កើនជំរុញសមាហរណកម្ម និងសហប្រតិបត្តិការក្នុងតំបន់ដែរ។

## ៤.១ បង្រួមគម្លាតអភិវឌ្ឍន៍ (NDG) ក្នុងអាស៊ាន

អាស៊ាន គឺមានការបែងចែក ហើយការបែងចែកលេចធ្លោបំផុត គឺ គម្លាតប្រាក់ចំណូល រចនាសម្ព័ន្ធសេដ្ឋកិច្ច ការវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធ និងទិដ្ឋភាពផ្សេងទៀតនៃការអភិវឌ្ឍធនធានមនុស្ស ដែលបែងចែកសមាជិកថ្មីរបស់អាស៊ាន ចេញពីបណ្តាប្រទេសក្នុងអាស៊ាន៦ ។ ដោយមូលហេតុនេះ សមាជិកអាស៊ាននិងដៃគូចរចាររបស់ពួកគេ បានព្រមព្រៀងគ្នាដាក់បញ្ចូលសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស ឲ្យទៅជាផ្នែកមួយដ៏សំខាន់នៃ RCEP ដើម្បីគាំទ្រដល់រដ្ឋជាសមាជិកអាស៊ាន និងបង្កើនជាអតិបរមានូវអត្ថប្រយោជន៍បានពីការអនុវត្តកិច្ចព្រមព្រៀងនេះ។

តាមពិត គំនិតផ្តួចផ្តើមក្នុងតំបន់ដើម្បីភ្ជិតគម្លាតអភិវឌ្ឍន៍ នៅតែមានប្រយោជន៍ និងសំខាន់ជាពិសេស យន្តការដូចជាហេដ្ឋារចនាសម្ព័ន្ធធំៗក្នុងតំបន់ ការចាត់ចែងពិសេស និងខុសគ្នាសម្រាប់ប្រទេសលូតលាស់តិចជាងគេ ការកសាងសមត្ថភាព និងការដោះស្រាយរបាំងមិនមែនពន្ធ។ ទោះយ៉ាងនេះក្តី មានការឯកភាពជាទូទៅថា កិច្ចប្រឹងប្រែងដ៏មានប្រសិទ្ធភាពបំផុតដើម្បីបង្រួមគម្លាតអភិវឌ្ឍន៍ ត្រូវតែមានចុះនៅក្នុងរបៀបវារៈអភិវឌ្ឍរបស់ប្រទេសនីមួយៗ (Menon 2012)។ ជំនួយអាចដើរតួនាទីមួយក៏ពិតមែន ប៉ុន្តែដំណោះស្រាយត្រូវផុសចេញពីសាមីប្រទេសនីមួយៗ ដោយត្រូវមាន ការអនុម័តគោលនយោបាយផ្សេងៗសំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងលឿន និងតម្រង់ចំគោលដៅរួមគ្នាមួយ។ ដើម្បីភ្ជិតគម្លាតអភិវឌ្ឍន៍ កម្ពុជាគួរលើកកម្ពស់កំណើនប្រកបដោយសមធម៌ និងសម្រាប់គ្រប់គ្នា, ជួយសម្រួលពាណិជ្ជកម្ម និងកែលំអការតភ្ជាប់ក្នុងតំបន់, បង្កើនផលិតភាពតាមការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ និងធ្វើវិនិយោគច្រើនៗលើមូលធនមនុស្ស, ពង្រឹងស្ថានប័ន និងបង្កើនប្រសិទ្ធភាពស្ថាប័ន។

## ៤.២ ចលនាពលកម្ម

ទោះបីចំណាកស្រុកកម្លាំងពលកម្មចេញពី និងនៅក្នុងអាស៊ាន បានកើនឡើងយ៉ាងលឿន ប៉ុន្តែសេរីភាវូបនីយកម្មចលនាមនុស្សនៅយឺតយ៉ាវនៅឡើយ។ ការចរចាស្តីពីកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក (MRAs) (ឧបករណ៍ដ៏សំខាន់ សម្រាប់ចលនាកម្លាំងពលកម្មមានជំនាញក្នុងតំបន់អាស៊ាន) ជាដំណើរការស្មុគស្មាញ និងប្រើប្រាស់ពេលវេលាច្រើន ប៉ុន្តែរដ្ឋជាសមាជិកអាស៊ាននៅតែរារែកក្នុងការអនុញ្ញាតឱ្យមាន លំហូរដោយសេរីនូវកម្លាំងពលកម្មមានជំនាញនៅក្នុង AEC (ចំណាកស្រុកដែលជាបញ្ហារសើបសម្រាប់ប្រទេសនីមួយៗ បានរារាំងដល់ប្រសិទ្ធភាពក្នុងសហប្រតិបត្តិការរហូតមកទល់បច្ចុប្បន្ន)។ របាំងជាបទបញ្ញត្តិច្បាប់ ដូចជា ការតម្រូវនិងនីតិវិធី

ផ្សេងៗសម្រាប់ទិដ្ឋាការការងារ និងប័ណ្ណការងារ, បទបញ្ញត្តិក្នុងវជ្ជធម្មនុញ្ញ និងច្បាប់ ដែលរក្សាទុកការងារសម្រាប់ពលរដ្ឋសាមីប្រទេស នៅតែឃើញមាននិងកំពុងរារាំងចលនាពលកម្មមានជំនាញ។

នាបច្ចុប្បន្ន កម្ពុជាកំពុងជួបបញ្ហាកង្វះជំនាញ និងគម្លាតជំនាញ។ ក្នុងដំណើរឈានទៅមុខ កម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពី AEC ព្រោះអាចបន្តនាំចូលកម្លាំងពលកម្មមានជំនាញពីប្រទេសអាស៊ានឯទៀត ក្នុងពេលកម្ពុជានៅខ្វះខាតពលករមានជំនាញ។ ប៉ុន្តែក្នុងរយៈពេលវែង កម្ពុជាគួរផ្តោតលើការអភិវឌ្ឍជំនាញរបស់ពលករក្នុងស្រុក ដើម្បីអាចកាត់បន្ថយការពឹងផ្អែកទៅលើកម្លាំងពលកម្មមានជំនាញមកពីបរទេស។ ការកែលំអប្រព័ន្ធអប់រំគួរតែជាចំណុចផ្តោតចម្បងនៃគោលនយោបាយ ជាពិសេសការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលផ្តល់ឲ្យយុវជនយុវនារីនូវជំនាញមូលដ្ឋានដ៏ចាំបាច់ ហើយការអប់រំនៅឧត្តមសិក្សា និងការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET) ក៏ឈរលើមូលដ្ឋាននេះដែរ។ ការកសាងសមត្ថភាពស្ថាប័នដើម្បីបង្កើតនិងអនុវត្តគោលនយោបាយនិងអន្តរាគមន៍ដ៏សមស្របនានាក្នុងវិស័យអប់រំ ក៏សំខាន់បំផុតដែរ។

## ៤.៣ សំណួរផ្នែកគោលនយោបាយមួយចំនួនសម្រាប់កម្ពុជា និងតំបន់ជុំវិញ

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ កម្ពុជាអាចពិចារណានូវសំណួរផ្នែកគោលនយោបាយមួយចំនួនដូចតទៅ៖ តើគំរូ "ស្ថាបត្យកម្មក្នុងតំបន់" ដែលទាក់ទងគ្នា និងជួនកាលប្រកួតប្រជែងគ្នា មួយណា "ឈ្នះ" គេ- អាស៊ានបូក៣? អាស៊ានបូក៦? អ្វីផ្សេង? មួយណាផ្តល់អត្ថប្រយោជន៍ច្រើនបំផុតដល់កម្ពុជា?

តើ "ភាពជាស្នូល" របស់អាស៊ាន នៅក្នុងស្ថាបត្យកម្មក្នុងតំបន់ នាពេលអនាគត អាចនៅមានដែរឬទេ? ហេតុអ្វី? តើធ្វើយ៉ាងណាអាចរក្សាទុកវាបានយ៉ាងប្រសើរ? តើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយចិន-ជប៉ុន-កូរ៉េ (CJK FTA) អាចមានន័យយ៉ាងណាសម្រាប់អនាគតរបស់អាស៊ាន និងកម្ពុជា? តើវាងាយអនុវត្តប៉ុណ្ណា ក្នុងពេល បញ្ហានិងភាពតានតឹងរវាងចិន ជប៉ុន និងកូរ៉េខាងត្បូងមិនទាន់ដោះស្រាយ? តើកម្ពុជានិងអាស៊ានមានផលប្រយោជន៍ឬទេ ក្នុង ការសម្រេចបាន CJK FTA រួចបន្ទាប់មក "ភ្ជាប់គ្នា" ជាមួយ AEC ដើម្បីបង្កើតនូវ សហគមន៍សេដ្ឋកិច្ចអាស៊ីបូព៌ា មួយក្លាយជាកម្លាំងជំរុញ RCEP ឬក៏ យន្តការសមាហរណកម្មនិងសហប្រតិបត្តិការក្នុងតំបន់ មួយសម្រាប់ជំនួសវិញ?

តើអាស៊ានត្រូវការពង្រឹងរចនាសម្ព័ន្ធស្ថាប័ន "ច្បាប់" និងធនធាន របស់ខ្លួនឬទេ? តើ "មាគ៌ាអាស៊ាន" នៅតែជាវិធីដ៏មានប្រសិទ្ធភាពសម្រាប់ដោះស្រាយ ភាពតានតឹងនិងបញ្ហាផ្សេងៗក្នុងតំបន់ឬទេ ប្រសិនបើអាស៊ាននៅតែបន្តអះអាង "ភាពជាស្នូល" របស់ខ្លួន នៅក្នុងសមាហរណកម្មសេដ្ឋកិច្ចនិងសហប្រតិបត្តិការក្នុងតំបន់?

តើការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច រវាងចិននិងសហរដ្ឋអាមេរិកនៅតំបន់អាស៊ី អាចប៉ះពាល់យ៉ាងណាដល់ស្ថាបត្យកម្មក្នុងតំបន់ និងសាមគ្គីភាពក្នុងតំបន់? តើមានផលពាក់ព័ន្ធអ្វីខ្លះដល់កម្ពុជា?

តើគំរូណាមួយនៃសមាហរណកម្មសេដ្ឋកិច្ចនិងសហប្រតិបត្តិការក្នុងតំបន់ ដែលបម្រើបានល្អបំផុតនូវផលប្រយោជន៍របស់បណ្តាប្រទេសលូលាស់តិចជាងគេក្នុងអាស៊ាន នៅពេលឥឡូវនេះ និងនៅពេលបានឡើងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប? តើ RCEP ជាយានប្រើបានឬទេ សម្រាប់ការបង្រួមគម្លាតអភិវឌ្ឍន៍? តើត្រូវប្រើយ៉ាងណា?

តើបញ្ហាទាំងនេះមានផលប៉ះពាល់អ្វីទេទៅលើ ជីវភាពរស់នៅនិងសកម្មភាពរបស់សហគមន៍ ក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាល នៅកម្ពុជា? តើបញ្ហាទាំងនេះគ្រាន់តែនាំឲ្យរវល់ដល់មន្ត្រីរដ្ឋាភិបាល ឬយ៉ាងណា? តើធ្វើយ៉ាងណាឲ្យអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងអនាគតនៃប្រទេសកម្ពុជានេះ អាចទទួលបានព័ត៌មានបន្ថែមនិងផលប្រយោជន៍ពីឱកាសផុសចេញពីសមាហរណកម្មសេដ្ឋកិច្ចនិងសហប្រតិបត្តិការក្នុងតំបន់?

# ឯកសារយោង

ADB (2013), "*Asian Development Outlook 2013: Asia's Energy Challenges*" (Mandaluyong City, Philippines: Asian Development Bank)

Chan, Sophal and Larry Strange (2012), "Achieving the AEC 2015: Challenges for Cambodia and its Businesses" in Sanchita Basu Das (ed.), *Achieving the ASEAN Economic Community 2015: Challenges for Members countries & Business* (Singapore: Institute of Southeast Asian Studies) pp. 37-52

Chia, Siow Yue (2013), *The ASEAN Economic Community: Progress, Challenges and Prospects*, ADBI Working Paper 440 (Tokyo: Asian Development Bank Institute)

Chia, Siow Yue (2011), "Free Flow of Skilled Labour in the AEC" in ERIA (ed.), *Toward A Competitive ASEAN Single Market: Sectoral Analysis* (Jakarta: Economic Research Institute for ASEAN and East Asia)

Choi, Byung-il and Kyounghee Lee (2013), *Future of Trading Architecture in Asia Pacific: TPP vs. RCEP*, KERI Brief (Seoul: Korea Economic Research Institute)

CDRI (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities* (Phnom Penh: Cambodia Development Resource Institute)

Clark, Julian Latimer and Vannara Sok (2013), *Getting Things Moving! Improving Cambodia's Logistics to Benefit Fully from Regional Growth, Issue Sheet, trade development* (Washington DC ; World Bank Group)

Fukunaga, Yoshifumi and Ikumo Isono (2013), *Taking ASEAN+1 FTAs towards the RECEP: A Mapping Study, ERIA Discussion Paper Series* (Jakarta: Economic Research Institute for ASEAN and East Asia)

Fukunaga, Yoshifumi (2013), *How Should ASEAN move forward FTAs toward RCEP?*, Presentation at ERIA Capacity Building Seminar 2013 in Cambodia onRCEP,Competition Law, Consumer Protection, IPR on 31 October-01 November 2013 at Sofitel Phnom Penh Phokeethra, Phnom Penh, Cambodia.

Hing Vutha (2013), *Leveraging Trade for Economic Growth in Cambodia*, Working Paper Series No. 81 (Phnom Penh: CDRI)

Itakura, Ken (2013), *Impact of Liberalization and Improved Connectivity and Facilitation in ASEAN for the ASEAN Economic Community*, ERIA Discussion Paper 2013-01 (Jakarta: Economic Research Institute for ASEAN and East Asia)

Kawai, Masahiro and Ganeshan Wignaraja (2013), *"Patterns of FTAs in Asia: A Review of Recent Evidence"*, Policy Studies No. 65 (Honolulu: East-West Center)

Menon, Jayant (2012), *Narrowing the Development Divide in ASEAN: The Role of Policy* (Manila: Asian Development Bank)

Strange, Larry, Hing Vutha, Khieng Sothy, Lun Pide, and Saing Chan Hang (2013), *ASEAN 2030: Growing Together for Economic Prosperity - The Challenges* (Phnom Penh: CDRI)

Strange, Larry (2012), "*ASEAN Small Less Developed Economies: Need for a New Approach"* in Zhang Yunling, Fukunari Kimura and Sothea Oum (ed.), Moving Toward a New Development Model for East Asia-The Role of Domestic Policy and Regional Cooperations (Jakarta: Economic Research Institute for ASEAN and East Asia) pp. 279-331

World Bank (2005), *World Development Report 2005: A Better Investment Climate for Everyone* (Washington, DC: World Bank)

-៣-

# ការវាយតម្លៃពីភាពអំណោយផលដល់ជនក្រីក្រនៃកំណើនសេដ្ឋកិច្ច ការថែទាំសុខភាព និងការអប់រំនៅកម្ពុជា

*ដោយ រ័ត្ន វឌ្ឍនា និង លន់ ពិដេ*[១]

## ១. សេចក្តីផ្តើម

អត្ថបទនេះ ពិនិត្យពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច វិសមភាព និងភាពក្រីក្រ ដោយផ្តោតជាសំខាន់លើឥទ្ធិពលរួមគ្នា នៃកំណើន និងវិសមភាព ទៅលើការថយចុះភាពក្រីក្រ។ ជាដំបូងគួរពិនិត្យថា តើកំណើនសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈទ្រទ្រង់ជនក្រីក្រ គឺ ធ្វើឲ្យវិសមភាពថយចុះដែរឬទេ។ បន្ទាប់មក ត្រូវពង្រីកភាពទ្រទ្រង់ជនក្រីក្រនេះ ទៅដល់ ផ្នែកមិនមែនប្រាក់ចំណូល មានជាអាទិ៍ ការអប់រំ សុខភាព និង ទ្រព្យសម្បត្តិគ្រួសារ។

ការសិក្សានេះរកឃើញថា អត្រាភាពក្រីក្រនៅកម្ពុជា បានធ្លាក់ចុះតាំងពីឆ្នាំ ២០០៤ មកដោយវាស់វែងតាមវិធីសាស្ត្រសន្ទស្សន៍ភាពក្រីក្រ Foster-Greer-Thorbecke (Foster *et al.* 1984)។ ការថយចុះអត្រាជនក្រីក្រ ដែលបានសង្កេតឃើញនៅរវាងឆ្នាំ២០០៤ និង ២០០៧ បានកើតមានជាបន្តទៀតនៅរវាងឆ្នាំ ២០០៩ និង ២០១១ ។ ទោះបីការសិក្សានេះមិនអាចផ្តល់តួលេខច្បាស់លាស់នៃអត្រាភាពក្រីក្រក្តី ក៏ការវិភាគពីកម្រិតរសើប (Sensitivity analyis) បានបង្ហាញ ការថយចុះជាបន្តបន្ទាប់នៃភាពក្រីក្រក្នុងអំឡុងពេលអង្កេត។ ការសិក្សាបានរកឃើញទៀតថា ការបែងចែកចំណាយប្រើប្រាស់តាមគ្រួសារក្នុងមនុស្សម្នាក់ បានល្អប្រសើរឡើង ក្នុងអំឡុងពេលអង្កេត។ វិសមភាពចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ បានថយចុះពី មេគុណ Gini ៣៨,៧ បូកឬដក ១ នៅឆ្នាំ២០០៤ មកត្រឹម ៣៦,០ នៅឆ្នាំ២០១១។ វិសមភាពនៃប្រាក់ចំណូល និងដីធ្លី ក៏ថយចុះដែរ ប៉ុន្តែនៅតែមានកម្រិតខ្ពស់ រហូតដល់ខ្ទង់ ៤០ និង ៥០ រៀងគ្នា។

ចំពោះលើចំណាយប្រើប្រាស់ ការសិក្សានេះបង្ហាញថា សេដ្ឋកិច្ចកម្ពុជាមានភាពទ្រទ្រង់កម្រិតបង្គួរដល់ជនក្រីក្រ នៅរវាងឆ្នាំ២០០៤ និង ២០១១ ដូចអាចមើលឃើញតាម សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ ខ្ពស់ដល់ ០,៥៣។ មានតែក្នុងអំឡុងឆ្នាំ ២០០៩-១១ ប៉ុណ្ណោះ ដែលកំណើនសេដ្ឋកិច្ចមានលក្ខណៈទ្រទ្រង់ជនក្រីក្រសុទ្ធសាធ។ ទិន្នន័យបង្ហាញថា កម្ពុជាកំពុងផ្លាស់ប្តូរជាបណ្តើរៗចេញពីកំណើនសេដ្ឋកិច្ចបែបបរិមាណ (ធ្វើឲ្យសេដ្ឋកិច្ចមានប្រសិទ្ធភាពបំផុត) ទៅជា កំណើនសេដ្ឋកិច្ចបែបគុណភាពដែលលើកកម្ពស់សមធម៌សេដ្ឋកិច្ច។ កម្ពុជាក៏កំពុងដើរទាន់ផែនការឈានទៅដល់ កំណើនសេដ្ឋកិច្ចជួយទ្រទ្រង់ជនក្រីក្រលើផ្នែកផ្សេងៗទៀតក្រៅពីចំណាយប្រើប្រាស់ ដែលជាកត្តាចម្បងចូលរួមចំណែកនៅក្នុងកំណើនសម្រាប់ទាំងអស់គ្នា។

---

[១] រ័ត្ន វឌ្ឍនា និង លុន ពិដេ ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។

## ២. ក្របខ័ណ្ឌវិភាគ និងវិធីសាស្ត្រស្រាវជ្រាវ

មានការខ្វែងគំនិតគ្នាមួយចំនួនទាក់ទិននឹង វិធីជួយជនក្រីក្រឲ្យចាកផុតពីភាពក្រីក្រ ហើយចំណុចមួយដែលគេមិនអាចមើលរំលងគឺ ផលប៉ះពាល់នៃវិសមភាពទៅលើការកាត់បន្ថយភាពក្រីក្រ ព្រោះវិសមភាពខ្ពស់ពេកអាចបង្កការរីករវក្នុងសង្គមនិងនយោបាយ ហើយរារាំងដល់កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងការរក្សាចីរភាពកំណើន។ គម្លាតប្រាក់ចំណូលរវាងតំបន់នានា និងក្នុងតំបន់នីមួយៗ ជួនកាលរីកធំឡើងនៅក្នុងប្រទេសមានសេដ្ឋកិច្ចរីកលូតលាស់លឿនដូចជានៅ ចិន និង កម្ពុជា។ ស្ថានភាពនេះបង្ហាញថា ប្រជាជនក្រីក្រទទួលបានផលប្រយោជន៍ពីការរីកចម្រើន ដោយសារកំណើនសេដ្ឋកិច្ចក៏ពិតមែន ប៉ុន្តែការចែកចាយផលប្រយោជន៍នេះកន្លងមកមិនបានស្មើគ្នាទេ (Ravallion and Chen 2004; World Bank 2009) ហើយបើសិនគ្មានវិធីជួយទ្រទ្រង់នោះ ជនក្រីក្រអាចត្រូវខូចខាតសមត្ថភាពក្នុងការចូលរួម និងទទួលផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច។ ដូច្នេះត្រូវស្វែងយល់ឲ្យបានច្បាស់ពីឥទ្ធិពលលាយឡំគ្នានៃ កំណើនសេដ្ឋកិច្ច និងវិសមភាពប្រាក់ចំណូល ទៅលើការកាត់បន្ថយភាពក្រីក្រ ដើម្បីអាចរចនារៀបចំ និងអនុវត្តគោលនយោបាយសាធារណៈញ៉ាំងឲ្យមានតុល្យភាពល្អរវាងកំណើន និងសមភាពក្នុងការចែកចាយប្រាក់ចំណូល។

ដោយសារអត្ថបទនេះអនុវត្តតាម និយមន័យធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលទទួលស្គាល់ថា កំណើនសេដ្ឋកិច្ចលឿនប្រកបដោយចីរភាព ត្រូវមានគួបផ្សំដោយ ការថយចុះវិសមភាពក្នុងប្រាក់ចំណូល និងអត្ថប្រយោជន៍មិនមែនប្រាក់ចំណូលនោះ វិធីសាស្ត្រកំណើនទ្រទ្រង់ជនក្រីក្រ របស់ Kakwani and Pernia (2000) អាចយកមកអនុវត្តបាន។ គោលគំនិតចម្បងរបស់ Kakwani and Pernia (2000) ដើម្បីពន្យល់ពីទំនាក់ទំនងរវាង កំណើន-ភាពក្រីក្រ-វិសមភាព គឺ ភាពក្រីក្រសរុប វាប្រែប្រួលទៅតាមកំណើនផង និងវិសមភាពផង។ ពួកគេបានស្នើយកសន្ទស្សន៍តែមួយ គឺ សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ ដើម្បីវាស់វែងភាពជួយទ្រទ្រង់នេះ ដោយអះអាងថា កំណើនវាជួយទ្រទ្រង់ដល់ជនក្រីក្រ បើសិនសន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រធំជាង ១ ហើយវាទ្រទ្រង់ដល់ប្រជាជនធូរធារ បើសិនសន្ទស្សន៍កំណើនតូចជាង ១។ សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ កំណត់ថា វិសមភាពត្រូវតែអវិជ្ជមាន ព្រោះកំណើនតែងតែកាត់បន្ថយភាពក្រីក្រ។ សន្ទស្សន៍នេះគេបំបែកវាចេញជា កម្រិតដែលភាពក្រីក្រប្រែប្រួលទៅតាមកំណើន និងកម្រិតដែលវាប្រប្រួលទៅតាមវិសមភាពហើយអថេរដែលត្រូវយកចិត្តទុកដាក់គឺចំណាយប្រើប្រាស់រវាងរយៈពេលទាំងពីរ។ ក្នុងការបំបែកនេះគេត្រូវគណនាៈ (១)ទំហំផលប៉ះពាល់នៃកំណើនចំណាយប្រើប្រាស់ទៅលើភាពក្រីក្រ បើសិនការចែកចាយចំណាយប្រើប្រាស់គ្មានផ្លាស់ប្តូរ (២) ផលប៉ះពាល់នៃវិសមភាពទៅលើភាពក្រីក្រ ដោយក្នុងនេះគេទុកឲ្យចំណាយប្រើប្រាស់ប្រែប្រួលចុះឡើងរវាងរយៈពេលទាំងពីរ ប៉ុន្តែកំណើនចំណាយប្រើប្រាស់គេទុកឲ្យនៅថេរ។

តារាង ១៖ កម្រិតចាប់ប្រែប្រួលសំខាន់ៗ បានយកមកប្រើសម្រាប់វាយតម្លៃលើកំណើនទ្រទ្រង់ជនក្រីក្រ

| សន្ទស្សន៍ទ្រទ្រង់ជនក្រីក្រ | ការវាយតម្លៃ |
|---|---|
| θ<0 | កំណើនប៉ះពាល់អាក្រក់ដល់ជនក្រីក្រ |
| 0<θ≤0.33 | កំណើនទ្រទ្រង់តិចតួចដល់ជនក្រីក្រ |
| 0.33<θ≤0.66 | កំណើនទ្រទ្រង់បង្គួរដល់ជនក្រីក្រ |
| 0.66<θ<1.0 | កំណើនទ្រទ្រង់ដល់ជនក្រីក្រ |
| θ≥1.0 | កំណើនទ្រទ្រង់សុទ្ធសាធដល់ជនក្រីក្រ |

ប្រភព៖ Kakwani and Pernia (2000)

## ៣. ទិន្នន័យ

ការសិក្សានេះប្រើប្រាស់ទិន្នន័យបានពី អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) លើគ្រួសារចំនួន ៤លើក (NIS 2004, 2007, 2009, 2011) និង អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា (CDHS) ចំនួន ៤លើក (NIS 2000, 2005, 2010)។ CSES ជាអង្កេតគ្រួសារតំណាងឲ្យប្រទេសទាំងមូល ដោយប្រមូលព័ត៌មានលើ ៣៥០០គ្រួសារ ជារៀងរាល់ឆ្នាំ និងលើ ១៥,០០០គ្រួសារ រៀងរាល់ប្រាំឆ្នាំម្តង។ លក្ខណៈសង្គម-វប្បធម៌- នយោបាយ សំខាន់ៗរបស់គ្រួសារ រួមមាន លក្ខណៈប្រជាសាស្ត្រ, លំនៅដ្ឋាន, កសិកម្ម, ការអប់រំ, ការងារ, សុខភាព និងអាហារូបត្ថម្ភ, ការទទួលរងគ្រោះ និង ចំណូល-ចំណាយរបស់គ្រួសារ។

ក្រុមស្រាវជ្រាវក៏បានប្រើសំណុំទិន្នន័យរបស់ CDHS ឆ្នាំ២០០០ ២០០៥ និង ២០១០ ដែលមានទិន្នន័យដូចជា ចំនួនឆ្នាំសិក្សា វត្តមាននៅសាលារៀន, អត្រាស្លាប់កុមារ និងអាហាររូបត្ថម្ភ, និង ទ្រព្យសម្បត្តិគ្រួសារ។ CDHS ជាសំណុំទិន្នន័យដ៏សម្បូរបែប ដែលផ្តល់ព៌តមានជាច្រើន ជាពិសេស ស្តីពី សុខភាពមាតានិងទារក។ អង្កេតនេះមានសំណុំទិន្នន័យ ៤ គឺសម្រាប់ឆ្នាំ ១៩៩៨ ២០០០ ២០០៥ និង ២០១០ ដោយបានជ្រើសរើសឲ្យមានលក្ខណៈតំណាងទូទាំងប្រទេសនូវបុរសនិងស្ត្រីមានអាយុពី ១៥-៤៩ឆ្នាំ ទាំងនៅទីក្រុង និងនៅជនបទ នៅក្នុង ១៤ខេត្តខុសៗគ្នាដែលស្ថិតក្នុង ៥ក្រុមខេត្ត ។

## ៤. ការពិពណ៌នាស្ថិតិសង្ខេប: ចំណាយប្រើប្រាស់ និង ចំណាយមិនប្រើប្រាស់

រូបភាព ១ បង្ហាញនូវដង់ស៊ីតេនៃ របាយចំណាយប្រើប្រាស់ពិតប្រចាំថ្ងៃក្នុងមនុស្សម្នាក់ ក្នុងអំឡុងពេលសង្កេតពិនិត្យ។ និន្នាការទូទៅតាំងពីឆ្នាំ២០០៤ មក គឺ ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់កើនឡើង ដែលមានន័យថា ក្រុមបញ្ចភាគក្រីក្របំផុត បានបង្កើនចំណាយប្រើប្រាស់របស់ខ្លួន។ ការផ្លាស់ប្តូរឆ្លុះបញ្ចាំងពីកំណើនកម្រិតជីវភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជាជាមធ្យម ហើយ អត្រាជនក្រីក្រកំពុងថយចុះ។ ការល្អប្រសើរឡើងនៃចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ បណ្តាលជាសំខាន់ដោយសារ ផសស មានអត្រាកំណើនខ្ពស់ដល់លេខពីរខ្ទង់ ចាប់ពីឆ្នាំ២០០៤ ដល់ ២០០៧ ការងើបឡើងវិញយ៉ាងលឿនបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ និង ទឹកជំនន់ឆ្នាំ២០១១។ ដូច្នេះកំណើនចំណាយប្រើប្រាស់ ពិតជាបានរួមចំណែកកាត់បន្ថយចំនួនអ្នកក្រីក្រមែន។ ទោះបីមានល្បឿនគ្នាខ្លះក្តី ក៏ការព្យាករណ៍របស់ធនាគារពិភពលោក និងក្រសួងផែនការ បានបង្ហាញថា អត្រាភាពក្រីក្រនៅកម្ពុជាបានថយចុះតាំងពីឆ្នាំ ២០០៤ មក។ ឯកសារជិតចេញ

ផ្សាយមួយរបស់ធនាគារពិភពលោក បានប៉ាន់ស្មានថា ចំនួនអ្នកក្រីក្រធ្លាក់ចុះពី ៥៣,២% នៅឆ្នាំ ២០០៤ មកត្រឹម ២០,៥%នៅឆ្នាំ២០១១ រីឯតួលេខរបស់ក្រសួងផែនការ(2013) គឺ ៤៧,៨% នៅឆ្នាំ ២០០៧ និង ១៩,៨%នៅឆ្នាំ២០១១។

រូបភាព ១៖ ខ្សែកោងដង់ស៊ីតេចំណាយប្រើប្រាស់ពិតប្រចាំថ្ងៃក្នុងមនុស្សម្នាក់




ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើ CSES

ការធ្វើតេស្តពីវេទយិតភាព ដើម្បីប៉ាន់ស្មានពីភាពក្រីក្រ ដោយផ្អែកលើបន្ទាត់ភាពក្រីក្រនីមួយៗ បានបង្ហាញច្បាស់ថា អត្រាជនក្រីក្រនៅកម្ពុជាបន្តធ្លាក់ចុះតាំងពីឆ្នាំ២០០៤ មក។ លទ្ធផលនេះស្របនឹងការរកឃើញ របស់ធនាគារពិភពលោក (ឯកសារជិតចេញផ្សាយ) និងក្រសួងផែនការ (2013)។ ការវិភាគពីវេទយិតភាព បង្ហាញនូវ ស្ថានភាពប្រសើរឡើងរបស់អ្នកមានកម្រិតជីវភាពនៅជិត (គម្លាតភាពក្រីក្រ) និងនៅឆ្ងាយ ពីក្រោមបន្ទាត់ភាពក្រីក្រ (គម្លាតភាពក្រីក្រលើកជាការ៉េ ដែលវាស់វែងកម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រ)។

ភាពល្អប្រសើរឡើង ក៏អាចមើលឃើញតាមកំណើននៅក្នុងចំណែកនៃចំណាយប្រើប្រាស់របស់ប្រជាជន ដែលគេបានបែងចែកជា ១០ក្រុមស្មើគ្នា (តារាង ២)។ អនុបាតនៃចំណែកនៃចំណាយប្រើប្រាស់របស់ប្រជាជនក្រីក្របំផុត ១០% ធៀបនឹង ប្រជាជនធូរធារបំផុត ១០% គឺ ១:១៣ នៅឆ្នាំ២០០៤ និង ១:៩ នៅឆ្នាំ២០១១។ ពីឆ្នាំ២០០៤ ដល់ ២០១១ ចំណែកនៃចំណាយប្រើប្រាស់របស់ជនក្រីក្របំផុត ១០% បានកើនឡើង ១៦,៨%។ ជារួម និន្នាការនេះមានលក្ខណៈស្របគ្នានឹង លទ្ធផលរកឃើញរបស់ CDRI (2013: 18) ដែលក្នុងនោះ អនុបាតចំណាយប្រើប្រាស់របស់ប្រជាជនធូរធារបំផុត ២០% បានកើនពី ៧,១% ក្នុងឆ្នាំ ២០០៤ ដល់ ៨,៥% ក្នុងឆ្នាំ ២០០៧ និង ធ្លាក់ចុះដល់ ៥,៨% ក្នុងឆ្នាំ ២០០៩ និង ៥,៣% ក្នុងឆ្នាំ ២០១១។ អត្រាកំណើនមានលេខពីរខ្ទង់ ក្នុងចន្លោះពេលពីឆ្នាំ២០០៤ ដល់ ២០០៧ គឺទទួលបានស្របពេលគ្នានឹង កំណើនវិសមភាពចំណាយប្រើប្រាស់ ដែលមាន មេគុណ Gini ៣៩,៦ នៅឆ្នាំ ២០០៤ និង ៤៣,១ នៅឆ្នាំ ២០០៧ (World Bank 2009)។ កំណើនវិសមភាពពីឆ្នាំ ២០០៤ ដល់ ២០០៧ ក៏អាចមើលឃើញច្បាស់តាម កំណើន ៨,២%នៃចំណែកនៃចំណាយប្រើប្រាស់ របស់អ្នកធូរធារបំផុត១០% នោះដែរ។ ការគណនារបស់

អ្នកនិពន្ធបង្ហាញថា វិសមភាពចំណាយប្រើប្រាស់ កើនឡើងពីឆ្នាំ២០០៤ ដល់ ២០០៧ ហើយថយចុះជាបន្តបន្ទាប់ (តារាង ២)។

តារាង ២៖ មេគុណ Gini ប៉ាន់ស្មាន នៃ វិសមភាពចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់, តាមឆ្នាំ

| ឆ្នាំ | តួលេខប៉ាន់ស្មាន | លំអៀងស្តង់ដា (Standard error) | កម្រិតទាបបំផុត (Lower bound) | កម្រិតខ្ពស់បំផុត (Upper bound) |
|---|---|---|---|---|
| 2004 | 0.387 | 0.006 | 0.374 | 0.401 |
| 2007 | 0.435 | 0.024 | 0.386 | 0.482 |
| 2009 | 0.362 | 0.006 | 0.348 | 0.375 |
| 2011 | 0.360 | 0.031 | 0.299 | 0.422 |

កំណត់សំគាល់៖ លំអៀងស្តង់ដាបង្ហាញពីទំនុកចិត្ត ៩៥%
ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើ CSES

កម្រិតអប់រំជាមធ្យមនៃសមាជិកគ្រួសារពេញវ័យ (១៥ឆ្នាំឡើង) បានផ្លាស់ប្តូរតិចតួច ពីឆ្នាំ ២០០០ ដល់ ២០១០ គឺ ជាមធ្យមរៀនបាន ៣,៣ឆ្នាំ (ក្រុមបញ្ចភាគខាងក្រោមបំផុតបានតិចជាង ២ឆ្នាំ ហើយ ក្រុមបញ្ចភាគខាងលើបំផុតបាន ៥ឆ្នាំ) ។ តួលេខនេះបង្ហាញថា រដ្ឋាភិបាលមិនបានយកចិត្តទុកដាក់ខ្លាំងលើកកម្ពស់ការអប់រំមនុស្សពេញវ័យទេ។ ចំនួនឆ្នាំសិក្សារបស់កុមារ កើនឡើងពីឆ្នាំ២០០០ ដល់ ២០០៥ ប៉ុន្តែធ្លាក់ចុះវិញនៅឆ្នាំ២០១០។ អត្រាស្លាប់កុមារ បានថយចុះជាលំដាប់។ អត្រាស្លាប់កុមារអាយុក្រោមប្រាំឆ្នាំគឺ ១២៤ ក្នុង១០០០កំណើតរស់នៅឆ្នាំ២០០០ ហើយបន្ទាប់មកធ្លាក់ចុះដល់ ៨៣ នៅឆ្នាំ២០០៥ និង ៥៤ នៅឆ្នាំ២០១០ ឬធ្លាក់ចុះ ៥៦%ក្នុងពេល ១០ឆ្នាំ។ ស្ថានភាពអាហារូបត្ថម្ភកុមារបានប្រសើរឡើងច្រើន ពីឆ្នាំ២០០០ ដល់ ២០០៥ ដោយមានការថយចុះចំនួនកុមារក្រិន កុមារស្គមស្គាំង(ធៀបនឹងកម្ពស់) និងកុមារមិនគ្រប់ទម្ងន់ (ធៀបនឹងអាយុ)។ និន្នាការក្នុងប្រាំឆ្នាំទៅមុខទៀត បង្ហាញនូវការរីកចម្រើនតិចតួចឬគ្មានសោះៈ ចំនួនកុមារមិនគ្រប់ទម្ងន់ (ធៀបនឹងអាយុ) ស្ទើរតែនៅថេរ, ចំនួនកុមារស្គមស្គាំង (ធៀបនឹងកម្ពស់) កើនពី ៨% ដល់ ១១% ហើយចំនួនកុមារក្រិនថយចុះពី ៤២% ដល់ ៣៨%។

តារាង ៣៖ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារអាយុក្រោមប្រាំឆ្នាំ គិតតាមក្រុមបញ្ចភាគ (z-score)[២]

| ក្រុមបញ្ចភាគ | ក្រិន (មធ្យមៈ mean) | | | មិនគ្រប់ទម្ងន់ (មធ្យម) | | | ស្គមស្គាំង (មធ្យម) | | |
|---|---|---|---|---|---|---|---|---|---|
| | 2000 | 2005 | 2010 | 2000 | 2005 | 2010 | 2000 | 2005 | 2010 |
| 1 | - 3.98 | - 3.76 | - 3.70 | - 3.28 | - 2.98 | - 3.03 | - 2.77 | - 2.24 | - 2.42 |
| 2 | - 2.52 | - 2.49 | - 2.48 | - 2.08 | - 2.07 | - 2.05 | - 1.25 | - 1.22 | - 1.23 |
| 3 | - 1.84 | - 1.82 | - 1.82 | - 1.53 | - 1.51 | - 1.52 | - 0.68 | - 0.69 | - 0.69 |
| 4 | - 1.12 | - 1.13 | - 1.15 | - 0.99 | - 0.98 | - 1.01 | - 0.16 | - 0.15 | - 0.16 |
| 5 | 0.79 | 0.16 | 0.30 | 0.1 | 0.01 | - 0.04 | 1.26 | 1.00 | 0.87 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើ CDHS

២ Z-ពិន្ទុ វាស់វែង ទំហំនៃភាពខុសគ្នារវាងតួលេខមធ្យម (mean) ក្នុងក្រុមមួយ។ ភាពខុសគ្នាស្មើ 0 មានន័យថា z-score ស្មើគ្នា នឹងលេខមធ្យម(mean)។ z-score វិជ្ជមាន/អវិជ្ជមាន បង្ហាញថា ពិន្ទុវាខ្ពស់ជាង/ទាបជាង មធ្យម។ ទំហំភាពខុសគ្នាត្រូវបានបកស្រាយជា គម្លាតស្តង់ដា។ ក្នុងការសិក្សានេះ z-score ត្រូវបានគណនាដោយប្រើ " z-score 06 " ក្នុងកម្មវិធីកុំព្យូទ័រ Stata ។

ពិន្ទុកង្វះអាហារូបត្ថម្ភនៃគ្រួសារធូរធារជាងគេ២០% បានធ្លាក់ចុះជាលំដាប់ (តារាង ៣)។ កុមារស្គមស្គាំង (ធៀបនឹងកម្ពស់) ធ្លាក់ពី ១,៣គម្លាតស្តង់ដានៅឆ្នាំ ២០០០ ដល់ ០,៩ នៅឆ្នាំ ២០១០ ហើយគេឃើញមាននិន្នាការស្រដៀងគ្នា សម្រាប់កុមារមិនគ្រប់ទម្ងន់(ធៀបនឹងអាយុ) និងក្រិន (លើកលែងពីឆ្នាំ២០០៥ ដល់ ២០១០)។ សម្រាប់គ្រួសារក្រីក្រជាងគេ២០% មានសេណារីយ៉ូពីរផ្សេងគ្នាកើតឡើង ស្តីពីកង្វះអាហារូបត្ថម្ភ។ ទី១ ពិន្ទុមធ្យមបានកើនឡើងសម្រាប់កុមារទាំងបីប្រភេទ ដែលបង្ហាញថា ស្ថានភាពសេដ្ឋកិច្ចទូទៅ បានជួយទ្រទ្រង់ជនក្រីក្រទាក់ទិននឹងស្ថានភាពអាហារូបត្ថម្ភកុមារ ពីឆ្នាំ២០០០ ដល់ ២០០៥។ បន្ទាប់មក ពីឆ្នាំ២០០៥ ដល់ ២០១០ មាននិន្នាការផ្ទុយមកវិញ ដោយពិន្ទុក្រុមបញ្ចភាគកណ្តាលនៅថេរ ដែលបង្ហាញថា បម្រែបម្រួលពិន្ទុក្រុមបញ្ចភាគលើគេ និង ក្រោមគេ ធ្វើឲ្យពិន្ទុមធ្យមប្រែប្រួល។

តារាង ៤៖សុខភាពគ្រួសារនិងការអប់រំ គិតតាមស្ថានភាពទ្រព្យធន ឆ្នាំ២០០៥-១០ (z-score)

| ក្រុមបញ្ចភាគ ទ្រព្យធន | ក្រិន | មិនគ្រប់ទម្ងន់ | ស្គមស្គាំង | ចំនួនឆ្នាំសិក្សា |
|---|---|---|---|---|
| 1 | - 2.10 | - 1.66 | - 0.67 | 2.70 |
| 2 | - 1.88 | - 1.58 | - 0.72 | 2.92 |
| 3 | - 1.69 | - 1.45 | - 0.64 | 2.99 |
| 4 | - 1.54 | - 1.37 | - 0.71 | 3.11 |
| 5 | - 1.46 | - 1.24 | - 0.61 | 3.24 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើ CDHS

ពីឆ្នាំ២០០៥ ដល់ ២០១០ សន្ទស្សន៍ទ្រព្យធនតាមគ្រួសារជាមធ្យមកើនជាង ៩០% ឬ ២,៧ពិន្ទុ ជាតួលេខសុទ្ធ ដែលបង្ហាញថា ជីវភាពបានល្អប្រសើរជាងមុន។ ភាពប្រសើរឡើងនេះឃើញមាននៅគ្រប់ក្រុមបញ្ចភាគ លើកលែងតែ ពិន្ទុក្រុមធូរធារជាងគេ ដែលធ្លាក់ចុះប្រហែល ៦៧%។ គិតជាតួលេខសុទ្ធ សន្ទស្សន៍ទ្រព្យសម្បត្តិក្រុមក្រីក្របំផុត បានប្រសើរឡើងខ្លាំងជាងគេរហូតដល់ ៦,៣ពិន្ទុ។ ជានិន្នាការទូទៅ កម្រិតជីវភាពគ្រួសារក្រីក្រ មានអត្រាកំណើនខ្ពស់ជាងគ្រួសារធូរធារ ដែលបញ្ជាក់ថា កំណើនសេដ្ឋកិច្ចបានជួយទ្រទ្រង់ដល់ជនក្រីក្រ បើពិនិត្យតាមកំណើនទ្រព្យធន។ ចំណងទាក់ទងរវាង សុខភាពនិងកម្រិតអប់រំក្នុងគ្រួសារ ជាមួយនឹង ស្ថានភាពទ្រព្យធនរបស់ពួកគេ ក៏គួរឱ្យចាប់អារម្មណ៍ព្រោះអាចបំភ្លឺថា តើទ្រព្យសម្បត្តិកាន់តែច្រើន នាំឲ្យសុខភាព និងកម្រិតអប់រំរបស់គ្រួសារក្រីក្រ កើនឡើងលឿនជាងគ្រួសារធូរធារ ឬយ៉ាងណា។ បញ្ហានេះស្រដៀងគ្នានឹងអ្វីដែល Grosse *et al.* (2008) ហៅថា កំណើនជួយទ្រទ្រង់ដល់ជនក្រីក្រដោយមានលក្ខខណ្ឌ។ ទិន្នន័យក្នុង តារាង ៤ បង្ហាញនូវ ទំនាក់ទំនងច្បាស់លាស់រវាង សុខភាព និងកម្រិតអប់រំរបស់គ្រួសារ ជាមួយនឹង ស្ថានភាពទ្រព្យធន។ ក្រុមបញ្ចភាគគ្រួសារមានទ្រព្យធនតិច គឺមាន z-score ទាបជាង និង ចំនួនឆ្នាំសិក្សាតិចជាង ក្រុមបញ្ចភាគគ្រួសារធូរធារ។

សរុបមក ការល្អប្រសើរឡើងនៃសូចនាករសុខភាព ពីឆ្នាំ២០០០ ដល់ ២០០៥ បង្ហាញថា កំណើនសេដ្ឋកិច្ចបានជួយទ្រទ្រង់ខ្លាំងដល់ជនក្រីក្រ ព្រោះគ្រួសារក្រីក្រទទួលអត្ថប្រយោជន៍បានច្រើនជាងគ្រួសារធូរធារ ប៉ុន្តែភាពជួយទ្រទ្រង់នេះបានថយចុះខ្លះវិញពីឆ្នាំ២០០៥ ដល់ ២០១០។ សម្រាប់ការអប់រំ កំណើនសេដ្ឋកិច្ចបានជួយទ្រទ្រង់ជនក្រីក្រកាន់តែខ្លាំងពីឆ្នាំ ២០០៥ ដល់ ២០១០។ លទ្ធផលទាំងនេះបង្ហាញថា បំណែងចែក អត្ថប្រយោជន៍មិនមែនប្រាក់ចំណូល អាច

គ្មានបញ្ហាចោទមែន ប៉ុន្តែស្ថានភាពសុខភាពនិងការអប់រំ នៅតែជាក្តីបារម្ភធ្ងន់ធ្ងរមួយ។ ទិន្នន័យពីឆ្នាំ២០០៥-១០ បង្ហាញថា ស្ថានភាពសុខភាពនិងការអប់រំមិនបានល្អប្រសើរឡើងទេ ដូច្នេះគួរមានអន្តរាគមន៍ខាងគោលនយោបាយដើម្បីសម្រួលឲ្យកំណើនមានតុល្យភាពល្អ។

## ៥. ភាពបានជាប្រយោជន៍ដល់ទាំងអស់គ្នា៖ កំណើនជួយទ្រទ្រង់ដល់ជនក្រីក្រ

### ៥.១ ចំណាយប្រើប្រាស់

តារាង ៥ បង្ហាញនូវលទ្ធផលនៃការបំបែកតួលេខកាត់បន្ថយភាពក្រីក្រពីឆ្នាំ២០០៤ ដល់ ២០១១ ចេញជាឥទ្ធិពលនៃកំណើនចំណាយប្រើប្រាស់ និង វិសមភាព។ ដូចបានរៀបរាប់ខាងលើ ការប្រែប្រួលនៃភាពក្រីក្រសរុប គឺជាការគួបផ្សំគ្នានៃ កំណើនសុទ្ធ និង ឥទ្ធិពលនៃវិសមភាព។ ឧទាហរណ៍ ពីឆ្នាំ២០០៤ ដល់ ២០០៧ ដោយសារចំណាយប្រើប្រាស់មានកំណើនជាមធ្យម ៤៣,៨% ចំនួនជនក្រីក្របានធ្លាក់ចុះ ០,២៥%។ ហើយបើសិនគ្មានការប្រែប្រួលក្នុងវិសមភាពចំណាយប្រើប្រាស់ទេនោះ កំណើននេះផ្តល់ផលប៉ះពាល់បាន ១-២ លើការកាត់បន្ថយភាពក្រីក្រ ដែលមានន័យថា កំណើន ១% ក្នុងចំណាយប្រើប្រាស់ជាមធ្យម នឹងកាត់បន្ថយភាពក្រីក្របាន ២,៤៣%។ ប៉ុន្តែ កំណើនវិសមភាពចំណាយប្រើប្រាស់ ២,១៩% បានរារាំងផលប៉ះពាល់ដោយផ្ទាល់ខាងលើនេះ។ ដូច្នេះពីឆ្នាំ២០០៤ ដល់ ២០០៧ កំណើនសេដ្ឋកិច្ចបានទ្រទ្រង់ខ្សោយដល់ជនក្រីក្រ (សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ គឺ ០,១០)។ ពីឆ្នាំ២០០៧ ដល់ ២០០៩ កំណើនបានទ្រទ្រង់ដល់ជនក្រីក្រ ដោយមានសន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ ០,៧៦។ ពីឆ្នាំ ២០០៤ ដល់២០១១ កំណើនយ៉ាងលឿននៅកម្ពុជា បានទ្រទ្រង់បង្គួរដល់ជនក្រីក្រ ដោយសារចំណាយប្រើប្រាស់ជាមធ្យមបានកើនឡើង ហើយការចែកចាយក៏ល្អប្រសើរឡើងដែរ។

តារាង ៥៖ ឥទ្ធិពលនៃកំណើន និងវិសមភាព ទៅលើភាពក្រីក្រ

| សន្ទស្សន៍ ចំនួន ប្រជាជន | កំណើនពិត (%) (a) | ការប្រែប្រួលភាពក្រីក្រសរុប (%) (b) =(c)+(d) | បំបែកចេញជា | | សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ (e) = (b)/(c) |
|---|---|---|---|---|---|
| | | | ឥទ្ធិពលនៃកំណើនសុទ្ធ (%) (c) | ឥទ្ធិពលនៃវិសមភាព (%) (d) | |
| 2004-2007 | 43.87 | - 0.25 | - 2.43 | 2.19 | 0.10 |
| 2007-2009 | 40.53 | - 2.30 | - 3.04 | 0.74 | 0.76 |
| 2009-2011 | 10.78 | - 6.28 | - 4.68 | - 1.59 | 1.34 |
| 2004-2011 | 95.18 | - 1.80 | - 3.40 | 1.60 | 0.53 |
| 2004-2009 | 84.40 | - 1.23 | - 3.04 | 1.81 | 0.40 |
| 2007-2011 | 51.31 | - 3.13 | - 3.55 | 0.42 | 0.88 |

ប្រភព៖ការគណនារបស់អ្នកនិពន្ធដោយប្រើ CSES

រូបភាព ២៖ អត្រាកំណើនសមមូលនៃភាពក្រីក្រ(PEGR) សម្រាប់ចំនួនជនក្រីក្រ $\alpha = 0$




ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើ CSES

ភាពទ្រទ្រង់ជនក្រីក្រនៃកំណើនចំណាយប្រើប្រាស់ក៏អាចកំណត់បាន ដោយពិនិត្យពីភាពខុសគ្នារវាង អត្រាកំណើនពិតនៃចំណាយប្រើប្រាស់ក្នុងគ្រួសារ នឹង អត្រាកំណើនសមមូលនៃភាពក្រីក្រ (poverty equivalent growth rate: PEGR) ដែរ។ ដូចមានបង្ហាញក្នុង រូបភាព ២ បើសិន PEGR វាធំជាង កំណើនពិត គឺ កំណើនបានជួយទ្រទ្រង់ដល់ជនក្រីក្រ ដែលមានន័យថា ជនក្រីក្រទទួលបានអត្ថប្រយោជន៍ក្នុងសមាមាត្រមួយច្រើនជាង ជនមិនមែនក្រីក្រ។ ក្នុងអំឡុងពេលបានសង្កេតពិនិត្យ មានតែក្នុងឆ្នាំ ២០០៩-១១ ប៉ុណ្ណោះដែលកំណើនចំណាយប្រើប្រាស់បានជួយទ្រទ្រង់ដល់ជនក្រីក្រ ព្រោះ PEGR ធំជាងអត្រាកំណើនពិត។ ក្នុងរយៈពេលនោះ មានព្រឹត្តិការណ៍សំខាន់ពីរ គឺ ១-ការងើបឡើងវិញពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកល និងវិបត្តិបំណុលអឺរ៉ុប ដែលបានប៉ះពាល់ខ្លាំងដល់ការនាំចេញរបស់កម្ពុជា ពិសេស សម្លៀកបំពាក់ និង ២-គ្រោះទឹកជំនន់។ វិបត្តិទាំងនេះបានបង្កក្តីបារម្ភថា សេដ្ឋកិច្ចកម្ពុជាដែលមានមូលដ្ឋានតូចចង្អៀតនេះ អាចធ្លាក់កំណើន និងអត្រាប្រជាជនស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ អាចកើនខ្លាំង។ ប៉ុន្តែនៅឆ្នាំ២០១១ សេដ្ឋកិច្ចកម្ពុជាបានស្ទុះឡើងវិញដោយ ផសស មានកំណើនរហូតដល់ ៦,៩ % ដែលអាចជួយបានមួយភាគដែរក្នុងការរក្សាជីវភាពកុំឲ្យធ្លាក់ទាបជាងកម្រិតស្តង់ដាអប្បបរមានិងការពារគ្រួសារកុំឲ្យធ្លាក់ចូលក្នុងភាពក្រីក្រ។ ថ្វីបើ សេណារីយ៉ូកំណើនផ្សេងទៀត មិនបានទ្រទ្រង់ជនក្រីក្រសុទ្ធសាធក្តី ក៏ការខុសគ្នារវាងកំណើនពិត និង PEGR បានរួមតូចដែរ។ ឧទាហរណ៍ កំណើនពិតវាធំជាខ្លាំងជាង PEGR កាលពីឆ្នាំ២០០៤-០៧ (៣៩,៤ ឯកតាភាគរយ), ប៉ុន្តែគម្លាតនេះបានរួមតូចវិញនៅរវាងឆ្នាំ ២០០៧ និង២០០៩ ដល់ត្រឹម ៩,៨%។ ដូច្នេះ គេចាត់ទុកថា សេណារីយ៉ូកំណើននេះបានជួយទ្រទ្រង់បង្គួរដល់ជនក្រីក្រ ហើយនេះក៏ជាករណីក្នុងអំឡុងឆ្នាំ២០០៤-១១ដែរ។

## ៥.២ ចំណាយមិនប្រើប្រាស់(non-consumption)៖ សុខភាព និងការអប់រំ

ប្រទេសកម្ពុជាមានស្ថានភាពអាហាររូបត្ថម្ភកុមារល្អប្រសើរឡើងពីឆ្នាំ ២០០០ ដល់ ២០០៥ ហើយកំណើនក៏បានជួយទ្រទ្រង់ខ្លាំងដល់ជនក្រីក្រ។ ក្នុងអំឡុងពេលនោះ ការរីកចម្រើននៃក្រុមក្រីក្រផ្នែកសុខភាព មានកម្រិតខ្ពស់ជាង ក្រុមបញ្ចភាគមិនក្រីក្រផ្នែកសុខភាព ដែលបង្ហាញថា មាន

ការយកចិត្តទុកដាក់ជាងមុនលើគោលនយោបាយពង្រឹងសុខភាពកុមារ។ កំណើនតួលេខមធ្យម (mean) នៃ z-score នៃសូចនាករបញ្ហាគ្រិន, មិនគ្រប់ទម្ងន់(ធៀបនឹងអាយុ) និង ស្គមស្គាំង (ធៀបនឹងកម្ពស់) សុទ្ធតែបញ្ជាក់ពីភាពទ្រទ្រង់ជនក្រីក្រ។ កំណើនគម្លាតស្តង់ដា ០,០៣៦ នៃ z-score ភាពគ្រិន បញ្ជាក់នូវការថយចុះចំនួនកុមារគ្រិន (កុមារនៅខាងក្រោម -២ គម្លាតស្តង់ដារ) អស់ ០,០៥% (តារាង ៦)។

តារាង ៦៖ ឥទ្ធិពលនៃកំណើន និងវិសមភាព ទៅលើភាពក្រីក្រផ្នែកសុខភាព

| សន្ទស្សន៍ចំនួនប្រជាជន | កំណើនពិត (absolute) (a) | ការប្រែប្រួលភាពក្រីក្រសរុប (%) (b) =(c)+(d) | បំបែកចេញជា | | សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ (e) = (b)/(c) | PEGR (absolute) (a)*(e) |
|---|---|---|---|---|---|---|
| | | | ឥទ្ធិពលនៃកំណើនសុទ្ធ (%) (c) | ឥទ្ធិពលនៃវិសមភាព (%) (d) | | |
| គ្រិន | | | | | | |
| 2000-2005 | 0.036 | - 0.051 | - 0.008 | - 0.043 | 6.255 | 0.222 |
| 2005-2010 | 0.155 | - 0.055 | - 0.056 | 0.000 | 0.993 | 0.154 |
| 2000-2010 | 0.190 | - 0.106 | - 0.065 | - 0.042 | 1.646 | 1.313 |
| មិនគ្រប់ទម្ងន់ | | | | | | |
| 2000-2005 | 0.268 | - 0.111 | - 0.089 | - 0.023 | 1.258 | 0.337 |
| 2005-2010 | - 0.0001 | - 0.012 | 0.001 | -0.013 | 1.0832 | 0.000 |
| 2000-2010 | 0.268 | - 0.124 | - 0.094 | - 0.030 | 1.314 | 0.352 |
| ស្គមស្គាំង | | | | | | |
| 2000-2005 | 0.303 | - 0.104 | - 0.030 | - 0.074 | 3.415 | 1.034 |
| 2005-2010 | - 0.131 | 0.024 | 0.012 | 0.017 | 0.7261 | - 0.31 |
| 2000-2010 | 0.171 | - 0.075 | - 0.019 | - 0.056 | 3.932 | 0.674 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើ CSES

សន្ទស្សន៍ក្រីក្រផ្នែកសុខភាព កំណើនពិត (តួលេខ) ការប្រែប្រួលតាមគ្នាសរុបនៃភាពក្រីក្រ (%) បំបែកចេញជាឥទ្ធិពលកំណើនសុទ្ធសាធ (%) ឥទ្ធិពលវិសមភាព (%) សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រ PEGR (absolute)

ការល្អប្រសើរឡើងនៃ z-score (ស្ថានភាពអាហាររូបត្ថម្ភល្អជាងមុន) និង ការប្រសើរឡើងក្នុងការចែកចាយ z-score នេះ នាំឲ្យចំនួនកុមារគ្រិនមានការថយចុះអស់ ០,០៤% ដែលបញ្ជាក់ថា កំណើនបានទ្រទ្រង់ដល់ជនក្រីក្រ។ សន្ទស្សន៍ទ្រទ្រង់ជនក្រីក្រសម្រាប់ភាពគ្រិន មានទំហំធំដល់ ៦,២៥ ហើយលទ្ធផលមានស្រដៀងគ្នា សម្រាប់កុមារស្គមស្គាំង(សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រសម្រាប់កុមារស្គមស្គាំង គឺ ៣,៤១) និង សម្រាប់កុមារមិនគ្រប់ទម្ងន់(សន្ទស្សន៍កំណើនទ្រទ្រង់ជនក្រីក្រសម្រាប់កុមារមិនគ្រប់ទម្ងន់ គឺ ១,២៥) ដែលបានន័យថា កំណើនទ្រទ្រង់ខ្លាំងដល់ជនក្រីក្រ។ ប៉ុន្តែពីឆ្នាំ២០០៥ ដល់ ២០១០ លទ្ធផលមានលក្ខណៈលាយឡំគ្នា។ សូចនាករភាពគ្រិនគឺទ្រទ្រង់ជនក្រីក្រ ដោយការប្រសើរឡើងនៃ z-score (លំអៀងស្តង់ដា៖ ០,១៥) នាំឲ្យកុមារគ្រិនថយចុះអស់០,០៥%ដែលបង្កឡើងដោយកំណើនz-scoreសុទ្ធសាធពីព្រោះរបាយវានៅថេរ។ សូចនាករនេះគឺទ្រទ្រង់ខ្លាំងដល់ជនក្រីក្រ បើសិនជា របាយ z-score អំណោយផលដល់ជនក្រីក្រ។

ក្នុងអំឡុងពេលនោះ z-score មធ្យម ស្ទើរតែគ្មានកំណើនសោះសម្រាប់សូចនាករមិនគ្រប់ទម្ងន់ (ធៀបនឹងអាយុ) ប៉ុន្តែកំណើនសេដ្ឋកិច្ចនៅតែទ្រទ្រង់ដល់ជនក្រីក្រ។

តារាង ៧៖ ឥទ្ធិពលនៃកំណើន និងវិសមភាព ទៅលើភាពក្រីក្រផ្នែកអប់រំ

| | កំណើនពិត (absolute) (a) | ការប្រែប្រួលភាពក្រីក្រសរុប (%) (b) =(c)+(d) | បំបែកចេញជា | | សន្ទស្សន៍កំណើន ទ្រទ្រង់ជនក្រីក្រ (e) = (b)/(c) | PEGR (absolute) (a)*(e) |
|---|---|---|---|---|---|---|
| | | | ឥទ្ធិពលនៃកំណើនសុទ្ធ (%) (c) | ឥទ្ធិពលនៃវិសមភាព (%) (d) | | |
| ការអប់រំមនុស្សពេញវ័យ | | | | | | |
| 2000-2005 | - 0.009 | 0.012 | 0.000 | 0.012 | 0.000 | 0.000 |
| 2005-2010 | - 0.007 | 0.008 | 0.000 | 0.008 | 0.000 | 0.000 |
| ការអប់រំកុមារ | | | | | | |
| 2000-2005 | 0.848 | - 0.080 | - 0.066 | - 0.014 | 1.205 | 1.022 |
| 2005-2010 | - 0.621 | 0.057 | 0.066 | - 0.009 | 1.160 | - 0.720 |
| ការអប់រំប្រជាជន | | | | | | |
| 2000-2005 | 0.285 | - 0.044 | - 0.099 | 0.055 | 0.449 | 0.128 |
| 2005-2010 | - 0.156 | 0.019 | 0.099 | - 0.080 | 5.178 | - 0.807 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើCSES

ភាពទ្រទ្រង់ជនក្រីក្រនៃកំណើនផ្អែកតាមកម្រិតអប់រំ មានលក្ខណៈខុសគ្នារវាងមនុស្សពេញវ័យ និងកុមារ ដូចមានបំបែកលំអិតក្នុង តារាង ៧ ។ បច្ចុប្បន្នពុំទាន់មាននិយមន័យទូទៅសម្រាប់អ្នកក្រីក្រផ្នែកអប់រំទេ ប៉ុន្តែយើងអាចកំណត់ជាបណ្ដោះអាសន្នថា ជាអ្នកមានចំនួនឆ្នាំសិក្សាស្ថិតក្នុងក្រុមប្រជាជន ៣០% ដែលមានការអប់រំតិចជាងគេ ហើយខ្សែបន្ទាត់ភាពក្រីក្រ ជាបន្ទាត់បែងចែកក្រុមមានការអប់រំតិចបំផុត៣០%និងក្រុមបញ្ញាភាគលើសពី៣០%។យើងប្រើខ្សែបន្ទាត់ភាពក្រីក្រនៃឆ្នាំគោលដើម្បីគណនាសន្ទស្សន៍ទ្រទ្រង់ជនក្រីក្រ។ ឧទាហរណ៍ យើងប្រើខ្សែបន្ទាត់ភាពក្រីក្រឆ្នាំ២០០៥ ដើម្បីគណនា សន្ទស្សន៍ទ្រទ្រង់ជួយជនក្រីក្រ ពីឆ្នាំ ២០០៥ ដល់ ២០១០ និង ខ្សែបន្ទាត់ភាពក្រីក្រឆ្នាំ ២០០០ ដើម្បីគណនាសន្ទស្សន៍ទ្រទ្រង់ជនក្រីក្រ ពីឆ្នាំ ២០០០ ដល់ ២០០៥។

ពីឆ្នាំ២០០០ ដល់ ២០០៥ ភាពប្រសើរឡើងជាទូទៅនៃការអប់រំ បានជួយទ្រទ្រង់បង្គួរដល់ជនក្រីក្រ ដោយមានសន្ទស្សន៍ទ្រទ្រង់ជនក្រីក្រ ០,៤៥។ កំណើនជាមធ្យម ០,២៨% នៃចំនួនឆ្នាំសិក្សារបស់សមាជិក គ្រួសារទាំងអស់ បានកាត់បន្ថយចំនួនអ្នកក្រីក្រផ្នែកអប់រំ អស់ ០,០៤% ដោយសារកំណើនសុទ្ធ មានការប្រែប្រួលខ្លាំងជាងមុន (-0,០៩%) ប៉ុន្តែមានរបាយអន់ជាងមុន (+0,០៥) ដែលមានន័យថា កំណើនវាផ្ដល់អត្ថប្រយោជន៍ដល់អ្នកធូរធារផ្នែកអប់រំ បានច្រើនជាងអ្នកក្រីក្រផ្នែកអប់រំ។ ក្នុងពេលជាមួយគ្នា ការអប់រំសម្រាប់មនុស្សពេញវ័យសឹងតែនៅថេរ។ ទិន្នន័យ CDHS បង្ហាញថា ការអប់រំរបស់មេគ្រួសារមានត្រឹម ៣,៣ឆ្នាំ នៅចន្លោះឆ្នាំ២០០០ និង ២០១០។ ការអប់រំមិនផ្លូវការ ប្រហែលអាចជួយពង្រឹងការអប់រំរបស់ពួកគេ។ មានឯកសារជាច្រើនបញ្ជាក់ថា

ផលិតភាពទទួលផលបានច្រើនពីការអប់រំ ជាពិសេស ការអប់រំកម្រិតបឋម។ ការអប់រំកុមារ មានការផ្លាស់ប្តូរយ៉ាងច្រើនដូចការរំពឹងទុក ហើយជួយទ្រទ្រង់ខ្លាំងដល់ជនក្រីក្រ។

ពីឆ្នាំ២០០៥ដល់២០១០ទោះបីកម្រិតអប់រំក្នុងគ្រួសារបានថយចុះអស់០,១៥%ក្នុងមួយឆ្នាំក្តី ក៏កំណើននៅតែទ្រទ្រង់ដល់ជនក្រីក្រ។ កំណើនអវិជ្ជមាន ធ្វើឲ្យគ្រួសារក្រីក្រផ្នែកអប់រំកើនឡើងក៏ពិតមែន ប៉ុន្តែរបាយល្អជាងមុនអាចប៉ះប៉ូវតទិ្ធពលអវិជ្ជមាននេះបាន។ លទ្ធផលបង្ហាញថា ការថយចុះចំនួនឆ្នាំសិក្សាអស់ ០,១៥ឆ្នាំ បណ្តាលឲ្យគ្រួសារ ០,០៩% ថែមទៀតធ្លាក់ចូលក្នុងភាពក្រីក្រផ្នែកអប់រំ ប៉ុន្តែ ឥទ្ធិពលនៃវិសមភាពបានរំកិលគ្រួសារ ០,០៨%ថែមទៀត ចេញពីភាពក្រីក្រផ្នែកអប់រំ។ ផលប៉ះពាល់អាចកាន់តែអាក្រក់ទៀត បើសិនជារបាយវាអាក្រក់ជាងមុននោះ។ ការអប់រំកុមារមាននិន្នាការដូចគ្នាៈ កំណើនគឺអវិជ្ជមាន ប៉ុន្តែនៅតែជួយទ្រទ្រង់ដល់ជនក្រីក្រ។

## ៦. ការសន្និដ្ឋាន និងអនុសាសន៍

ពាក់ព័ន្ធនឹងចំណាយប្រើប្រាស់ លទ្ធផលបង្ហាញថា ការធ្លាក់ចុះអត្រាក្រីក្រនៅកម្ពុជាយ៉ាងច្រើនពីឆ្នាំ២០០៤ ដល់ ២០១១ បណ្តាលជាសំខាន់ ពីឥទ្ធិពលគួបផ្សំគ្នានៃកំណើន និងការចែកចាយ ដែលបញ្ជាក់ថា កម្ពុជាបានងាកចេញជាបណ្តើរៗពី កំណើនសេដ្ឋកិច្ចបែបបរិមាណ ទៅកាន់ កំណើនសេដ្ឋកិច្ចមានការចែកចាយប្រកបដោយសមធម៌ ហើយប្រជាជនក៏ទទួលបានឱកាសច្រើនជាងមុនដែរ។ ទោះបីជាអត្រាភាពក្រីក្រកំពុងថយចុះក្តី ប៉ុន្តែវាផ្សារភ្ជាប់ទៅនឹងបន្ទាត់ភាពក្រីក្រកម្រិតខ្ពស់ (១,២៥ដុល្លារ ឬ ២,០០ដុល្លារ ក្នុងមួយថ្ងៃ) ដែលមានន័យថា គ្រួសារភាគច្រើនកំពុងចេញផុតពីភាពក្រីក្រ ប៉ុន្តែស្ថិតនៅក្បែរបន្ទាត់ភាពក្រីក្រនៅឡើយ ហើយងាយរងគ្រោះដោយសារបញ្ហាប្រាក់ចំណូល។ កម្ពុជាកំពុងដើរទាន់ផែនការដើម្បីសម្រេចនូវ កំណើនចំណាយមិនប្រើប្រាស់ជួយទ្រទ្រង់ដល់ជនក្រីក្រ ដែលជាកត្តាចម្បងជំរុញកំណើនសម្រាប់ទាំងអស់គ្នា។ កម្រិតជីវភាពបានកើនច្រើន និងមានភាពទ្រទ្រង់ដល់ជនក្រីក្រ។ លទ្ធផលជារួមខាងផ្នែកសុខភាព ផ្អែកលើស្ថានភាពអាហារូបត្ថម្ភកុមារ គឺគួរឲ្យពេញចិត្ត។ ដូច្នេះ បញ្ហាប្រឈមគឺការរក្សាកំណើន។ សូចនាករនៃចំណាយមិនមែនប្រើប្រាស់មានរបាយល្អ ប៉ុន្តែ ឧទាហរណ៍ កំណើននៃសូចនាករអាហារូបត្ថម្ភគឺនៅយឺត ឬគ្មានសោះ ពីឆ្នាំ២០០៥ ដល់ ២០១០។

តាមការបកស្រាយដូចខាងលើ បញ្ហាប្រឈមដែលនៅសេសសល់ គឺ ការរក្សាកំណើន និងធានាឲ្យប្រជាជនភាគច្រើនមានលទ្ធភាពប្រហាក់ប្រហែលគ្នា។ នេះជាការងារដ៏លំបាក ព្រោះត្រូវជំនះលើឧបសគ្គជាច្រើនដូចតទៅនេះ៖

- ធនធានមនុស្សមានកំណត់ នៅតែជាឧបសគ្គចម្បង ក្នុងការសម្រេចបានកំណើនឲ្យកាន់តែច្រើន និងជៀសវាងការជាប់គាំងនៅក្នុងស្ថានភាពមានចំណូលមធ្យម។
- កម្លាំងពលកម្មនៅកម្ពុជាមួយផ្នែកធំមានជំនាញទាប និងចូលរួមភាគច្រើនក្នុងការងារកសិកម្ម។ គុណភាពការអប់រំ ពិសេសនៅបឋមសិក្សា និងអនុវិទ្យាល័យ ត្រូវពង្រឹងបន្ថែម។ លទ្ធភាពទទួលបាន ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ អាចជាដំណោះស្រាយមួយដែលគួរពិនិត្យពិចារណា។

- លទ្ធភាពតូចក្នុងការទទួលសេវាថែទាំសុខភាពមានគុណភាពល្អ និងតម្លៃសមរម្យ គឺជាឧបសគ្គមួយទៀតដែលអាចប៉ះពាល់ដល់ផលិតភាពកម្លាំងពលកម្ម។ ទោះបីមានការរីកចម្រើនមួយចំនួនក្តី ប៉ុន្តែត្រូវប្រឹងប្រែងបន្ថែមទៀត ជាពិសេសក្នុងចំណោមប្រជាជននៅទីជនបទ ដើម្បីបង្កើនលទ្ធភាពទទួល បានសេវាថែទាំសុខភាព និងបង្រួមគម្លាតរវាងអ្នកមាន និងអ្នកក្រ។ ដោយសារតែហេដ្ឋារចនាសម្ព័ន្ធមិនល្អ និងប្រាក់ខែទាប បុគ្គលិកថែទាំសុខភាពមានការលើកទឹកចិត្តតិចតួចណាស់ឲ្យនៅបម្រើការក្នុងតំបន់ជនបទ។ ការលៃចែកថវិកាជាតិគិតក្នុងមនុស្សម្នាក់ សម្រាប់ការថែទាំសុខភាពមានតិចតួចណាស់ ដែលបង្ខំឲ្យប្រជាជនត្រូវរ៉ាប់រងមួយចំណែកធំនៃចំណាយថែទាំសុខភាព។ ស្ថានភាពនេះធ្វើឱ្យគ្រួសារងាយរងគ្រោះនានា អាចធ្លាក់ក្នុងភាពក្រីក្រនៅពេលមានវិបត្តិសុខភាព។

- ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ បណ្តាញអគ្គិសនី និងប្រព័ន្ធធារាសាស្ត្រ នៅអន់ថយនៅឡើយ ជាពិសេស នៅតាមតំបន់ជនបទ។ ស្ថានភាពមិនអាចប្រើប្រាស់របស់សាធារណៈសំខាន់ៗទាំងនេះបាន ជាកត្តាមួយដែលពង្រីកគម្លាតរវាងតំបន់ទីក្រុង និងជនបទ ក្នុងការទទួលបានឱកាសផ្សេងៗ។

- នៅឆ្នាំ ២០១១ រដ្ឋាភិបាលបានអនុម័ត ផែនការប្រាំឆ្នាំនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមលើកទី១ ដែលអាចជាជំហានទៅមុខមួយដើម្បីពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់ក្រុមងាយរងគ្រោះនិងប្រជាជនទន់ខ្សោយ។ ប៉ុន្តែបច្ចុប្បន្នគេមិនទាន់ដឹងពីការអនុវត្ត ហើយអាចវិនិច្ឆ័យនូវយុទ្ធសាស្ត្រនេះបានទេ។ បញ្ហាជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុ ក៏ជាក្តីបារម្ភមួយដែរ។

អត្ថបទនេះមិនបានស្នើឡើងនូវ គោលនយោបាយជាក់លាក់ទ្រទ្រង់ដល់ជនក្រីក្រក៏ពិតមែន ប៉ុន្តែបានបង្ហាញថា ការដោះស្រាយបញ្ហាប្រឈមខាងលើជួយឲ្យកម្ពុជាស្ថិតលើមាគ៌ាដ៏ត្រឹមត្រូវឈានទៅសម្រេចបាន កំណើនខ្ពស់ និងសម្រាប់ទាំងអស់គ្នា។

# ឯកសារយោង


ADB, Asian Development Bank (2013), *Key Indicators for Asia and the Pacific* (Manila: ADB)

CDRI, Cambodia Development Resource Institute (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities* (Phnom Penh: CDRI)

Foster, James, Joel Greer and Erik Thorbecke (1984), "A Class of Decomposable Poverty Measures", *Econometrica*, 52 (3), pp. 761-766

Grosse, Melanie, Kenneth Harttgen & Stephan Klasen (2008), "Measuring Pro-Poor Growth in Non-Income Dimension", *World Development*, 36 (6), pp. 1021-1047

Kakwani, Nanak and Ernesto M. Pernia (2000), "What is Pro-poor Growth?" *Asian Development Review*, 18 (1), pp. 2-15

Kuznets, Simon (1955), "Economic Growth and Income Inequality", *American Economic Review*, 45(1), pp. 1-28

MOP, Ministry of Planning (2013), *Poverty in Cambodia—A New Approach: Redefining the poverty line* (Phnom Penh: MoP)

NIS, National Institute of Statistics (2000), *Cambodia Demographic and Health Survey* (Phnom Penh: NIS)

NIS (2004), *Cambodia Socio-Economic Survey* (Phnom Penh: NIS)

NIS (2005), *Cambodia Demographic and Health Survey* (Phnom Penh: NIS)

NIS—National Institute of Statistics (2005), Cambodia Socio-Economic Survey: *Technical Report on Survey Design and Implementation* (Phnom Penh: NIS)

NIS (2007), *Cambodia Socio-Economic Survey* (Phnom Penh: NIS)

NIS (2009), *Cambodia Socio-Economic Survey* (Phnom Penh: NIS)

NIS (2010), *Cambodia Demographic and Health Survey* (Phnom Penh: NIS)

NIS (2011), *Cambodia Socio-Economic Survey* (Phnom Penh: NIS)

World Bank (forthcoming), *Poverty Monitoring and Analysis: Where Have All the Poor Gone?* (Phnom Penh: World Bank)

World Bank (2009), *Poverty Profile and trends in Cambodia: Findings from the 2007 Cambodia Socio-Economic Survey (CSES)*, Report No. 48618-KH (Washington, DC: World Bank)

-៤-

# យុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែម សម្រាប់កុមារ៖ ការវាយតម្លៃពីឥទ្ធិពលយុទ្ធនាការ ទៅលើទម្លាប់នៃការផ្តល់អាហារទៅឲ្យកុមារ

*ដោយ ឈា ឆវណ្ណ នូ កែវសុទ្ធា និង រស់ បណ្ដេត*[១]

## ១. សេចក្តីផ្តើម

ការកែលំអអាហារូបត្ថម្ភសម្រាប់កុមារ ជាអាទិភាពមួយដ៏ខ្ពស់ក្នុងការញ៉ាំងឲ្យសុខភាពប្រជាពលរដ្ឋមានភាពល្អប្រសើរ និងជាចំណែកមួយនៃ ការប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីឲ្យកម្ពុជាមានកំណើនសេដ្ឋកិច្ចរឹងមាំ និងសម្រាប់គ្រប់គ្នា (CDRI 2013)។ ពីឆ្នាំ ២០០០ ដល់ ២០០៥ កម្ពុជាមានការរីកចំរើនច្រើនក្នុងការកែលំអអាហារូបត្ថម្ភសម្រាប់កុមារ ប៉ុន្តែដំណើរការនេះបានជាប់គាំង ឬធ្លាក់ចុះទៅវិញ ពីឆ្នាំ២០០៥ ដល់ ២០១០ (World Bank 2013)។ នៅឆ្នាំ២០១០ អត្រាកុមារខ្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (ក្រិន៖ stunted) បានធ្លាក់ចុះមកត្រឹម ៤០% ធៀបនឹង ៤២% កាលពីឆ្នាំ២០០៥ រីឯអត្រាកុមារមិនគ្រប់ ទម្ងន់ (underweight) នៅថេរត្រឹម ២៨%។ អ្វីដែលគួរឲ្យកត់សម្គាល់គឺ អត្រាកុមារខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ (ស្គមស្គាំង: wasted) កើនដល់ ១១% ធៀបនឹង ៨% នៅឆ្នាំ២០០៥ (World Bank 2013)។ កង្វះអាហារូបត្ថម្ភកុមារទាក់ទងនឹងកត្តាជាច្រើន ក្នុងនោះក៏មាន ទម្លាប់នៃការផ្តល់អាហារឲ្យកុមារ ផងដែរ។ ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់កុមារ គួរមានកិច្ចប្រឹងប្រែងជំរុញការផ្តល់អាហារបន្ថែម បន្ទាប់ពីកុមារមានអាយុ ៦ខែ (World Bank 2013) ។

នៅខែមេសា ២០១២ ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាកង្វះអាហារូបត្ថម្ភកុមារនៅកម្ពុជា មានការអនុវត្តយុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែម (CFC) ក្នុង ១០ខេត្ត ក្រោមការដឹកនាំរបស់ មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព (NCHP) និង មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាពមាតានិងកុមារ (NMCHC) ដោយរួមសហការជាមួយដៃគូអភិវឌ្ឍន៍មួយចំនួន។ CFC ប្រើប្រាស់ការផ្សព្វផ្សាយជាយុទ្ធសាស្ត្រ ដើម្បីជំរុញការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនក្នុងតំបន់ ពោលគឺ វិធីសាស្ត្រផ្សព្វផ្សាយជះឥទ្ធិពលទៅលើឥរិយាបថ (COMBI)។ គោលដៅរួមរបស់ CFC នៅកម្ពុជាគឺ ចូលរួមចំណែកកែលំអស្ថានភាពអាហារូបត្ថម្ភសម្រាប់កុមារនៅកម្ពុជា តាមរយៈការបង្កើនអត្រាផ្តល់អាហារបន្ថែមសមស្របដល់ទារក និងកុមារអាយុពី ៦ខែ ទៅ ២៤ខែ។ គោលដៅនេះអាចសម្រេចទៅបាន នៅពេល មាតា/អ្នកថែទាំ អនុវត្តនិងរក្សាទម្លាប់ចម្អិន និងផ្តល់បបរខាប់គ្រប់គ្រឿងដល់កូនៗរបស់ខ្លួន។

សកម្មភាពរបស់ CFC រួមមាន ប្រព័ន្ធផ្សព្វផ្សាយ និងការផ្សព្វផ្សាយពីបុគ្គលទៅបុគ្គលមួយ ដូចជា ពិពណ៌សុខភាពកុមារដែលមានការដាំបបរខាប់គ្រប់គ្រឿងបង្ហាញជាក់ស្តែង, ទស្សន

---

[១] ឈា ឆវណ្ណ ព្រឹទ្ធបុរសសាលាសុខភាពសាធារណៈនៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ។ នូ កែវសុទ្ធា ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ និង រស់ បណ្ដេត ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។

កិច្ចតាមផ្ទះ, និង កិច្ចប្រជុំជាក្រុម។ សារគន្លឹះនៃគម្រោងនេះ គឺ មាតាគួរផ្តល់បបរខាបគ្រប់គ្រឿងដល់កូនៗដើម្បីឲ្យពួកគេមានសុខភាពល្អ កម្លាំងមាំមួន និងបញ្ញាវាងវៃ។ បបរនេះគេផ្សំវាជាអាហារបន្ថែមពិសេសសម្រាប់កុមារអាយុពី ៦ខែ ដល់ ២៤ខែ។ ក្នុងដំណើរការនៃយុទ្ធនាការផ្សព្វផ្សាយនេះ មានបញ្ចូលនូវសារដែលបានគិតគូរពីតម្រូវការអាហាររូបត្ថម្ភរបស់កុមារ ដោយផ្តោតលើ កម្រិតកំហាប់ (ឧ. ធ្វើឲ្យបបរខាប់) ប្រភេទគ្រឿងផ្សំ (ទាក់ទងនឹង អាហារ ៣ក្រុម បូកនឹង ប្រេងឆា) បរិមាណ និង ភាពញឹកញាប់នៃការផ្តល់អាហារ។ គម្រោងនេះផ្តោតលើ ក្រុមបឋម រួមមាន មាតានិងអ្នកថែទាំកុមារអាយុពី ៦ខែ ដល់ ២៤ខែ និង ក្រុមបន្ទាប់បន្សំ ដូចជា ប្តី ឪពុកម្តាយ សមាជិកគ្រួសារ និងស្ត្រីគ្រប់អាយុបន្តពូជ ព្រមទាំង ក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) ក្រុមទ្រទ្រង់មាតា (MSGs) ប្រធានភូមិ គណៈកម្មការពិគ្រោះយោបល់ស្ត្រីនិងកុមារ និងក្រុមដទៃទៀតដែលយកចិត្តទុកដាក់លើកុមារ។

របាយការណ៍នេះព្យាយាមវាយតម្លៃជាដំបូង ពីទំហំឥទ្ធិពលនៃគម្រោង CFC ទៅលើឥរិយាបថរបស់អ្នកទទួលផលជាគោលដៅ ក្នុងការផ្តល់អាហារបន្ថែមស្របតាមសេចក្តីណែនាំនៃយុទ្ធនាការផ្សព្វផ្សាយ។ លទ្ធផលនៃការសិក្សានេះនឹងផ្តល់ជាព័ត៌មានបន្ថែមដល់រដ្ឋាភិបាល អ្នកពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍន៍ អំពីវិធីកែលំអ CFC និងពង្រីកគម្រោងទៅទូទាំងប្រទេស។

## ២. វិធីសាស្ត្រ និងក្របខណ្ឌវិភាគ

ការផ្លាស់ប្តូរឥរិយាបថដោយសារឥទ្ធិពលយុទ្ធនាការផ្សព្វផ្សាយ គឺជាប្រធានបទដែលបានបកស្រាយនៅក្នុងទ្រឹស្តីជាច្រើន ដូចជា "ដំណាក់កាលនៃការផ្លាស់ប្តូរ" ឬ "គំរូអន្តរទ្រឹស្តី (transtheoretical model)" ដែលបែងចែកការផ្លាស់ប្តូរឥរិយាបថជា ៥ដំណាក់កាល (WHO 2012; Prochaska, DiClemente & Norcross 1992; Slater 1999)។ ដំណាក់កាលទី១ ពេលមុនគិតគូរ (Precontemplation) ជាដំណាក់កាលដែលមនុស្សពុំមានចេតនាផ្លាស់ប្តូរសោះ ព្រោះខ្វះការយល់ដឹង ចំណេះដឹង និងការយកចិត្តទុកដាក់។ ដំណាក់កាលទី២ ពេលកំពុងគិតគូរ (Contempation) ជាពេលដែលមនុស្សបានទទួលស្គាល់នូវបញ្ហា និងគិតគូរប្រុងធ្វើសកម្មភាពក្នុងពេលដ៏ខ្លី។ដំណាក់កាលទី៣ការត្រៀមរៀបចំ (Preparation) ជាពេលដែលមនុស្សចាប់ផ្តើមអនុវត្តសាកល្បង ប៉ុន្តែមិនទាន់ ផ្លាស់ប្តូរឥរិយាបទបានជោគជ័យនោះទេ។ ដំណាក់កាលទី៤ សកម្មភាព (Action) សំដៅលើពេលដែលមនុស្សផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនបានជោគជ័យក្នុងអំឡុងពេលមួយ។ ដំណាក់កាលចុងក្រោយគឺ *ការថែរក្សា (Maintenance)* ដែលបង្ហាញពីសមត្ថភាពរបស់មនុស្សក្នុងការរក្សាឥរិយាបថបានផ្លាស់ប្តូរនោះ ក្នុងរយៈពេលវែង។

ក្នុងចំណោមអ្នកស្រាវជ្រាវលើប្រធានបទ ការផ្លាស់ប្តូរឥរិយាបថនេះ លោក Slater (1999) បានពិនិត្យឡើងវិញនូវទ្រឹស្តីជាច្រើនអំពីការផ្លាស់ប្តូរឥរិយាបថ និងបានបកស្រាយពីដំណើរការផ្លាស់ប្តូរពីមួយដំណាក់កាលទៅមួយដំណាក់កាល។ ដោយផ្អែកលើការសិក្សារបស់ McGuire (1989) លោក Slater បានវែកញែកថា ការផ្លាស់ប្តូរឥរិយាបថពី *ពេលមុនគិតគូរ* ទៅ *ពេលកំពុងគិតគូរ* ទាមទារនូវការយល់ដឹង/ចំណេះដឹង និងការយកចិត្តទុកដាក់។ ស្រដៀងគ្នានេះដែរ ទ្រឹស្តីស្ថានការណ៍ (situation theory) របស់លោក Grunig (1978) សង្កត់ធ្ងន់លើសារៈសំខាន់នៃការទទួលស្គាល់បញ្ហាពី សំណាក់មនុស្សម្នានៅក្នុងការកែប្រែឥរិយាបថ។ ផ្ទុយទៅវិញ ទ្រឹស្តីសកម្មភាពផ្អែកលើហេតុផល (theory of reasoned action) លើកឡើងថា ការ

ផ្លាស់ប្តូរពី *ពេលកំពុងគិតគូរ* ទៅ *ការត្រៀមរៀបចំ* កើតមានឡើងនៅពេលមនុស្សបានជឿមុតមាំអំពីលទ្ធផលនៃឥរិយាបថ(ដែលល្អ)។ មនុស្សតែងពិចារណាពីចំណាយ និងអត្ថប្រយោជន៍នៃឥរិយាបថដែលគេបានណែនាំឡើង និងសំពាធសង្គម មុននឹងអនុវត្តតាមចេតនាចង់ផ្លាស់ប្តូររបស់ខ្លួន (Slater 1999) ។ យោងតាមទ្រឹស្តីការយល់ដឹងពីសង្គម (social cognitive theory), ទ្រឹស្តីសិក្សាពីសង្គម (social learning theory) និងទ្រឹស្តីប្រសិទ្ធភាពរបស់ខ្លួនឯង (self efficacy theory) ការផ្លាស់ប្តូរឥរិយាបថពី *ពេលមុនគិតគូរ* ទៅដល់ *សកម្មភាព* កើតមាននៅពេលមនុស្សមានទំនុកចិត្តថា ពួកគេអាចផ្លាស់ប្តូរឥរិយាបថបាន និងអាចមើលឃើញថា ការសាកល្បងផ្លាស់ប្តូរឥរិយាបទទំនងទទួលបានជោគជ័យ (Prochaka et al 1992 as cited in Slater 1999) ។ ដោយឡែកការផ្លាស់ប្តូរឥរិយាបថពី សកម្មភាព ទៅ ការថែរក្សា ទាមទារឲ្យបុគ្គលមានទាំងជំនឿ និងទំនុកចិត្តដែលអាចមានការជំរុញបន្ថែម ដោយសារ សង្គមក៏បានទទួលយកឥរិយាបថនោះដែរ។

ការស្រាវជ្រាវនេះ ប្រើវិធីសាស្ត្របែបគុណភាព ដើម្បីបំពេញតាមគោលដៅខាងលើ។ ខេត្តបី គឺ កំពត ស្វាយរៀង និង ស្ទឹងត្រែង ត្រូវបានជ្រើសរើសចេញពី ខេត្តទាំង ១០ ដែលបានអនុវត្តយុទ្ធនាការនេះ ដោយផ្អែកលើកម្រិតភាពក្រីក្រ និងចំនួនភាគរយនៃភាពក្រិន។ ដើម្បីញ៉ាំងឲ្យទិន្នន័យមានលក្ខណៈសម្បូរបែបបំផុត ការសិក្សានេះបានជ្រើសរើសដោយចៃដន្យនូវមណ្ឌលសុខភាពពីរចេញពីខេត្តនីមួយៗ ដោយមណ្ឌលសុខភាពមួយមានទីតាំងនៅទីរួមខេត្ត និងមួយទៀតនៅក្នុងតំបន់ដាច់ស្រយាល។ ដូច្នេះមណ្ឌលសុខភាពចំនួនប្រាំមួយត្រូវបានជ្រើសចេញពីខេត្តចំនួន៣នេះ។ សម្រាប់ មណ្ឌលសុខភាពនីមួយៗ បានយកមកសិក្សាតែ ២ភូមិប៉ុណ្ណោះ ដែលធ្លាប់មានការដាំបបរខាប់គ្រប់គ្រឿងបង្ហាញជាក់ស្តែង។ កិច្ចសម្ភាសន៍សរុបចំនួន៣៦ បានអនុវត្តឡើងតាមវិធីសាស្ត្រប្រមូលទិន្នន័យ ដូចជា ការសម្ភាសស៊ីជម្រៅ (IDI), ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ (KII), និង ការពិភាក្សាតាមក្រុមស្នូល (FGD), ដើម្បីប្រមូលព័ត៌មានពីមាតាឬអ្នកថែទាំកុមារនានា ប្រធានសហគមន៍ បុគ្គលិកសុខាភិបាល តួអង្គសង្គមស៊ីវិលជាប់ពាក់ព័ន្ធ និង អ្នកផ្តល់ព័ត៌មានដទៃទៀត។ ទិន្នន័យសម្ភាសន៍បានកត់ត្រាចេញជាលាយលក្ខណ៍អក្សរ និងធ្វើវិភាគអត្ថន័យ។ ការសិក្សានេះក៏បានពិនិត្យឡើងវិញ និងដាក់បញ្ចូលនូវលទ្ធផលនៃការសិក្សាពីមុនៗ និងឯកសារផ្សេងៗនៃគម្រោងស្តីពី ការផ្តល់អាហារូបត្ថម្ភសម្រាប់កុមារ។

## ៣. លទ្ធផលស្រាវជ្រាវ

ការសិក្សានេះបានរកឃើញថា ទោះបីជាយុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែម (CFC) ទើបដំណើរការក្តី ក៏កម្មវិធីនេះហាក់មានឥទ្ធិពលគួរកត់សម្គាល់ ក្នុងការលើកកម្ពស់ការយល់ដឹង និងការទទួលយកសេចក្តីណែនាំពីសំណាក់ក្រុមទទួលផលគោលដៅ លើដំណាក់កាលបីដំបូងនៃការផ្លាស់ប្តូរឥរិយាបថ គឺ ពេលមុនគិតគូរ, ពេលកំពុងគិតគូរ និង ការត្រៀមរៀបចំ។ CFC មានឥទ្ធិពលជាវិជ្ជមាន ប៉ុន្តែមិនទាន់ធំធេងប៉ុន្មានទេទៅលើដំណាក់កាលពីរទៀត គឺ ដំណាក់កាល សកម្មភាព និង ការថែរក្សា ដែលគេអាចយល់បានព្រោះ កម្មវិធីនេះទើបតែបានចាប់ផ្តើមអនុវត្តនាពេលថ្មីៗនេះ។ ផ្នែកខាងក្រោម បង្ហាញពីលទ្ធផលលំអិតនៃការសិក្សា។

## ៣.១ ការរំលឹកពី សាររបស់ CFC ការយល់ដឹង/ ចំណេះដឹង និងការយកចិត្តទុកដាក់

លទ្ធផលសិក្សាបង្ហាញថា អ្នកដែលបានចូលរួមក្នុងការសិក្សាអាចនៅចងចាំបានយ៉ាងល្អនូវសារដែលបានផ្សព្វផ្សាយក្នុងអំឡុងពេលធ្វើយុទ្ធនាការ CFC។ ពួកគេទទួលសារទាំងអស់នោះពីប្រភពព័ត៌មានសំខាន់ៗ រួមមាន ផ្ទាំងរូបភាព ការចម្អិនអាហារបង្ហាញជាក់ស្តែង ប្រព័ន្ធផ្សព្វផ្សាយ និងការផ្សព្វផ្សាយពីបុគ្គលមួយទៅបុគ្គលមួយ។ អ្នកចូលរួមជាច្រើនរាយការណ៍ថា គាត់ចូលចិត្តទទួលយកសារផ្នែកសុខភាពដែលផ្សាយក្នុងទូរទស្សន៍។ ប៉ុន្តែសហគមន៍នៅដាច់ស្រយាលនានាបានអះអាងថាពួកគាត់ មានលទ្ធភាពតិចតួចក្នុងការទទួលសារពីទូរទស្សន៍ ដោយសារកង្វះថាមពលអគ្គិសនី។អ្នកចូលរួមក៏បានលើកឡើងដែរថាពួកគាត់ចូលចិត្តកាន់តែខ្លាំងថែមទៀតចំពោះការជួបផ្ទាល់ជាមួយជនបង្គោល (ក្រុមទ្រទ្រង់សុខភាពភូមិ) នៅតាមសហគមន៍ព្រោះងាយស្រួលទាក់ទងសួរសំណួរដែលគាត់ចង់ដឹង។

> "ខ្ញុំតែងបានជួបលោកគ្រូម្នាក់ (VHSG) ដែលមកហៅពួកខ្ញុំទៅចូលរួមក្នុងការប្រជុំបង្ហាញពីរបៀបចម្អិនបបរខាប់គ្រប់គ្រឿង" (មាតាម្នាក់ ក្នុង IDI) "មានរូបភាពម្តាយបញ្ចុកបបរកូន" (សមាជិកគ្រួសារម្នាក់ ក្នុង FGD) "ពួកគាត់ [ថ្នាក់ខេត្ត] មកបង្រៀនយើងពីរបៀបចម្អិនបបរ ដោយបន្ថែមល្ពៅ ការ៉ុត ស្លឹកបាស ។ល។" (សមាជិកគ្រួសារម្នាក់ ក្នុង FGD)

មាតា និងសមាជិកគ្រួសារនានាបានឲ្យដឹងថា គាត់គួរចាប់ផ្តល់អាហារបន្ថែមដល់កូនៗដែលអាយុបាន ៦ខែ ព្រោះវាសំខាន់សម្រាប់ការលូតលាស់របស់ទារក។ សារផ្នែកសុខភាពមួយទៀតដែលបានជ្រាតជ្រាបល្អក្នុងស្រទាប់មហាជន គឺ បញ្ហាអនាម័យ។ អ្នកចូលរួមក្នុងការសិក្សានេះតែងលើកថា កង្វះអនាម័យតែងធ្វើឲ្យកុមាររាគរូស។

> "ពួកគាត់ណែនាំយើងឲ្យសំអាតអ្វីៗទាំងអស់ ជាពិសេសនៅពេលថែទាំកុមារ។ ប្រសិនបើយើងមើលថែកុមារមិនបានត្រឹមត្រូវទេ [កុមារនឹង] កើតជំងឺរាគរូសហើយ។ បន្លែសម្រាប់បង់ក្នុងបបរត្រូវលាងឲ្យស្អាត... ហើយយើងត្រូវលាងដៃ, ឆ្នាំង, ស្លាបព្រា...។" (សមាជិកគ្រួសារម្នាក់ ក្នុង FGD)

អ្នកចូលរួមក្នុងការសិក្សា ក៏បានយកចិត្តទុកដាក់លើវត្ថុបំណងនៃគម្រោងក្នុងការបង្ការភាពគ្រិន និងបង្កើនកម្លាំងបញ្ញារបស់កុមារដែរ។ ថ្វីបើអ្នកចូលរួមនានាហាក់ពិបាកចងចាំបានថា អាហារប្រភេទណាផ្តល់ថាមពល បង្កើនការលូតលាស់ ឬផ្តល់វិតាមីនដល់រាងកាយកុមារ ប៉ុន្តែគាត់អាចពណ៌នាពីគ្រឿងផ្សំសំខាន់ៗសម្រាប់ការចម្អិនបបរខាប់គ្រប់គ្រឿង ដើម្បីពង្រឹងសុខភាពកូនៗ។

## ៣.២ ការទទួលយក និងភាពសមស្របនៃសារ

ក្រៅពីការយល់ដឹង និងការយកចិត្តទុកដាក់ អ្នកចូលរួមក៏បានបង្ហាញពី ការយល់ស្របនឹងសារដែលគាត់ទទួលបាន។ សារបានបញ្ជូនដើម្បីជំរុញការប្រើប្រាស់បបរខាប់គ្រប់គ្រឿងនោះ មានភាពសមស្របខ្លាំងសម្រាប់មាតា ព្រោះមាតាភាគច្រើនឲ្យតម្លៃខ្ពស់ទៅលើ "សុខភាពកូនៗ"។ មាតាត្រៀមលះបង់កម្លាំងកាយចិត្តដើម្បីឲ្យកូនលូតលាស់ល្អ និងមានប្រាជ្ញាវាងវៃ។

"រឿងសំខាន់បំផុតសម្រាប់ខ្ញុំ គឺ កូនខ្ញុំ។ បើសិនកូនខ្ញុំឈឺខ្ញុំគ្មានកម្លាំងធ្វើការទេ" (មាតាម្នាក់ក្នុង IDI) "ហេតុអ្វីបានជាអ្នកអនុវត្តតាមសាររបស់ CFC? ខ្ញុំចង់ឲ្យកូនខ្ញុំលូតលាស់ល្អហើយសារនេះនឹងជួយកូនខ្ញុំឲ្យកាន់តែឆ្លាត និងជៀសផុតពីការឈឺថ្កាត់" (មាតាម្នាក់ ក្នុង IDI)

មាតាជាច្រើនជឿជាក់ថា បបរខាប់គ្រប់គ្រឿងវាល្អសម្រាប់កូនគាត់ និងទទួលស្គាល់ថាកូនៗមានសុខភាពល្អ បើធៀបនឹងក្មេងដទៃទៀត ឬបើធៀបសុខភាពកូនៗនៅមុន និងក្រោយពេលបានហូបបបរខាប់គ្រប់គ្រឿង។ អ្នកចូលរួមខ្លះក៏បានសម្គាល់នូវការប្រែប្រួលក្នុង ការលូតលាស់ធំរបស់កូនអ្នកជិតខាងដែលបានហូបបបរខាប់គ្រប់គ្រឿងដែរ។

"ក្រោយពីញុំាវាមក កូនខ្ញុំមិនដែលឈឺទេ" (មាតាម្នាក់ ក្នុង IDI)

## ៣.៣ ការអនុវត្ត

គេរាយការណ៍ថា ភាគច្រើននៃអ្នកចូលរួមក្នុងការសិក្សា បានអនុវត្តចម្អិនបបរខាប់គ្រប់គ្រឿងសម្រាប់កុមារអាយុចាប់ពី ៦ខែឡើងទៅហូប ប៉ុន្តែមិនទាន់រក្សាឥរិយាបថនេះបានជាប់លាប់ល្អគួរឲ្យពេញចិត្តទេ។ អ្នកចូលរួមក្នុងការសិក្សាប្រាប់ថា ពួកគាត់បានអនុវត្តផ្តល់បបរខាប់គ្រប់គ្រឿងធ្វើជាអាហារជាប្រចាំសម្រាប់កូនៗ ប៉ុន្តែអ្នកខ្លះមិនអាចអនុវត្តតាមការណែនាំនៃយុទ្ធនាការផ្តល់អាហារបន្ថែមបានទាំងស្រុងទេ ឬក៏ឈប់ផ្តល់ ឬក៏ប្តូរទៅទិញបបរធម្មតា (ជាទូទៅ លក់នៅពេលព្រឹក) យកមកបញ្ចុកកូនៗ ដោយសារមានកត្តាជាច្រើន។

ទី១ ទោះបីគ្រឿងផ្សំទាំងអស់ដែលគេបានណែនាំឲ្យប្រើសម្រាប់ចម្អិនបបរខាប់គ្រប់គ្រឿងគេគិតថាអាចរកបាននៅតាមមូលដ្ឋានក្តី ក៏មាតាមួយចំនួនត្អូញត្អែរថា មិនអាចរកគ្រឿងផ្សំទាំងនោះបានគ្រប់មុខទេ (ប្រភេទបន្លែ សាច់...) ។

ទី២ មាតាត្រូវទិញគ្រឿងផ្សំ ដូចជា បន្លែ និងសាច់ដើម្បីចម្អិនបបរ ប៉ុន្តែឈ្មួញក្នុងភូមិស្រុកមិនព្រមលក់សាច់ឲ្យក្នុងចំនួនតិចតួចនោះទេ។ ជាលទ្ធផលមាតាក្រីក្រក៏សម្រេចចិត្តមិនទិញសាច់ និងមិនចម្អិនបបរខាប់គ្រប់គ្រឿងនោះទៅ។ បញ្ហាប្រឈមមួយទៀតគឺ កង្វះពេលវេលាធ្វើដំណើរទៅទិញគ្រឿងផ្សំ បើសិនមាតាៗរវល់ធ្វើការ ឬ ទីផ្សារនៅឆ្ងាយពីផ្ទះពេក។

ទី៣ មាតាមួយចំនួនបានត្អូញត្អែរពីបញ្ហាខ្វះលុយទិញសាច់យកមកចម្អិនបបរខាប់គ្រប់គ្រឿង ហើយចំណាយក្នុងការធ្វើបបរនេះក៏មិនត្រូវបានគេប៉ាន់ស្មាន នៅក្នុងសេចក្តីណែនាំអំពីគម្រោង ឬក្នុងឯកសារពាក់ព័ន្ធទៀតដែរ។ យោងតាម FGDs ការចម្អិនបបរនេះពីរដង ត្រូវចំណាយអស់ប្រហែល ៦០០០រៀល ឬ ១,៥ដុល្លារ ដែលភាគច្រើនជាចំណាយលើការទិញសាច់។ ដូច្នេះ គ្រួសារក្រីក្រ (ចំណូលសរុបតិចជាង ១ដុល្លារក្នុងមួយថ្ងៃ) ទំនងពុំមានលទ្ធភាពចម្អិនបបរនេះឲ្យកូនតូចៗបានទេ។

ទី៤ មានការយល់ខុសមួយទាក់ទងនឹងការចម្អិនបបរខាប់គ្រប់គ្រឿង។ មាតាខ្លះយល់ថា គាត់ត្រូវរកបន្លែ និងសាច់ឲ្យបានគ្រប់មុខ ដើម្បីចម្អិនបបរខាប់គ្រប់គ្រឿងតាមការណែនាំ។ បើគ្មានគ្រឿងផ្សំគ្រប់មុខទេ គាត់មិនចម្អិនបបរនោះឡើយ។ មាតាខ្លះទៀតគិតថា បបរខាប់គ្រប់គ្រឿងធ្វើឲ្យកុមារពុកធ្មេញ ហើយក្មេងតូចៗក៏ពិបាកលេបព្រោះបបរនេះវាខាប់។

ទី៥ មានចម្លើយតបផ្សេងៗគ្នាទៅនឹងសំណួរថា តើកុមារចូលចិត្តហូបបបរខាប់គ្រប់គ្រឿងឬទេ។ មាតាដែល បានបន្ថែមគ្រឿងទេសចូលក្នុងបបរនៅពេលចម្អិនតែងរាយការណ៍ថា កូនគាត់ចូលចិត្តហូបបបរនោះ ហើយមាតាដែលមិនបង់គ្រឿងទេសចូល តែងរាយការណ៍ផ្ទុយពីនេះ។ មាតាដែលបង់សារធាតុបន្ថែមវីតាមីនចូលទៅក្នុងបបរខាប់គ្រប់គ្រឿង រាយការណ៍ថា កូនៗគាត់មិនព្រមហូបបបរនោះទេ ព្រោះមិនចូលចិត្តរសជាតិវា។

ទី៦ ការរចនារៀបចំការផ្សព្វផ្សាយ និងការអនុវត្តគម្រោង ដើម្បីពង្រឹងយុទ្ធនាការផ្តល់អាហារបន្ថែម បានជួបកំហិតមួយ។ ពិពណ៌សុខភាពកុមារតាមសហគមន៍ ធ្វើឡើងមិនបានញឹកញាប់គ្រប់គ្រាន់ទេ ដោយសារបញ្ហាកង្វះថវិកា។ រយៈពេលនៃការដាំបបរខាប់គ្រប់គ្រឿងបង្ហាញជាក់ស្តែង ក៏មិនបានវែងគ្រប់គ្រាន់ដែរ។ បញ្ហាផ្សេងទៀតមានដូចជា កង្វះការលើកទឹកចិត្តដល់សមាជិក VHSG ក្នុងការអនុវត្តកិច្ចការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព, កង្វះសម្ភារៈអប់រំផ្នែកសុខភាព និងកង្វះថវិកាសម្រាប់ VHSG ប្រើក្នុងការបង្ហាញពីរបៀបចម្អិនជាក់ស្តែង។

## ៤. ការពិភាក្សា

បទសម្ភាសន៍នានាបានបញ្ជាក់ពីការយល់ដឹង និងការយកចិត្តទុកដាក់ពីសំណាក់ក្រុមគោលដៅនៃគម្រោង ទៅលើសារៈសំខាន់នៃការចម្អិននិងផ្តល់បបរខាប់គ្រប់គ្រឿងឲ្យកុមារ ដែលស្របគ្នានឹងរបាយការណ៍របស់ Slatter (1999) លើការផ្លាស់ប្តូរឥរិយាបថ ពីដំណាក់កាល ពេលមុនគិតគូរ ទៅដល់ ពេលកំពុងគិតគូរ ។ ប្រជាពលរដ្ឋក្រុមគោលដៅចេះកត់សម្គាល់ និងទទួលស្គាល់ពីសារៈសំខាន់នៃការផ្តល់អាហារបន្ថែមដែលខ្លួនមិនធ្លាប់អនុវត្តសោះពីមុនមក។

ការទទួលយកសារ ដោយក្រុមគោលដៅក្នុងមូលដ្ឋាន, ជំនឿរបស់ពួកគេទៅលើគម្រោង និងការអនុវត្តសាកល្បងចម្អិនបបរខាប់គ្រប់គ្រឿង គឺជាសញ្ញាមួយទៀតនៃការផ្លាស់ប្តូរឥរិយាបថពីដំណាក់កាលកំពុងគិតគូរ ទៅការត្រៀមរៀបចំដូចអ្វីដែលបានវែកញែករបស់ Slatter (1999)។ មាតា និងអ្នកថែទាំកុមារ បានរៀនអនុវត្តសាកល្បងនូវឥរិយាបថដែលគេបានណែនាំ ដោយសង្ឃឹមថានឹងទទួលបានលទ្ធផលដូចដែលយុទ្ធនាការបានផ្សព្វផ្សាយ។

ឥរិយាបថទទួលអនុវត្តការចម្អិនបបរខាប់គ្រប់គ្រឿង បង្ហាញនូវការផ្លាស់ប្តូរឥរិយាបថពីដំណាក់កាល ត្រៀមរៀបចំ ទៅ សកម្មភាព។ ចំណុចគួរកត់សម្គាល់ គឺ ឥរិយាបថនេះនៅប្រែប្រួលស្ថិតក្នុងការសាកល្បងនៅឡើយ ហើយមិនទាន់ជាប់លាប់គួរឲ្យទុកចិត្តទេ៖ អ្នកចូលរួមខ្លះបានឈប់កាន់ឥរិយាបថនេះ ដោយសារត្រូវជួបនឹងការចំណាយមិនអាចទាយទុកមុនមួយចំនួន។ គេមិនទាន់ដឹងទេថា អ្នកដែលអនុវត្តតាមនឹងរក្សាឥរិយាបទនេះបានយូរឆ្នាំប៉ុណ្ណា ដោយសារចំណុចខ្វះខាតរបស់គម្រោងក្នុងការពង្រឹងសារផ្សព្វផ្សាយទៅឲ្យប្រជាជន, កង្វះថវិកានិងគ្រឿងលើកទឹកចិត្ត និង កង្វះសម្ភារៈអប់រំផ្នែកសុខភាព និងជំនួយទ្រទ្រង់ផ្នែកភស្តុភារ។ Slatter (1999)

បានរកឃើញថា ការពង្រឹងសារគឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការលើកទឹកចិត្តអ្នកចូលរួមឲ្យបន្តអនុវត្តឥរិយាបថដែលបានណែនាំ។

ដោយគម្រោងនេះទើបចាប់ផ្តើមបានជាង ១ឆ្នាំ ដូច្នេះ ទិន្នន័យនៃការស្រាវជ្រាវនេះពុំអាចធ្វើការវាយតម្លៃទៅលើឥទ្ធិពលរបស់យុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែម ទៅលើការផ្លាស់ប្តូរការយល់ឃើញរបស់សហគមន៍ និងឥរិយាបថសង្គមនោះទេ។ Slatter (1999) បានរកឃើញថា ការផ្លាស់ប្តូរឥរិយាបថពី ដំណាក់កាល សកម្មភាព ទៅដល់ ការថែរក្សា ទាមទារឲ្យបុគ្គលមានជំនឿ និងដឹងថា ឥរិយាបថនោះត្រូវបានខាងសង្គម ទទួលយក។ ការគាំទ្រពីមិត្តភក្តិ ក្រុមគ្រួសារ និងសហគមន៍ សំខាន់ខ្លាំងណាស់ក្នុងការបង្កើតឱកាសឲ្យបុគ្គលផ្លាស់ប្តូរឥរិយាបថ។

## ៥. សេចក្តីសន្និដ្ឋាន និងការរៀនសូត្របាន

ការអនុវត្តយុទ្ធនាការផ្សព្វផ្សាយពីការផ្តល់អាហារបន្ថែមនៅកម្ពុជា ទទួលបានលទ្ធផលជាទីគាប់ចិត្ត ក្នុងចំណោមអ្នកចូលរួមជាគោលដៅ ទោះបីមិនទាន់បានបង្ហាញច្បាស់នូវការផ្លាស់ប្តូរឥរិយាបថជ្រាលជ្រៅក្តី។ CFC បានជួយបង្កើនការយល់ដឹង និងការយកចិត្តទុកដាក់របស់មាតា និងអ្នកមើលថែកុមារនៅមូលដ្ឋាន អំពីការផ្តល់អាហារបន្ថែមដែលមិនសូវឃើញមានពីមុនមក ហើយជាលទ្ធផល ពួកគេក៏បានយល់ដឹង និងទទួលយកនូវសារនេះ ហើយភាគច្រើនបានអនុវត្តតាមឥរិយាបថដែលគេបានណែនាំ។ លទ្ធផលនេះបង្ហាញថា CFC មានប្រសិទ្ធភាពក្នុងការជួយកែប្រែឥរិយាបថរបស់ប្រជាពលរដ្ឋគោលដៅ ពីដំណាក់កាល មុនគិតគូរ ទៅដំណាក់កាល កំពុងគិតគូរ, ត្រៀមរៀបចំ និង សកម្មភាព ។

ទោះមានលទ្ធផលដូចខាងលើក្តី ក៏គម្រោង CFC ពុំទាន់បង្ហាញច្បាស់ទេថា អាចជួយឲ្យប្រជាជនគោលដៅរក្សាបានឥរិយាបថដូចបានណែនាំ។ ការទទួលអនុវត្តឥរិយាបថដូចបានណែនាំនៅតែអាចប្រែប្រួល ហើយគម្រោងនេះស្ថិតក្នុងការសាកល្បងនៅឡើយ ដោយសារក្រុមប្រជាពលរដ្ឋគោលដៅជួបនូវបញ្ហាការចំណាយដែលគម្រោងមិនបានកំណត់ ទុកមុនក្នុងការទិញគ្រឿងផ្សំ, ការយល់ខុសខ្លះៗ និងចំណុចខ្វះខាតការអនុវត្តគម្រោង។ ប្រសិនបើមានកិច្ចប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមខាងលើ គម្រោងនេះគួរតែអាចកំណត់បាននូវវិធីល្អបំផុតសម្រាប់ជំរុញឲ្យមាតា និងអ្នកថែទាំកុមារអនុវត្តនូវឥរិយាបថដូចបានស្នើឡើងនាពេលខាងមុខ។

ការសិក្សានេះបង្ហាញនូវការរៀនសូត្របានមួយចំនួន ដើម្បីកែលំអការអនុវត្តគម្រោងនៅដំណាក់កាលបន្ទាប់ទៀត៖

- ព័ត៌មានលំអិតក្នុងសារមួយចំនួន ដូចជា គ្រឿងផ្សំ, ព័ត៌មានអំពីក្រុមអាហារ និងគោលគំនិតនៃការជ្រើសរើសគ្រឿងផ្សំ, បច្ចេកទេសក្នុងការចម្អិនបបរឲ្យខាប់ល្អ ឬ បញ្ហាគួរបង់គ្រឿងទេសទៅក្នុងបបរឬក៏អត់, គឺត្រូវមានបញ្ជាក់ច្បាស់ ដើម្បីជៀសវាងការយល់ច្រឡំក្នុងចំណោមមាតាមានកូនអាយុក្រោមពីរឆ្នាំ ដែលជាគោលដៅនៃគម្រោង CFC ។

- កុមារហាក់មិនសូវចូលចិត្តហូប បបរខាប់គ្រប់គ្រឿងដែលមិនមានបង់គ្រឿងទេសបន្ថែមឡើយ។ ហេតុនេះ គួរមានចុងភៅអាជីពចូលរួមជួយកែលំអរូបមន្តចម្អិនបបរខាប់គ្រប់គ្រឿង ដើម្បីបង្កើនរសជាតិ និងកែសម្រួលកំហាប់។

- គួរមានការប៉ាន់ស្មានពីចំណាយផ្សេងៗលើការចម្អិនបបរខាប់គ្រប់គ្រឿង និងការវាយតម្លៃពីផលប៉ះពាល់របស់វា ទៅលើសេដ្ឋកិច្ចគ្រួសារ។

- គួរលៃចែកថវិកាទៅជួយឲ្យមានធ្វើពិពណ៌សុខភាពកុមារច្រើនថែមទៀត ព្រោះវាជាឱកាសដ៏កម្រសម្រាប់ឲ្យអ្នកភូមិបានទទួលព័ត៌មានពីការថែទាំសុខភាព បានឃើញការបង្ហាញជាក់ស្តែងនូវសាររបស់ CFC និងបានអ្នកចូលរួមដទៃទៀតជួយលើកទឹកចិត្ត និងជំរុញឲ្យអនុវត្តតាមការណែនាំ។

- ក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) គួរទទួលបានការបណ្តុះបណ្តាលបន្ថែមពីកម្មវិធីផ្តល់អាហារបន្ថែម ពីព្រោះក្រុមនេះមានការផ្លាស់ប្តូរសមាជិកញឹកញាប់។ ម្យ៉ាងទៀត VHSG ក៏គួរទទួលបានឱកាសរៀនសូត្រពីគ្នាទៅវិញទៅមក តាមរយៈកម្មវិធីផ្លាស់ប្តូរចំណេះដឹង ឬទស្សនកិច្ចសិក្សានៅតំបន់ដទៃទៀត។

- កម្មវិធីទាក់ទងនឹងផលិតកម្មអាហារតាមផ្ទះ និងសន្តិសុខស្បៀង គួរមានអនុវត្តច្រើនថែមទៀតនៅតាមសហគមន៍នានា។

## បញ្ជីគន្ថនិទ្ទេស


Baesler, E. J. and J.K. Burgoon (1994), “The Temporal Effects of Story and Statistical Evidence on Belief Change”, *Communication Research,* 21, 582-602

CDRI, Cambodia Development Resource Institute (2013), *Cambodia’s Development Dynamics: Past Performance and Emerging Priorities* (Phnom Penh: CDRI)

Grunig, James E. (1978), “Defining Publics in Public Relations: The Case of a Suburban Hospital”, *Journalism Quarterly*, 55(1), 109-18,124

McGuire, W. J. (1989),”Theoretical Foundations of Campaigns”, in R.E. Rice and C.K. Atkin (eds.), *Public Communication Campaigns,* 2nd edition (Newbury Park, CA: Sage) 43-66

MOH, Ministry of Health (2011), *Communication for Behavioural Impact (COMBI)Campaign to Promote Complementary Feeding in Cambodia: 2011-2013*

Oetting, E.R., J.F. Donnermeyer, B.A. Plested, R.W. Edwards, K. Kelly and F. Beauvais (1995), “Assessing Community Readiness for Prevention”, *International Journal of Addictions,* 30, 659-683

Prochaska, J.O., C.C. DiClemente and J.C. Norcross (1992), “In Search of How People Change: Applications to Addictive Behaviors”, *American Psychologist,* 47, 1102-1114

Shaw, D. L. and M.E. McCombs (1977), *The Emergence of American Political Issues: The Agenda Setting Functions of the Press* (St. Paul, MN: West)

Slater, M.D. (1999),”Integrating Application of Media Effects, Persuasion, and Behavior Change Theories to Communication Campaigns: A Stages-of-Change Framework”, *Health Communication,* 11(4), 335-354

World Bank (2013), *Where Have All the Poor Gone? Cambodia Poverty Assessment 2013* (Washington, DC: World Bank)

WHO, World Health Organization (2012), *Communication for Behavioural Impact (COMBI): A Toolkit for Behavioural and Social Communication in Outbreak Response* (Geneva:WHO)

-៥-

# ចំណាយសាធារណៈលើការអប់រំសម្រាប់គ្រប់គ្នានៅកម្ពុជា៖ ការវិភាគពីទំហំអត្ថប្រយោជន៍[១]

*ដោយបណ្ឌិត តុង គឹមស៊ុន និង ផៃ សុខចេង[២]*

## ១. សេចក្តីផ្តើម

កម្ពុជាសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចគួរឲ្យកត់សម្គាល់ក្នុង ២០ឆ្នាំកន្លងមកនេះ។ ផលិតផលក្នុងស្រុកសរុប (ផសស) កើនតាមអត្រាប្រចាំឆ្នាំ ៧,៨% តាំងពីឆ្នាំ១៩៩៤ មកលើកលែងតែក្នុងឆ្នាំ២០០៩ ដែលមានត្រឹមតែ 0,១% ដោយសារមូលហេតុចំបងនៃការផ្ទុះវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកល។ ជាលទ្ធផល ផសស ក្នុងម្នាក់ កើនជិតមួយជាបី ពីត្រឹម ២១០ដុល្លារ (ថ្លៃគោលឆ្នាំ២០០០) នៅឆ្នាំ១៩៩៤ ដល់ ៥៩០ដុល្លារ នៅឆ្នាំ២០១១។ ក្នុងពេលជាមួយគ្នា ការអប់រំ និងការថែទាំសុខភាព ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ ក៏បានរីកលូតលាស់ច្រើនដែរ។ កម្ពុជាស្ទើរតែសម្រេចបាននូវគោលដៅនៃការអប់រំកម្រិតបឋមជាសកល ពោលគឺ អត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា មានដល់ ៩៦% នៅឆ្នាំ២០១០ ហើយ អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាមានដល់ ៨៧% នៅឆ្នាំ២០១១។ ការសិក្សាវាយតម្លៃក្នុងពេលថ្មីៗបំផុត បានបញ្ជាក់ថា សេដ្ឋកិច្ចកម្ពុជាមានលក្ខណៈមួយចំនួនជួយទ្រទ្រង់ដល់ប្រជាជនក្រីក្រ (Roth and Lun (forthcoming); Tong (2012); McKinley 2010)។

គោលនយោបាយសារពើពន្ធ ដើរតួនាទីសំខាន់ណាស់ក្នុងការសម្រេចបានជោគជ័យទាំងនេះ។ ដោយសារ គោលនយោបាយសារពើពន្ធ គ្របដណ្តប់លើផ្នែកផ្សេងៗជាច្រើននៃចំណាយសាធារណៈ អត្ថបទនេះផ្តោតជាសំខាន់លើផ្នែកតែមួយប៉ុណ្ណោះ ពោលគឺ ចំណាយលើវិស័យអប់រំ។ ការសិក្សានេះ មានគូសបញ្ជាក់ជាសំខាន់ពីភាពខុសគ្នា នៅក្នុងចំណាយផ្នែកអប់រំ ទៅតាមតំបន់អេកូឡូស៊ី កម្រិតនៃការអប់រំ និងក្រុមចំណូលផ្សេងៗ។ លទ្ធផលសិក្សាឃើញជាក់ស្តែង នឹងផ្តល់ជាប្រយោជន៍សម្រាប់ទាំងម្ចាស់ជំនួយ និងរដ្ឋាភិបាល ក្នុងការកែសម្រួលចំណាយផ្នែកអប់រំនេះ ពីព្រោះលទ្ធភាពទទួលបានសេវាអប់រំសម្រាប់គ្រប់គ្នាកំពុងក្លាយជា អាទិភាពចម្បងនៃការអភិវឌ្ឍនៅកម្ពុជា (CDRI, 2013)។

---

[១] អត្ថបទនេះ ដកស្រង់ចេញពីការសិក្សាស្រាវជ្រាវស្តីពី "ការវាយតម្លៃ ការប្រឆាំងនឹងភាពក្រីក្រនៃគោលនយោបាយសារពើពន្ធនៅប្រទេសកម្ពុជា"ដែលជាផ្នែកមួយនៃគម្រោងសិក្សា៥ឆ្នាំពី"ការរីកចម្រើនរួមគ្នា" ដោយទទួលហិរញ្ញប្បទាន ពី ទីភ្នាក់ងារ សហប្រតិបត្តិការ អភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែ (Sida) ។ អ្នកនិពន្ធសូមថ្លែងអំណរគុណ ដល់ Sida និង CDRI ចំពោះការគាំទ្រដល់ការសិក្សានេះ។

[២] បណ្ឌិត តុង គឹមស៊ុន ជាអ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ហើយ ផៃ សុខចេង ជាជំនួយការស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI ។ អត្ថបទនេះ ទទួលបានការចូលរួមផ្តល់យោបល់ដ៏មានតម្លៃពីលោក Larry Strange, បណ្ឌិត Srinivasa Madhur, លោកស្រី Jan Taylor និង Susan Watkins និងអ្នកចូលរួមក្នុងសិក្ខាសាលាស្រាវជ្រាវពីរសប្តាហ៍ម្តងរបស់ CDRI កាលពីថ្ងៃទី១៥ វិច្ឆិកា ២០១៣។

អត្ថបទនេះចែកចេញជាផ្នែកដូចតទៅៈ ផ្នែកទី២ ពិនិត្យឡើងវិញលើការសិក្សាពីមុនៗអំពីគោលនយោបាយសារពើពន្ធ និងចំណាយផ្នែកអប់រំនៅកម្ពុជា។ ផ្នែកទី៣ បកស្រាយទិន្នន័យ និងវិធីសាស្ត្រនៃការវិភាគទំហំអត្ថប្រយោជន៍។ ផ្នែកទី៤ បង្ហាញពីលទ្ធផលជាក់ស្តែង ហើយផ្នែកទី៥ បង្ហាញនូវការសន្និដ្ឋាន និងការទាញគោលនយោបាយ។

## ២. ការសិក្សាលើឯកសារពាក់ព័ន្ធនានា

ឯកសារគោលនយោបាយ មានចំណងជើងថា "កម្ពុជាៈ ការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការធានានូវការអភិវឌ្ឍមានមូលដ្ឋានធំទូលាយប្រកបដោយចីរភាព" (Montague, 2001) បានស្នើឡើងនូវ គោលនយោបាយសារពើពន្ធមានកម្មវិធីកំណែទម្រង់ជាច្រើនសំដៅ ពង្រីកប្រាក់ចំណូលក្នុងស្រុក បង្កើនការបែងចែកចំណាយសាធារណៈទៅឲ្យវិស័យសង្គមកិច្ច មានជាអាទិ៍ វិស័យអប់រំ និងសុខាភិបាល និងកែលំអប្រសិទ្ធភាពចំណាយសាធារណៈជារួម។

ឯកសាររបស់ Montague បញ្ជាក់ថា កំណែទម្រង់ពាណិជ្ជកម្ម មានប្រសិទ្ធភាពជាងគេសម្រាប់ការកាត់បន្ថយភាពក្រីក្រជារួម ក៏ដូចជាការកែសម្រួលអត្រាប្តូរប្រាក់ ដើម្បីជំរុញការនាំចេញផលិតផលកសិកម្ម និងការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ។ កំណែទម្រង់គោលនយោបាយសារពើពន្ធ ហាក់មានផលប៉ះពាល់តិចតួចទៅលើភាពក្រីក្រ និងការបែងចែកប្រាក់ចំណូល បើធៀបនឹងគោលនយោបាយផ្សេងៗទៀត ។ អ្នកនិពន្ធផ្តល់យោបល់ថា ឥទ្ធិពលនៃកំណែទម្រង់គោលនយោបាយសារពើពន្ធ អាចប្រសើរឡើងថែមទៀត តាមការកាត់បន្ថយពន្ធផ្ទាល់ (direct taxes) ផ្សេងៗ ដែលប្រមូលលើប្រជាជនក្រីក្រនៅកម្ពុជា។ អ្នកនិពន្ធក៏បានកត់សម្គាល់ដែរថា គ្រួសារធូរធារនានា តែងប្រើប្រាស់សេវាសុខភាពសាធារណៈ និងការអប់រំនៅមធ្យមសិក្សា និងឧត្តមសិក្សាបានច្រើនជាងគ្រួសារក្រីក្រ។

លោក Beresford *et al.* (2004) បានពិនិត្យយ៉ាងលំអិតឡើងវិញលើ គោលនយោបាយសារពើពន្ធពីឆ្នាំ១៩៩១-២០០២ នៅកម្ពុជា ដើម្បីផ្តល់គំនិតបន្ថែមទៀតធ្វើឲ្យគោលនយោបាយកាន់តែអំណោយផលខ្លាំងឡើងដល់ជនក្រីក្រ។ ក្រុមអ្នកនិពន្ធនេះបានសន្និដ្ឋានថា ដើម្បីសម្រេចបានគោលដៅកំណើនសេដ្ឋកិច្ច ៦-៧% ដោយមានការបែងចែកប្រាក់ចំណូលប្រកបដោយសមធម៌នោះ គោលនយោបាយសារពើពន្ធ គួរមានបីជំហានដូចតទៅៈ ការពង្រឹងការប្រមូលចំណូល ការលើកកម្ពស់តម្លាភាពនៃប្រតិបត្តិការប្រមូលពន្ធ និងការបង្កើនចំណាយសាធារណៈក្នុង " វិស័យអាទិភាព" ដូចជា អប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ។ Jenkin និង Klevchuk (2006) បានព្យាយាមកំណត់ពីចំណុចរាំងស្ទះសំខាន់ៗ បង្កដោយគោលនយោបាយសារពើពន្ធពិសេសក្នុងវិស័យជាអាទិភាព ដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចមិនសូវអំណោយផលដល់ជនក្រីក្រ ព្រមទាំងបានស្នើនូវគោលនយោបាយកែសម្រួលមួយចំនួន សម្រាប់ជួយដោះស្រាយឧបសគ្គទាំងនោះ។ ជារួម ពួកគេបានកត់សម្គាល់ថា ប្រទេសកម្ពុជាត្រូវប្រឈមមុខនឹងបញ្ហាធំពីរគឺៈ ប្រព័ន្ធរដ្ឋបាលសាធារណៈទន់ខ្សោយ និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ និងមានគុណភាពទាប នៅខាងក្រៅរាជធានី។ សម្រាប់វិស័យអប់រំ ឧបសគ្គចម្បងៗហាក់ឃើញមានក្នុងផ្នែក លទ្ធកម្ម, សមត្ថភាពបុគ្គល និងស្ថាប័ន, ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយសម្រួលការងារផ្សេងៗ។

ថ្មីៗនេះទៀត ធនាគារពិភពលោក (2011) បានវាយតម្លៃលើទិដ្ឋភាពផ្សេងៗនៃវិស័យអប់រំ មានទាំង លទ្ធផលអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ផង ដែលផ្តោតលើ៖ លទ្ធភាពបានចូលរៀនគុណភាពនិងស្ថាប័ន,រចនាសម្ព័ន្ធនៃចំណាយលើការអប់រំ,បញ្ហាទាក់ទងនឹងគ្រូបង្រៀន និងបៀវត្សរ៍, សៀវភៅសិក្សា, ចំណាយផ្ទាល់ខ្លួនលើការអប់រំ, និងចំណាយលើការអប់រំថ្នាក់ឧត្តមសិក្សា។ របាយការណ៍នោះគូសបញ្ជាក់ថា កម្ពុជាមានភាពរីកចម្រើនច្រើនក្នុងការផ្តល់លទ្ធភាពឲ្យទទួលបានសេវាអប់រំកម្រិតបឋម ប៉ុន្តែការកែលំអគុណភាពអប់រំ និងការផ្តល់លទ្ធភាពឲ្យទទួលបានសេវាអប់រំកម្រិតផ្សេងទៀត នៅតែជាបញ្ហាប្រឈមដ៏ធំ។

## ៣. ទិន្នន័យ និង វិធីសាស្ត្រស្រាវជ្រាវ

### ៣.១. ទិន្នន័យ

ការសិក្សានេះផ្អែកជាចម្បងលើ ទិន្នន័យអង្កេតគ្រួសារ ពោលគឺអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (CSES) ធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងឆ្នាំ២០០៤ ២០០៩ និង ២០១១។[៣] អង្កេតនេះតំណាងឲ្យទូទាំងប្រទេស ដោយអនុវត្តលើគ្រួសារក្នុងទាំង ២៤ខេត្ត/ក្រុង។

### ៣.២. ការវិភាគទំហំអត្ថប្រយោជន៍

ការវិភាគទំហំអត្ថប្រយោជន៍នេះ គេតែងប្រើប្រាស់ជាទូទៅតាំងពីទសវត្សរ៍១៩៦០មកដើម្បីវាយតម្លៃពីឥទ្ធិពលនៃការបែងចែកចំណាយសាធារណៈទៅលើតំបន់ផ្សេងៗ។ លោក Gillespie បានផ្តួចផ្តើមធ្វើការសិក្សានេះមុនគេ ដោយផ្តោតសំខាន់លើប្រទេសកាណាដានៅឆ្នាំ១៩៦៥ និងសហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៦។ វិធីសាស្ត្រវិភាគទំហំអត្ថប្រយោជន៍ (BIA) គេបានបង្កើតឡើងជាសំខាន់ដើម្បីគួបផ្សំ ចំណាយសាធារណៈសរុបនៃសេវាសាធារណៈនីមួយៗ ជាមួយនឹងព័ត៌មានស្តីពីអ្នកប្រើប្រាស់ ដើម្បីបង្ហាញនូវរូបភាពស្តីពី ការបែងចែកអត្ថប្រយោជន៍នៃចំណាយរដ្ឋាភិបាល និងលក្ខណៈរីកចម្រើនរបស់វា។ គុណវិបត្តិមួយនៃការប្រើប្រាស់ BIA គឺចំណាយរដ្ឋាភិបាលលើសេវាសាធារណៈក្នុងប្រទេសមួយចំនួន មិនមានផ្តល់ដល់ការប្រើប្រាស់ជាសាធារណៈនោះទេ។ ដើម្បីបំពេញចំណុចខ្វះខាតនេះ Araar និង Duclos (2009, 2013) បានណែនាំពី វិធីសាស្ត្រថ្មីមួយសម្រាប់ប៉ាន់ស្មានពីទំហំអត្ថប្រយោជន៍ ដោយមិនតម្រូវឱ្យដឹងព័ត៌មានដូចខាងលើនេះទេ។

---

[៣] វិទ្យាស្ថានជាតិស្ថិតិ បានចុះអង្កេតគ្រួសារតំណាងទូទាំងប្រទេស (ពោលគឺ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា) ជាច្រើនលើក តាំងពីឆ្នាំ១៩៩៣/៩៤ មក។ តាមព័ត៌មានទទួលបាន ទិន្នន័យអង្កេតដែលអាចស្វែងរកមកប្រើជាសាធារណៈបាន គឺមាន ទិន្នន័យឆ្នាំ ១៩៩៣/៩៤, ១៩៩៧, ១៩៩៩, ២០០៤, ២០០៧, ២០០៨, ២០០៩, ២០១០ និង ២០១១ ក្នុងនេះ មានតែទិន្នន័យអង្កេតចាប់ពីឆ្នាំ២០០៤ មកប៉ុណ្ណោះ ដែលផ្អែកលើក្របខ័ណ្ឌយកសំណាកត្រឹមត្រូវ (ឧទាហរណ៍៖ ជំរឿនប្រជាជនទូទៅ) និងមានគុណភាពល្អ។ ក្របខ័ណ្ឌសំណាកឆ្នាំ២០០៤, ២០០៧ និង២០០៨ ផ្អែកលើជំរឿនប្រជាជនទូទៅឆ្នាំ១៩៩៨ ហើយទិន្នន័យអង្កេតក្រៅពីនោះ ផ្អែកលើជំរឿនប្រជាជនទូទៅឆ្នាំ២០០៨។ អង្កេតឆ្នាំ២០០៤ និង ២០០៩ ប្រើប្រាស់សំណាក ៧២០ភូមិ និង១២.០០០គ្រួសារ រីឯអង្កេតឆ្នាំ២០០៧, ២០០៨, ២០១០ និង ២០១១ ប្រើតែពាក់កណ្តាលនៃចំនួនភូមិសំណាក និងប្រហែលមួយភាគបីនៃចំនួនគ្រួសារសំណាកប៉ុណ្ណោះ បើធៀបនឹងចំនួនសំណាកឆ្នាំ២០០៤។ ភូមិសំណាកសម្រាប់ឆ្នាំ២០០៧ និង ២០០៨ គឺជាសំណាករងនៃឆ្នាំ២០០៤ ហើយ ភូមិសំណាកសម្រាប់ឆ្នាំ២០១០ និង ២០១១ ជាសំណាករងនៃឆ្នាំ២០០៩។ ដោយមូលហេតុនេះ ក្រុមស្រាវជ្រាវប្រើប្រាស់តែទិន្នន័យឆ្នាំ២០០៤ និង ២០០៩ ប៉ុណ្ណោះ ប៉ុន្តែដើម្បីអាចក្តាប់បានពីការវិវត្តថ្មីៗបំផុតនោះ ក៏មានការបកស្រាយពីលទ្ធផលទទួលបានពីអង្កេតឆ្នាំ ២០១១ ផងដែរ។

ដូចមានបង្ហាញក្នុង រូបភាព១ ចំណាយរដ្ឋាភិបាលលើការផ្តល់សេវា វាអំណោយផល ដល់ជនក្រីក្រ ប្រសិនបើ ខ្សែកោងតំណាងឲ្យអត្ថប្រយោជន៍ទាំងនោះ វាស្ថិតនៅខាងលើបន្ទាត់ ៤៥ដឺក្រេ។ ប្រសិនបើខ្សែកោងតំណាងឲ្យអត្ថប្រយោជន៍ទាំងនោះ ស្ថិតនៅក្រោមបន្ទាត់ ៤៥ដឺក្រេ និងខាងលើ ខ្សែកោង Lorenz សម្រាប់ប្រាក់ចំណូល ឬចំណាយប្រើប្រាស់នោះ គឺ ចំណាយរបស់ រដ្ឋាភិបាលទៅលើសេវាសាធារណៈវាមានភាពរីកចម្រើន។ ផ្ទុយទៅវិញ ចំណាយរបស់រដ្ឋាភិបាល មានលក្ខណៈអន់ថយ ប្រសិនបើខ្សែកោងតំណាងឲ្យអត្ថប្រយោជន៍ទាំងនោះ វាស្ថិតនៅខាងក្រោម ខ្សែកោង Lorenz ។

រូបភាព១៖ ខ្សែកោងតំណាងឲ្យចំណាយរបស់រដ្ឋាភិបាល និង គំរូប្រៀបធៀបពីរ




ប្រភព៖ Davoodi *et. al.* (2003), pp. 14

## ៣.៣. ការវិភាគទំហំអត្ថប្រយោជន៍ទទួលបានពីឯកតាបន្ថែម

ដោយសារការកែលំអលើវិធីសាស្ត្រ BIA ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ វិធីសាស្ត្រពីបុរាណក៏ ទទួលការរិះគន់ថា ជាឧបករណ៍មិនល្អគ្រប់គ្រាន់ទេ សម្រាប់វាយតម្លៃលើការផ្លាស់ប្តូរគោល នយោបាយ (van de Walle 2003, Younger 2003)។ ដើម្បីដោះស្រាយបញ្ហានេះ Lanjouw and Ravallion (1999) និង Ajwad and Wodon (2001) បានស្នើឡើងនូវវិធីសាស្ត្រជាក់ស្តែងថ្មីៗដូចជា បច្ចេកទេស regression សម្រាប់វាស់វែងពីទំហំអត្ថប្រយោជន៍ទទួលបានពីឯកតាបន្ថែម ដោយប្រើ ទិន្នន័យបានពីអង្កេតនៅត្រង់ចំណុចមួយនៃពេលវេលា ហៅថា ការវិភាគទំហំអត្ថប្រយោជន៍ទទួល បានពីឯកតាបន្ថែម។ ក្នុងការប៉ាន់ស្មានពីទំហំអត្ថប្រយោជន៍ទទួលបានពីឯកតាបន្ថែម ការសិក្សា នេះអនុវត្តតាមនីតិវិធី ដែលស្នើឡើងដោយ Ajwad and Wodon (2001) ដោយសារវាមានកំណត់ និយមន័យច្បាស់លាស់លើពាក្យសុខុមាលភាព។

## ៤. លទ្ធផលសិក្សាជាក់ស្តែង

តារាង១ បង្ហាញពីអត្រានៃការចូលរួម និងចំណែកនៃចំណាយសាធារណៈនៅក្នុងកម្រិតអប់រំទាំង ៣ និងនៅក្នុងគ្រួសារដែលចែកចេញជា ៥ ក្រុមបញ្ចភាគចំណូល។ លទ្ធផលសិក្សាបង្ហាញថា អត្រាចូលរួមក្នុងកម្រិតអប់រំទាំង៣ បានកើនឡើង ក្នុងអំឡុងឆ្នាំសិក្សា២០០៤-២០១១ ជាពិសេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ចំណាយសាធារណៈនៅថ្នាក់បឋមសិក្សា មានចំណែកស្មើគ្នាក្នុងចំណោមគ្រួសារទាំងប្រាំក្រុមចំណូល។ ប៉ុន្តែចំណាយនៅថ្នាក់មធ្យមសិក្សាបឋមភូមិមានចំណែកមិនស្មើគ្នាទេ។ គេសង្កេតឃើញទៀតថា ក្រុមគ្រួសារក្រីក្របំផុត និងក្រុមគ្រួសារធូរធារបំផុត ទទួលបានអត្ថប្រយោជន៍ខុសគ្នាជាខ្លាំងពីចំណាយសាធារណៈនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ។ ភស្តុតាងនេះបង្ហាញថា ក្រុមគ្រួសារធូរធារបំផុត ទទួលបានអត្ថប្រយោជន៍ពីចំណាយសាធារណៈលើការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ច្រើនជាងក្រុមគ្រួសារក្រីក្របំផុត។

តារាង១៖ អត្រានៃការចូលរួម និងចំណែកនៃចំណាយសាធារណៈ (%)

| | 2004 | | 2009 | | 2011 | |
|---|---|---|---|---|---|---|
| | អត្រានៃការចូលរួម | ចំណែកតាមក្រុមចំណូល | អត្រានៃការចូលរួម | ចំណែកតាមក្រុមចំណូល | អត្រានៃការចូលរួម | ចំណែកតាមក្រុមចំណូល |
| **កម្រិតបឋមសិក្សា** | | | | | | |
| ក្រុមបញ្ចភាគទី១ | 77 | 18 | 78 | 18 | 83 | 19 |
| ក្រុមបញ្ចភាគទី២ | 84 | 20 | 88 | 20 | 89 | 20 |
| ក្រុមបញ្ចភាគទី៣ | 86 | 20 | 88 | 21 | 90 | 20 |
| ក្រុមបញ្ចភាគទី៤ | 88 | 21 | 88 | 21 | 94 | 21 |
| ក្រុមបញ្ចភាគទី៥ | 90 | 21 | 90 | 21 | 88 | 20 |
| សរុប | 85 | 100 | 86 | 100 | 89 | 100 |
| **កម្រិតមធ្យមសិក្សាបឋមភូមិ** | | | | | | |
| ក្រុមបញ្ចភាគទី១ | 51 | 13 | 61 | 15 | 64 | 15 |
| ក្រុមបញ្ចភាគទី២ | 71 | 19 | 76 | 19 | 81 | 19 |
| ក្រុមបញ្ចភាគទី៣ | 82 | 21 | 84 | 21 | 92 | 22 |
| ក្រុមបញ្ចភាគទី៤ | 87 | 23 | 86 | 22 | 93 | 21 |
| ក្រុមបញ្ចភាគទី៥ | 93 | 24 | 89 | 23 | 95 | 23 |
| សរុប | 77 | 100 | 79 | 100 | 85 | 100 |
| **កម្រិតមធ្យមសិក្សាទុតិយភូមិ** | | | | | | |
| ក្រុមបញ្ចភាគទី១ | 2 | 2 | 7 | 5 | 10 | 5 |
| ក្រុមបញ្ចភាគទី២ | 7 | 7 | 15 | 10 | 19 | 9 |
| ក្រុមបញ្ចភាគទី៣ | 13 | 13 | 26 | 17 | 39 | 19 |
| ក្រុមបញ្ចភាគទី៤ | 22 | 22 | 41 | 27 | 59 | 28 |
| ក្រុមបញ្ចភាគទី៥ | 56 | 56 | 62 | 41 | 82 | 39 |
| សរុប | 20 | 100 | 30 | 100 | 42 | 100 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធ

ដើម្បីបញ្ជាក់លើលទ្ធផលបង្ហាញជូនក្នុង តារាង១ អ្នកស្រាវជ្រាវបានគូសខ្សែកោងតំណាងឲ្យ ចំណាយសាធារណៈនៅតាមកម្រិតអប់រំនីមួយៗ។ ខ្សែកោងចំណាយលើការអប់រំនៅកម្រិតបឋមសិក្សា ស្ថិតនៅពីលើខ្សែបន្ទាត់ ៤៥ដឺក្រេ ដែលបញ្ជាក់ថា ចំណាយសាធារណៈនៅកម្រិតបឋមសិក្សាវាអំណោយផលដល់ជនក្រីក្រ។ ចំណាយសាធារណៈនៅកម្រិតមធ្យមសិក្សាបឋមភូមិមានខ្សែកោងស្ថិតនៅក្រោមបន្ទាត់ ៤៥ដឺក្រេ ប៉ុន្តែស្ថិតនៅលើខ្សែកោង Lorenz curve ដែលបង្ហាញថា វាមានលក្ខណៈជឿនលឿន (ជួយជនក្រីក្រ ច្រើនជាងជនមិនក្រីក្រ)។ ដោយឡែក ខ្សែកោងចំណាយសាធារណៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ វារត់កាត់ខ្សែកោង Lorenz curve ដូច្នេះ ចំណាយសាធារណៈលើសេវានេះ មិនអាចសន្និដ្ឋានថាមានលក្ខណៈជឿនលឿន ឬអន់ថយនោះឡើយ។

រូបភាព ២៖ ខ្សែកោងតំណាងឲ្យចំណាយសាធារណៈលើវិស័យអប់រំក្នុងឆ្នាំ២០១១




ប្រភព៖ CSES 2011

ការវិភាគទំហំអត្ថប្រយោជន៍ទទួលបានពីឯកតាបន្ថែមនៅក្នុងតារាង២ បង្ហាញថា គ្រួសារនៅក្នុង ៤ក្រុមបញ្ចភាគខាងទាប ទទួលបានអត្ថប្រយោជន៍ច្រើនជាង គ្រួសារក្នុងក្រុមបញ្ចភាគខ្ពស់បំផុត បើសិនមានកំណើនចំណាយសាធារណៈនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ភស្តុតាងនេះបង្ហាញថា កំណើនលទ្ធភាពទទួលបានការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ វាអំណោយផលដល់ជនក្រីក្រជាង ព្រោះគ្រួសារមានជីវភាពធូរធារបំផុតភាគច្រើន គេមានលទ្ធភាពប្រើប្រាស់សេវាមូលដ្ឋាននេះរួចស្រេចហើយ។ ប៉ុន្តែប្រសិនបើចំណាយសាធារណៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិកើនឡើង គឺគ្រួសារក្នុងបីក្រុមបញ្ចភាគនៅកណ្តាល ទំនងទទួលបានប្រយោជន៍ច្រើនជាង គ្រួសារក្នុងក្រុមបញ្ចភាគទាបបំផុត និងខ្ពស់បំផុត។

តារាង ២៖ អត្ថប្រយោជន៍ទទួលបានពីឯកតាបន្ថែម

| | 2004 | 2009 | 2011 |
|---|---|---|---|
| **កម្រិតបឋមសិក្សា** | | | |
| ក្រុមបញ្ចភាគទី១ | 0.93 | 1.28 | 1.17 |
| ក្រុមបញ្ចភាគទី២ | 1.27 | 1.30 | 1.23 |
| ក្រុមបញ្ចភាគទី៣ | 1.12 | 1.07 | 1.06 |
| ក្រុមបញ្ចភាគទី៤ | 1.03 | 0.86 | 1.03 |
| ក្រុមបញ្ចភាគទី៥ | 0.66 | 0.48 | 0.52 |
| **កម្រិតមធ្យមសិក្សាបឋមភូមិ** | | | |
| ក្រុមបញ្ចភាគទី១ | 1.46 | 1.52 | 1.85 |
| ក្រុមបញ្ចភាគទី២ | 1.21 | 1.38 | 1.28 |
| ក្រុមបញ្ចភាគទី៣ | 1.01 | 0.95 | 1.00 |
| ក្រុមបញ្ចភាគទី៤ | 0.90 | 0.95 | 0.51 |
| ក្រុមបញ្ចភាគទី៥ | 0.42 | 0.21 | 0.36 |
| **កម្រិតមធ្យមសិក្សាទុតិយភូមិ** | | | |
| ក្រុមបញ្ចភាគទី១ | 0.66 | 1.09 | 0.89 |
| ក្រុមបញ្ចភាគទី២ | 0.73 | 1.09 | 1.00 |
| ក្រុមបញ្ចភាគទី៣ | 1.22 | 0.98 | 1.30 |
| ក្រុមបញ្ចភាគទី៤ | 1.39 | 1.14 | 0.96 |
| ក្រុមបញ្ចភាគទី៥ | 0.99 | 0.71 | 0.86 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធ

សម្រាប់ការបែងចែកតាមតំបន់ តារាង៣ បង្ហាញពីអត្រាសិស្សចូលរៀន និងចំណែកនៃចំណាយសាធារណៈក្នុងប្រព័ន្ធអប់រំនៅតាមតំបន់ភូមិសាស្ត្រធំៗទាំង ៥។ គួរកត់សម្គាល់ថា អត្រាសិស្សចូលរៀននៅគ្រឹះស្ថានអប់រំទាំងបីកម្រិតក្នុងរាជធានីភ្នំពេញ មានកម្រិតខ្ពស់បំផុតក្នុងឆ្នាំ ២០០៤ ស្របពេលដែលតំបន់ខ្ពង់រាប និងតំបន់ភ្នំមានអត្រាសិស្សចូលរៀនទាបបំផុត។ ទោះយ៉ាងនេះក្តី នៅឆ្នាំ២០១១ អត្រាសិស្សចូលរៀននៅសាលាបឋមសិក្សារបស់រដ្ឋក្នុងរាជធានីភ្នំពេញ វាមានកម្រិតទាបបំផុតវិញ ក្នុងចំណោមតំបន់ភូមិសាស្ត្រទាំង៥ ប៉ុន្តែអត្រាសិស្សចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិនៅរាជធានីភ្នំពេញ នៅរក្សាលំដាប់ខ្ពស់ដដែល ខណៈដែលតំបន់ទន្លេសាប និងតំបន់ឆ្នេរ មានអត្រាសិស្សចូលរៀនកម្រិតទាបបំផុត។ ការបែងចែកថវិកាទៅតាមតំបន់ភូមិសាស្ត្រទាំង៥ ពុំបានស្មើភាពគ្នាទេ ដោយតំបន់ឆ្នេរហាក់ទទួលបានចំណែកតូចបំផុតពីចំណាយសាធារណៈនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា នៅក្នុងអំឡុងពេលសិក្សានេះ។

ប្រសិនបើធ្វើការវិភាគទៅតាមតំបន់ទីក្រុង និងជនបទវិញ គេឃើញថា អត្រាសិស្សចូលរៀននៅគ្រប់កម្រិតអប់រំនៅតំបន់ទីក្រុង តែងតែខ្ពស់ជាងនៅតាមតំបន់ជនបទ។ ក្នុងការបែងចែកថវិកាវិញ តំបន់ទីក្រុងទទួលបានតែ ៣១% និង ៤១% ប៉ុណ្ណោះ នៃចំណាយសរុបនៅកម្រិតបឋមសិក្សា

និងមធ្យមសិក្សាបឋមភូមិ ក្នុងឆ្នាំ២០១១។ ផ្ទុយទៅវិញ តំបន់ទីក្រុងទទួលបានរហូតដល់ ៦១% នៃចំណាយសាធារណៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ រីឯតំបន់ជនបទទទួលបានត្រឹមតែ ៣៩%។

តារាង៣៖ អត្រាសិស្សចូលរៀន និងការបែងចែកចំណាយសាធារណៈតាមតំបន់ភូមិសាស្ត្រ (%)

| | 2004 | | 2009 | | 2011 | |
|---|---|---|---|---|---|---|
| | អត្រាសិស្សចូលរៀន | ការបែងចែកតាមតំបន់ | អត្រាសិស្សចូលរៀន | ការបែងចែកតាមតំបន់ | អត្រាសិស្សចូលរៀន | ការបែងចែកតាមតំបន់ |
| កម្រិតបឋមសិក្សា | | | | | | |
| ភ្នំពេញ | 90 | 6 | 88 | 6 | 85 | 13 |
| តំបន់វាលទំនាប | 86 | 43 | 88 | 42 | 90 | 37 |
| ទន្លេសាប | 84 | 32 | 86 | 33 | 90 | 31 |
| តំបន់ឆ្នេរ | 87 | 8 | 87 | 8 | 92 | 7 |
| ខ្ពង់រាប និងតំបន់ភ្នំ | 80 | 10 | 81 | 12 | 86 | 13 |
| ទីក្រុង | 87 | 20 | 88 | 15 | 90 | 31 |
| ជនបទ | 85 | 80 | 86 | 85 | 88 | 69 |
| សរុប | 85 | 100 | 86 | 100 | 89 | 100 |
| កម្រិតមធ្យមសិក្សាបឋមភូមិ | | | | | | |
| ភ្នំពេញ | 93 | 16 | 90 | 11 | 91 | 22 |
| តំបន់វាលទំនាប | 77 | 41 | 79 | 41 | 87 | 38 |
| ទន្លេសាប | 72 | 27 | 77 | 32 | 79 | 25 |
| តំបន់ឆ្នេរ | 79 | 9 | 83 | 8 | 88 | 7 |
| ខ្ពង់រាប និងតំបន់ភ្នំ | 67 | 7 | 74 | 9 | 80 | 10 |
| ទីក្រុង | 88 | 37 | 87 | 24 | 89 | 41 |
| ជនបទ | 71 | 63 | 77 | 76 | 83 | 59 |
| សរុប | 77 | 100 | 79 | 100 | 85 | 100 |
| កម្រិតមធ្យមសិក្សាទុតិយភូមិ | | | | | | |
| ភ្នំពេញ | 58 | 33 | 63 | 22 | 73 | 40 |
| តំបន់វាលទំនាប | 15 | 29 | 29 | 38 | 34 | 26 |
| ទន្លេសាប | 14 | 23 | 24 | 27 | 30 | 20 |
| តំបន់ឆ្នេរ | 26 | 12 | 33 | 8 | 29 | 5 |
| ខ្ពង់រាប និងតំបន់ភ្នំ | 11 | 5 | 20 | 6 | 37 | 9 |
| ទីក្រុង | 45 | 63 | 55 | 40 | 60 | 61 |
| ជនបទ | 11 | 37 | 23 | 60 | 28 | 39 |
| សរុប | 20 | 100 | 30 | 100 | 42 | 100 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធ

## ៥. សេចក្តីសន្និដ្ឋាន និងគោលនយោបាយពាក់ព័ន្ធ

ការវិភាគទំហំអត្ថប្រយោជន៍បង្ហាញថា ចំណាយសាធារណៈលើសេវាអប់រំនៅកម្ពុជាមានលក្ខណៈជួយដល់ជនក្រីក្រនៅកម្រិតបឋមសិក្សា និងមានលក្ខណៈជឿនលឿននៅកម្រិតមធ្យមសិក្សាបឋមសិក្សា ប៉ុន្តែចំណាយនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គឺមិនទាន់អាចសន្និដ្ឋានបានទេ។ គ្រួសារក្រីក្រហាក់ទទួលបានអត្ថប្រយោជន៍ច្រើនជាងពី ការពង្រីកចំណាយសាធារណៈនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ បើធៀបនឹងក្រុមគ្រួសារធូរធារបំផុត។ ការពង្រីកចំណាយសាធារណៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ អាចផ្តល់អត្ថប្រយោជន៍ដល់គ្រួសារមានចំណូលមធ្យម ច្រើនជាង គ្រួសារក្រីក្របំផុត និងគ្រួសារធូរធារបំផុត។ ការសិក្សានេះក៏បង្ហាញនូវភាពខុសគ្នាខ្លាំងនៃចំណាយសាធារណៈលើសេវាអប់រំនៅតាមតំបន់នានា ជាពិសេសរវាងតំបន់ទីក្រុង និងតំបន់ជនបទ សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ។

ជម្រើសគោលនយោបាយជាច្រើនអាចទាញយកបានពី លទ្ធផលសិក្សានេះ។ ការបែងចែកជាថ្មីនូវថវិកាដែលមានស្រាប់នៅក្នុងវិស័យអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ក៏អាចជាជម្រើសគោលនយោបាយជួយទ្រទ្រង់ដល់ជនក្រីក្រមួយដែរ។ ហើយប្រសិនបើមានការពង្រីកចំណាយលើវិស័យអប់រំនោះ គួរបែងចែកថវិកាឲ្យបានច្រើនថែមទៀតសម្រាប់កម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិវិញ ចំណាយរបស់រដ្ឋាភិបាលគួរតែបែងចែកជាថ្មីដោយផ្តល់ថវិកាច្រើនជាងមុនទៅឲ្យតំបន់ជនបទ។ ប្រការនេះអាចសម្រេចទៅបាន តាមការបង្កើនឱកាសទទួលបានការអប់រំ កម្មវិធីជួយទ្រទ្រង់ផ្នែកអាហារ ឬប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់សិស្សមកពីតំបន់ដាច់ស្រយាល។

## ឯកសារយោង


Ajwad, Mohamed Ihsan & Quentin Wodon (2001), *Marginal Benefit Incidence Analysis Using a Single Cross-section of Data*, (Washington D.C: World Bank)

Araar, Abdelkrim & Jean-Yves Duclos (2013), *DASP 2.3: Distributive Analysis Stata Package*, PEP, CIRPEE and World Bank

Araar, Abdelkrim & Jean-Yves Duclos (2009), *DASP 2.1: Distributive Analysis Stata Package*, PEP, CIRPEE and World Bank

Beresford, Melanie, Nguon Sokha, Rathin Roy, Sau Sisovanna & Ceema Namazie (2004), *The Macroeconomics of Poverty Reduction in Cambodia*, Asian-Pacific Regional Programme on The Macroeconomics of Poverty Reduction (Phnom Penh: UNDP)

Cambodia Development Resource Institute (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities* (Phnom Penh: CDRI)

Gillespie, W. Irwin (1965), "Public Expenditure and Income Distribution", in Richard Musgrave (ed.), *Essays in Fiscal Federalism* (Washington: Brooking Institute)

Gillespie, W. Irwin (1966), "The Incidence of Taxes and Public Expenditures in the Canadian Economy", *Studies of the Royal Commission on Taxation*, No.2 (Ottawa: Carleton University)

Jenkins, P. Glenn & Klevchuk Andrey (2006), "Expenditure Policy to Promote Growth: Cambodia", Development Discussion Paper Number. 2 (Phnom Penh: World Bank)

Lanjouw, Peter & Martin Ravallion (1999), "Benefit Incidence, Public Spending Reforms, and the Timing of Program Capture", *the World Bank Economic Review*, Vol. 13, No. 2, pp. 257-273

McKinley, Terry (2010), *Inclusive Growth Criteria and Indicators: An Inclusive Growth Index for Diagnosis Index of Country Progress*, ADB Sustainable Development Working Paper Series (Manila: ADB)

Montague, J. Lord (2001), *Macroeconomic Policies for Poverty Reduction in Cambodia*, MPRA Paper No. 41174, http://mpra.ub.uni-muenchen.de/41174/(accessed on 19th April 2013)

National Institute of Statistics (2005), *Cambodia Socio-Economic Survey 2004: Technical Report on Survey Design and Implementation*, (National Institute of Statistics, Ministry of Planning: Phnom Penh)

Roth Vathana & Lun Pide (forthcoming), *Assessing Economic Inclusiveness in Cambodia: Consumption and Non-consumption Pro-Poor Approach*, Cambodia Paper for the Project Report on Inclusive Development in the GMS (Phnom Penh: CDRI)

Tong Kimsun (2012), "Inclusive Growth for Cambodia: What is it and How can we achieve it?", Presentation for the 2012 Cambodia Outlook Conference, Cambodia's Priorities for Inclusive

Younger, Stephen D. (2000), *Benefits on the Margin: Observations on Averagevs, Marginal Benefit Incidence*, Cornel Food and Nutrition Policy Program, Working Paper No. 127 (New York: Cornel University)

van de Walle Dominique & K. Nead, eds. (1995), "Public Spending and the Poor: Theory and Evidence", (Baltimore, MD: Johns Hopkins University Press)

World Bank (2011), "Cambodia More Efficient Government Spending for Strong and Inclusive Growth", (Poverty Reduction and Economic Management Unit, East Asia and Pacific Region)

## ឧបសម្ព័ន្ធ ១៖ រចនាសម្ព័ន្ធអប់រំនៅកម្ពុជា

| អាយុ | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្នាក់ | | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| កម្រិត | មតេយ្យ | | | បឋមសិក្សា | | | | | | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
| លទ្ធភាពទទួលសេវា | តាមការស្ម័គ្រចិត្ត | | | ជាកាតព្វកិច្ច | | | | | | | | | តាមការស្ម័គ្រចិត្ត | | |
| បន្ទុកចំណាយ | ឥតគិតថ្លៃ ឬបង់ប្រាក់តិចតួច | | | ឥតគិតថ្លៃ | | | | | | | | | | | |

## ឧបសម្ព័ន្ធ ២៖ លក្ខណៈជឿនលឿននៃចំណាយសាធារណៈលើវិស័យអប់រំ នៅឆ្នាំ២០០៤ និង២០០៩



-៦-

# អាទិភាពគោលនយោបាយដើម្បីបង្កើនទិន្នផល និងផលស្រូវនៅកម្ពុជា

*ដោយបណ្ឌិត ថេង វុទ្ធី និង Ben Flower[១]*

## ១. សេចក្តីផ្តើម

លទ្ធផលក្នុងវិស័យកសិកម្មនៅកម្ពុជាបានល្អប្រសើរឡើងគួរឲ្យកត់សំគាល់ ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ។ ទិន្នផលស្រូវកើនឡើងមួយជាពីរ ពី ១៣៦០គីឡូក្រាមក្នុងមួយហិកតាក្នុងឆ្នាំ ១៩៩០ ដល់ ៣១០០គីឡូក្រាមក្នុងមួយហិកតាក្នុងឆ្នាំ២០១២ (NIS 2008; MAFF 2013), ដែលនាំឲ្យផលស្រូវកើនឡើងយ៉ាងខ្លាំង ធ្វើឲ្យមានអតិរេកស្រូវឡើងរហូតដល់ ៤.៧លានតោនក្នុងឆ្នាំ ២០១២ (MAFF 2013)។ អ្នកបង្កើតគោលនយោបាយ បានជំរុញឲ្យប្រើប្រាស់វិធីសាស្ត្រមានពីរមុខព្រួញ ដើម្បីប្រែក្លាយកម្ពុជាទៅជាប្រទេសនាំចេញស្រូវធំបំផុតលំដាប់ទី៣ នៅលើពិភពលោកនៅឆ្នាំ២០១៥ តាមការបង្កើនផលិតភាពនិងទិន្នផល ជាពិសេសចំពោះកសិដ្ឋានតូចៗតាមគ្រួសារ និងការផ្លាស់ប្តូរផលិតផលទៅជាផលិតផលមានតម្លៃខ្ពស់សម្រាប់លក់។ យុទ្ធសាស្ត្រចតុកោណរបស់ប្រទេសកម្ពុជាដំណាក់កាលទី៣ឆ្នាំ២០១៤-១៨បានបញ្ជាក់ជាថ្មីពីគោលដៅរបស់រដ្ឋាភិបាល ដើម្បីនាំចេញអង្ករឲ្យបាន ១លានតោនក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៥ (RGC 2013)។ ប៉ុន្តែនៅមានលទ្ធភាពច្រើនណាស់ដើម្បីលើកស្ទួយវិស័យនេះ ដែលនៅយឺតយ៉ាវជាងផលិតករចម្បងៗក្នុងតំបន់ពោលគឺ ថៃ និងវៀតណាម (CDRI 2013)។ អត្ថបទនេះបង្ហាញពីបញ្ហានៅសេសសល់ដើម្បីអភិវឌ្ឍវិស័យស្រូវនៅកម្ពុជា និងផ្តល់យោបល់ពីគោលនយោបាយដើម្បីបំបាត់ឧបសគ្គទាំងនោះ។

## ២. ចំណាយខ្ពស់លើធាតុចូលកសិកម្ម

ដូចប្រទេសឯទៀតក្នុងតំបន់ដែរ ប្រាក់ចំណេញរបស់កសិករតូចតាចនៅកម្ពុជាបានថយចុះដោយសារគាត់មានចំណាយផលិតកម្មយ៉ាងច្រើន ក្នុងនេះ ជីមានចំណែកយ៉ាងធំក្នុងចំណាយសរុបដល់ប្រហែល ២៣% នៅរដូវវស្សា និង ៣៧% នៅរដូវប្រាំង (Chhim *et al.* 2013) ដែលស្រដៀងគ្នានឹងប្រទេសជិតខាងគឺ វៀតណាម និងឡាវ (ពុំអាចរកបានព័ត៌មានថ្មីអំពីប្រទេសថៃទេ)។ ម្យ៉ាងទៀត ធាតុចូលមានគុណភាពទាប សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅអន់ថយ និងឥណទានមានតម្លៃខ្ពស់ ក៏បានបង្កឧបសគ្គដល់ការអភិវឌ្ឍវិស័យស្រូវដែរ។

ទីផ្សារជីពិតមែនតែមានការរៀបចំយ៉ាងល្អនៅកម្រិតមូលដ្ឋានក្តី ប៉ុន្តែឃើញមានចំណុចខ្វះខាតជាច្រើនដែលបានរារាំងដល់កំណើនទិន្នផល។ បញ្ហាជាច្រើនផុសចេញពី នីតិវិធីអធិការកិច្ចគ្មានប្រសិទ្ធភាពដែលអនុវត្តលើជីនាំចូល។ ប្រព័ន្ធកំពុងអនុវត្តសព្វថ្ងៃមិនគ្រប់គ្រាន់ដើម្បីទប់ស្កាត់ការនាំចូលផលិតផលក្រោមស្តង់ដារ និងផលិតផលក្លែងក្លាយក្នុងទីផ្សារកម្ពុជា។ ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណនាំចូលនាបច្ចុប្បន្ន បានបង្កើតឱកាសសម្រាប់ឲ្យពួកមន្ត្រីអ្នកចេញលិខិតអនុញ្ញាតទទួលបានផលប្រយោជន៍តាមការទារយក "ប្រាក់កម្រៃក្រៅផ្លូវការ" ដែលធ្វើឲ្យខូចដល់ភាពស្អាតស្អំនៃប្រព័ន្ធ (IFDC2010; Theng 2012)។

វិធានការរឹតបន្តឹងលើបរិមាណជីអាចនាំចូលដោយស្របច្បាប់មកក្នុងប្រទេសកម្ពុជា កំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាពេលបច្ចុប្បន្នត្រឹម ៣០.០០០តោនក្នុងមួយឆ្នាំក្នុងមួយអាជ្ញាប័ណ្ណ បានដាក់កំហិតយ៉ាងខ្លាំងទៅលើផ្នែកផ្គត់ផ្គង់នៃទីផ្សារជីនៅកម្ពុជា។ កូតានាំចូលបានរាំងស្ទះដល់សេដ្ឋកិច្ចមាត្រដ្ឋាន និងជំរុញពាណិជ្ជកម្មឆ្លងកាត់ព្រំដែនជាមួយប្រទេសវៀតណាម និងថៃ ជាលក្ខណៈក្រៅផ្លូវការ និងគ្មានការត្រួតពិនិត្យ ហើយផលិតផលក្លែងក្លាយ និងផលិតផលមានគុណភាពទាប ក៏ហូរចូលមកពេញទីផ្សារក្នុងស្រុក តាមរយៈអ្នកនាំចូល និងឈ្មួញក្នុងស្រុក (Theng 2012)។

ចំណុចខ្វះខាតនៃទីផ្សារជីនៅកម្ពុជា គឺជាហេតុផលមួយទៀតនៃការហូរចូលផលិតផលក្លែងក្លាយជាច្រើនមកក្នុងខ្សែចង្វាក់ផ្គត់ផ្គង់។ គេប៉ាន់ស្មានថា ប្រហែល ១០% នៃជីបានយកមកប្រើក្នុងការដាំដំណាំនៅកម្ពុជា ជាជីមានការលាយបន្លំ ឬជីមិនត្រូវនឹងមុខដំណាំ។ ជារឿយៗ គេយកជីគុណភាពទាប ទៅច្រកក្នុងបាវមានស្លាកយីហោជីគុណភាពខ្ពស់។ ផលិតផលទាំងនេះជះឥទ្ធិពលអាក្រក់ទៅលើទិន្នផលស្រូវ និងបានប៉ះពាល់ដល់ជីវភាពរស់នៅរបស់កសិករតូចតាច ដែលបានរាយការណ៍ពីការបាត់បង់ចំណូលរហូតដល់ ២៨៥-២៥០ដុល្លារក្នុងមួយឆ្នាំ ដោយសារតែជីខ្វះគុណភាព។

ការរីកចម្រើនបច្ចេកទេសដាំដុះស្រូវ ក៏បាត់បង់ឥទ្ធិពលអស់មួយកម្រិតដោយសារលក្ខណៈនៃការផ្គត់ផ្គង់ និងតម្រូវការនៃទីផ្សារគ្រាប់ពូជ ធ្វើឲ្យគ្រាប់ពូជមានគុណភាពទាប និងផ្តល់ទិន្នផលទាប។ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មានគោលបំណងណែនាំបញ្ចូលពូជស្រូវមានទិន្នផលខ្ពស់ ១០មុខ ទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ប៉ុន្តែកសិករនៅតែចូលចិត្តប្រើពូជស្រូវដែលគាត់ស្គាល់ច្បាស់ថា គាត់អាចដាំដុះ និងលក់ចេញបាន។ បើទោះបីជាកសិករបានជ្រើសយកពូជស្រូវមានគុណភាពខ្ពស់ក្តី ក៏នៅមានឧបសគ្គជាច្រើនខាងផ្នែកផ្គត់ផ្គង់ដែលត្រូវដោះស្រាយ។ នាពេលបច្ចុប្បន្ន ការផ្គត់ផ្គង់ពូជស្រូវមានគុណភាពខ្ពស់ មានត្រឹមប្រមាណ ២០% នៃតម្រូវការប៉ុណ្ណោះ (CEFP 2011:2012)។

ចំណុចខ្វះខាតនៃទីផ្សារគ្រាប់ពូជនិងជី បានចោទកាន់តែធ្ងន់ធ្ងរទៀត ដោយសារសេវាផ្សព្វផ្សាយនៅអន់ខ្សោយ ដែលរាំងស្ទះដល់ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មទំនើបទៅដល់គ្រប់តំបន់ជនបទកម្ពុជា។ ការស្រាវជ្រាវកសិកម្ម និងការដាំដុះជាក់ស្តែងនាបច្ចុប្បន្ន វាមិនផ្សារភ្ជាប់គ្នាទេ។ ស្ថាប័នស្រាវជ្រាវនានាបានរកឃើញបច្ចេកទេសទំនើបៗជាច្រើនសម្រាប់ការដាំដុះស្រូវនៅកម្ពុជា ប៉ុន្តែស្ថាប័នសម្រាប់ពាំនាំចំណេះដឹងនេះទៅឲ្យថ្នាក់មូលដ្ឋានគឺពុំទាន់មានគ្រប់គ្រាន់ទេ។

ក្រៅពីចំណាយលើធាតុចូលនោះ ឧបសគ្គធំមួយទៀតដែលរារាំងវិនិយោគរបស់កសិករទៅលើផលិតកម្មស្រូវ គឺឥណទានមានតម្លៃខ្ពស់។ កន្លងមកមានសញ្ញាផ្លាស់ប្តូរខ្លះហើយនៅក្នុងរចនាសម្ព័ន្ធនៃទីផ្សារឥណទានជនបទ ដោយសារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) បានឈោងកាន់តែឆ្ងាយ និងកាន់តែសកម្មខ្លាំងឡើងនៅក្នុងតំបន់ជនបទ។ ទោះជាយ៉ាងនេះក្តី គ្រួសារភាគច្រើននៅតែទទួលបានឥណទានពីអ្នកចងការប្រាក់ក្រៅផ្លូវការដដែល (Kem 2012)។

មូលហេតុដែលអ្នកចងការប្រាក់ក្រៅផ្លូវការ នៅតែជាប្រភពសំខាន់នៃឥណទាននៅជនបទ ទោះបីពួកគេយកការប្រាក់ខ្ពស់ក្តី (៥% ក្នុងមួយខែ) គឺដោយសារគ្រួសារក្រីក្រងាយទៅទាក់ទងខ្ចីពួកគេ។ កម្ចីក្រៅផ្លូវការមានសកម្មភាពរស់រវើក និងចាក់ឫសជាប់ទៅក្នុងទំនាក់ទំនងសង្គម។ គ្រួសារ

នានាអាចរកវាបានយ៉ាងឆាប់រហ័ស នៅពេលជួបនឹងវិបត្តិធ្វើឲ្យបាត់បង់ធនធានហិរញ្ញវត្ថុ ហើយលក្ខខណ្ឌកម្ចីក៏អាចរៀបចំឲ្យស្របទៅតាមតម្រូវការដ៏ស្មុគស្មាញរបស់គ្រួសារងាយរងគ្រោះ។ ម្យ៉ាងវិញទៀត MFIs អាចរារែកក្នុងការផ្តល់កម្ចីដល់កសិករក្រីក្រ ដោយគេគិតថា មានហានិភ័យខ្ពស់ពេក និងផ្តល់ប្រាក់ចំណេញតិចពេក។ គ្រួសារក្រីក្រជាច្រើនក៏ខ្វះខាតទ្រព្យសម្រាប់ដាក់បញ្ចាំ ព្រោះពួកគេពុំមានដីធ្លី ឬពុំមានកម្មសិទ្ធិដីជាផ្លូវការ។ ទោះបីគ្រួសារនោះអាចបំពេញបានតាមការតម្រូវផ្សេងៗសម្រាប់កម្ចីពីស្ថាប័នហិរញ្ញវត្ថុក្តី ក៏អាត្រាការប្រាក់ខ្ពស់ដល់ ២,៥% ក្នុងមួយខែ គឺជាបន្ទុកយ៉ាងធំសម្រាប់កសិករតូចតាច។

ធាតុចូលថ្លៃខ្ពស់នាំឲ្យកសិករ មិនសូវមានទឹកចិត្តក្នុងការប្រើប្រាស់ឥណទានសម្រាប់ធ្វើវិនិយោគ ដែលធ្វើឲ្យពួកគេនៅតែជាប់ផុងធ្វើកសិកម្មបែបចិញ្ចឹមពោះ។ ដើម្បីអាចបានលទ្ធផលប្រសើរបំផុត ឥណទានមានការប្រាក់ទាប គួរមានគួបផ្សំដោយ ធាតុចូលកសិកម្មមានគុណភាពខ្ពស់ និងតម្លៃទាប និងមានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មគុណភាពខ្ពស់ជួយទ្រទ្រង់ផង។

## ៣. ការចែកចាយកម្មសិទ្ធិដីធ្លីដោយគ្មានប្រសិទ្ធភាព និងសមធម៌

កម្ពុជាមានអត្រាអវិសមភាពដីធ្លីស្ថិតក្នុងចំណោមអត្រាខ្ពស់ៗជាងគេក្នុងតំបន់ហើយកសិករជាច្រើនត្រូវរងគ្រោះដោយសារអសន្តិសុខក្នុងការកាន់កាប់ដី (SNEC 2007; Muller 2012)។ មានឯកសារជាច្រើនបញ្ជាក់ថា ការបែងចែកដីធ្លីដោយស្មើភាព និងកម្មសិទ្ធិដីធ្លីរឹងមាំ គឺជាគ្រឹះដ៏រឹងមាំនៃកំណើនសម្រាប់គ្រប់គ្នា (Lipton 2009)។ ដូច្នេះ បញ្ហាជុំវិញសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជាគឺជាឧបសគ្គដ៏ធំបំផុតដែលរារាំងកំណើនផលិតកម្មស្រូវ និងជាកត្តាចម្បងដែលនាំឲ្យមានភាពក្រីក្រ (Muller 2012)។

ក្នុងកសិកម្មប្រើពលកម្មច្រើន គេឃើញមានទំនាក់ទំនងបញ្ច្រាសរវាងទំហំដី នឹងផលិតភាព ពីព្រោះកសិដ្ឋានតូចៗអាចប្រើប្រាស់កម្លាំងពលកម្មបានល្អជាង ដូច្នេះហើយគេក៏ទទួលបានទិន្នផលស្រូវខ្ពស់ជាងកសិដ្ឋានធំៗ (Lipton 2009)។ ទំនាក់ទំនងបញ្ច្រាសនេះពិតជាត្រឹមត្រូវសម្រាប់ប្រទេសកម្ពុជា (Ngo and Chan 2010)។ ប៉ុន្តែនៅតាមតំបន់ដែលមានអវិសមភាពដីធ្លីខ្ពស់ ឧត្តមភាពផ្នែកទិន្នផលនេះពុំធ្វើឲ្យគ្រួសារម្ចាស់ដីតូចៗមានអតិរេកស្រូវអង្ករនោះទេ ព្រោះទំហំដីតូចវាមិនគ្រប់គ្រាន់សម្រាប់ដោះស្រាយតម្រូវការចិញ្ចឹមពោះរបស់គ្រួសារកសិករផង កុំថាឡើយដល់ទៅសល់ស្រូវសម្រាប់លក់ដូរ។

នាបច្ចុប្បន្ន ៥៥% នៃគ្រួសារនៅជនបទជួបកង្វះដីធ្លី ពោលគឺ ១៥% គ្មានដីសោះ និង ៤០% មានដីតិចជាង ១ហិកតា (រូបភាព ១)។ ការបែងចែកប្រសើរបំផុតនូវដីកសិកម្ម វានាំឲ្យមានការប្រើប្រាស់កម្លាំងល្អបំផុតនៅក្នុងសេដ្ឋកិច្ចនៃជនបទកម្ពុជា ហើយគេអាចសំគាល់បានតាមលក្ខណៈដែលគ្រួសារនានាមានដីធ្លីគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់កម្លាំងពលកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

រូបភាព ១៖ កម្មសិទ្ធិដីធ្លីក្នុងវិស័យកសិកម្មចំពោះគ្រួសារជនបទនៅកម្ពុជា




ប្រភព៖ CSES (2004-2011)

## ៤. ឧបសគ្គជាលក្ខណៈរចនាសម្ព័ន្ធនៃទីផ្សារស្រូវអង្កររបស់កសិករតូចតាច

ព័ត៌មានទទួលបានមិនស្មើភាពគ្នាក្នុងទីផ្សារស្រូវអង្ករនៅកម្ពុជា ឃើញមានតាំងពីខាងលើដល់ខាងក្រោមនៃខ្សែចង្វាក់បង្កើតតម្លៃ។ នៅថ្នាក់មូលដ្ឋានកសិករតូចតាចពឹងផ្អែកយ៉ាងខ្លាំងទៅលើឈ្មួញកណ្តាលមក ពីប្រទេសថៃ និងវៀតណាម ដើម្បីសម្រួលដល់សកម្មភាពពាណិជ្ជកម្ម។ ឈ្មួញកណ្តាលទាំងនេះអាចកំណត់ថ្លៃ និងតម្រូវការផលិតផលជាក់លាក់ណាមួយ ហើយតាមនេះអាចបង្កើតប្រាក់ចំណេញបានយ៉ាងច្រើនសម្រាប់ខ្លួនគេ (Gergely *et al.* 2010; JICA 2012. Chhim *et al.* 2013)។ រចនាសម្ព័ន្ធទីផ្សារបែបនេះមិនគួរឲ្យចង់បានសោះបើគិត ពីប្រសិទ្ធភាព និងសមធម៌។ កសិករម្ចាស់ដីតូចៗដែលចូលរួមជំរុញកំណើនតាមការបង្កើតអតិរេកស្រូវ តែងលក់ផលិតផលបានថោកជាងថ្លៃទីផ្សារ និងត្រូវប្រឈមនឹងតម្រូវការមិនច្បាស់លាស់ដែលកាត់បន្ថយទាំងវិនិយោគ និងផលិតភាព។ ប៉ុន្តែពាណិជ្ជករដែលស្វែងរកកម្រៃ (ដកយកតម្លៃចេញពីខ្សែចង្វាក់អង្ករដោយគ្មានចូលរួមអ្វីសោះក្នុងផលិតភាពអង្ករ) គឺបានទទួលផលប្រយោជន៍ច្រើនជាងកសិករ និងបានធ្វើឲ្យកើនចំណាយប្រតិបត្តិការនៅក្នុងទីផ្សារស្រូវអង្ករ (តារាង ១)។

តារាង ១៖ ខ្សែចង្វាក់តម្លៃអង្ករនៅរដូវវស្សា និងរដូវប្រាំង នៅខេត្តតាកែវ, ខែកុម្ភៈ ២០១២

| តួអង្គក្នុងខ្សែចង្វាក់តម្លៃ | ថ្លៃនៅរដូវវស្សា-កម្រិតបន្ថែមតម្លៃ (ដុល្លារ/តោន) | | ថ្លៃនៅរដូវប្រាំង-កម្រិតបន្ថែមតម្លៃ (ដុល្លារ/តោន) | |
|---|---|---|---|---|
| | USD | % | USD | % |
| ថ្លៃនៅកសិដ្ឋាន | 250 | 100 | 193 | 100 |
| អ្នកប្រមូលតាមភូមិ | 9.1 | 3.6 | 6.6 | 3.4 |
| ពាណិជ្ជករតាមភូមិ/មូលដ្ឋាន | 54.9 | 22 | 7.4 | 3.8 |
| ពាណិជ្ជករក្នុងតំបន់ | 40.0 | 16 | 10.0 | 5.2 |
| អ្នកកិនស្រូវថ្នាក់ខេត្ត | 375 | - | - | - |
| អ្នកនាំចេញអង្ករ | - | - | 14.5 | 7.5 |
| ពាណិជ្ជករវៀតណាម | - | - | 262.5 | - |

ប្រភព៖ Chhim *et al.* 2013

ដើម្បីដោះស្រាយភាពខ្វះចន្លោះក្នុងទីផ្សារនេះ កសិករតូចតាចត្រូវទទួលឲ្យបានគ្រប់គ្រាន់នូវព័ត៌មានទីផ្សារអំពីថ្លៃផលដំណាំ និងតម្រូវការ ដើម្បីអាចទទួលនូវថ្លៃទីផ្សារត្រឹមត្រូវសម្រាប់ផលិតផលរបស់ខ្លួន។ ជំហានផ្នែកគោលនយោបាយដ៏ជាក់លាក់មួយដែលអាចមានប្រយោជន៍ដល់កសិករតូចតាច គឺការបង្កើតមូលដ្ឋានទិន្នន័យមួយនៃថ្លៃផលិតផលភ្ជាប់នឹងគុណភាព ដែលបើកឲ្យសាធារណជនប្រើប្រាស់បាន (JICA 2012)។ ដើម្បីដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធ របៀបរបបស្ថាប័នថ្មីៗមួយចំនួនដែលកំពុងអនុវត្តសាកល្បងនៅក្នុងផលិតកម្មស្រូវអង្ករ នឹងអាចជួយបំបាត់ភាពលំអៀងមិនអំណោយផលដល់កសិករតូចតាច ដែលកំពុងឃើញមាននៅក្នុងទីផ្សារស្រូវអង្ករ។ យន្តការថ្មីមួយដែលកំពុងទាក់ទាញការយកចិត្តទុកដាក់ខ្លាំង គឺការធ្វើកសិកម្មតាមកិច្ចសន្យា ដែលគេតែងយល់ថា ផ្តល់ផលប្រយោជន៍ឲ្យកសិករតូចតាច ព្រោះវាលុបបំបាត់ភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងកិច្ចចរចារជាមួយឈ្មួញស្រូវអង្ករ។

ទោះជាមានចំណុចល្អដូចខាងលើក្តី ការធ្វើកសិកម្មតាមកិច្ចសន្យាមិនបានផ្តល់សិទ្ធិអំណាចគ្រប់គ្រាន់ដល់កសិករតូចតាចទេ។ កសិករមិនបានចូលរួមពិគ្រោះយោបល់នៅក្នុងការតាក់តែងលក្ខខណ្ឌនៃកិច្ចសន្យាទេ និងមានសិទ្ធិអំណាចតែមួយគត់ គឺយល់ស្របតាមលក្ខខណ្ឌរបស់គេ ឬមិនចូលរួមក្នុងកិច្ចសន្យានោះ។ កសិករមានសិទ្ធិអំណាចតិចតួចក្នុងការចរចាថ្លៃ ឬកំណត់ថាអ្វីជា "ផលិតផលមានគុណភាពល្អ" និងមានការយល់ច្រឡំជាញឹកញាប់ដោយសារតែលក្ខខណ្ឌស្មុគស្មាញ។ ជាលទ្ធផល កសិករជាច្រើនបានចាកចេញពីគម្រោងកិច្ចសន្យានេះ ដោយមិនឃើញមានអត្ថប្រយោជន៍អ្វីឡើយ (Nou and Heng 2013)។ ចំណុចខ្សោយនៅក្នុងរបៀបរបបធ្វើកសិកម្មតាមកិច្ចសន្យាសព្វថ្ងៃ គឺជាក់ស្តែងវាជាកិច្ចសន្យារវាងកសិករម្នាក់ៗ និងអ្នកម៉ៅការធំៗ។

## ៥. ការជ្រៀតចូលទៅក្នុងទីផ្សារអន្តរពិភពលោក

ដើម្បីប្រកួតប្រជែងក្នុងទីផ្សារពិភពលោក ត្រូវកសាងទំនុកចិត្តកម្រិតខ្ពស់ ដើម្បីអាចបំពេញបានតាមលក្ខខណ្ឌគុណភាពនិងបរិមាណរបស់អតិថិជន។ ប៉ុន្តែទោះបីមានអតិរេកអង្ករដល់ជាង ៤.៧លានតោនក្នុងឆ្នាំ២០១២ ក្តី ក៏កម្ពុជានៅតែមិនអាចប៉ាន់ដឹងជាមុនពី បរិមាណផលិតផលដែលមានគុណភាពដូចគ្នាសម្រាប់ការនាំចេញ។

ឧបសគ្គនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ផលិតអង្ករ ដែលធ្វើឲ្យផលិតផលមានគុណភាពប្រែប្រួល បានរារាំងអង្ករកម្ពុជាក្នុងការជ្រៀតចូលទៅក្នុងទីផ្សារសកល។ បន្ទាប់ពីប្រមូលផលរួច គេមិនបានសម្ងួត និងស្តុកស្រូវឲ្យបានសមស្របទេ ធ្វើឲ្យស្រូវមានសំណើមមិនស្មើគ្នា និង/ឬមានសំណើមខ្ពស់ ហើយនៅពេលកិនក៏បានដើមអង្ករតិច (បានចុងអង្ករច្រើន) (JICA 2012)។ ម្យ៉ាងទៀត ស្រូវពូជខុសៗគ្នាគេអាចដាក់លាយចូលគ្នាក្រោយពេលប្រមូលផល ដែលធ្វើឲ្យខូចដល់គុណភាពទូទៅនៃផលិតផល (Chhim *et al.* 2013)។

នាបច្ចុប្បន្ន សមត្ថភាពផលិតអង្ករមានកម្រិតទាប។ រោងម៉ាស៊ីនកិនស្រូវនៅកម្ពុជាអាចកិនបានត្រឹមតែ ២១%នៃអតិរេកស្រូវប៉ុណ្ណោះ ក្នុងនេះ ៧% កិនដោយរោងម៉ាស៊ីនប្រើប្រាស់បច្ចេកទេសទំនើបអាចផលិតអង្ករមានគុណភាពសម្រាប់នាំចេញ (តារាង ២; Gergely *et al.* 2010)។ ដូច្នេះសមត្ថភាពកិនត្រូវឈានធំៗទៅមុខ ប្រសិនបើចង់សម្រេចគោលដៅនាំចេញអង្ករ ១លានតោន ពោលគឺ ត្រូវបង្កើត ៩២ រោងម៉ាស៊ីនកិនស្រូវខ្នាតមធ្យម និង ១៨រោងម៉ាស៊ីនកិនខ្នាតធំថែមទៀត។

តារាង ២៖ សមត្ថភាពរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា

| ប្រភេទរោងម៉ាស៊ីនកិន | ចំនួនរោងម៉ាស៊ីនកិន | សមត្ថភាព (តោនស្រូវ/ ម៉ោង) | ចំនួនម៉ោងក្នុងមួយឆ្នាំ | សមត្ថភាពកិន (តោនស្រូវ/ឆ្នាំ) | សមត្ថភាពកិន (តោនអង្ករ/ឆ្នាំ) |
|---|---|---|---|---|---|
| ខ្នាតតូច | 200 | 1.5 | 2000 | 600000 | 372000 |
| ខ្នាតមធ្យម[Exp] | 12 | 5 | 2000 | 120000 | 74400 |
| ខ្នាតធំ[Exp] | 8 | 10 | 2200 | 176000 | 109120 |
| សរុប | | | | 896000 | 555520 |
| រោងម៉ាស៊ីនគុណភាពនាំចេញ[Exp] | | | | 296000 | 183520 |
| សមត្ថភាពកិន (% នៃអតិរេកស្រូវ) | | | | 21 | |
| សមត្ថភាពកិន (% នៃអតិរេកស្រូវ)[Exp] | | | | 7 | |

ប្រភព៖ Gergely *et al.* (2010)

សំគាល់៖ ស្រូវលើសនៅឆ្នាំ២០១១ មាន ៤,៣៤លានតោន ដោយមានអត្រារីបឡើងវិញជាមធ្យម ៦២% (MAFF 2012)។ [Exp] = រោងម៉ាស៊ីនកិនស្រូវ ផលិតអង្ករសម្រាប់នាំចេញ។

តម្លៃខ្ពស់នៃធាតុចូល សម្រាប់រោងម៉ាស៊ីនកិនស្រូវ នាំឲ្យផលិតផលកម្ពុជាមានថ្លៃខ្ពស់ មិនសូវមានកម្លាំងប្រកួតប្រជែងក្នុងទីផ្សារពិភពលោក និងបាត់ប្រាក់ចំណូលរបស់អ្នកកិនស្រូវ។ ធាតុផ្សំចម្បងៗនៅក្នុងបន្ទុកចំណាយកិនស្រូវ រួមមាន ថាមពលអគ្គិសនីបានពីបណ្ដាញជាតិមានថ្លៃខ្ពស់ និងមិនអាចទុកចិត្តបាន និងឥណទានមានតម្លៃខ្ពស់ តំណាងឲ្យ ៣២% និង ២៨% នៃបន្ទុកចំណាយសរុប។ ដើម្បីបំពេញតាមគោលដៅនាំចេញអង្ករ ១លានតោននៅឆ្នាំ២០១៥ នោះ រោងម៉ាស៊ីនកិនស្រូវកម្ពុជាត្រូវការទុន ៤៧០លានដុល្លារ សម្រាប់ទិញស្រូវ និង ២០០លានដុល្លារទៀតសម្រាប់ទុនបង្វិល (Gergely *et al.* 2010: 58)។

នៅពេលផលិតអង្ករបានហើយ នៅមានឧបសគ្គជាច្រើនទៀត ដើម្បីបញ្ជូនវាទៅទីផ្សារមានជាអាទិ៍ ចំណាយខ្ពស់លើការដឹកជញ្ជូនតាមផ្លូវគោក (១៥ដុល្លារ/តោន ពីរោងម៉ាស៊ីនកិនស្រូវទៅកំពង់ផែក្រុងព្រះសីហនុ) នីតិវិធីនាំចេញស្មុគស្មាញនិងមានតម្លៃខ្ពស់ និងការទារយកប្រាក់កម្រៃផ្លូវការ និងក្រៅផ្លូវការច្រើនបែបយ៉ាងដោយមន្ត្រីនានា។ យោងតាមបទបញ្ញត្តិផ្លូវការ កម្រៃត្រូវបង់គឺ ១០ដុល្លារ/តោន ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែង នៅពេលបូកទាំងចំណាយក្រៅផ្លូវការផងតួលេខឡើងដល់ ២០ដុល្លារ/តោន (Gergely *et al.* 2010)។

ក្នុងប៉ុន្មានឆ្នាំចុងក្រោយ មានការរីកចម្រើនគួរឱ្យកត់សំគាល់នៅក្នុងនីតិវិធីការិយាធិបតេយ្យទាក់ទងនឹងការនាំចេញ ដូចជា សេវាច្រកចេញចូលតែមួយ ជាដើម ដែលបានកាត់បន្ថយគួរឲ្យកត់សំគាល់នូវប្រាក់កម្រៃក្រៅផ្លូវការ និងថ្លៃផ្សេងៗទៀត គេទារយកពីក្រុមហ៊ុននៅពេលដឹកអង្ករឆ្លងកាត់ប្រទេសនិងព្រំដែន។ ទោះជាយ៉ាងនេះក្ដី កម្ពុជាត្រូវដើរវែងឆ្ងាយទៀតវិធីដើម្បីតាមទាន់ស្តង់ដារ និងនីតិវិធីអន្តរជាតិសម្រាប់ការនាំចេញអង្ករ។ ថ្លៃសេវាគយពិតប្រាកដសព្វថ្ងៃ ដែលស្មើនឹងពីរដងនៃតួលេខផ្លូវការបង្ហាញថា នៅមានការងារត្រូវធ្វើជាច្រើនទៀតដើម្បីកាត់បន្ថយចំណាយសរុបដោយសារអំពើពុករលួយក្នុងចំណោមស្ថាប័នត្រួតពិនិត្យផ្សេងៗ។

## ៦. គោលនយោបាយនាបច្ចុប្បន្ន និងទៅអនាគត

អត្ថបទនេះបានបង្ហាញថា មានចំណុចខ្វះខាតជាច្រើនក្នុងរចនាសម្ព័ន្ធទីផ្សារទាក់ទងនឹងផលិតកម្មស្រូវ ដូចជា ទីផ្សារធាតុចូល ទីផ្សារឥណទាន និងទីផ្សារស្រូវអង្ករផ្ទាល់ ដែលបានកាត់បន្ថយកំណើនវិនិយោគ និងផលិតភាពផ្នែកស្រូវអង្ករ។ ដើម្បីបំបាត់ឧបសគ្គបច្ចុប្បន្នក្នុងការបង្កើនផលិតកម្មស្រូវ និងដោះស្រាយចំណុចខ្វះខាតផ្សេងៗផ្នែកស្ថាប័ន និងក្របខ័ណ្ឌនយោបាយ រដ្ឋាភិបាលគួរអនុវត្តនូវជម្រើសគោលនយោបាយមួយចំនួនដូចតទៅ៖

១. លើកកម្ពស់សមាហរណកម្មតាមខ្សែឈរ តាមរយៈ ការផ្តល់គ្រាប់ពូជគុណភាពល្អ ការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេស ការផ្តល់ជីនិងឥណទាន ដើម្បីឲ្យផលិតផលមានគុណភាពកាន់តែល្អសម្រាប់ការនាំចេញ ហើយលក់បានថ្លៃកាន់តែខ្ពស់ចំណេញដល់ផលិតករ។

២. លើកកម្ពស់ចំណងទាក់ទងតាមខ្សែដេក ក្នុងនេះ អង្គការកសិករ និងគម្រោងធ្វើកសិកម្មតាមកិច្ចសន្យា អាចបង្កើនអំណាចតថ្លៃរបស់កសិករ ផ្តល់អត្ថប្រយោជន៍សម្រាប់កសិករតូចតាចក្រីក្រ និងធានានូវស្ថិរភាពទាំងផ្នែកបរិមាណ និងផ្នែកគុណភាពផលិតផលសម្រាប់ការនាំចេញ។

៣. ពង្រឹងការសម្របសម្រួលរវាងក្រសួងនិងស្ថាប័នផ្សេងៗ ដោយធ្វើឲ្យសាមញ្ញនូវនីតិវិធីរដ្ឋបាល ដូចជាតាមការបង្កើតសេវាច្រកចេញចូលតែមួយ ជាដើម ដែលនឹងលើកទឹកចិត្តឲ្យមានការវិនិយោគកាន់តែច្រើនទៅលើការកែច្នៃម្ហូបអាហារ និងការនាំចេញផលិតផលកែច្នៃ។

៤. ប្រែក្លាយពាណិជ្ជកម្មក្រៅផ្លូវការ ឲ្យទៅជាពាណិជ្ជកម្មផ្លូវការដោយពង្រឹងឧស្សាហកម្មកែច្នៃស្រូវអង្ករ តាមរយៈប្រព័ន្ធជួយទ្រទ្រង់ហិរញ្ញវត្ថុ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើឲ្យមានបរិយាកាសកាន់តែអំណោយផលឡើងសម្រាប់អាជីវកម្មផ្សេងៗ។

៥. កែសម្រួលគោលនយោបាយគ្រប់គ្រងដីធ្លី ដើម្បីឲ្យប្រជាពលរដ្ឋក្រីក្រ កសិករតូចតាច និងជនជាតិភាគតិចនានា ទទួលបានផលប្រយោជន៍ដោយផ្ទាល់កាន់តែច្រើនឡើង។

# ឯកសារយោង

CDRI (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities* (Phnom Penh: CDRI)

CEFP,ChantiersEcoles de Formation Professionnelle(2011), *Review Report on the Implementation of the Policy Paper on the Promotion of Paddy Production and Rice Export* (Phnom Penh: CEFP)

Chhim Chhun, Theng Vuthy and Nou Keosothea (2013), "Case Study: Rice Marketing Value Chains in Takeo Province"'*Cambodia Development Review*, 17(2), pp.9-14

CSES (2011), *Cambodia Socio-Economic Survey 2011* (Phnom Penh: NIS/MOP)

Gergely, N., P. Baris and C. Meas (2010), *An Economic Survey of Rice Sector in Cambodia* (Phnom Penh: AFD, SNEC and GIG Consultants)

IFDC, International Fertilizer Development Center(2010), *Rapid Appraisal of Fertilizer Quality in Cambodia* (Phnom Penh: IFDC/World Bank)

JICA, Japan International Cooperation Agency (2012), *Data Collection Survey on Selecting the Processed Foods to be Focused on the Promoting Foreign Direct Investment in the Food Business in the Kingdom of Cambodia* (Phnom Penh: JICA/MAFF)

Kem Sothorn (2012), "Credit for Rice Farmers: A Study in Takeo Province", *Cambodia Development Review*, 16(3), pp. 6-10

Lipton, M. (2009), *Land Reform in Developing Countries: Property Rights and Property Wrongs* (London: Routledge)

MAFF (2013), *Ministry of Agriculture Forestry and Fisheries Report 2012-2013* (Phnom Penh: MAFF)

Muller (2012), *Commune-Based Land Allocation for Poverty Reduction in Cambodia*(Washington, DC: World Bank)

Ngo Sothath and Chan Sophal (2010), *Does Large Scale Agricultural Investment Benefit the Poor? Research Report 2* (Phnom Penh: Cambodia Economic Association)

NIS (2008), *Statistical Year Book of Cambodia 2008*(Phnom Penh: NIS/MOP)

Nou Keosothea and Heng Molyaneth (2013), "Making Rice Contract Farming Work for Smallholders and Agribusiness", *Cambodia Development Review*, 17(3) (forthcoming)

RGC (2013), *Rectangular Strategy-Phase III 2014-2018* (Phnom Penh: RGC)

SNEC, Supreme National Economic Council (2007), *The Report of Land and Human Development in Cambodia,* available at http://www.un.org.kh/undp/media/files/DiscussionPaper5_LandandHumanDevelopment2007.eng.pdf (accessed 10 Jan 2013)

Theng Vuthy (2012), "Fertiliser Value Chain in Cambodia: A Case Study in Takeo Province", *Cambodia Development Review*,16(4), pp. 5-9

-៧-

# ឧស្សាហកម្មជីនៅកម្ពុជាៈ និន្នាការ បញ្ហាប្រឈម និងឱកាស

*ដោយបណ្ឌិត ថេង វុទ្ធី និង ខៀវ ភិរម្យ*[១]

## ១. សេចក្តីផ្តើម

កំណើនកសិកម្មមានជាមធ្យមប្រហែល ៤,៦% ក្នុងអំឡុងឆ្នាំ១៩៩៤ ដល់ ២០១០ (NIS 2011)។ ផលិតកម្មកសិកម្មកើនឡើងជាសំខាន់ដោយសារ ទិន្នផលស្រូវដែលបានកើនឡើងជាង មួយជាពីរ ពី ១៣៦០គីឡូក្រាម/ហិកតា នៅឆ្នាំ១៩៩០ ដល់ ៣១០០គីឡូក្រាមនៅឆ្នាំ២០១២ (NIS 2008; MAFF 2013)។ ការផ្លាស់ប្តូរដ៏គួរឱ្យចាប់អារម្មណ៍នេះ បណ្តាលជាចម្បងមកពី កំណើន ការប្រើប្រាស់ជីគីមី ការប្រើពូជស្រូវល្អៗ និងប្រព័ន្ធធារាសាស្ត្រកាន់តែប្រសើរឡើង (Yu និង Fan 2009)។ ការផ្គត់ផ្គង់ជីកើនឡើងយ៉ាងឆាប់រហ័ស ដើម្បីឆ្លើយតបនឹងតម្រូវការដាំដំណាំតាមបែប ប្រពលវប្បកម្ម។ ឧទាហរណ៍នៅឆ្នាំ២០០២ មានការនាំចូលជី NPK ប្រហែល ១៣៧.៨៧៧តោន ធៀបនឹង ៤៣៣.១២០តោននៅឆ្នាំ២០១១ ដែលបង្ហាញពីកំណើនតម្រូវការដល់ ២១០% ក្នុងរយៈ ពេល១០ឆ្នាំ។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ការឡើងថ្លៃជីបានរារាំងកសិករក្នុងការប្រើជីឲ្យ បានដូច ការណែនាំ ដោយកសិករប្រមាណ ៧៩% រាយការណ៍ថា មូលហេតុចម្បងនៃការប្រើជីមិន គ្រប់គ្រាន់ គឺបញ្ហាហិរញ្ញវត្ថុ (Lim 2006)។ ម្យ៉ាងទៀត វត្តមានជីគុណភាពអន់ធ្វើឱ្យកសិករជាច្រើន បាត់ទំនុកចិត្តលើទីផ្សារ ហើយក៏ឈប់ប្រើជីតែម្តង (Schamel and Hongen 2003)។ ដោយសារ ជីដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ផលិតភាពដំណាំនិងសន្តិសុខស្បៀង គេគួរពិនិត្យឡើងវិញ អំពីរចនាសម្ព័ន្ធឧស្សាហកម្មជី និន្នាការប្រើប្រាស់ជី ឧបសគ្គសំខាន់ៗរារាំងតម្រូវការនិងការផ្គត់ផ្គង់ គោលនយោបាយ និងបទប្បញ្ញត្តិផ្នែកបរិស្ថាន ដែលជះឥទ្ធិពលទៅលើទីផ្សារ និងការប្រើប្រាស់ជី ក៏ដូចជា អន្តរាគមន៍ផ្សេងៗដែលអាចធ្វើទៅបានដើម្បីកែលំអ។

## ២. រចនាសម្ព័ន្ធឧស្សាហកម្មជី

### ២.១. សារតារ

ពីឆ្នាំ១៩៧៩ ដល់ ១៩៩៣ រដ្ឋាភិបាលទទួលខុសត្រូវលើការនាំចូលនិងចែកចាយសារ ធាតុគីមីកសិកម្មភាគច្រើន ជាពិសេស ជីនិងថ្នាំសម្លាប់សត្វចង្រៃ។ ក្នុងអំឡុងពេលវៀតណាម កាន់កាប់ពីឆ្នាំ១៩៨០ ដល់ ១៩៨៩ មានការនាំចូលជីពីប្រទេសវៀតណាម ប្រមាណ ៣៥-៤០ពាន់ តោន/ឆ្នាំ ។ ពីឆ្នាំ១៩៩៣ ដល់ ២០០០ ក្រុមហ៊ុន Agricultural Inputs Company (AIC) ដែលជាក្រុមហ៊ុនរដ្ឋស្ថិតក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បាននាំចូល

---

១ រៀបរៀងដោយបណ្ឌិត ថេង វុទ្ធី ជាអ្នកស្រាវជ្រាវ និងសម្របសម្រួលកម្មវិធី និង ខៀវ ភិរម្យ ជាអ្នកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI។ អត្ថបទនេះបង្ហាញពីមុខងារឯកសារសម្រាប់គម្រោង "ការអភិវឌ្ឍឧស្សាហកម្មជីនៅកម្ពុជា" ផ្តល់ហិរញ្ញប្បទានដោយ IFPRI/USAID។ ទស្សនៈទាំងឡាយនៅក្នុងអត្ថបទនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ CDRI ឬ USAID ទេ។ អ្នកនិពន្ធក៏បានទទួលស្គាល់ USAID និង CDRI សម្រាប់ការគាំទ្ររបស់គាត់លើការសិក្សានេះ។

និងចែកចាយជីប្រភេទផ្សេងៗចំនួន ១៣១.៤២៤តោន និង ថ្នាំសម្លាប់សត្វចង្រៃ ៨៩.៣៥៣តោន (ACI 2002)។ ចាប់ពីឆ្នាំ១៩៩៦ វិស័យឯកជនបានទទួលខុសត្រូវជាសំខាន់លើការនាំចូលជី ដែលជាទូទៅគេឃើញថា មានប្រសិទ្ធភាពល្អក្នុងការផ្គត់ផ្គង់ជីអសរីរាង្គទាំងចំពោះបរិមាណ ប្រភេទ ថ្លៃ និងលទ្ធភាពអាចរកទិញបាន (Young & Raab, 2000:14)។

## ២.២. និន្នាការនៃការផ្គត់ផ្គង់

ការផ្គត់ផ្គង់ជីមាននិន្នាការកើនឡើងយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារគោលនយោបាយស្រូវ ដែលសំដៅបង្កើនផលិតកម្មស្រូវតាមការធ្វើប្រពលវប្បកម្ម (RGC 2010)។ គោលនយោបាយស្រូវ ដែលចាប់អនុវត្តតាំងពីពាក់កណ្តាលឆ្នាំ២០១០ មក ធ្វើឱ្យកម្ពុជាត្រូវនាំចូលជីកើនមួយជាពីរដល់ ៤៣៣.១២០តោននៅឆ្នាំ២០១១។ ជីប្រភេទផ្សេងៗបាននាំចូលមក ក្នុងទម្រង់ជាជីទោល ឬជីមានលាយសារធាតុចិញ្ចឹមច្រើនមុខ ដូចជា NP ឬ NPK។ អ្នកផ្គត់ផ្គង់ជីចម្បងៗមកកម្ពុជា រួមមាន ប្រទេសថៃដែលមានចំណែក ៣៥%នៃជីនាំចូលសរុប និងវៀតណាមដែលមានដល់ ៦៥ % ហើយពាណិជ្ជកម្មជាមួយវៀតណាមរំពឹងថានឹងកើនឡើងក្នុងប៉ុន្មានឆ្នាំខាងមុខនេះទៀត (IFDC 2010)។

## ២.៣. តួនាទីរដ្ឋាភិបាល

រដ្ឋាភិបាលមិនមានគោលនយោបាយផ្តល់ឧបត្ថម្ភធន លើការផ្គត់ផ្គង់ជីនោះទេ ប៉ុន្តែមានច្បាប់ផ្តល់នូវការលើកទឹកចិត្ត ដើម្បីគាំទ្រដល់ការផ្គត់ផ្គង់ធាតុចូលកសិកម្ម រួមទាំងជីផងដែរ។ គោលនយោបាយរដ្ឋាភិបាលមួយចំនួនទៀត ដូចជាគោលនយោបាយស្រូវ (RGC 2010) ជាដើម ក៏សំដៅជំរុញការផ្គត់ផ្គង់ធាតុចូលកសិកម្មផងដែរ តាមការជួយសម្រួលនីតិវិធីនាំចូល ស្រូវពូជ ជីធាតុចូលកសិកម្ម និងគ្រឿងចក្រ និងដោយបន្តផ្តល់នូវការលើកទឹកចិត្តខាងពន្ធ (ពន្ធអត្រាសូន្យ) លើការនាំចូលវត្ថុធាតុដើម និងបរិក្ខារផ្សេងៗ។ ក្រសួងកសិកម្មដែលទទួលបន្ទុកត្រួតពិនិត្យការនាំចូលធាតុចូលកសិកម្ម បានគ្រប់គ្រងលើពាណិជ្ជកម្មជី តាមការផ្តល់អាជ្ញាប័ណ្ណដល់គ្រប់ក្រុមហ៊ុនជាប់ពាក់ព័ន្ធ។

## ២.៤. រចនាសម្ព័ន្ធឧស្សាហកម្មជី

នៅកម្ពុជាមិនមានរោងចក្រផលិតជីទេ ប៉ុន្តែមានរោងចក្រលាយជីមួយក្នុងខេត្តកណ្តាល ដែលបានចាប់ដំណើរការតាំងពីដើមឆ្នាំ២០១៣។ ក្នុងដំណាក់កាលចាប់ដំណើរការដំបូង រោងចក្រនេះអាចលាយជី NPK ប្រមាណ ៣៥០.០០០តោនក្នុងមួយឆ្នាំ ហើយនៅពេលមានសមត្ថភាពពេញលេញ អាចលាយបានប្រហែល ៥០០.០០០តោនក្នុងមួយឆ្នាំ។ ទោះជាយ៉ាងនេះក្តី គេប៉ាន់ស្មានថា កម្ពុជាត្រូវការជីប្រហែល ៦១៧.០០០តោនក្នុងមួយឆ្នាំ សម្រាប់ដីស្រែ ៤,១លានហិកតា។ ដូច្នេះ ផលិតកម្មក្នុងស្រុកនៅមិនទាន់បំពេញបាន តាមតម្រូវការទីផ្សារក្នុងស្រុកទេ។

រដ្ឋាភិបាលមិនមានគោលនយោបាយគាំពារនិយម ដែលហាមឃាត់ការនាំចូល ដើម្បីការពារផលិតករក្នុងស្រុកនោះទេ។ ផ្ទុយទៅវិញ រដ្ឋាភិបាលបានជួយជំរុញទីផ្សារសេរី ដោយយកពន្ធនាំចូលមានអត្រាសូន្យលើការនាំចូលធាតុចូលកសិកម្ម។ ដូច្នេះ ផលិតករក្នុងស្រុក និងអ្នកនាំចូល ដើរតួនាទីស្មើគ្នានៅក្នុងទីផ្សារសេរី និងប្រកួតប្រជែងគ្នានៅគ្រប់កម្រិតនៃខ្សែចង្វាក់ចែកចាយជី តាំងពីផលិតករ អ្នកនាំចូល និងអ្នកលក់រាយនៅតាមភូមិ។

## ២.៥. អង្គភាពនាំចូល

អ្នកនាំចូលសម្ភារៈកសិឧស្សាហកម្មគីមីទាំងអស់ ត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម សម្រាប់ប្រតិបត្តិការអាជីវកម្ម និងការបង់ពន្ធ និងបន្ទាប់មក ត្រូវចុះបញ្ជីនៅក្រសួងកសិកម្ម ដើម្បីបានអាជ្ញាប័ណ្ណនាំចូលសម្ភារៈកសិឧស្សាហកម្មគីមី ដូចជា ជី និងថ្នាំសម្លាប់សត្វចង្រៃ ជាដើម។ ដំណើរការផ្តល់អាជ្ញាប័ណ្ណចំណាយពេលអស់ពី ៤-១២សប្តាហ៍ ហើយត្រូវបង់ថ្លៃសេវាផ្លូវការអស់ ១៥០ដុល្លារ។ ដើម្បីឱ្យដំណើរការរលូនល្អឆ្លងកាត់ការិយាល័យទាំង ៨ នៃក្រសួងកសិកម្មដែលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាប័ណ្ណនាំចូល អ្នកនាំចូលភាគច្រើនតែងស្វែងរកអ្នកសម្របសម្រួល ហើយមានរបាយការណ៍បង្ហាញថា មានការបង់ថ្លៃសេវាក្រៅផ្លូវការជាច្រើនទៀត (IFDC 2010)។ ក្រសួងកសិកម្មអាចកែសម្រួលចំនួនតោនសុំនាំចូលក្នុងអាជ្ញាប័ណ្ណ ដែលមានលក្ខណៈស្រដៀងគ្នានឹងប្រព័ន្ធកូតាដែរ ព្រោះមានការដាក់កម្រិតអតិបរមាត្រឹម ៣០.០០០តោនសម្រាប់ផលិតផលមួយមុខ ឬច្រើនមុខ ក្នុងមួយអាជ្ញាប័ណ្ណ។ នៅឆ្នាំ២០០៩ មានក្រុមហ៊ុននាំចូលជីបានចុះបញ្ជីប្រហែល ២០ក្រុមហ៊ុន ប៉ុន្តែមានតែ ៦ក្រុមហ៊ុនប៉ុណ្ណោះដែលសកម្មជាងគេ (IFCD 2010)។

## ៣. បញ្ហាចោទខាងផ្នែកតម្រូវការ

## ៣.១. និន្នាការនៃការប្រើប្រាស់

ការប្រើប្រាស់ជីនៅរដូវវស្សាមាននិន្នាការកើនឡើងជាលំដាប់ លើកលែងតែក្នុងឆ្នាំ២០០៨ ដែលមានការធ្លាក់ចុះ និងក្នុងឆ្នាំ២០០៩ ដែលវាកើនខ្ពស់បំផុតដល់ ២៦៧.៨៥០តោន។ ការធ្លាក់ចុះក្នុងឆ្នាំ២០០៨ បណ្តាលចេញពី ការឡើងថ្លៃជីយ៉ាងគំហុក ហើយការប្រើប្រាស់ជីច្រើនក្នុងឆ្នាំ២០០៩ អាចបណ្តាលចេញពីការធ្លាក់ចុះថ្លៃជី ធ្វើឱ្យកសិករអាចបង្កើនការប្រើប្រាស់បាន។ ការប្រើប្រាស់ជីនៅរដូវប្រាំងប្រែប្រួលពី ៧៥.០០០តោន ដល់ ជាង ៨០.០០០តោនក្នុងមួយឆ្នាំ លើកលែងតែនៅឆ្នាំ២០០៩ ដែលការប្រើប្រាស់សរុបបានធ្លាក់ចុះដល់ប្រហែល ៦៥.០០០តោន។ ជារួម ការប្រើប្រាស់ជីបានកើនឡើងសម្រាប់ដំណាំគ្រប់មុខ ហើយវាកើនយឺតៗក្នុងបីឆ្នាំចុងក្រោយនេះ ដោយសារជីឡើងថ្លៃខ្ពស់។

រូបភាព ១៖ និន្នាការក្នុងការប្រើប្រាស់ជី ឆ្នាំ២០០៧-២០១១ (តោន)




ប្រភព៖ ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយផ្អែកលើ CSES 2007-2011 (sampling weight applied)

### ៣.២. ការប្រើប្រាស់តាមមុខដំណាំ

បរិមាណជីប្រើប្រាស់ក្នុងមួយហិកតាស្រូវប្រាំង(១៥០-២០០គ.ក/ហ.ត) និងបន្លែ (២០០-៣០០គ.ក/ហ.ត) មានកម្រិតខ្ពស់បំផុតក្នុងចំណោមមុខដំណាំទាំងអស់ ដោយសារស្រូវប្រាំង និងបន្លែផ្តល់ប្រាក់ចំណូលយ៉ាង–គួរឲ្យកត់សំគាល់។ កសិករដាំស្រូវវស្សា ប្រើជីប្រមាណ១០០គ.ក ក្នុងមួយហិកតា។ ជាទូទៅការប្រើប្រាស់ជីក្នុងមួយហិកតាលើគ្រប់មុខដំណាំ វាប្រែប្រួលទៅតាមថ្លៃជី។ ចំណុចនេះបង្ហាញថា ថ្លៃជីជាកត្តាកំណត់សំខាន់នៃការប្រើប្រាស់ជី ហើយបញ្ជាក់គាំទ្រដល់លទ្ធផលរកឃើញក្នុងអង្កេតពីមុនដែលក្នុងនោះ កសិករ ៧៩%បានរាយការណ៍ថា ពួកគេបានកាត់បន្ថយចំនួនជីប្រើប្រាស់ ដោយសារជីឡើងថ្លៃ(Lim 2006)។ គួរកត់សំគាល់ថា ស្រូវប្រាំងត្រូវការជីច្រើនជាងស្រូវវស្សា ហើយកសិករប្រមាណ៩០% ប្រើប្រាស់ជីនៅរដូវប្រាំង។

### ៣.៣. ឧបសគ្គចម្បងៗប៉ះពាល់ដល់ការប្រើប្រាស់ជី

**បញ្ហាថ្លៃជី៖** ថ្លៃជីជាកត្តាមួយដ៏សំខាន់ដែលរារាំងដល់ការប្រើជីដែលមានចំណែករហូតដល់ ៣៧%នៃចំណាយសរុបសម្រាប់ស្រូវប្រាំង និង ២១% សម្រាប់ស្រូវវស្សា ឬ ប្រហែល១៥% នៃតម្លៃស្រូវប្រមូលផលបាន (Chhun *et al.* 2013; Ovesen *et al.* 2012)។ នៅឆ្នាំ២០០៨ ជីអ៊ុយរ៉េបានឡើងថ្លៃយ៉ាងខ្លាំងដល់ប្រហែល ៤០ដុល្លារក្នុងមួយបាវ៥០គ.ក ដែលកាលពីឆ្នាំ២០០៧ ថ្លៃតែ១៨ដុល្លារប៉ុណ្ណោះ ចំណែកឯជី DAP ឡើងថ្លៃរហូតដល់ ៦០ដុល្លារក្នុងមួយបាវ៥០គ.ក ដែលកាលពីមួយឆ្នាំមុន ថ្លៃត្រឹមតែ ២៥ដុល្លារ។ ថ្លៃឡើងខ្ពស់ដល់កំពូលបែបនេះ ធ្វើឲ្យជីគ្រប់ប្រភេទថ្លៃហួសលទ្ធភាពប្រើប្រាស់របស់កសិករតូចតាចភាគច្រើន ហើយប្រាក់ចំណូលបានពីការប្រើជីក៏ក្លាយជាអវិជ្ជមាន ។

**ការទទួលបានឥណទាន៖** តាមធម្មតាកសិករតែងមានសល់ប្រាក់ខ្លះនៅដើមរដូវប្រាំង ទុកសម្រាប់ទិញជីដាក់ដំណាំរដូវប្រាំង។ ដូច្នេះ ការទិញជីសម្រាប់ស្រូវវស្សា អាស្រ័យជាសំខាន់លើឥណទានដែលអាចរកបាន។ នៅតំបន់ជនបទភាគច្រើន សព្វថ្ងៃមានសេវាមីក្រូហិរញ្ញវត្ថុ ប៉ុន្តែកសិករក្រីក្រមិនមានលទ្ធភាពប្រើប្រាស់សេវានេះទេ (Kem 2012; Ovesen 2012)។មីក្រូហិរញ្ញវត្ថុមានអត្រាការប្រាក់ពី ២,៥-៣%ក្នុងមួយខែ ដែលជាបន្ទុកដ៏ធ្ងន់សម្រាប់កសិករតូចតាច។

**ការធានាគុណភាព៖** ការវិភាគសារធាតុចិញ្ចឹមបង្ហាញថា ជី NP និង NPK ភាគច្រើនដែលលក់នៅទីផ្សារ មានគុណភាពទាបខ្លាំងជាង សន្ទស្សន៍គុណភាពអាចទទួលយកបាន (IFDC 2010)។ មូលហេតុចម្បងគឺ ជីមានចូលមេរោគឬកើតផ្សិត ជីមានគេប៉ះពាល់ធ្វើឲ្យខូចគុណភាព និងជីបានប្តូរចេញ និងជំនួសដោយជីគុណភាពអន់លាយគ្នាជាមួយជីមានគុណភាពខ្ពស់។ ការអនុវត្តមិនល្អតែងឃើញមានជាទូទៅមួយទៀតក្នុងវិស័យជី គឺការច្រកជីគុណភាពអន់ ទៅក្នុងបាវមានស្លាកសញ្ញាជីគុណភាពខ្ពស់ ហើយលក់ចេញជាជីមានគុណភាពខ្ពស់។ ការសិក្សារបស់ CDRI នៅខេត្តតាកែវបង្ហាញថា កសិករប្រមាណ ១០%បានទិញជីមានគុណភាពទាប បណ្តាលឱ្យខាតបង់ទិន្នផលធ្ងន់ធ្ងររហូតដល់ ២៨៥-៣៥០ដុល្លារក្នុងកសិករម្នាក់(Theng 2012)។

**សេវាផ្សព្វផ្សាយបច្ចេកទេស៖** កសិករកម្ពុជាតិចនាក់ណាស់ដែលយល់ដឹងពីការប្រើប្រាស់ជីគីមីឲ្យមានប្រសិទ្ធិភាព ហើយភាគច្រើនបានរៀនសូត្រតាមរយៈសេវាសាធារណៈផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងកម្មវិធីអង្គការមិនមែនរដ្ឋាភិបាល និងតាមរយៈទិន្នផលដំណាំឆ្នាំមុនៗរបស់ខ្លួន។ កសិករកម្ពុជាដែលមិនបានដឹងពីការប្រើប្រាស់ជីឱ្យបានត្រឹមត្រូវ និងមិនសូវចេះអក្សរដើម្បី

អានស្លាកសញ្ញាលើបាវជី ពួកគេត្រូវខាតបង់ប្រាក់កាស និងដាំដំណាំមិនសូវបានផល។ កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មមានថវិកាមិនគ្រប់គ្រាន់ បានបង្កនូវ កង្វះខាតមន្ត្រីផ្សព្វផ្សាយបច្ចេកទេសដែលមានការបណ្តុះបណ្តាលនិងបទពិសោធន៍ និងជំនួយគាំទ្រ និងការផ្ទេរបច្ចេកវិទ្យាកសិកម្មមិនគ្រប់គ្រាន់។

សរុបមក ជីថ្លៃខ្ពស់ ជីគុណភាពអន់ ឥណទានមានការប្រាក់ខ្ពស់ និងសេវាផ្សព្វផ្សាយបច្ចេកទេសមិនគ្រប់គ្រាន់ ជាក្តីបារម្ភ និងកត្តាចម្បងៗដែលរារាំងកំណើនផលិតភាពកសិកម្មរបស់កសិករក្រីក្រមួយចំនួននៅកម្ពុជា។ ប្រព័ន្ធធារាសាស្ត្រមិនគ្រប់គ្រាន់ និង កង្វះទឹកក៏បង្អាក់ទឹកចិត្តកសិករស្វែងរកឥណទានមកទិញជីដើម្បីកែលំអការដាំដុះរបស់ខ្លួនដែរ។

## ៤. បញ្ហាចោទខាងផ្នែកផ្គត់ផ្គង់

### ៤.១. ខ្សែចង្វាក់ផ្គត់ផ្គង់ជី

**ច្រកទីផ្សារ៖** រចនាសម្ព័ន្ធទីផ្សារមានរៀបចំយ៉ាងល្អដោយមានបណ្តាញអ្នកនាំចូល អ្នកចែកចាយ/អ្នកលក់ដុំតាមខេត្តនិងអ្នកលក់រាយតាមខេត្តស្រុកភូមិ។ទីផ្សារនេះនាំមុខដោយវិស័យឯកជនដែលធ្វើប្រតិបត្តិការមានការប្រកួតប្រជែងខ្លាំង និងមានថ្លៃកំណត់ដោយកម្លាំងទីផ្សារ។ អ្នកនាំចូលកម្ពុជាដែលមានអាជ្ញាប័ណ្ណ តែងនាំចូលនិងស្តុកជីក្នុងឃ្លាំងនៅជិតព្រំដែន (ប្រទេសថៃ និងវៀតណាម) និង/ឬ នៅក្រុងភ្នំពេញ និងមានអ្នកចែកចាយធ្វើការដឹកជញ្ជូនផលិតផលទៅលក់រាយនៅឯទីក្រុងធំៗតាមខេត្ត (IFDC 2010) ។

នៅតាមជនបទ កន្លែងលក់រាយតាមធម្មតាជាហាងលក់ធាតុចូលកសិកម្មគ្រប់មុខ ដូចជា ជី ចំណីសត្វ ថ្នាំសម្លាប់សត្វចង្រៃ គ្រាប់ពូជ និងប្រេងឥន្ធនៈ។ពាណិជ្ជករទាំងអស់ដែលលក់ផលិតផលគីមីកសិកម្ម ត្រូវចុះបញ្ជីនៅការិយាល័យនីតិកម្មកសិកម្មនៃមន្ទីរកសិកម្មខេត្តជារៀងរាល់ឆ្នាំ បើមិនដូច្នេះទេ សកម្មភាពអាជីវកម្មនឹងក្លាយជាខុសច្បាប់។

**ការវិភាគខ្សែចង្វាក់តម្លៃ៖** ការវិភាគខ្សែសង្វាក់តម្លៃបង្ហាញថា អត្រាចំណេញរបស់ឈ្មួញក្រៅពីអ្នកនាំចូល គឺមានកម្រិតទាបត្រឹមពី ២-៤% ចំណែកឯក្រុមហ៊ុននាំចូលមានប្រហែល ៦% (IFDC 2010; Theng 2012) ។ បើគិតបញ្ចូលទាំងចំណាយប្រតិបត្តិការផង ប្រាក់ចំណេញសម្រាប់ឈ្មួញនៅថ្នាក់ភូមិ ឃុំ ស្រុក ខេត្ត មានកម្រិតទាបណាស់ ហើយតម្លៃបន្ថែមភាគច្រើនក្រៅពីរបស់រោងចក្រផលិតជី គឺបានទៅលើអ្នកនាំចូល។

ការវិភាគខាងលើបង្ហាញថា ទីផ្សារជីមានការប្រកួតប្រជែងខ្លាំង រវាងពួកឈ្មួញដើម្បីទទួលបានប្រាក់ចំណេញឯកតាបន្ថែមបន្តពីអ្នកនាំចូល។ តម្លៃបន្ថែមភាគច្រើនរបស់ឈ្មួញបន្តពីអ្នកនាំចូល គឺការចំណាយខ្ពស់លើការដឹកជញ្ជូនពីកន្លែងចែកចាយថ្នាក់ខេត្ត ទៅដល់ហាងតាមភូមិ ដោយសារមានការបង់ប្រាក់កម្រៃក្រៅផ្លូវការយ៉ាងច្រើន ទៅឱ្យប៉ូលីសតាមដងផ្លូវក្នុងពេលដឹកជញ្ជូន។

### ៤.២. ប្រព័ន្ធបទបញ្ញត្តិច្បាប់

យោងតាមបទបញ្ញត្តិច្បាប់ ឈ្មួញនិងអ្នកលក់រាយផលិតផលគីមីកសិកម្មទាំងអស់ ត្រូវចុះបញ្ជីនៅការិយាល័យនីតិកម្មនៃមន្ទីរកសិកម្មខេត្ត ដើម្បីទទួលបានវិញ្ញាបនប័ត្រពាណិជ្ជកម្មក្នុងការជួញដូរទំនិញគីមីកសិកម្ម។ ប៉ុន្តែ ឈ្មួញកណ្តាល អ្នកចែកចាយចល័ត និង/ឬអ្នកលក់រាយខ្នាតតូចតាមរដូវក្នុងភូមិ គឺគ្មានការសំគាល់អត្តសញ្ញាណ និងគ្មានការគ្រប់គ្រងដោយច្បាប់ទេ (IFDC

2010)។ ប្រតិបត្តិករទាំងនេះត្រូវគេចោទថា បានបង្កើតបញ្ហាលើគុណភាពជី និងបង្កការខាតបង់ធំធេងដល់អ្នកទិញជី (Theng 2012)។ ដើម្បីដោះស្រាយបញ្ហា ឈ្មួញជីត្រូវតែមានការគ្រប់គ្រងដោយច្បាប់ និងត្រូវតែចុះបញ្ជីជាឈ្មួញជី ដើម្បីឲ្យអាជ្ញាធរអាចតាមដាន និងត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់ពួកគេ។

### ៤.៣. ឧបសគ្គសំខាន់ៗប៉ះពាល់ការផ្គត់ផ្គង់ជី

អ្នកនាំចូលជីត្រូវមាន អាជ្ញាប័ណ្ណចេញដោយក្រសួងកសិកម្ម។ នីតិវិធីចេញអាជ្ញាប័ណ្ណនាំចូលមានភាពស្មុគស្មាញ មិនស្របតាមតម្រូវការទីផ្សារទេ និងមានការរឹតបន្តឹងទៅលើប្រតិបត្តិករទីផ្សារមានការប្រកួតប្រជែង។ដំណើរការផ្តល់អាជ្ញាប័ណ្ណគ្មានតម្លាភាពទេ និងបង្កើតឱកាសសម្រាប់ការទារយកកម្រៃក្រៅផ្លូវការ។ការដាក់កម្រិតលើចំនួនតោននាំចូលដោយអ្នកនាំចូលម្នាក់វាផ្ទុយនឹងគោលការណ៍ទីផ្សារគ្រប់យ៉ាង បង្កការលំបាកធំធេងដល់ពាណិជ្ជកម្ម និងធ្វើឲ្យអ្នកនាំចេញមិនអាចបានចំណេញពីសេដ្ឋកិច្ចមាត្រដ្ឋាន។ក្នុងប្រទេសមានសេដ្ឋកិច្ចទីផ្សារទាំងអស់វិស័យឯកជនគួរមានសេរីភាពកំណត់បរិមាណត្រូវផ្គត់ផ្គង់ ដោយផ្អែកលើទីផ្សារ និងការវាយតម្លៃហានិភ័យពាណិជ្ជកម្ម។ តួនាទីរដ្ឋាភិបាលគួរផ្តោតទៅលើការត្រួតពិនិត្យគុណភាព ដោយផ្អែកលើបទបញ្ញត្តិច្បាប់ស្តីពីផ្លាកសញ្ញាត្រឹមត្រូវ។ ការផ្តល់អាជ្ញាប័ណ្ណ និងប្រព័ន្ធកូតាចំនួនតោន ក៏រាំងអ្នកនាំចូលធំៗក្នុងការទទួលបានចំណេញតាមការនាំចូលមានតម្លៃទាបពីទីផ្សារអន្តរជាតិ ហើយបែរជាត្រូវបង្ខំចិត្តនាំចូលឆ្លងតាមប្រទេសវៀតណាម ឬថៃទៅវិញ។ ប្រព័ន្ធនេះក៏បានលើកទឹកចិត្តដល់ការនាំចូលខុសច្បាប់ បានរារាំងក្រុមហ៊ុនតូចៗ ក្នុងការចូលធ្វើប្រតិបត្តិការក្នុងទីផ្សារ បានរាំងស្ទះដល់ការប្រកួតប្រជែងក្នុងទីផ្សារដែលអាចធ្វើឱ្យថ្លៃលក់រាយធ្លាក់ចុះ និងបានចំណេញដល់កសិករកម្ពុជា។

## ៥. ផ្លូវដើរទៅមុខ

កំណើនផលិតភាពកសិកម្មនាពេលអនាគត រំពឹងថា ទទួលបានជាសំខាន់ពីការធ្វើប្រពលវប្បកម្មផលិតកម្មដំណាំរបស់កសិករតូចតាច (CDRI 2013) ក្នុងនេះ ជីដើរតួនាទីសំខាន់ណាស់ក្នុងការបង្កើនទិន្នផលដំណាំ និងការរក្សាធនធានធម្មជាតិគឺដីកសិកម្មឲ្យមានចីរភាព (Bumb 1996)។ ដើម្បីលើកស្ទួយតួនាទីជីក្នុងការផ្លាស់ប្តូរវិស័យកសិកម្ម មសំដៅពង្រឹងសន្តិសុខស្បៀង និងជំរុញកំណើនកសិកម្ម និងការនាំចេញ ចំណុចខ្វះខាតផ្សេងៗនៃឧស្សាហកម្មជីដែលជាប់ទាក់ទងនឹងរចនាសម្ព័ន្ធការនាំចូល និងប្រព័ន្ធច្បាប់ គួរតែដោះស្រាយដូចខាងក្រោម៖

១. កំហិតលើការនាំចូល៖ ក្រសួងកសិកម្មគួរកែប្រែបទបញ្ញត្តិនិងនីតិវិធីផ្តល់អាជ្ញាប័ណ្ណការនាំចូលធ្វើឲ្យសាមញ្ញក្នុងដំណើរការផ្តល់អាជ្ញាប័ណ្ណ និងលុបបំបាត់ឱកាសទារយកប្រាក់កម្រៃក្រៅផ្លូវការ។ ក្រសួងកសិកម្មគួរលុបបំបាត់ការដាក់កម្រិតលើចំនួនតោននាំចូល ដោយអនុញ្ញាតឱ្យពាណិជ្ជករអាចកំណត់ដោយសេរីនូវបរិមាណ ផលិតផលជីបានចុះបញ្ជីរួចដែលត្រូវនាំចូលដោយផ្អែកលើតម្រូវការ និងការវាយតម្លៃហានិភ័យទីផ្សារ។ ម្យ៉ាងទៀត ក្រសួងកសិកម្មគួរអនុញ្ញាតតែផលិតផលណាដែលសមស្របសម្រាប់ប្រើប្រាស់នៅកម្ពុជា។ ការបំបាត់របាំងធំៗដែលរាំងស្ទះពាណិជ្ជកម្មសេរី នឹងជួយសម្រួលការចូលធ្វើប្រតិបត្តិការក្នុងទីផ្សារ ការបានចំណេញពីសេដ្ឋកិច្ចមាត្រដ្ឋានដល់អ្នកនាំចូល ការបង្កើនការប្រកួតប្រជែងក្នុងទីផ្សារ និងការកែលំអគុណភាពផលិតផលនិងកាត់បន្ថយថ្លៃលក់រាយ។

២. ការរៀបចំរចនាសម្ព័ន្ធស្ថាប័នឡើងវិញ៖ ដើម្បីសម្របសម្រួលតួនាទី និងទំនួលខុសត្រូវរបស់ក្រសួងជាប់ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មជី និងត្រួតពិនិត្យគុណភាពផលិតផលជីនៅលើទីផ្សារ រដ្ឋាភិបាលគួរបង្កើតនាយកដ្ឋានមួយដែលមានធនធានមនុស្សមកពីក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម ដើម្បីបង្កើតច្បាប់គ្រប់គ្រងឧស្សាហកម្មជីនៅពេលនាំចូល នៅកម្រិតលក់ដុំ និងកម្រិតលក់រាយ។

៣. ការប្រមូលទិន្នន័យ និងការតាមដានត្រួតពិនិត្យ៖ អ្នកនាំចូល និងអ្នកចែកចាយទាំងអស់ គួរតែតម្រូវឱ្យបញ្ជូនទិន្នន័យដាច់ដោយឡែកពីគ្នាលើការនាំចូល ការចែកចាយ និងការកំណត់ថ្លៃទៅឲ្យនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម ជារៀងរាល់ត្រីមាស។ ព័ត៌មានទីផ្សារស្ដីពីផលិតផលនាំចូល និងថ្លៃ ក៏គួរចងក្រង និងអនុញ្ញាតឲ្យសាធារណជនប្រើប្រាស់បាន ដើម្បីឲ្យកសិករអាចផ្ទៀងផ្ទាត់ថ្លៃដែលគាត់បង់ ទៅនឹងថ្លៃផលិតផលផ្សេងគ្នា នៅក្នុងទីផ្សារខុសៗគ្នា។

## ឯកសារយោង


ACI, Agrifood Consulting International (2002), "Rice Value Chain Study: Cambodia" (Bethesda, MA: ACI)

Bumb, B. and C. Baanante (1996), *The Role of Fertilizers in Sustaining Food Security and Protecting the Environment to 2020* (Washington, DC: IFPRI)

CDRI, Cambodia Development Research Institute (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities* (Phnom Penh: CDRI)

Chhim Chhun, Theng Vuthy and Nou Keosothea (2013), "Case Study: Rice Marketing Value Chains in Takeo Province",*Cambodia Development Review*, 17(2), pp. 9-14

IFDC, International Fertilizer Development Center (2010), *Rapid Appraisal of Fertiliser Quality in Cambodia*, IFDC report prepared for the World Bank

Kem Sothorn (2012), "Credit for Rice Farmers: A Study in Takeo Province", *Cambodia Development Review*, 16(3), pp. 6-10

Lim Visal (2006), *Cambodia Agriculture Development Report,* Mimeo (Phnom Penh: Economic Institute of Cambodia)

MAFF, Ministry of Agriculture, Fishery and Forestry (2013), *Annual Report of Ministry of Agriculture, Fishery and Forestry for 2012-2013 and Direction for 2013-2014* (Phnom Penh: MAFF)

NIS (2011), *National Accounts of Cambodia 1993-2010* (Phnom Penh: NIS, Ministry of Planning)

NIS, National Institute of Statistics (2008), *Statistical Year Book of Cambodia 2008* (Phnom Penh: NIS/MOP)

Ovesen, J., I.B. Trankell, Heng K. and Chen S. (2012), "Rice Farming and Microcredit in Takeo Province, Cambodia Rice: A Socio-economic and Social Anthropological Study with Special Reference to *InteanPoalroathRongroeurng* (IPR) Microfinance Institution"(Phnom Penh: InteanPoalroathRongroeurng)

RGC, Royal Government of Cambodia (2010), *Policy Document on Promotion of Paddy Rice Production and Export of Milled Rice* (Phnom Penh: RGC)

Schamel G. and F. Hongen (2003), "Adverse Selection in Developing Country Factor Markets: The Case of Fertiliser In Cambodia", paper prepared for the 2003 AAEA Annual Meeting, Montreal, Canada, 27-30 July 2003

Theng Vuthy (2012), "Fertiliser Value Chain in Cambodia: A Case Study in Takeo Province", *Cambodia Development Review*,16 (4), pp. 5-9

Yu B. and S. Fan (2009), "Rice Production Response in Cambodia", IFPRI Discussion Paper 00939 (Washington, DC: IFPRI)

Young, D., R. T. Raab, (2000), "Economic Impact Assessment of the Cambodia-IRRI-Australia Project" Cambodian Journal of Agriculture 3: 48-52

-៨-

# ឥទ្ធិពលសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម នៅលើផលិតកម្មស្រូវ៖ ភស្តុតាងផ្អែកលើទិន្នន័យ បានពីអង្កេតជាបន្តបន្ទាប់ ក្នុងប្រាំបួនភូមិ នៅកម្ពុជា

*ដោយ កែវ សុជាតិ និង បណ្ឌិត ថេង វុទ្ធី*[១]

## ១. សេចក្តីផ្តើម

ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បាននិងកំពុងដើរតួនាទីសំខាន់ក្នុងការបង្កើនទិន្នផលដំណាំ តាមការផ្តល់ឲ្យកសិករនូវការណែនាំផ្នែកបច្ចេកទេស និងព័ត៌មានស្តីពីបច្ចេកវិទ្យាកសិកម្មប្រសើរឡើង (Baig and Aldosari 2013)។ នៅកម្ពុជា ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌសម្រាប់ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការពង្រីកសេវាផ្សព្វផ្សាយកសិកម្មទៅដល់កម្រិតឃុំ គឺជាវិធានការគោលនយោបាយដែលមានលើកឡើងក្នុងឯកសារគោលនយោបាយ ដើម្បីលើកកម្ពស់ផលិតភាព ប្រពលវប្បកម្ម និងពាណិជ្ជកម្មស្រូវ (MAFF 2011)។ មកទល់បច្ចុប្បន្ន ការសិក្សាស្រាវជ្រាវពីការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅកម្ពុជា មិនទាន់បានទូលំទូលាយទេ។ ក្នុងចំណោមការសិក្សាដ៏តិចតួចនោះ មានករណីសិក្សាមួយអនុវត្តដោយ Ngo and Chan (2010) ដើម្បីពិនិត្យជារួមពីសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅខេត្តកណ្តាល និងខេត្តតាកែវ។ ការសិក្សារបស់ Tong *et al.* (2011) បានពិនិត្យឃើញទំនាក់ទំនងសហេតុរវាង សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងប្រពលវប្បកម្មកសិកម្ម តាមការវិភាគសេដ្ឋកិច្ចមាត្រសាស្ត្រ និងទិន្នន័យបានពីអង្កេតបន្តបន្ទាប់ពីរលើក លើ ២៣១ គ្រួសារនៅតំបន់ជនបទកម្ពុជា។ ការសិក្សាមួយទៀតអនុវត្តដោយ Chhim *et al.* (2013) បានប្រើការវិភាគបែបគុណវិស័យដើម្បីពិនិត្យពីបញ្ហាសំខាន់ៗនៅក្នុងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅខេត្តតាកែវ។ ការសិក្សាពីលទ្ធផលនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅលើទិន្នផលស្រូវ មិនត្រឹមតែរួមចំណែកដល់ការសិក្សាផ្នែកនេះទេ ប៉ុន្តែថែមទាំងផ្តល់ជាព័ត៌មានដល់រដ្ឋាភិបាលអំពីឥទ្ធិពលសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ទៅលើផលិតភាពស្រូវទៀតផង។

ការសិក្សានេះ សំដៅវាយតម្លៃពីផលប៉ះពាល់នៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅលើទិន្នផលស្រូវ ដោយប្រើវិធីសាស្ត្រ Propensity Score Matching (PSM) និង Difference-in-Differences ព្រមទាំងទិន្នន័យពីអង្កេតគ្រួសារក្នុង ៩ភូមិ នៅកម្ពុជា។

## ២. ការពិនិត្យលើឯកសារពាក់ព័ន្ធ

ការសិក្សាដោយ Hasan *et al.* (2008) បានពិនិត្យថា តើការផ្សព្វផ្សាយបច្ចេកទេសកសិកម្មបានជួយបង្កើនផលិតភាពដំណាំរបស់គ្រួសារនានាដែរឬទេ។ ដោយបានប្រើទិន្នន័យអង្កេតតាមពេលវេលាបន្តបន្ទាប់ក្នុងអំឡុងឆ្នាំ២០០៩-១០ និងជ្រើសយកចម្ងាយផ្លូវទៅកាន់មជ្ឈមណ្ឌល

[១] រៀបរៀងដោយ កែវ សុជាតិ ជាអ្នកស្រាវជ្រាវ និង បណ្ឌិត ថេង វុទ្ធី ជាអ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ ប្រចាំវិទ្យាស្ថាន CDRI។

សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មធ្វើជា អថេរជំនួយសម្រាប់កំណត់ការចូលរួមក្នុងកម្មវិធីសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក្រុមលោក Hasan បានរកឃើញថា សេវាផ្សព្វផ្សាយមានឥទ្ធិពលវិជ្ជមានទៅលើផលិតភាពដំណាំ។ ការសិក្សាមួយផ្សេងទៀតដោយ Owens *et al.* (2003) ដែលប្រើវិធីសាស្ត្រការប៉ាន់ស្មានឥទ្ធិពលថេរ (fixed-effect estimation) និងមានការត្រួតពិនិត្យលើសមត្ថភាពកសិករ និងលក្ខណៈមានផលិតភាពពីធម្មជាតិ បានបង្ហាញថា បុគ្គលិកផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលចុះទៅជួបកសិករម្តងឬពីរដងក្នុងមួយឆ្នាំ អាចជួយបង្កើនផលិតភាពដំណាំបានយ៉ាងច្រើន។ ប៉ុន្តែ Cerdan-Infantes *et al.* (2008) ដែលសិក្សាវាយតម្លៃពីឥទ្ធិពលនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅលើផលិតករទំពាំងបាយជូរ ក្នុងខេត្ត Mendoza នៃប្រទេសអាហ្សង់ទីន ដោយប្រើវិធីសាស្ត្រការប៉ាន់ស្មានឥទ្ធិពលថេរ, វិធីសាស្ត្រ difference-in-difference និងទិន្នន័យអង្កេតតាមពេលវេលាបន្តបន្ទាប់ បានរកឃើញថា មិនមានឥទ្ធិពលអ្វីជាដុំកំភួនទៅលើទិន្នផលទំពាំងបាយជូរ។ Feder *et al.* (2003) ដែលប្រើទិន្នន័យអង្កេតតាមពេលវេលាបន្តបន្ទាប់ និងវិធីសាស្ត្រ difference-in-difference បានរកឃើញថា កម្មវិធីផ្សព្វផ្សាយបច្ចេកទេស មិនមានឥទ្ធិពលជាដុំកំភួនទេទៅលើទិន្នផលស្រូវ និងការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ។ ការសិក្សារបស់ Yamazaki and Budy (2007) ដែលបានប្រើសំណុំទិន្នន័យពី Feder *et al.* (2003) ម៉្យដែលកែសម្រួល និងបច្ចេកទេសសេដ្ឋកិច្ចមាត្រសាស្ត្រតាមតំបន់ ដើម្បីវាយតម្លៃឡើងវិញពីឥទ្ធិពលនៃកម្មវិធី farmer field school (FFS: វិធីសាស្ត្រមួយនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម) បានរកឃើញលទ្ធផលខុសគ្នា។

## ៣. សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅកម្ពុជា

ប្រទេសកម្ពុជាមានសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្ម ប៉ុន្តែចំណាយរដ្ឋាភិបាលកម្ពុជាទៅលើវិស័យកសិកម្មមិនបានទ្រទ្រង់ច្រើនប៉ុន្មានទេដល់ការអភិវឌ្ឍវិស័យនេះ។ តួយ៉ាងទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងឆ្នាំ២០១០ បង្ហាញថា តាំងពីឆ្នាំ២០០២ មក ចំណែកនៃចំណាយសាធារណៈសម្រាប់វិស័យកសិកម្មមានពី ១,៧ ទៅ ២,៤% ហើយគេប៉ាន់ស្មានថា មានប្រហែល ២,៣% នៅឆ្នាំ២០១៥។

គិតលើទូទាំងប្រទេស សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅមានដែនគ្របដណ្តប់តូច ជាពិសេសសេវាផ្សព្វផ្សាយដែលរដ្ឋាភិបាលផ្តល់ទៅឲ្យកសិករមានដីតូចៗ (IFPRI 2011)។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកលើការពង្រឹង និងពង្រីកសេវាសាធារណៈផ្នែកកសិកម្ម។ តាមរបាយការណ៍ បុគ្គលិកផ្សព្វផ្សាយកសិកម្មនៅកម្ពុជាភាគច្រើន ធ្វើការនៅកម្រិតខេត្ត និងមានមួយភាគតូចទទួលការចាត់តាំងឲ្យទៅធ្វើការនៅកម្រិតស្រុក។ ជាទូទៅ បុគ្គលិកនៅការិយាល័យកសិកម្មស្រុក តែងធ្វើការជាសមភាគី ជាមួយម្ចាស់ជំនួយ និងគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ព្រោះមន្ត្រីថ្នាក់ស្រុកមិនមានថវិកាសម្រាប់ផ្តល់សេវានេះទេ (IFPRI 2011)។ របាយការណ៍របស់វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារ (IFPRI) (2011) បង្ហាញថា បុគ្គលិកផ្សព្វផ្សាយកសិកម្មសាធារណៈនៅកម្ពុជាមានសរុប ១២៤៤នាក់ ក្នុងនោះមាន ៩០% ជាបុគ្គលិកចុះផ្សព្វផ្សាយដល់កន្លែង។ អ្នកផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសមានបីប្រភេទធំៗ គឺ ស្ថាប័នសាធារណៈ វិស័យឯកជន និង អង្គការមិនមែនរដ្ឋាភិបាល។

## ៤. ទិន្នន័យ

### ៤.១. ប្រភពទិន្នន័យ

ការសិក្សានេះ ប្រើសំណុំទិន្នន័យបានពីអង្កេតគ្រួសារពីរលើក ធ្វើឡើងដោយវិទ្យាស្ថាន CDRI ក្នុងឆ្នាំ២០០៨ និង ២០១១ នៅ ៩ភូមិ ក្នុង ៤តំបន់ភូមិសាស្ត្រ គឺៈ (១) តំបន់ទន្លេមេគង្គ, (២) តំបន់ទន្លេសាប, (៣) តំបន់ខ្ពង់រាប និង (៤) តំបន់ឆ្នេរ។

ដើម្បីប៉ាន់ស្មានពីឥទ្ធិពលសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការសិក្សានេះប្រើសំណុំទិន្នន័យទំហំប្រហាក់ប្រហែលគ្នាបានពីអង្កេតនៅឆ្នាំ២០០៨ និងឆ្នាំ២០១១ លើ ៥៤៧គ្រួសារក្នុងឆ្នាំនីមួយៗ ដោយប្រើវិធីសាស្ត្រ difference-in-differences ។

### ៤.២. ស្ថិតិបែបពណ៌នាសម្រាប់អង្កេតដំបូង និងចុងបញ្ចប់

ដោយការសិក្សានេះប្រើប្រាស់វិធីសាស្ត្របែបពិសោធន៍ (quasi-experimental approach) ដូច្នេះយើងចែកគ្រួសារជាពីរក្រុមគឺៈ ក្រុមរងប្រព្រឹត្តកម្ម និងក្រុមសម្រាប់ប្រៀបធៀប។ គ្រួសាររងប្រព្រឹត្តកម្ម គឺជាគ្រួសារដែលបានទទួលព័ត៌មាន ទាក់ទងនឹងការបង្កើនទិន្នផលស្រូវនៅឆ្នាំ ២០០៨ (អង្កេតដំបូង) រីឯគ្រួសារក្នុងក្រុមសម្រាប់ប្រៀបធៀប មិនបានទទួលព័ត៌មាននោះទេ។ ផលស្រូវ, ទិន្នផលស្រូវ, តម្លៃផលិតកម្មស្រូវក្នុងមួយហិកតា និងចំណេញដុល[២] គឺជាអថេរសម្រាប់ការវាយតម្លៃផលប៉ះពាល់នេះ ដែលសំដៅ កំណត់រកទំនាក់ទំនងសមហេតុរវាងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម នឹងសូចនាការទាំងបីខាងលើ។ ជាមធ្យម គ្រួសារក្នុងក្រុមរងប្រព្រឹត្តកម្មអាចផលិតស្រូវបាន ២០៩៥គ.ក/ហិកតាក្នុងឆ្នាំ២០០៨ និង ២៣២៩គ.ក/ហិកតាក្នុងឆ្នាំ២០១១ រីឯទិន្នផលស្រូវជាមធ្យមរបស់ក្រុមសម្រាប់ប្រៀបធៀប គឺ ២៤២១គ.ក/ហិកតាក្នុងឆ្នាំ២០០៨ និង ២៦៣៤គ.ក/ហិកតាក្នុងឆ្នាំ២០១១ (តារាង ១)។ គួរកត់សំគាល់ថាទិន្នផលស្រូវរបស់ក្រុមរងប្រព្រឹត្តិកម្ម គឺទាបខ្លាំងជាង ទិន្នផលស្រូវរបស់ក្រុមសម្រាប់ប្រៀបធៀប ទាំងក្នុងពេលអង្កេតដំបូង និងអង្កេតចុងបញ្ចប់ ហើយតម្លៃផលិតកម្មស្រូវក្នុងមួយហិកតា ក៏ដូច្នេះដែរ។ ចំណុចនេះមិនទាន់អាចពន្យល់បានទេនៅដំណាក់កាលបច្ចុប្បន្ន ព្រោះយើងមិនទាន់ធ្វើការត្រួតពិនិត្យលើកត្តាផ្សេងទៀតដែលអាចជះឥទ្ធិពលលើភាពខុសគ្នារវាងផលិតកម្មស្រូវរបស់ក្រុមរងប្រព្រឹត្តកម្ម នឹងក្រុមសម្រាប់ប្រៀបធៀប។

តារាង ១៖ ផលិតកម្មស្រូវ បែងចែកតាមប្រភេទក្រុមគ្រួសារ និងឆ្នាំ

| អថេរ | 2008 | | 2011 | | 2008 | 2011 |
|---|---|---|---|---|---|---|
| | T | C | T | C | t-stat. | t-stat. |
| | (n=348) | (n= 199) | (n=348) | (n= 199) | | |
| ទិន្នផលស្រូវ (គ.ក/ហិកតា) | 2095 | 2421 | 2329 | 2634 | -2.807*** | -2.44** |
| តម្លៃស្រូវ/ហិកតា (ម៉ឺនរៀល/ហិកតា) | 197.65 | 224.75 | 178.79 | 207.02 | -2.382** | -2.25** |
| ចំណេញដុល (ម៉ឺនរៀល/ហិកតា) | 128.58 | 137.53 | 127.56 | 140.94 | -1.020 | -1.169 |
| ផ្ទៃដីដាំស្រូវ (ហិកតា) | 2.26 | 2.12 | 2.22 | 2.25 | 0.654 | -0.1191 |

សំគាល់៖ T តំណាងឲ្យក្រុមរងប្រព្រឹត្តកម្ម, C តំណាងឲ្យក្រុមសម្រាប់ប្រៀបធៀប។ មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត ១០% *; ៥% **; ១% ***

ប្រភព៖ អង្កេតគ្រួសារអនុវត្តដោយ CDRI ក្នុងឆ្នាំ២០០៨ និង ២០១១

---

[២] ចំណេញដុលបានមកពី តម្លៃផលិតកម្មសុទ្ធ ចែកនឹង ផ្ទៃដីប្រមូលផល។

## ៥. វិធីសាស្ត្រគណនា

ការសិក្សានេះប្រើវិធីសាស្ត្រ Propensity Score Matching (PSM) និង Difference-in-Differences (DD) ដើម្បីប៉ាន់ស្មានពី ឥទ្ធិពលនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅលើផលិតភាពស្រូវ។ វិធីសាស្ត្រ PSM បានយកមកប្រើ ដើម្បីផ្គូផ្គងគ្រួសាររងប្រព្រឹត្តកម្ម ជាមួយនឹងគ្រួសារសម្រាប់ប្រៀបធៀប ឲ្យមានលក្ខណៈស្រដៀងគ្នាងាយប្រៀបធៀប ហើយវិធីសាស្ត្រ DD បានយកមកប្រើ ដើម្បីគ្រប់គ្រងទាំងលើចរិតលក្ខណៈមិនផ្អែកលើពេលវេលាដែលគេមើលឃើញ ដូចជា អាយុ ភេទ តំបន់ និងកម្រិតអប់រំរបស់មេគ្រួសារ និងលើចរិតលក្ខណៈមិនផ្អែកលើពេលវេលាដែលគេមើលមិនឃើញ (ដូចជា ការគោរពវិន័យផ្ទាល់ខ្លួន និងទឹកចិត្តខិតខំ)។ វិធីសាស្ត្រ DD បានយកមកប្រើដោយផ្អែកលើការសន្មតថា ប្រសិនបើគ្មានកម្មវិធីផ្សព្វផ្សាយកសិកម្ម (ឧទាហរណ៍ សេវាផ្សព្វផ្សាយបច្ចេកទេសដាំស្រូវ) ទេនោះ ក្រុមរងប្រព្រឹត្តកម្ម នឹងបានលទ្ធផលប្រហាក់ប្រហែលគ្នានឹងក្រុមសម្រាប់ប្រៀបធៀបដែរ (សម្រាប់ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រសិក្សា សូមមើលអត្ថបទជាភាសាអង់គ្លេស)។

## ៦. ការគណនាជាក់ស្តែង

ផ្នែកនេះ បង្ហាញនូវលទ្ធផលជាក់ស្តែងនៃ ការវាយតម្លៃពីឥទ្ធិពលនៃសេវាផ្សព្វផ្សាយបច្ចេកទេសដាំស្រូវទៅលើផលិតភាពស្រូវ ដោយពិនិត្យតាមទិន្នផលស្រូវ។

ឥទ្ធិពលប្រព្រឹត្តកម្មនៃសេវាផ្សព្វផ្សាយបច្ចេកទេសដាំស្រូវ ទៅលើទិន្នផលស្រូវ មានតម្លៃស្មើ ១១ (តារាង ២) ដែលមានន័យថា ទិន្នផលស្រូវរបស់ក្រុមរងប្រព្រឹត្តកម្ម ប្រែប្រួលជាមធ្យម ១១គ.ក លើសពីការប្រែប្រួលជាមធ្យមក្នុងទិន្នផលស្រូវរបស់ក្រុមមិនរងប្រព្រឹត្តកម្ម ប៉ុន្តែលទ្ធផលនេះមិនមានសារៈសំខាន់ផ្នែកស្ថិតិទេ។ ការគណនារបស់យើងក៏បង្ហាញដែរថា សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម មិនមានឥទ្ធិពលជាដុំកំភួនទៅលើតម្លៃផលិតកម្មស្រូវ និងចំណេញដុលឡើយ។

លទ្ធផលសិក្សានេះមិនខុសគ្នាខ្លាំងពី លទ្ធផលនៃការសិក្សាមុនៗដែលបានលើកឡើងនៅខាងលើនោះទេ។ ជាអាទិ៍ Feder *et al.* (2003) រកឃើញថា កម្មវិធី farmer field school (FFS) នៅប្រទេសឥណ្ឌូនេស៊ី មិនមានឥទ្ធិពលអ្វីច្រើនទេទៅលើទិន្នផលដំណាំសម្រេចបានដោយកសិករបញ្ចប់វគ្គសិក្សា បើធៀបនឹងកសិករនៅជិតខាងគ្នា។ ការសិក្សារបស់ Yamazakia and Budy (2007) ក៏បង្ហាញដែរថា ទិន្នផលស្រូវរបស់កសិករបានចូលរួមកម្មវិធី FFS មានការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ។ Okoboi *et al.* (2013) ដែលធ្វើការវាយតម្លៃពី ឥទ្ធិពលនៃកម្មវិធីសេវាប្រឹក្សាផ្នែកកសិកម្មជាតិរបស់ប្រទេសអ៊ូហ្គង់ដា (NAADS) ទៅលើទិន្នផលដំណាំ បានរកឃើញថា កម្មវិធីនេះមានឥទ្ធិពលតិចតួចណាស់។ ការសិក្សាមួយទៀតក៏រកឃើញថា ការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅប្រទេសអាហ្សង់ទីន មានឥទ្ធិពលតិចតួចណាស់ទៅលើទិន្នផលទំពាំងបាយជូរនៅទីនោះ (Cerdan-Infantes*et al.*, 2008)។

តារាង ២៖ លទ្ធផលវាយតម្លៃដោយប្រើវិធីសាស្ត្រ DD (ការប្រៀបធៀបរវាងទិន្នផលជាមធ្យម នៃក្រុមរងប្រព្រឹត្តកម្ម នឹងក្រុមសម្រាប់ប្រៀបធៀប) គណនាដោយប្រើកម្មវិធី STATA

| ទិន្នផល (គ.ក/ហិកតា) | | | |
|---|---|---|---|
| | **2008** | **2011** | **ឥទ្ធិពល (DD)** |
| ក្រុមរងប្រព្រឹត្តកម្ម (n=331) | 2098 | 2309 | |
| ក្រុមសម្រាប់ប្រៀបធៀប (n=199) | 2306 | 2505 | |
| ការប្រែប្រួល | -208 | -197 | **11** |
| P-value | 0.074* | 0.090* | **0.948** |
| **តម្លៃផលិតកម្មក្នុងមួយហិកតា (ម៉ឺនរៀល/ហិកតា)** | | | |
| ក្រុមរងប្រព្រឹត្តកម្ម (n=331) | 198.6 | 178.1 | |
| ក្រុមសម្រាប់ប្រៀបធៀប (n=199) | 213.7 | 201.4 | |
| ការប្រែប្រួល | -15.1 | -23.3 | **-8.2** |
| P-value | 0.221 | 0.059* | **0.637** |
| **ចំណេញដុល (ម៉ឺនរៀល/ហិកតា)** | | | |
| ក្រុមរងប្រព្រឹត្តកម្ម (n=331) | 129.1 | 127.1 | |
| ក្រុមសម្រាប់ប្រៀបធៀប (n=199) | 134.3 | 141.3 | |
| ការប្រែប្រួល | -5.2 | -14.2 | **-9** |
| P-value | 0.621 | 0.252 | **0.547** |

សំគាល់៖ មានសារៈសំខាន់ផ្នែកស្ថិតិចាប់ពីកម្រិត ១០% *; ៥% **; ១% ***
ប្រភព៖ ការគណនាផ្អែកលើអង្កេតគ្រួសារអនុវត្តដោយវិទ្យាស្ថាន CDRI ក្នុងឆ្នាំ២០០៨ និង ២០១១

## ៧. សន្និដ្ឋាន

តើវិនិយោគសាធារណៈលើសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម មានឥទ្ធិពលច្រើនឬតិច ជាបញ្ហាមួយសំខាន់ណាស់សម្រាប់អ្នកសិក្សាស្រាវជ្រាវ និងអ្នកបង្កើតគោលនយោបាយ។ ការសិក្សានេះមានគោលដៅវាយតម្លៃពីឥទ្ធិពលនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅលើទិន្នផលស្រូវ ដោយប្រើវិធីសាស្ត្រ PSM និង DD ជាមួយនឹងទិន្នន័យអង្កេតគ្រួសារតាមពេលវេលាបន្តបន្ទាប់ នៅក្នុង ៩ភូមិ នៅកម្ពុជា។ លទ្ធផលសិក្សាបានពីវិធីសាស្ត្រ DD បង្ហាញថា សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មជះឥទ្ធិពលវិជ្ជមានទៅលើផលិតភាពស្រូវនៅតំបន់អង្កេត ក្នុងភូមិទាំង៩ ប៉ុន្តែលទ្ធផលនេះមិនមានសារៈសំខាន់ផ្នែកស្ថិតិទេ។

ការសិក្សានេះមានចំណុចខ្សោយមួយដោយ អង្កេតគ្រួសារតាមពេលវេលាបន្តបន្ទាប់ដែលបានយកមកប្រើ មិនមែនរៀបចំឡើងសម្រាប់ការវាយតម្លៃផលប៉ះពាល់នៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនោះទេ ប៉ុន្តែមានគោលដៅចម្បង សិក្សាស្រាវជ្រាវពីស្ថានភាពក្រីក្រក្នុងភូមិទាំង ៩។ មួយវិញទៀត ដោយសារសំណាកមានទំហំតូច ដូច្នេះលទ្ធផលសិក្សាមិនអាចសន្និដ្ឋានជាទូទៅថា សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មជះឥទ្ធិពលច្រើនឬតិចប៉ុណ្ណា ទៅលើផលិតភាពកសិកម្មនោះឡើយ។ ការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅកម្ពុជាមានទម្រង់ច្រើនបែបយ៉ាង ដូច្នេះការសិក្សាបន្តទៀតដោយប្រើសំណាកធំជាងមុន និងដោយពិនិត្យលំអិតទៅតាមទម្រង់ជាក់លាក់

នីមួយៗនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម អាចជួយបង្កើតនូវសេចក្តីសន្និដ្ឋានកាន់តែប្រាកដនិយម និងជម្រើសគោលនយោបាយ សម្រាប់កែលំអការផ្តល់សេវាផ្សព្វផ្សាយដែលមានស្រាប់ ដើម្បីបង្កើនឥទ្ធិពលនៃសេវាទាំងនោះ។

សរុបមក លទ្ធផលសិក្សាដែលថា សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មមិនមានឥទ្ធិពលអ្វីជាដុំកំភួននេះ មិនអាចយកមកអះអាងផ្តល់យោបល់ថា រដ្ឋាភិបាលគួរកាត់បន្ថយវិនិយោគលើវិស័យនេះ បានឡើយ។ ផ្ទុយទៅវិញ រដ្ឋាភិបាលគួរប្រឹងប្រែងខ្លាំងថែមទៀតក្នុងការដោះស្រាយបញ្ហាប្រឈមសំខាន់ៗ ដើម្បីញ៉ាំងឲ្យសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មកាន់តែមានឥទ្ធិពលខ្លាំងឡើងទៅលើផលិតកម្មស្រូវ។

## ឯកសារយោង


Baig, M. B. & F. Aldosari (2013), “Agricultural Extension in Asia: Constraints and Options for Improvement”, *Journal of Animal & Plant Sciences,* Vol. 22, No.2, pp. 619-632

Cerdan-Infantes, P., A. Maffiolo& D. Ubfal (2008) “The Impact of Agricultural Extension Services: The Case of Grape Production in Argentina”, Project Evaluation Report (Washington, D.C: Inter-American Development Bank)

ChhimChhun; Theng Vuthy &NouKeosothea (2013), ‘Case Study: Rice Marketing Value Chains in Takeo Province’, *Cambodia Development Review*, 17 (2): 9-14. Phnom Penh: CDRI

Feder, G., R. Murgai& J.B. Quizon (2003), *Sending Farmers Back to School: The Impact of Farmer Field Schools in Indonesia,* World BankPolicy Research Working Paper 3022

Hasan, M. F., K. S. Imai, T. Sato (2008) “Impacts of Agricultural Extension on Crop Productivity, Poverty Vulnerability: Evidence from Uganda”, Kobe University Discussion Paper DP201234 (Kobe: Kobe University)

IFPRI (2011), Extension and Advisory Services in Cambodia http://www.worldwide-extension.org/asia/cambodia/s-cambodia(accessed date: 15 October 2013)

MAFF (2011), Action Plan for Implementation Policy Paper on the Promotion of Paddy Production and Rice Export (Phnom Penh: MAFF)

Meas,P. (2010), Policy Analysis for Strengthening the Agricultural Services Delivery at District Level. FAOreport prepared for MAFF, Feb 2010 (Unpublished) (Phnom Penh: FAO/MAFF)

Ngo, S. & C. Sophal (2010), Agriculture Sector Financing and Services for Smallholder Farmers. Published by The NGO Forum on Cambodia’s Aid Effectiveness Project of the Development Issues Programme. (Phnom Penh: The NGO Forum on Cambodia)

Okoboi, G., A. Kuteesa& M. Barungi (2003), *The Impact of National Agricultural Advisory Services Prpogram on Household Production and Welfare in Uganda,* African Growth Initiative Working Paper 7 (Washington DC: Brooking Institute)

Owens, T., J. Hoddinott, B., B. Kinsey (2003) “The impact of agricultural extension on farm production in resettlement area of Zimbabwe”, *Economic Development and Cultural Change,* Vol. 51, pp. 337–357

Tong, K. (2011), What *Limits Agricultural Intensification in Cambodia? The Role of Emigration, Agricultural Extension Services and Credit Constraints*CDRI Working Paper No. 56 (Phnom Penh: CDRI)

Yamazaki S. & B. P. Resosudarmo (2007) *Does Sending Farmers Back to School Have an Impact? A Spatial Econometric Approach*, Working Paper No. 2007/03, the Australian National University

-៩-

# ការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ សមត្ថភាពបន្សាំ និងអភិបាលកិច្ចធនធានទឹក ក្នុងអាងទន្លេសាប

*ដោយបណ្ឌិត ចែម ផល្លា និង លោក គីម សួ*[១]

## ១. សេចក្តីផ្តើម

### ១.១. ការប្រែប្រួលអាកាសធាតុ នៅប្រទេសកម្ពុជា និងនៅអាងទន្លេសាប

កម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ និងបានចូលរួមបំភាយឧស្ម័នផ្ទះកញ្ចក់តិចតួចបំផុត ដែលបង្កជាការប្រែប្រួលអាកាសធាតុសាកល។ ផ្ទុយទៅវិញ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ ដោយសារភាពក្រីក្ររបស់ប្រជាជន និងជីវភាពរស់នៅដែលពឹងផ្អែកយ៉ាងខ្លាំងលើវិស័យងាយរងគ្រោះ ដោយសារតែការប្រែប្រួលអាកាសធាតុ (Yusuf and Francisco 2009)។ បឹងទន្លេសាបដែលជាទីសម្បូរត្រី និងទឹកជំនន់ទន្លេមេគង្គដែលផ្តល់ដីល្បប់មានជីជាតិ ចាក់លើវាលស្រែប្រាំង អំណោយផលដល់ផលិតកម្មកសិកម្ម កំពុងប្រឈមនឹងបញ្ហាប្រែប្រួលអាកាសធាតុ និងសកម្មភាពខុសឆ្គងរបស់មនុស្ស (ដូចជាការកសាងទំនប់វារីអគ្គិសនីកាត់ទន្លេ) ជាដើម ដែលបានប៉ះពាល់ទៅលើរបបជលសាស្ត្រនៃបឹងទន្លេសាប (Eastham *et al.* 2008)។ ជាធម្មតា តំបន់នៅជុំវិញបឹងទន្លេសាប ត្រូវទឹកជន់លិចនៅរដូវវស្សា និងគោកទៅវិញនៅរដូវប្រាំង ហើយបង្កើតបានជាតំបន់អេកូឡូស៊ីមួយ ដែលមានទឹកផង និងគោកផង ក្លាយជាជីពចរនៃបឹងទន្លេសាប និងអាងទន្លេមេគង្គទាំងមូល (Keskinen *et al.* 2012: 10)។

ការប្រែប្រួលអាកាសធាតុ គួបផ្សំជាមួយនឹងកំហុសក្នុងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចផង (ការកាប់បំផ្លាញព្រៃឈើ ការកសាងទំនប់វារីអគ្គិសនីកាត់ទន្លេជាដើម) ធ្វើឲ្យប្រទេសកម្ពុជាប្រឈមខ្លាំងនឹងគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ និងខ្យល់ព្យុះ ជាដើម។ កំណើនគ្រោះធម្មជាតិ ចាប់តាំងពីចុងទសវត្សរ៍១៩៨០មក ដែលមានទំនាក់ទំនងជាមួយកំណើនសីតុណ្ហភាព និងការប្រែប្រួលរបបទឹកភ្លៀង បានប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា។ ជាឧទាហរណ៍ ទឹកជំនន់ក្នុងឆ្នាំ ២០០០ ២០១១ និង ២០១៣ នៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប ជាគ្រោះធម្មជាតិដ៏អាក្រក់បំផុតក្នុងប្រវត្តិសាស្ត្រថ្មីៗនៃទឹកជំនន់នៅកម្ពុជា។

ដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំស្វែងយល់ និងសិក្សាពីភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំរបស់ប្រជាជន ដើម្បីរៀបចំគោលនយោបាយ និងផែនការសកម្មភាពទប់ទល់នឹងគ្រោះថ្នាក់នេះ។ កិច្ចខិតខំទាំងនោះ ដូចជាការបង្កើតកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ឆ្នាំ២០០៦) កម្មវិធីសាកល្បងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងថ្មីៗនេះទៀត រដ្ឋាភិបាលបានអនុម័ត

[១] សូមថ្លែងអំណរគុណដល់បណ្ឌិត ប៉ិច សុខែម និងកញ្ញា ថៃ សុដា នៃក្រុម Hatfield ដែលបានជួយដល់ការរៀបចំអង្គសិក្ខាសាលាថ្នាក់ឃុំ និងថ្នាក់ខេត្ត។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា សម្រាប់ឆ្នាំ២០១៤ ដល់ ២០២៣ ហើយយុទ្ធសាស្ត្រទាំងអស់នេះបានយោងតាមឯកសារគោលនយោបាយជាតិ ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ និងគោលនយោបាយជាតិអភិវឌ្ឍន៍បៃតង ជាដើម។ កិច្ចខិតខំទាំងនេះ សំដៅឆ្លើយតបចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា តាមរយៈការបង្កើតវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍកាបូនទាប។ វិធានការបន្សាំដែលបានអនុវត្តកន្លងមក មានដូចជា ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការវាយតម្លៃភាពងាយរងគ្រោះ សមត្ថភាពបន្សាំ និងការកាត់បន្ថយហានិភ័យដោយផ្តោតលើវិស័យសំខាន់ៗទាំងប្រាំ គឺមាន កសិកម្ម ធនធានទឹក រុក្ខាប្រមាញ់ ជលផល និងទេសចរណ៍។

## ១.២. គោលបំណង និងសំណួរស្រាវជ្រាវ

យោងតាមការសិក្សាកន្លងមក និងក្របខ័ណ្ឌនៃគម្រោងការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចធនធានទឹករបស់ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ការសិក្សានេះព្យាយាមស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ទៅលើជីវភាពរស់នៅរបស់ប្រជាជននៅតំបន់អាងទន្លេសាប និងការបន្សាំរបស់ពួកគេ។ ដើម្បីសម្រេចគោលបំណងខាងលើ ការសិក្សាបានផ្តោតលើសំណួរបី៖

១. តើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានអ្វីខ្លះ ទៅលើជីវភាពរស់នៅរបស់ប្រជាជននៅអាងទន្លេសាប ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត?

២. តើប្រជាជនមានវិធានការដូចម្តេចខ្លះ ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់មកលើជីវភាពរស់នៅរបស់ខ្លួន?

៣. តើមានវិធានការអភិបាលកិច្ចធនធានទឹកអ្វីខ្លះដែលត្រូវកែទម្រង់ ដើម្បីបង្កលក្ខណៈឲ្យប្រជាជន អាចបន្សាំបានកាន់តែប្រសើរ ទៅនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់មកលើជីវភាពរស់នៅរបស់ខ្លួន?

## ១.៣. ទស្សនទាននៃការប្រែប្រួលអាកាសធាតុ និងសមាសភាគនៃភាពងាយរងគ្រោះ

ការសិក្សានេះ បានប្រើប្រាស់ទស្សនទានមួយចំនួន ដែលពាក់ព័ន្ធជាមួយនឹងការប្រែប្រួលអាកាសធាតុ ដូចជា ភាពងាយរងគ្រោះ ភាពប្រឈម ភាពឆាប់ងាយរងគ្រោះ និងសមត្ថភាពបន្សាំ ជាដើម។ ក្រុមអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ (IPCC 2001: 982-996) ក្នុងឆ្នាំ២០០១ បានកំណត់និយមន័យពាក្យ *ភាពងាយរងគ្រោះ* ថា "ជាកម្រិត ដែលប្រព័ន្ធណាមួយអាច ឬមិនអាចទប់ទល់ ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ។ ភាពងាយរងគ្រោះនៃប្រព័ន្ធណាមួយ មានទំនាក់ទំនងជាមួយនឹងទំហំនិងលក្ខណៈនៃភាពប្រឈម ភាពឆាប់ងាយរងគ្រោះ និងសមត្ថភាពបន្សាំរបស់ប្រព័ន្ធនោះ"។ *ភាពប្រឈម* គឺជា "កម្រិតដែលប្រព័ន្ធណាមួយត្រូវប្រឈមមុខចំពោះការប្រែប្រួលអាកាសធាតុ"។ *ភាពឆាប់ងាយរងគ្រោះ* គឺជា "កម្រិតដែលប្រព័ន្ធណាមួយទទួលរងផលប៉ះពាល់ល្អ ឬអាក្រក់ពីការប្រែប្រួលអាកាសធាតុ"។ ចំណែកឯ *សមត្ថភាពបន្សាំ* គឺជា "សមត្ថភាព ដែលប្រព័ន្ធណាមួយ អាចសម្របខ្លួនជាមួយនឹងការប្រែប្រួល

អាកាសធាតុ (រាប់ទាំងការប្រែប្រួលធាតុអាកាស និងភាពធ្ងន់ធ្ងររបស់វាផង) ដើម្បីជំនះលើផលវិបាកនៃការប្រែប្រួលអាកាសធាតុ"។

យោងតាមនិយមន័យខាងលើ បើប្រព័ន្ធណាមួយ មានភាពប្រឈម និងភាពឆាប់ងាយរងគ្រោះខ្ពស់ និងមានសមត្ថភាពបន្សាំទាប គេអាចសន្និដ្ឋានថា ប្រព័ន្ធនោះមានភាពងាយរងគ្រោះខ្ពស់។ ម្យ៉ាងទៀត សម្រាប់ប្រព័ន្ធពីរ ដែលមានភាពប្រឈមនឹងភាពឆាប់ងាយរងគ្រោះកម្រិតស្មើគ្នា បើប្រព័ន្ធណាមានសមត្ថភាពបន្សាំខ្ពស់ ប្រព័ន្ធនោះ មានភាពងាយរងគ្រោះទាប។ សូមមើលរូបភាព ១ ដែលអាចពន្យល់ពីការសន្និដ្ឋាននេះ។

រូបភាព ១៖ ទំនាក់ទំនងរវាងសមាសភាគផ្សេងៗ នៃភាពងាយរងគ្រោះ




## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួម ដើម្បីលើកទឹកចិត្តអ្នកចូលរួមក្នុងដំណើរការស្រាវជ្រាវថ្នាក់មូលដ្ឋាន ក្នុងខេត្តគោលដៅទាំងបីគឺ កំពង់ឆ្នាំង ពោធិ៍សាត់ និងកំពង់ធំ ដែលស្ថិតនៅជុំវិញបឹងទន្លេសាប ឲ្យមកចូលរួមយ៉ាងសកម្មក្នុងការផ្តល់ទិន្នន័យបែបគុណភាព ដើម្បីឆ្លើយតបនឹងសំណួរស្រាវជ្រាវទាំងបីខាងលើ។ ទិន្នន័យបែបគុណភាពសំខាន់ៗ បានប្រមូលយកពីអ្នកចូលរួម ថ្នាក់ខេត្ត (មន្ត្រីជំនាញជុំវិញសាលាខេត្ត) និងថ្នាក់មូលដ្ឋាន ភូមិ ឃុំ (កសិករ គ្រូបង្រៀន ក្រុមប្រឹក្សាស្រុក ឃុំ សង្កាត់) តាមរយៈសិក្ខាសាលាថ្នាក់ឃុំ និងថ្នាក់ខេត្ត នៅតាមខេត្តគោលដៅទាំងបី។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ឃុំ និងថ្នាក់ខេត្ត បានចងក្រងទិន្នន័យស្តីពីភាពប្រឈម ភាពឆាប់ងាយរងគ្រោះ និងសមត្ថភាពបន្សាំ (ក្នុងវិស័យកសិកម្ម ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធ) សម្រាប់ខេត្តទាំងបីខាងលើ។ ក្នុងដំណើរការវិភាគ ក្រុមការងារបានប្រមូលទិន្នន័យថ្នាក់ឃុំ រួចហើយយកទៅពិភាក្សា និងវាយតម្លៃនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្តបន្តទៀត ដែលមានមន្ត្រីជំនាញខេត្ត និងស្រុក មកចូលរួមពិភាក្សា និងផ្តល់យោបល់។

## ៣. លទ្ធផល

## ៣.១. ការប្រែប្រួលអាកាសធាតុ៖ និន្នាការ និងផលប៉ះពាល់

### *ខេត្តកំពង់ធំ*

រូបភាព ២៖ ប្រភេទនិងទំហំនៃការខូចខាត បណ្តាលមកពីគ្រោះធម្មជាតិ ក្នុងខេត្តកំពង់ធំ




ខេត្តកំពង់ធំ មាន ៨ស្រុក និងមានស្ទឹងសំខាន់ៗ ៣ ដែលហូរចូលទៅក្នុងបឹងទន្លេសាប គឺស្ទឹងសែន ស្ទឹងស្ទោង និងស្ទឹងជីនិត។ កិច្ចពិគ្រោះយោបល់ថ្នាក់ឃុំនិងថ្នាក់ខេត្ត បានផ្តោតលើប្រវត្តិនៃគ្រោះធម្មជាតិ ចាប់តាំងពីឆ្នាំ១៩៦០ រហូតដល់ពេលបច្ចុប្បន្ន។ គ្រោះធម្មជាតិដែលកើតឡើងញឹកញាប់ជាងគេ គឺមាន ទឹកជំនន់ ខ្យល់ព្យុះ និងភាពរាំងស្ងួត។ ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ មានបាតុភូត ខ្យល់ព្យុះ ផ្គររន្ទះ ទឹកជំនន់ញឹកញាប់ ការប្រែប្រួលរដូវភ្លៀងធ្លាក់ដូចជារដូវវស្សាចាប់ផ្តើមយឺត និងជំងឺរាតត្បាត ជាដើម។ ប្រជាជនបានជួបប្រទះទឹកជំនន់ និងផ្គររន្ទះញឹកញាប់ជាងមុន ដែលបណ្តាលឲ្យខូចខាតផ្ទះសំបែង ផលដំណាំ ស្រូវ និងហេដ្ឋារចនាសម្ព័ន្ធជនបទផ្សេងៗ។

គ្រោះធម្មជាតិដូចរៀបរាប់ខាងលើ បានប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតកម្មកសិកម្ម ជាពិសេស ដំណាំស្រូវ ផលិតកម្មសត្វ និងធនធានធម្មជាតិក្នុងខេត្ត។ កំណើនប្រជាជន ជាសម្ពាធមួយទៀតមកលើប្រព័ន្ធអេកូឡូស៊ី ដូចជា ការកាប់បំផ្លាញព្រៃឈើ ដែលជាការបំផ្លាញដល់ទីជម្រកជីវចម្រុះផងដែរ។ ជំងឺរាតត្បាតក្រោយពេលទឹកជំនន់ គឺជាបញ្ហាធំមួយទៀត។ ការសិក្សាបានរកឃើញថា ដោយសារភាពក្រីក្រ និងកង្វះខាតប្រព័ន្ធទឹកស្អាតនិងអនាម័យនោះ ប្រជាជនពុំមានលទ្ធភាព និងវិធានការគ្រប់គ្រាន់ ដើម្បីបង្ការនិងព្យាបាលជំងឺឡើយ។ គ្រោះធម្មជាតិ បានប៉ះពាល់ដល់សុខភាពមនុស្សនិងសត្វចិញ្ចឹម។ បញ្ហាគ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ បានប៉ះពាល់ជាទូទៅលើជីវភាពរស់នៅ និងសុខមាលភាពប្រជាជន។

កិច្ចពិភាក្សាក្នុងសិក្ខាសាលាថ្នាក់ឃុំ បានបង្ហាញថា ស្រុកសណ្ដាន់ និងស្រុកបារាយណ៍ មានភាពប្រឈមនឹងការប្រែប្រួលអាកាសធាតុខ្លាំងជាងគេ នៅក្នុងខេត្ត។ នៅស្រុកសណ្ដាន់ មានគ្រោះធម្មជាតិបីយ៉ាង គឺខ្យល់ព្យុះ និងរន្ទះ ទឹកជំនន់ និងជំងឺរាតត្បាត។ នៅស្រុកបារាយណ៍ គ្រោះទឹកជំនន់មានភាពធ្ងន់ធ្ងរជាងគេ ក្នុងចំណោមគ្រោះធម្មជាតិ ដូចបានរៀបរាប់ខាងលើ។ ចំណែកឯស្រុកទាំង ៦ ផ្សេងទៀត ក៏មានគ្រោះធម្មជាតិដែរ ប៉ុន្តែមានសភាពធូរស្រាលជាង។

## *ខេត្តពោធិ៍សាត់*

រូបភាព ៣៖ ប្រភេទនិងទំហំនៃការខូចខាត បណ្ដាលមកពីគ្រោះធម្មជាតិ ក្នុងខេត្តពោធិ៍សាត់




ខេត្តពោធិ៍សាត់ មាន៦ស្រុក។ ប្រវត្តិគ្រោះធម្មជាតិដែលគេអាចនៅចាំបាន មានតាំងពីឆ្នាំ១៩៥៨ មក នៅពេលមានទឹកជំនន់ដ៏ធំមួយដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឃុំតាលូ ក្នុងស្រុកបាកាន។ ខេត្តនេះបានជួបគ្រោះធម្មជាតិធំៗ និងកាន់តែញឹកញាប់ក្នុងទសវត្សរ៍ចុងក្រោយនេះ ដូចជា ទឹកជំនន់ ខ្យល់ព្យុះ រន្ទះ ភាពរាំងស្ងួត និងជំងឺរាតត្បាតដល់មនុស្ស និងសត្វចិញ្ចឹម។ ក្នុងចំណោមគ្រោះធម្មជាតិទាំងអស់នេះ គេរាយការណ៍ថា ទឹកជំនន់មានឥទ្ធិពលអាក្រក់ជាងគេ ដោយវាមានកម្រិតកាន់តែធំ និងមានរយៈពេលវែងជាងមុន។ ស្រដៀងគ្នានេះដែរ ភាពរាំងស្ងួតបានបំផ្លាញផលដំណាំធ្ងន់ធ្ងរ។ ជួនកាលមានកើតគ្រោះទឹកជំនន់ផង និងជួបភាពរាំងស្ងួតផងក្នុងឆ្នាំតែមួយ។ គេរាយការណ៍ទៀតថា មានការបាត់បង់ជីវិតមនុស្សកាន់តែច្រើនដោយសាររន្ទះបាញ់ បើប្រៀបធៀបជាមួយនឹងទសវត្សរ៍១៩៥០។

ស្រុកកណ្ដៀង មានភាពប្រឈមនឹងទឹកជំនន់ខ្លាំងជាងគេ។ ការសិក្សាបានកត់ត្រាថា ជំងឺរាតត្បាតក្នុងស្រុកនេះ ក្រោយពេលទឹកជំនន់ កើតមានយ៉ាងច្រើន ចំណែកឯភាពរាំងស្ងួត និងសត្វចង្រៃរាតត្បាត ស្ថិតនៅលំដាប់លេខរៀងទី២ និង ទី៣ នៃការបំផ្លាញដោយគ្រោះធម្មជាតិ (រូបភាព ២)។ បន្ទាប់ពីស្រុកកណ្ដៀងមក ស្រុកបាកាន ក៏ធ្លាប់ទទួលរងគ្រោះ ដោយសារទឹកជំនន់ញឹកញាប់

ដែរ។ គេប៉ាន់ស្មានថា ទឹកជំនន់ជាគ្រោះធំជាងគេ បន្ទាប់មក គឺភាពរាំងស្ងួតដែលបានកើតឡើងក្នុងស្រុកទាំងអស់នោះ។ ស្រុកក្រគរ ស្ថិតនៅលំដាប់លេខរៀងទី៣ ប៉ុន្តែក្រុមការងារមិនទាន់បានសិក្សាលំអិតនៅទីនោះទេ។

សហគមន៍ទាំងឡាយបានយល់ស្របគ្នាថា គ្រោះធម្មជាតិដូចបានរៀបរាប់ខាងលើ អាចមានសភាពធ្ងន់ធ្ងរ និងញឹកញាប់ជាងមុនថែមទៀត នៅពេលអនាគត។ ប្រព័ន្ធទឹកស្ទឹងកាន់តែកករាក់ បណ្តាលឲ្យមានទឹកជំនន់កាន់តែធំ និងកង្វះខាតទឹកក្នុងរដូវប្រាំងកាន់តែធ្ងន់ធ្ងរ ដោយសារកំណើនសីតុណ្ហភាព ដែលអាចជះឥទ្ធិពលដល់ការប្រែប្រួលកម្រិតនិងបរិមាណទឹកភ្លៀង ហើយនៅទីបំផុតជះឥទ្ធិពលកាន់តែអាក្រក់ទៅលើជីវភាពរស់នៅរបស់ប្រជាជន។

### *ខេត្តកំពង់ឆ្នាំង*

ខេត្តកំពង់ឆ្នាំងមានស្រុកចំនួន ៨។ គេចាំបានថា គ្រោះធម្មជាតិក្នុងខេត្តនេះ កើតមានតាំងពីឆ្នាំ១៩៥០ នៅពេលដែលទឹកទន្លេសាបបានជន់លិចផ្លូវជាតិលេខ៥។ កាលណោះស្រុកនៅជិតដងទន្លេ សុទ្ធតែទទួលរងគ្រោះ ដូចជា ស្រុកកំពង់ត្រឡាច រលាប្អៀរ បរិបូរ កំពង់លែង និងជលគីរី ជាដើម។ ទឹកជំនន់ ក៏បានធ្វើឲ្យខូចខាតផ្លូវថ្នល់ ស្រូវ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងប៉ះពាល់ដល់សុខភាពផងដែរ។

បើប្រៀបធៀបនឹង៥០ឆ្នាំមុន គ្រោះធម្មជាតិ ដូចជា ទឹកជំនន់ ខ្យល់ព្យុះ រន្ទះ និងភាពរាំងស្ងួត និងជំងឺរាតត្បាតលើមនុស្សនិងសត្វចិញ្ចឹម មានសភាពធ្ងន់ធ្ងរនិងញឹកញាប់ជាង (ស្ទើរតែរាល់ឆ្នាំ) ចាប់តាំងពីឆ្នាំ២០០០ ដល់ ២០១៣នេះ។ ប្រជាជនហៅទឹកជំនន់ថា ជំនន់ភ្នំ និងជំនន់ទន្លេ។ ប្រជាជនកត់សំគាល់ថា រដូវវស្សាបានចាប់ផ្តើមមានភ្លៀងធ្លាក់យឺតពេលប្រហែល ១ខែ ហើយរដូវរំហើយក្នុងឆ្នាំខ្លះលែងមានភាពរងារ។

រូបភាព ៤៖ ប្រភេទនិងទំហំនៃការខូចខាត បណ្តាលមកពីគ្រោះធម្មជាតិ ក្នុងខេត្តកំពង់ឆ្នាំង



បញ្ហានិងសកម្មភាពមួយចំនួន អាចចាត់បញ្ចូលថា បានចូលរួមបង្កការប្រែប្រួលអាកាសធាតុ ដូចជា កំណើនប្រជាជនដែលបានធ្វើឲ្យមានកំណើនតម្រូវការជាទូទៅ ជាដើម។ ការកាប់ឈើដើម្បីធ្វើគ្រឿងសង្ហារឹម ផ្ទះសំបែង ធ្វើអុស ធ្យូងក្នុងទ្រង់ទ្រាយធំ និងការផ្ដល់ព្រៃសម្បទានសេដ្ឋកិច្ច បានធ្វើឲ្យបាត់បង់ព្រៃឈើដែលជាប្រភពស្រូបយកឧស្ម័នកាបូនពីបរិយាកាស និងបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសថែមទៀត។ ការបាត់បង់ព្រៃឈើ បានធ្វើឲ្យសំណឹកកើនឡើងនៅទីជម្រាល និងកំណកបាតស្ទឹងកាន់តែកើនឡើងដែរ ជាហេតុធ្វើឲ្យមានទឹកជំនន់ឆាប់រហ័សក្នុងរដូវវស្សា និងការខ្សត់ទឹកក្នុងរដូវប្រាំង។ ប្រជាជនជួបប្រទះភាពរាំងស្ងួតស្ទើរតែរាល់ពីរឆ្នាំម្ដង។ ភាពរាំងស្ងួតបណ្ដាលឲ្យខូចខាតដំណាំរបស់ប្រជាជន នៅតាមកន្លែងដែលពុំមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់។

ស្រុកជលគីរី ទទួលចំណាត់ថ្នាក់ជាស្រុកងាយរងគ្រោះដោយសារទឹកជំនន់ខ្លាំងជាងគេ។ បន្ទាប់មក ស្រុកសាមគ្គីមានជ័យ ទឹកផុស និងរលាប្អៀរ ក៏គេចាត់ទុកជាស្រុកប្រឈមនឹងទឹកជំនន់ និងភាពរាំងស្ងួតដែរ (រូបភាព៤)។

## ៣.២. សមត្ថភាពបន្សាំ

កន្លងមក មានយន្តការមួយចំនួនដែលគេបានអនុវត្ត ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ យន្តការដ៏សំខាន់ជាងគេគឺ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមាននៅគ្រប់លំដាប់ថ្នាក់ តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ភូមិ។ គណៈកម្មាធិការនេះ ចែកចេញជា ៤ផ្នែកនៃការទទួលខុសត្រូវ គឺមាន៖ ផ្នែកប្រមូលព័ត៌មាន ផ្នែកជួយសង្គ្រោះបន្ទាន់ ផ្នែករៃអង្គាសថវិកា និងផ្នែកសុខភាព។ គណៈកម្មាធិការនេះ ដើរតួនាទីសំខាន់ណាស់ ក្នុងការដោះស្រាយបញ្ហាគ្រោះធម្មជាតិនានានៅក្នុងខេត្ត ក្នុងការទាក់ទង ការផ្ដល់ព័ត៌មាន ការស្រង់ស្ថិតិខូចខាតនិងបាត់បង់ និងការធ្វើផែនការជួយសង្គ្រោះ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ភូមិ ធ្វើសេចក្ដីរាយការណ៍ទៅថ្នាក់លើជាបន្តបន្ទាប់ អំពីទំហំនៃការខូចខាត ក៏ដូចជាតម្រូវការរបស់សហគមន៍។ គណៈកម្មាធិការនេះ ក៏ជួយផ្សព្វផ្សាយព័ត៌មាននិងជូនដំណឹងជាមុនបន្ត ស្ដីពីគ្រោះធម្មជាតិ តាមរយៈការផ្សព្វផ្សាយផ្ទាល់មាត់ស្ដីពីកម្ពស់ទឹកស្ទឹងនិងទន្លេ បរិមាណកម្រិតទឹកភ្លៀង ខ្យល់ព្យុះនិងទឹកជំនន់ ជាដើម ដែលប្រកាសឡើងដោយក្រសួងធនធានទឹក និងឧតុនិយម ដើម្បីឲ្យប្រជាជនបានដឹងជាមុន។ ក្នុងករណីធ្ងន់ធ្ងរ គឺមានជំនួយពីរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល ហើយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយចុះទៅធ្វើការជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីរៀបចំបែងចែកជំនួយសង្គ្រោះបន្ទាន់។

បណ្ដាមន្ទីរជំនាញក្នុងខេត្ត ក៏ដើរតួនាទីសំខាន់ដែរ ក្នុងការជួយប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ដូចជាការផ្ដល់ម៉ាស៊ីនបូមទឹកសង្គ្រោះដំណាំស្រូវនៅពេលរាំងស្ងួត ការផ្ដល់ពូជក្រោយពេលទឹកជំនន់ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធជនបទផ្សេងទៀត។ នៅតាមខេត្តនីមួយៗ មានស្ថានីយ៍វាស់កម្រិតកម្ពស់ទឹកភ្លៀង និងឧតុនិយម និងវាស់កម្ពស់ទឹកស្ទឹង។ ទិន្នន័យទាំងអស់នេះ ប្រមូលបញ្ជូនទៅឲ្យក្រសួងធនធានទឹក និងឧតុនិយម ដើម្បីតម្កល់ទុក សិក្សាវិភាគ និងធ្វើការផ្សព្វផ្សាយ។

នៅតាមភូមិ ឃុំ ស្រុក និងខេត្ត សុទ្ធតែមានការបង្កើតនូវទីទួលសុវត្ថិភាព សម្រាប់ទទួលជនរងគ្រោះដែលជន្លៀសមកដោយសារទឹកជំនន់។ ទីទួលសុវត្ថិភាពទាំងនោះ មានដូចជា ទីវត្តអារាម

សាលារៀន ជាដើម។ ក្រុមប្រឹក្សាឃុំ សង្កាត់ ចូលរួមធ្វើការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីជួយដោះស្រាយបញ្ហាបន្ទាន់ៗរបស់សហគមន៍ក្នុងពេលដំបូងបង្អស់ នៅមុនពេលខាងកាកបាទក្រហមចុះទៅដល់។

ជាទូទៅ នៅគ្រប់ប្រព័ន្ធធារាសាស្ត្រ តែងមានសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ជាអ្នកគ្រប់គ្រងនិងដំណើរការបែងចែកទឹកស្រោចស្រព។ សកបទ ក៏ដើរតួនាទីសំខាន់ដែរ ក្នុងការជួយប្រមូលទិន្នន័យ កម្ពស់ទឹកក្នុងអាងប្រព័ន្ធធារាសាស្ត្រ។ ប៉ុន្តែ សមត្ថភាពជំនាញ និងបច្ចេកទេសរបស់សហគមន៍នៅមានកម្រិត និងមិនអាចឆ្លើយតបទាន់ពេលវេលានៅពេលមានគ្រោះធម្មជាតិកើតឡើងនោះទេ។ ការសិក្សាបានរកឃើញថា មានកត្តាបី ដែលជាបញ្ហាប្រឈម ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋានគឺ កត្តាសង្គម សេដ្ឋកិច្ច និងអភិបាលកិច្ច។

ភាពក្រីក្រ គឺជាបញ្ហាសង្គមយ៉ាងធំ ហើយសហគមន៍មិនមានលទ្ធភាព និងធនធានគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាបណ្តាលមកពីគ្រោះធម្មជាតិនោះទេ។ ដោយការលូតលាស់សេដ្ឋកិច្ចមូលដ្ឋាននៅមានកម្រិត ដូច្នេះថវិកាក៏នៅខ្វះខាតសម្រាប់ជួសជុលហេដ្ឋារចនាសម្ព័ន្ធបម្រើការអភិវឌ្ឍន៍សេដ្ឋកិច្ច បណ្តាលឲ្យផ្លូវថ្នល់ត្រូវខូចខាត ប្រព័ន្ធធារាសាស្ត្រចាស់ទ្រុឌទ្រោម មិនអាចស្តុកទឹកសម្រាប់ប្រើប្រាស់ក្នុងរដូវប្រាំងបានច្រើនទេ។ ប្រជាជនខ្វះការងារធ្វើ ធ្វើឲ្យមានភាពខ្វះខាតក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ គ្រួសារក្រីក្រ ខ្វះខាតថវិកា និងសម្ភារៈផលិតកម្មកសិកម្ម ដើម្បីស្តារជីវភាព ក្រោយពេលគ្រោះធម្មជាតិកើតឡើង។ ចំណែកកត្តាអភិបាលកិច្ច និងការគ្រប់គ្រងវិញ ថ្វីត្បិតនៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលមូលដ្ឋាន តែងមានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្តី ក៏នៅតែមិនទាន់មានយន្តការនិងផែនការដ៏មានប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហាទឹកជំនន់ គ្រោះរាំងស្ងួត និងសុខភាពមនុស្សនិងសត្វចិញ្ចឹម ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិញឹកញាប់នេះទេ។ ម្យ៉ាងទៀត ស្ថាប័នជំនាញក៏នៅមិនទាន់បានសហការគ្នាល្អ ដែលបង្កឧបសគ្គដល់ការស្តារជីវភាពរស់នៅរបស់ប្រជាជនក្រោយពេលជួបគ្រោះធម្មជាតិ។

### ៣.៣. វិបាក ចំពោះអភិបាលកិច្ចធនធានទឹក

ការសិក្សាខិតខំស្វែងយល់ពីយន្តការ និងតម្រូវការរបស់សហគមន៍ ក្នុងការពង្រឹងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងខេត្តទាំងបីគឺ កំពង់ធំ ពោធិ៍សាត់ និងកំពង់ឆ្នាំង។ សមាជិកសហគមន៍ដែលបានចូលរួមនៅក្នុងការសិក្សានេះ ភាគច្រើនត្រូវការថែមទៀតនូវការផ្សព្វផ្សាយស្តីពីការពង្រឹងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ការពង្រឹងការគ្រប់គ្រងទឹក និងប្រព័ន្ធធារាសាស្ត្រនៅតាមសហគមន៍។ កិច្ចសហការល្អរវាងស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ចាំបាច់បំផុត ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការជួយកសាងផែនការយុទ្ធសាស្ត្រ និងអនុវត្តផែនការនោះឲ្យបានជោគជ័យ។

ការផ្តល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា គមនាគមន៍ សុខភាព ការសិក្សាអប់រំ និងធារាសាស្ត្រកសិកម្ម គឺជាសេវាដ៏ចាំបាច់ ដើម្បីពង្រឹងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ រចនាសម្ព័ន្ធសហគមន៍មានស្រាប់ ដូចជា សកបទ ជាដើម អាចជួយពង្រឹងការបែងចែកទឹកស្រោចស្រពកសិកម្មបាន ប៉ុន្តែសហគមន៍ទាំងនោះត្រូវការជំនួយបច្ចេកទេស និងថវិកា ដើម្បីអនុវត្តកិច្ចការទាំងនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

ម្យ៉ាងទៀត ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានកម្រិតនិងលក្ខណៈខុសៗគ្នា ពីឃុំឬស្រុកមួយ ទៅឃុំឬស្រុកមួយទៀត ក៏ដូចជាពីខេត្តមួយទៅខេត្តមួយទៀត។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន ត្រូវដឹងពីភាពប្រឈមរបស់មូលដ្ឋានខ្លួនចំពោះទឹកជំនន់ ខ្យល់ព្យុះ រន្ទះបាញ់ ឬភាពរាំងស្ងួត ដើម្បីត្រៀមលក្ខណៈ ក្នុងការទាក់ទងជាមួយថ្នាក់លើ និងធ្វើផែនការត្រៀមទុកជាមុន។

យន្តការមួយទៀត ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺការផ្លាស់ប្តូរទម្លាប់ដាំដុះ និងការប្រើប្រាស់ពូជដំណាំដែលធន់នឹងអាកាសធាតុប្រែប្រួលខ្លាំង។ ដើម្បីអនុវត្តយន្តការនេះ រដ្ឋាភិបាលត្រូវផ្តល់សេវាផ្សព្វផ្សាយកសិកម្មឲ្យបានទូលំទូលាយដល់កសិករ ដើម្បីសាកល្បងនិងបញ្ជាក់ពីវិធីសាស្រ្តដាំដុះ ការសន្សំសំចៃទឹក និងកាលបរិច្ឆេទនៃការដាំដុះបែបថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ សកបទ ត្រូវការព័ត៌មានស្តីពីនិន្នាការនៃការប្រែប្រួលរបបជលសាស្រ្តនៅតាមស្ទឹង និងប្រព័ន្ធធារាសាស្រ្ត ដែលខ្លួនគ្រប់គ្រង ដើម្បីងាយស្រួលធ្វើផែនការបែងចែកទឹកស្រោចស្រព។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសិក្សានេះ បានចងក្រងប្រវត្តិនៃគ្រោះធម្មជាតិ នៅក្នុងខេត្តគោលដៅទាំងបីគឺ កំពង់ធំ ពោធិ៍សាត់និងកំពង់ឆ្នាំងដោយមានការបែងចែកទំហំនៃការខូចខាតទៅតាមស្រុកនីមួយៗចាប់តាំងពីឆ្នាំ១៩៥០ដល់២០១៣។ការសិក្សាបង្ហាញថាមានគ្រោះធម្មជាតិធំៗបួនបែបដែលបានកើតឡើងនៅក្នុងខេត្តទាំងបីគឺៈ ទឹកជំនន់ ភាពរាំងស្ងួត ខ្យល់ព្យុះនិងរន្ទះ និងជំងឺរាតត្បាតដល់មនុស្សនិងសត្វចិញ្ចឹម។ ទឹកជំនន់គេចាត់ទុកវាថា ជាគ្រោះធម្មជាតិកើតមានញឹកញាប់ និងមានទំហំខូចខាតធំជាងគេបង្អស់ ក្នុងចំណោមគ្រោះធម្មជាតិទាំងបួនប្រភេទ រីឯភាពរាំងស្ងួតជាគ្រោះធម្មជាតិធំទី២។ គ្រោះធម្មជាតិទឹកជំនន់ ខ្យល់ព្យុះ និងភាពរាំងស្ងួត បានកើតមានកាន់តែញឹកញាប់ឡើង និងមានទំហំខូចខាតកាន់តែធំ។ គ្រោះធម្មជាតិកើតមានស្ទើរតែរៀងរាល់ឆ្នាំ ជាពិសេស ក្នុងទសវត្សរ៍ចុងក្រោយនេះ (លើកលែងតែឆ្នាំ២០០៣ និង ២០០៨)។ បើផ្អែកលើនិន្នាការកំណើននេះ គ្រោះធម្មជាតិអាចកាន់តែធ្ងន់ធ្ងរឡើងទៀត ទៅថ្ងៃអនាគត។

ជារួម ខេត្តទាំងបីជួបគ្រោះធម្មជាតិប្រហាក់ប្រហែលគ្នា ប៉ុន្តែមានភាពខុសប្លែកគ្នាទៅតាមស្រុកនីមួយៗ អាស្រ័យលើ ទីតាំងភូមិសាស្រ្តនៅក្បែរផ្លូវទឹក ( ទន្លេ ស្ទឹង បឹង ) ព្រោះទីតាំងបែបនេះអាចប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ ផ្ទុយទៅវិញ ទីតាំងភូមិសាស្រ្តស្ថិតនៅឆ្ងាយពីផ្លូវទឹកតែងជួបប្រទះគ្រោះរាំងស្ងួតខ្លាំងជាង តំបន់នៅជិតផ្លូវទឹក។ ស្រុកសណ្តាន់ក្នុងខេត្តកំពង់ធំ ស្រុកកណ្តៀងក្នុងខេត្តពោធិ៍សាត់ និងស្រុកជលគីរី ក្នុងខេត្តកំពង់ឆ្នាំង ត្រូវប្រឈមនឹងទឹកជំនន់ខ្លាំងជាងគេ។ ប្រជាជនដែលក្រីក្រជាងគេ តែងងាយរងគ្រោះខ្លាំងបំផុត ព្រោះពុំមានសមត្ថភាពផ្នែកសម្ភារៈនិងធនធាន សម្រាប់ទប់ទល់នឹងផលប៉ះពាល់នៃគ្រោះធម្មជាតិទាំងនោះ។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ជាយន្តការរបស់រាជរដ្ឋាភិបាល ដើម្បីជួយដោះស្រាយបញ្ហាគ្រោះមហន្តរាយនៅថ្នាក់មូលដ្ឋាន។ យន្តការនេះដើរតួសំខាន់ណាស់ ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលកើតមានឡើង នៅថ្នាក់មូលដ្ឋាន ។ ប៉ុន្តែប្រសិទ្ធភាពនៃការអនុវត្តយន្តការនេះ នៅមានកម្រិតនៅឡើយ។ ការឆ្លើយតបចំពោះគ្រោះទឹកជំនន់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះមានការយឺតយ៉ាវ និងមិនទាន់ពេលវេលា។ អន្តរាគមន៍ភាគច្រើន បានមកពីកាកបាទក្រហមកម្ពុជា

ព្រោះគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ពុំមានថវិកា ឧបករណ៍ សម្ភារៈ និងធនធានមនុស្ស គ្រប់គ្រាន់ ដើម្បីអនុវត្តការងារនេះឡើយ។

ការសិក្សានេះ មានអនុសាសន៍មួយចំនួន សម្រាប់ឲ្យអ្នកពាក់ព័ន្ធទាំងឡាយ យកទៅពិចារណា៖

ទី១៖ ទឹកភ្លៀងមានការប្រែប្រួល (ទាំងបរិមាណនិងភាពញឹកញាប់)។ ការណែនាំនូវពូជដំណាំថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងបច្ចេកទេសបង្កើនទិន្នផល ដែលអាចឲ្យកសិករបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពខ្ពស់បំផុតមួយ។

ទី២៖ វិធានការត្រៀមទុកជាមុននូវ ស្បៀង សម្ភារៈបរិក្ខារចាំបាច់ និងផែនការស្តារជីវភាព នៅក្រោយពេលគ្រោះធម្មជាតិ គួរគិតគូររៀបចំឲ្យរួចជាស្រេច និងមានជាស្រេច នៅតាមមូលដ្ឋាន។

ទី៣៖ សេវាផ្សព្វផ្សាយ ពីគ្រោះធម្មជាតិនិងផលប៉ះពាល់របស់វា ត្រូវធ្វើឲ្យបានដល់មូលដ្ឋាន ភូមិ ឃុំ ដើម្បីបង្រៀនប្រជាជនមូលដ្ឋាន ឲ្យយល់ពីហានិភ័យនៃគ្រោះធម្មជាតិ ពីការត្រៀមខ្លួនទប់ទល់ចំពោះហេតុការណ៍ដែលអាចនឹងកើតឡើង និងដើម្បីកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ទី៤៖ ទំនាក់ទំនង និងសហការរវាងភូមិ ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ ត្រូវធ្វើឲ្យមានប្រសិទ្ធភាព និងបានទាន់ពេលវេលា ដើម្បីផ្សព្វផ្សាយព័ត៌មានទាន់ហេតុការណ៍ និងអាចឆ្លើយតបទាន់ពេលវេលាចំពោះតម្រូវការចាំបាច់របស់ជនរងគ្រោះ។

ទី៥៖ ព្យាករណ៍ធាតុអាកាស ខ្យល់ព្យុះ ភាពរាំងស្ងួត គឺជាព័ត៌មានសំខាន់ណាស់ ក្នុងការជូនដំណឹងជាមុនពីគ្រោះហានិភ័យនានា។ ប្រព័ន្ធព័ត៌មាន ការជូនដំណឹងជាមុន ត្រូវដាក់នៅតាមតំបន់គោលដៅនៃគ្រោះធម្មជាតិសំខាន់ៗនៃបណ្តាស្រុក និងខេត្តគោលដៅ ហើយព័ត៌មានទាំងអស់នេះ ត្រូវផ្សព្វផ្សាយដល់ប្រជាជនគោលដៅឲ្យទាន់ហេតុការណ៍ មុនពេលគ្រោះកាចមកដល់។

ទី៦៖ ការឆ្លើយតបទាន់ៗ និងកិច្ចខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពបន្សាំ ត្រូវផ្តោតឲ្យបានខ្លាំងថែមទៀត ទៅលើប្រជាជនក្រីក្រជាងគេ ព្រោះជាក្រុមងាយរងគ្រោះខ្លាំងបំផុត ដោយសារការប្រែប្រួលអាកាសធាតុ។

## ឯកសារយោង

Eastham, J., F. Mpelasoka, M. Mainuddin, C. Ticehurst, P. Dyce, G. Hodgson, R. Ali and M. Kirby (2008), "Mekong River Basin Water Resources Assessment: Impacts of Climate Change", Water for a Healthy Country National Research Flagship (Canberra: CSIRO)

IPCC, Intergovernmental Panel on Climate Change (2001), "Annex B: Glossary of Terms", in R.T. Watson and the Core Writing Team (eds.), *Climate Change 2001: Synthesis Report Contributions of Working Group II to the Third Assessment Report of the Intergovernmental Panel on Climate Change* (Cambridge; New York: Cambridge University Press)

Keskinen, Marko, Matti Kummu, Aura Salmivaara, Paradis Someth, Hannu Lauri, Hans de Moel, Philip Ward and Sokhem Pech (2012), "Tonle Sap Now and in the Future?" final report of the Exploring Tonle Sap Futures study, Aalto University and 100Gen Ltd with Hatfield Consultants Partnership, VU University Amsterdam, EIA Ltd. and Institute of Technology of Cambodia, in partnership with Tonle Sap Authority and Supreme National Economic Council (Espoo, Finland: Water and Development Publications WD11, Aalto University)

Yusuf, Anshory and Herminia Francisco (2009), "Climate Change Vulnerability Mapping for Southeast Asia" (Singapore: Economy and Environment Program for Southeast Asia)

# -១០-
# ការធ្វើឲ្យវិស័យទេសចរណ៍នៅកម្ពុជា មានភាពបៃតង: សក្តានុពល ឧបសគ្គ និង ជម្រើសគោលនយោបាយ[១]

*ដោយ លន់ ពេជ្រតារា*[១]

## ១. សេចក្តីផ្តើម

វិស័យទេសចរណ៍គេបានចាត់ទុកថា មានអាទិភាពខ្ពស់ក្នុងចំណោមវិស័យអាទិភាពនានានៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍន៍ សមធម៌ និងប្រសិទ្ធភាព (RGC, 2012) ដោយមានការទទួលស្គាល់ថា បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមតាមរយៈ ការបង្កើតការងារនិងប្រាក់ចំណូល បានធ្វើឲ្យកម្រិតជីវភាពកើនឡើង ជួយកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការអភិវឌ្ឍបៃតង (MoT 2012a)។ វិស័យនេះមិនត្រឹមតែផ្តល់នូវប្រាក់ចំណូលសន្ទឹកសន្ធាប់ជំរុញកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយធ្វើឲ្យមានតុល្យភាពពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មក្នុងតំបន់ និងអន្តរជាតិ (MoT 2012a)។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យទេសចរណ៍ បានទាក់ទាញភ្ញៀវទេសចរប្រមាណ ៣លាននាក់ ក្នុងមួយឆ្នាំៗ ដោយបានផ្តល់នូវចំណូលពីបរទេសស្មើនឹង ២៦% នៃ ផសស (ផសស កម្ពុជាមានទំហំ ១៤.០៦២លានដុល្លារ ក្នុងឆ្នាំ២០១២) និងបានផ្តល់ ១,៨លានការងារដែលស្មើនឹង ២២% នៃការងារសរុបនៅកម្ពុជា (តារាង ១)។ គណៈកម្មការទេសចរណ៍ និងការធ្វើដំណើរក្នុងពិភពលោក បានប៉ាន់ស្មានថា វិស័យទេសចរណ៍នៅកម្ពុជាបានបង្កើតការងារ និង ប្រាក់ចំណូល បានច្រើនជាងនៅប្រទេសនានាឯទៀតនៅអាស៊ីអាគ្នេយ៍ (តារាង ១)។

វិស័យទេសចរណ៍នៅកម្ពុជាបានកើនឡើងក្នុងអត្រា ២០% ទៅ ៣០% ចាប់តាំងពីឆ្នាំ ១៩៩៧ បន្ទាប់ពីមានការបើកឲ្យប្រើអាកាសយានដ្ឋានអន្តរជាតិក្រុងសៀមរាប ដែលជាទីប្រជុំនៃប្រាសាទបុរាណ ជាពិសេស ប្រាសាទអង្គរវត្ត។ ភ្ញៀវទេសចរជាតិមានចំនួន ៨,២លាននាក់ (កើន ៣% ធៀបនឹងឆ្នាំមុន) ចំណែកឯភ្ញៀវទេសចរអន្តរជាតិ មាន ៣,៥លាននាក់ នៅឆ្នាំ២០១២ (តារាង ៣) ឬកើន ២៤% បើធៀបនឹងឆ្នាំ២០១១ (MoT 2012b)។ គេសង្កេតឃើញថា ភ្ញៀវទេសចរមកពីប្រទេសជិតខាង និងក្នុងតំបន់ បានកើនឡើងយ៉ាងខ្លាំង ជាពិសេស មកពីប្រទេសវៀតណាម កូរ៉េ ចិន ឡាវ និងថៃ (តារាង ២) ដែលបង្ហាញពីសក្តានុពលយ៉ាងធំសម្រាប់វិស័យទេសចរណ៍កម្ពុជានាពេលអនាគត។ ទោះបីនៅអឺរ៉ុបមានស្ថានភាពសេដ្ឋកិច្ចមិនសូវល្អក្តី ក៏ទេសចរមកពីអឺរ៉ុបតាមផ្លូវអាកាសបានកើនឡើង ២៤% បើធៀបនឹងឆ្នាំមុន (MoT 2012b)។

---

[១] រៀបចំដោយ លន់ ពេជ្រតារា ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI, អត្ថបទនេះដកស្រង់ចេញពី Ellis *et al.* (2013)។

តារាង ១៖ ការរួមចំណែករបស់វិស័យទេសចរណ៍ក្នុងការបង្កើតប្រាក់ចំណូល និងការងារ ក្នុងឆ្នាំ២០១២

| ប្រទេស | ការចូលរួមចំណែកក្នុងការបង្កើតប្រាក់ចំណូល (ជា % នៃ ផសស) | | ការចូលរួមចំណែកក្នុងការបង្កើតការងារ (ជា % នៃការងារសរុប) | |
|---|---|---|---|---|
| | ដោយផ្ទាល់ | សរុប (ដោយផ្ទាល់ + ដោយប្រយោល) | ដោយផ្ទាល់ | សរុប (ដោយផ្ទាល់ + ដោយប្រយោល) |
| កម្ពុជា | 11.5 | 25.8 | 9.7 | 22.3 |
| ឡាវ | 5.3 | 16.7 | 4.5 | 14.6 |
| ថៃ | 7.3 | 16.7 | 5.2 | 12.4 |
| ម៉ាឡេស៊ី | 7.0 | 15.6 | 6.5 | 13.6 |
| សិង្ហបុរី | 5.2 | 11.3 | 4.4 | 9.1 |
| វៀតណាម | 4.5 | 9.4 | 3.8 | 8.1 |
| ឥណ្ឌូនេស៊ី | 3 | 8.9 | 2.6 | 8 |
| ហ្វីលីពីន | 2.0 | 7 | 2.0 | 7.7 |
| ប្រ៊ុយណេ | 1.8 | 5.8 | 2.6 | 6.8 |
| មីយ៉ាន់ម៉ា | 1.3 | 3 | 1.1 | 2.6 |

ប្រភព៖ World Travel & Tourism Council: Economic Impact 2013

តារាង ២៖ ទីផ្សារធំៗទាំង ៥ របស់វិស័យទេសចរណ៍កម្ពុជាពីឆ្នាំ២០០៥ ដល់ ២០១២

| ចំណាត់ថ្នាក់ | សញ្ជាតិ | % នៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុប | ចំណាត់ថ្នាក់ | សញ្ជាតិ | % នៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុប |
|---|---|---|---|---|---|
| ២០០៥ | | | ២០០៦ | | |
| 1 | កូរ៉េ | 15.2 | 1 | កូរ៉េ | 16.8 |
| 2 | ជប៉ុន | 9.7 | 2 | ជប៉ុន | 9.3 |
| 3 | សហរដ្ឋអាមេរិក | 7.7 | 3 | សហរដ្ឋអាមេរិក | 7.3 |
| 4 | បារាំង | 4.8 | 4 | តៃវ៉ាន់ | 5.0 |
| 5 | អង់គ្លេស | 4.7 | 5 | ចិន | 4.7 |
| ២០០៧ | | | ២០០៨ | | |
| 1 | កូរ៉េ | 16.4 | 1 | កូរ៉េ | 12.5 |
| 2 | ជប៉ុន | 8.0 | 2 | វៀតណាម | 9.9 |
| 3 | សហរដ្ឋអាមេរិក | 6.8 | 3 | ជប៉ុន | 7.7 |
| 4 | វៀតណាម | 6.2 | 4 | សហរដ្ឋអាមេរិក | 6.8 |
| 5 | ចិន | 5.9 | 5 | ចិន | 6.1 |

| ២០០៩ | | | ២០១០ | | |
|---|---|---|---|---|---|
| 1 | វៀតណាម | 14.6 | 1 | វៀតណាម | 20.5 |
| 2 | កូរ៉េ | 9.1 | 2 | កូរ៉េ | 11.5 |
| 3 | សហរដ្ឋអាមេរិក | 6.9 | 3 | ចិន | 7.1 |
| 4 | ជប៉ុន | 6.8 | 4 | ជប៉ុន | 6.1 |
| 5 | ចិន | 5.9 | 5 | សហរដ្ឋអាមេរិក | 5.8 |
| ២០១១ | | | ២០១២ | | |
| 1 | វៀតណាម | 21.3 | 1 | វៀតណាម | 21.3 |
| 2 | កូរ៉េ | 11.9 | 2 | កូរ៉េ | 11.5 |
| 3 | ចិន | 8.6 | 3 | ចិន | 9.3 |
| 4 | ជប៉ុន | 5.6 | 4 | ឡាវ | 7.1 |
| 5 | សហរដ្ឋអាមេរិក | 5.3 | 5 | ថៃ | 5.6 |

ប្រភព៖ យកពី Hem Socheat (2013)

## តារាង ៣៖ ព័ត៌មានទេសចរណ៍នានា

| ឆ្នាំ | ភ្ញៀវទេសចរអន្តរជាតិមកដល់ | | ការស្នាក់នៅជាមធ្យម | សណ្ឋាគារ | ផ្ទះសំណាក់ | អត្រាមានភ្ញៀវស្នាក់នៅក្នុងសណ្ឋាគារ | ចំណូលពីទេសចរណ៍ |
|---|---|---|---|---|---|---|---|
| | ចំនួន (នាក់) | % ប្រែប្រួល | ចំនួនថ្ងៃ | ចំនួន | ចំនួន | (%) | លានដុល្លារ |
| **1998** | **286524** | **30.9** | **5.2** | **216** | **147** | **40** | **166** |
| 1999 | 367743 | 28.3 | 5.5 | 221 | 186 | 44 | 190 |
| 2000 | 466365 | 26.8 | 5.5 | 240 | 292 | 45 | 228 |
| 2001 | 604919 | 29.7 | 5.5 | 247 | 370 | 48 | 304 |
| 2002 | 786524 | 30 | 5.8 | 267 | 489 | 50 | 379 |
| 2003 | 701014 | -10.9 | 5.5 | 292 | 549 | 50 | 347 |
| 2004 | 1055202 | 50.5 | 6.3 | 299 | 615 | 52 | 578 |
| 2005 | 1421615 | 34.7 | 6.3 | 317 | 684 | 52 | 832 |
| 2006 | 1700041 | 19.6 | 6.5 | 351 | 742 | 54.79 | 1049 |
| 2007 | 2015128 | 18.5 | 6.5 | 395 | 891 | 54.79 | 1400 |
| **2008** | **2125465** | **5.5** | **6.65** | **398** | **925** | **62.68** | **1595** |
| 2009 | 2161577 | 1.7 | 6.45 | 451 | 1018 | 63.57 | 1561 |
| 2010 | 2508289 | 16 | 6.45 | 440 | 1087 | 65.74 | 1786 |
| 2011 | 2881862 | 14.9 | 6.5 | na | na | 66.15 | 1912 |
| 2012 | 3584307 | 24.4 | 6.3 | na | na | 68.49 | 2210 |

ប្រភព៖ ក្រសួងទេសចរណ៍ 2012b, វិទ្យាស្ថានជាតិស្ថិតិ 2012

ចំណូលបានមកពីទេសចរណ៍មានដល់ទៅ ២២១០លានដុល្លារ នៅឆ្នាំ២០១២ (តារាង ៣)។ ជាមធ្យមភ្ញៀវទេសចរបរទេសម្នាក់ចំណាយ ៤១០ដុល្លារ និងស្នាក់នៅ ៦,៣ថ្ងៃ ក្នុងការមកកំសាន្តមួយលើកនៅកម្ពុជា រីឯទេសចរណ៍ជាក្រុមវិញចំណាយអស់ ១១០០ដុល្លារក្នុងមួយក្រុមក្នុងមួយលើក (NIS 2012)។ ដោយសារតម្រូវការកន្លែងស្នាក់នៅរបស់ភ្ញៀវកើនឡើង ដូចនេះចំនួនផ្ទះសំណាក់ និងសណ្ឋាគារ ក៏កើនឡើងជាលំដាប់ដែរ ។ នៅឆ្នាំ២០១០ មានសណ្ឋាគារចំនួន ៤៤០ ដោយជាមធ្យម សណ្ឋាគារមួយមាន ៥៥បន្ទប់ រីឯផ្ទះសំណាក់មានចំនួនសរុប ១,០៨៧ ដោយជាមធ្យម ផ្ទះសំណាក់មួយមាន ១៤បន្ទប់ (NIS 2012)។

អង្គការវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum: WEF) បានឲ្យដឹងថា ខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ មានជាអាទិ៍ សន្តិសុខ សុវត្ថិភាព សុខភាពអនាម័យ និងធនធានវប្បធម៌ កម្ពុជាបានឈានឡើងពីចំណាត់ថ្នាក់លេខ១០៩ នៅឆ្នាំ២០១១ មកលេខ១០៦ ក្នុងចំណោម ១៤០ប្រទេស នៅឆ្នាំ២០១៣ (CDRI 2013; WEF 2013)។ កម្ពុជាក៏កំពុងប្រឹងប្រែងកែលំអវិស័យនេះឡើងទៀត ឲ្យមានការទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដែលអាចធ្វើឲ្យកម្ពុជាទទួលបាននូវផលចំណេញផ្សេងៗដោយផ្ទាល់ ឬដោយប្រយោល ដូចជា បន្ទុកចំណាយតិចជាងមុនក្នុងការធ្វើអាជីវកម្ម និង កំណើនសមត្ថភាពប្រកួតប្រជែង នៅពេលមានការពង្រឹងចំណងទាក់ទងក្នុងតំបន់ ដូចជា ការចូលជាសមាជិកក្នុងមហាអនុតំបន់មេគង្គ(GMS) សមាគមអាស៊ាន (ASEAN) និងអាស៊ានបូក៣ (ASEAN+3) ជាដើម (CDRI 2013)។

នៅពេលដែលវិស័យទេសចរណ៍បាននឹងកំពុងផ្តល់នូវ ប្រភពចំណូលដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ វិស័យនេះបានជួបឧបសគ្គ ៣ ដែលអាចធ្វើឲ្យចុះខ្សោយដល់សមត្ថភាពប្រកួតប្រជែង គឺមាន៖ ១)ឥទ្ធិពលនៃការកាន់តែខ្សត់ខ្សោយធនធានធម្មជាតិ ២) គោលនយោបាយអន្តរជាតិទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និង ៣) ការប្រែប្រួលអាកាសធាតុនេះតែម្តង (Ellis 2013)។ ក្នុងបរិបទនេះ តើនឹងមានផលប៉ះពាល់ កត្តាគំរាមកំហែង ឬកាលានុវត្តភាពបែបណាខ្លះទៅលើសមត្ថភាពប្រកួតប្រជែង និងការរីកចម្រើនវិស័យទេសចរណ៍នៅកម្ពុជា? តើអ្នកបង្កើតគោលនយោបាយ និងអ្នកធ្វើអាជីវកម្មក្នុងវិស័យនេះ គួរត្រៀមខ្លួន និងឆ្លើយតបយ៉ាងណាដែរ? (Ellis 2013) ។

ការសិក្សានេះព្យាយាមស្វែងយល់ពីបញ្ហាប្រឈមក្នុងមួយទសវត្សរ៍ខាងមុខ ជាពិសេសការធ្វើឲ្យវិស័យទេសចរណ៍មានភាពបៃតង ពោលគឺ មិនប៉ះពាល់ ឬបំពុលបរិស្ថាន។ ការសិក្សានេះជាករណីសិក្សាដែលបានប្រើមធ្យោបាយមួយចំនួន ដូចជា ការប្រមូលព័ត៌មានដែលមានស្រាប់ ការធ្វើសម្ភាសន៍បុគ្គលដែលផ្តល់ ព័ត៌មានសំខាន់ៗ និងការធ្វើសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ។ សម្ភាសន៍បានធ្វើឡើងចាប់ពីថ្ងៃទី ១៨ ដល់ ២៧ កុម្ភៈ ២០១៣ ជាមួយនឹងតំណាងមន្ទីរស្ថាប័នពាក់ព័ន្ធចំនួន ២២នាក់ ដូចជា មន្ត្រីក្រសួងបរិស្ថាន, ឧត្តមក្រុមប្រឹក្សាជាតិកម្ពុជា, អាជ្ញាធរអគ្គិសនី, ធនាគារអភិវឌ្ឍន៍ជនបទ, សមាគមអ្នកសេដ្ឋកិច្ចកម្ពុជា, អង្គការមិនមែនរដ្ឋាភិបាល ដូចជា សង្គមអភិរក្សសត្វព្រៃ WCS មូលនិធិសត្វព្រៃពិភពលោក WWF និង អង្គការម្លប់បៃតង, វិស័យឯកជនរួមមានសណ្ឋាគារចំនួន៣និងសហគមន៍អេកូទេសចរណ៍ចំបក់។សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិបានធ្វើឡើងនៅថ្ងៃទី២៤ កក្កដា ២០១៣ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ៥៥រូប។ ការសិក្សានេះមិនបានផ្តល់ជាអនុសាសន៍គោលនយោបាយលំអិតលើវិស័យនេះទេ ប៉ុន្តែបានបង្ហើប

បង្ហាញនូវគោលផ្លូវដើរ ការឆ្លើយតប និងដំណោះស្រាយមួយចំនួនចំពោះបញ្ហាប្រឈមផ្សេងៗ ដែលអាចផុសឡើងនាពេលខាងមុខ។ ការឆ្លើយតប និងដំណោះស្រាយនានានៅក្នុងអត្ថបទនេះ ទាមទារឲ្យមានការពិភាក្សា និងការសិក្សាលំអិតថែមទៀត។

## ២. សក្តានុពលសម្រាប់ទេសចរណ៍ធម្មជាតិនៅកម្ពុជា

### ២.១. ទេសចរណ៍ប្រកបដោយនិរន្តរភាព

បច្ចុប្បន្ននេះ ពាក្យ "ទេសចរណ៍ប្រកបដោយនិរន្តរភាព" គេកំពុងប្រើប្រាស់កាន់តែច្រើនឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃទេសចរណ៍បែបប្រមូលផ្តុំមនុស្សច្រើន (mass tourism) (Shoko nd)។ និយមន័យទេសចរណ៍ប្រកបដោយនិរន្តរភាព មាននៅក្នុងប្រអប់ ១៖

**ប្រអប់ ១៖ និយមន័យរបស់អង្គការសហប្រជាជាតិស្តីអំពីទេសចរណ៍ប្រកបដោយនិរន្តរភាព**

ក្នុងន័យសាមញ្ញ៖

"គឺជាទេសចរណ៍ដែលទទួលខុសត្រូវទាំងស្រុងចំពោះហេតុប៉ះពាល់ទៅលើ កត្តាសេដ្ឋកិច្ច សង្គម និងបរិស្ថានរបស់សង្គមជាតិនាពេលបច្ចុប្បន្ន និងទៅអនាគត ដោយឆ្លើយតបបានទៅនឹងតម្រូវការរបស់ភ្ញៀវទេសចរ ឧស្សាហកម្ម ទេសចរណ៍ បរិស្ថាន និងសហគមន៍ដែលជាម្ចាស់និងជាអ្នកទទួលភ្ញៀវ។

ក្នុងន័យធំទូលាយ ទេសចរណ៍ប្រកបដោយនិរន្តភាពគឺ:

1. ធ្វើការប្រើប្រាស់ធនធានបរិស្ថានឲ្យបានសមល្មម ហើយអាចក្លាយជាផ្នែកសំខាន់មួយក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ដែលការពារប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ និងជួយអភិរក្សកេរ្តិ៍មរតក និងជីវចម្រុះ។
2. គោរពនូវប្រភពដើមនៃសង្គមវប្បធម៌របស់សហគមន៍ជាម្ចាស់ទឹកដី និងជាម្ចាស់ផ្ទះ ដោយចូលរួមអភិរក្សកេរ្តិ៍មរតកវប្បធម៌រស់រវើកនិងតម្លៃជាប្រពៃណីដែលពួកគេបានកសាងឡើង និងចូលរួមចំណែកដល់ការយល់ដឹងពីគ្នា និងការយោគយល់គ្នារវាងវប្បធម៌ផ្សេងៗ។
3. ធានាឲ្យមានដំណើរការសេដ្ឋកិច្ចយូរអង្វែង និងការផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច-សង្គម ទៅដល់អ្នកពាក់ព័ន្ធទាំងឡាយ ឲ្យមានការចែករំលែកផលប្រយោជន៍ទាំងនោះប្រកបដោយយុត្តិធម៌ ដូចជា ការងារមានស្ថិរភាព កាលានុវត្តភាពក្នុងការរកប្រាក់ចំណូល សេវាសង្គមចំពោះសហគមន៍ជាម្ចាស់ទឹកដី និងឲ្យមានការចូលរួមចំណែកជួយកាត់បន្ថយភាពក្រីក្រ។

ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តភាព ទាមទារនូវការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ភាពដឹកនាំ និងគោលនយោបាយរឹងមាំ ដើម្បីធានាឲ្យមានការចូលរួមទូលំទូលាយ និងការពេញចិត្តទទួលយកទាំងអស់គ្នា។ ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព គួរធ្វើយ៉ាងណាឲ្យអ្នកទេសចរមានការពេញចិត្តខ្ពស់ និងទទួលបានបទពិសោធន៍ដ៏មានន័យតាមរយៈការលើកកម្ពស់ការយល់ដឹងអំពីនិរន្តរភាព និងទេសចរណ៍ប្រកបដោយនិរន្តរភាព។

ប្រភព៖ UNEP and UNWTO 2005

### ២.២. អេកូទេសចរណ៍

អេកូទេសចរណ៍មានលក្ខណៈខុសប្លែកពី ទេសចរណ៍ប្រកបដោយនិរន្តភាពដ៏ធំទូលាយ ដោយវាជាទម្រង់ទេសចរណ៍មួយប្រភេទដែលផ្តោតទៅលើ ការអភិរក្សបរិស្ថានធម្មជាតិតាមរយៈសកម្មភាពទេសចរណ៍ (Shoko nd)។ អេកូទេសចរណ៍ គឺជាទេសចរណ៍ដែលមានការទទួល

ខុសត្រូវ និងជាផ្នែកមួយនៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ដែលត្រូវបានប្រកាសជាយុទ្ធសាស្ត្រពិភពលោក នៅឯជំនួបប្រជុំកំពូលនៅទីក្រុង Rio De Janeiro ឆ្នាំ១៩៩២ (Leksakundilok 2004)។

នៅប្រទេសកម្ពុជា អេកូទេសចរណ៍ដែលផ្អែកលើសហគមន៍(គ្រប់គ្រងដោយសហគមន៍) គេឲ្យនិយមន័យថាជា "ការធ្វើដំណើរប្រកបដោយទំនួលខុសត្រូវទៅតំបន់ទេសចរណ៍ធម្មជាតិដោយមានការអភិរក្សបរិស្ថាន និងការជួយលើកកម្ពស់ជីវភាពប្រជាពលរដ្ឋក្នុងមូលដ្ឋាន" (TIES 2012)។ តំបន់អេកូទេសចរណ៍កម្ពុជាដំបូងគេ បានកកើតឡើងនៅឆ្នាំ១៩៩៨ នៅបឹងយក្សឡោម ខេត្តរតនគីរី ហើយមានដំណើរការមកដល់សព្វថ្ងៃ (Reimer & Walter 2012) ។ ដើម្បីញាំងឲ្យតំបន់អេកូទេសចរណ៍មួយទទួលបានជោគជ័យ លោក Honey (2008) បានផ្តល់នូវគោលគំនិត ៧ចំណុចៈ ១) វាជាទេសចរណ៍ដែលពាក់ព័ន្ធទៅនឹងការធ្វើដំណើរទៅគោលដៅតំបន់ធម្មជាតិ ២) កាត់បន្ថយហេតុប៉ះពាល់ ៣) លើកកម្ពស់ការយល់ដឹងពីបរិស្ថាន ៤)ផ្តល់នូវថវិកាហិរញ្ញវត្ថុផ្ទាល់ដល់ការអភិរក្ស ៥)ផ្តល់ផលប្រយោជន៍ហិរញ្ញវត្ថុ និងសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ៦) គោរពវប្បធម៌របស់ប្រជាពលរដ្ឋមូលដ្ឋាន ៧) គាំទ្រការគោរពសិទ្ធិមនុស្ស និងចលនាប្រជាធិបតេយ្យ (ដកស្រង់ចេញពី Reimer & Walter 2012)។ ដូច្នេះ អេកូទេសចរណ៍មានបំណងបង្រៀនអ្នកទេសចរអំពីសហគមន៍នៅមូលដ្ឋាន (ដើម្បីចូលរួមថែរក្សា សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានឲ្យមាននិរន្តរភាព) ជំរុញឲ្យអ្នកទេសចរចូលរួមក្នុងការអភិរក្សបរិស្ថាន និងចូលរួមចំណែកលើកកម្ពស់ជីវភាពរបស់សហគមន៍។

## ២.៣. ទេសចរណ៍បៃតង

ទេសចរណ៍បៃតងខុសប្លែកពីអេកូទេសចរណ៍ ព្រោះវាផ្តោតទៅលើក្រុមអ្នកទេសចរដែលរស់នៅតាមទីក្រុង ដោយណែនាំពីរបៀបចំណាយពេលឈប់សម្រាកមួយបែប តាមការទៅលេងតំបន់ជនបទធម្មជាតិ ដើម្បីអាចលំហែកាយ និងកាត់បន្ថយភាពតានតឹងឬសម្ពាធនៃការងារប្រចាំថ្ងៃ (Shoko nd)។ និយមន័យនេះ ទទួលឥទ្ធិពលពី កិច្ចប្រជុំស្តីពីទេសចរណ៍នៅជនបទនៅឆ្នាំ១៩៨៦ នៅប្រទេសអង់គ្លេស ដែលនៅពេលនោះគេបានកំណត់ទេសចរណ៍បៃតងថាជា "ក្រុមមនុស្សមានជីវភាពប្រសើរ មានចំណេះដឹង និងមានព័ត៌មានពេញលេញ ដែលចំណាយពេល ២ ឬ ៣ថ្ងៃ ទៅលេងតំបន់ជនបទ ហើយអាចទទួលបាននូវផលប្រយោជន៍ពីការសម្របសម្រួលល្អនៃសេវាផ្តល់ឲ្យនៅក្នុងតំបន់ជនបទ" (Jones 1987 ដកស្រង់ចេញពី Shoko nd: 6)។ ទោះជាយ៉ាងនេះក្តី ពាក្យ ទេសចរណ៍បៃតង ពុំទាន់មាននិយមន័យឯកភាពគ្នាជាទូទៅនៅឡើយទេ (Yokoyama 2006 ដកស្រង់ចេញពី Shoko nd: 6)។ នៅប្រទេសកម្ពុជា ទេសចរណ៍បៃតងច្រើនសំដៅ ទៅលើសកម្មភាពទេសចរណ៍ ដែលយកចិត្តទុកដាក់ទៅលើការការពារបរិស្ថាន ពីព្រោះបរិស្ថានបៃតងអាចចូលរួមចំណែកជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិនានា ព្រមទាំងសម្រេចបាននូវគោលដៅទេសចរណ៍ប្រកបដោយនិរន្តរភាព (Xinhua English News 2013)។

## ២.៤. សក្តានុពលអេកូទេសចរណ៍ និង ទេសចរណ៍បៃតងនៅកម្ពុជា

អ្នកទេសចរលើពិភពលោក ចូលចិត្តធ្វើដំណើរកំសាន្តទៅប្រទេសកំពុងអភិវឌ្ឍន៍ជាងទៅប្រទេសអភិវឌ្ឍន៍ (UNEP 2013)។ នៅពេលមនុស្សមានការយល់ដឹងកាន់តែច្រើនពីបញ្ហាបរិស្ថាន និងសង្គមពួកគេស្វែងរកជម្រើសផ្សេងៗនៃការធ្វើដំណើរដែលមានការទទួលខុសត្រូវ។ឧទាហរណ៍

អង្កេតឆ្នាំ២០១០ ដោយ ក្រុមហ៊ុន VISA និង សមាគមន៍ធ្វើដំណើរអាស៊ីប៉ាស៊ីហ្វិក (Pacific Asia Travel Association: PATA) បានរកឃើញថា ប្រជាជនចិនចូលចិត្តកម្មវិធីទេសចរណ៍ណា ដែលមានការយកចិត្តទុកដាក់ទៅលើការថែរក្សាបរិស្ថាន និងការបង្កប់នូវអត្តន័យវប្បធម៌ (VISA 2010)។ នៅឆ្នាំ២០១២ ក្រុមហ៊ុន Blue and Green Tomorrow បានធ្វើការស្ទង់មតិមួយដែល បង្ហាញថា ៤៧% នៃទេសចរគិតគូរពីការចំណាយពេលវេលា ទៅកំសាន្តក្នុងពេលសម្រាកលំហែ នៅតាមកន្លែងដែលមានក្រមសីលធម៌ និងបរិស្ថាន។ ការស្រាវជ្រាវបានបង្ហាញទៀតថា ទេសចរ សុខចិត្តចំណាយប្រាក់ច្រើនជាងមុន ប្រសិនបើគេប្រាកដថា អ្នកបម្រើការងារនៅក្នុងវិស័យនោះ បានទទួលនូវលក្ខខណ្ឌការងារប្រកបដោយក្រមសីលធម៌ (ILO 2010)។ ក្រុមហ៊ុន Trip Advisor បានរកឃើញថា ៣៤% នៃអ្នកធ្វើដំណើរកំសាន្ត ពេញចិត្តនឹងចំណាយអស់ច្រើនជាងមុន ទៅលើ ការស្នាក់នៅតាមសណ្ឋាគារ ប្រសិនណាបើសណ្ឋាគារនោះ យកចិត្តទុកដាក់ថែរក្សាបរិស្ថាន (Pollock 2009)។

ដើម្បីចាប់យកឱកាស និងពង្រឹងការប្រកួតប្រជែងទាំងនេះ ប្រទេសកម្ពុជាបានធ្វើការ ផ្សព្វផ្សាយពីចលនាទេសចរណ៍បៃតង និងអេកូទេសចរណ៍នានា ព្រមទាំងបានបង្កើត ពានរង្វាន់ សណ្ឋាគារបៃតង។ ក្នុងពេលជាមួយគ្នា គំនិតផ្តួចផ្តើមបង្កើតសហគមន៍អេកូទេសចរណ៍ (CBET) បានទទួលការគាំទ្រពីអង្គការ និងក្រសួងពាក់ព័ន្ធនានា ដូចជា ក្រសួងបរិស្ថាន ក្រសួង ទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាដើម។ នាបច្ចុប្បន្ន មានតំបន់អេកូ ទេសចរណ៍ចំនួន ៥៦កន្លែង នៅតំបន់ភាគឦសាន្ត តំបន់ទន្លេសាប តំបន់សមុទ្រ និងតំបន់និរតី នៃប្រទេសកម្ពុជា ដែលមានធនធានធម្មជាតិសម្បូរបែប និងវិសេសគ្មានពីរ ដូចជា ពូជផ្សោត ទន្លេអ៊ីរ៉ាវ៉ាឌី ទន្លេមេគង្គ ទន្លេសាប ព្រៃភ្នំ សមុទ្រ ដែលអាចទាក់ទាញភ្ញៀវទេសចរអន្តរជាតិ បានដល់ ១លាននាក់ និងភ្ញៀវជាតិបាន ៥លាននាក់ នៅឆ្នាំ២០២០ (The Phnom Penh Post, 2013)។ បណ្តាខេត្តនៅភាគឦសាន្តប្រទេសមានសក្តានុពលធំធេងសម្រាប់ការពង្រីកតំបន់អេកូ ទេសចរណ៍។ នៅឆ្នាំ២០១២ ចំនួនភ្ញៀវទេសចរទៅទស្សនាតំបន់នោះមានសរុប ៥៣.៣៧៤នាក់ ឬកើនឡើង ១០% បើធៀបនឹងឆ្នាំមុន។ ភ្ញៀវអេកូទេចរណ៍ភាគច្រើនមកពីប្រទេសបារាំង ចិន អង់គ្លេស អាល្លឺម៉ង់ វៀតណាម អូស្ត្រាលី ហូឡង់ សហរដ្ឋអាមេរិក ស្វីស និងកូរ៉េខាងត្បូង។

របាយការណ៍ក្រសួងទេសចរណ៍បង្ហាញថា ភ្ញៀវអេកូទេសចរណ៍ សរុប ៤៥០.០០០នាក់ នៅឆ្នាំ២០១១ ឬស្មើនឹង ១៦% នៃភ្ញៀវទេសចរណ៍សរុបក្នុងប្រទេសកម្ពុជា។ វិស័យទេសចរណ៍ កម្ពុជា ច្រើនផ្តោតទៅលើតំបន់កេរ្តិ៍តំណែលពិភពលោកដែលចុះបញ្ជីក្នុងអង្គការ UNESCO ដូចជា ប្រាសាទអង្គរវត្ត និងប្រាសាទព្រះវិហារ។ ទោះជាយ៉ាងនេះក្តី មានតែតំបន់អេកូទេសរណ៍មួយចំនួន តូចប៉ុណ្ណោះដែលអាចរកប្រាក់ចំណូល ដើម្បីយកមកជួយដល់ការថែរក្សាធនធានធម្មជាតិ និង ព្រៃឈើដោយសហគមន៍ផ្ទាល់ ដូចជា សហគមន៍អេកូទេសរណ៍ចំបក់ ក្នុងឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលជាសហគមន៍មានជោគជ័យមួយ ដោយនៅឆ្នាំ២០១១ អាចរកចំណូលបាន ២៦.៥០០ដុល្លារ និងទាក់ទាញភ្ញៀវទេសចរបាន ១១.២០០នាក់ក្នុងនេះមាន ៨០% ជាជនជាតិខ្មែរ ព្រោះតំបន់នេះស្ថិតនៅក្បែរទីក្រុងភ្នំពេញ និងមានទឹកធ្លាក់ ដែលភ្ញៀវអាចចូលលេងកំសាន្តបាន។

តំបន់អេកូទេសចរណ៍មានជោគជ័យមួយទៀតគឺ ដំណើរស្វែងយល់ពីទន្លេមេគង្គ (Mekong Discovery Trail: MDT) ដែលជាគម្រោងរួមគ្នាមួយរវាងក្រសួងទេសចរណ៍ អង្គការអភិវឌ្ឍន៍ ហូឡង់ (SNV) និង អង្គការទេសចរណ៍ពិភពលោករបស់សហប្រជាជាតិ។ គម្រោងនេះមាន

បំណាងជំរុញទេសចរណ៍ប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ និងអភិរក្សផ្សោតទន្លេមេគង្គ (SNV 2010)។ គម្រោងនេះជាផ្នែកមួយនៃអេកូទេសចរណ៍ និងស្ថិតនៅតាមដងទន្លេមេគង្គ ក្នុងខេត្តក្រចេះ និង ស្ទឹងត្រែង និងមានផ្តល់ឲ្យអ្នកទេចរណ៍នូវការកំសាន្តផ្សេងៗ ដូចជា ការជិះរទេះសេះ ផ្ទះស្នាក់នៅក្នុងភូមិ ការសំដែងបង្ហាញសិល្បៈវប្បធម៌ផ្សេងៗ ការដាំដើមឈើ ការជិះទូកតាមដងទន្លេ និង ការជិះកង់តាមភ្នំជាដើម (Tourism of Cambodia 2013)។

ការសិក្សាពីឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍ក្នុងខេត្តសៀមរាបបង្ហាញថា វិស័យនេះបានចូលរួមចំណែកក្នុងការលើកម្ពស់ជីវភាពប្រជាពលរដ្ឋក្នុងតំបន់ ដោយជួយផ្តល់ចំណូលបានដល់ បីភាគបួននៃប្រាក់ចំណូលសរុបរបស់គ្រួសារ (Men 2007)។ ការសិក្សាមួយទៀតបង្ហាញថា វិស័យទេសចរណ៍នៅខេត្តសៀមរាបបានផ្តល់ការងារ និងឱកាសរកប្រាក់កម្រៃនៅក្នុងវិស័យផ្សេងៗទៀត ដូចជា សំណង់សណ្ឋាគារ ភោជនីយដ្ឋាន ការដឹកជញ្ជូន ហើយការរីកចម្រើនវិស័យទេសចរណ៍ក៏ជួយធ្វើដីធ្លីឡើងថ្លៃដែរ។

គំនិតផ្តួចផ្តើមដែលមានសក្តានុពលជួយគាំទ្រដល់ការអភិវឌ្ឍអេកូទេសចរណ៍ មានជាអាទិ៍ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ (Climate Investment Funds: CIF) ដែលជួយគម្រោងអេកូទេសចរណ៍ក្នុងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងយន្តការហិរញ្ញប្បទានកាបូន (carbon finance mechanisms) ដែលអនុវត្តឡើងតាមការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បណ្តាលមកពីការកាប់ព្រៃឈើ និងការរេចរិលព្រៃឈើ ការគ្រប់គ្រងព្រៃប្រកបដោយនិរន្តភាព ការអភិរក្សព្រៃឈើ និងការបង្កើនបរិមាណកាបូនបង្ខាំងទុក (REDD+)។ ដោយសារទីផ្សារកាបូនបានដើរទៅមុខយឺតៗ ដូច្នេះក្នុងរយៈខ្លីរដ្ឋាភិបាលគួរគិតគូរផ្តល់នូវហិរញ្ញប្បទានកាបូនផ្ទាល់ខ្លួនទៅដល់សហគមន៍ ដើម្បីជួយឲ្យតំបន់អេកូទេសចរណ៍រីកចម្រើនទៅមុខបាន។

## ៣. ការធ្វើឲ្យវិស័យទេសចរណ៍កម្ពុជាមាននិរន្តរភាព: ឧបសគ្គ និងតម្រូវការ

តម្រូវការផ្សេងៗដែលធ្វើឲ្យទេសចរណ៍មានទំនាក់ទំនងល្អជាមួយបរិស្ថាន មានដូចជា តម្រូវការផលិតផលកសិកម្មក្នុងស្រុកមានគុណភាពល្អ ហេដ្ឋារចនាសម្ព័ន្ធ ច្បាប់ស្តីពីការគ្រប់គ្រងតំបន់អេកូទេសចរណ៍ អភិបាលកិច្ចល្អ ការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍអេកូទេសចរណ៍។ បញ្ហាប្រឈមមានជាអាទិ៍ ការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលនៃការរីកចម្រើនវិស័យទេសចរណ៍ទៅលើធនធានធម្មជាតិ។

ការអភិវឌ្ឍវិស័យទេសចរណ៍មិនទាន់ឡើងដល់កម្រិតអតិបរមានៅឡើយទេ ជាពិសេសខាងផ្នែកអេកូទេសចរណ៍។ តាមការប៉ាន់ស្មាន ការបាត់បង់ចំណូលបានមកពីទេសចរណ៍ មានរហូតដល់ ២៥% ដោយសារការនាំចូលទំនិញពីបរទេស ដើម្បីផ្គត់ផ្គង់តម្រូវការដែលចេះតែកើនឡើងនៅក្នុងស្រុក (MoT 2012a)។ ការបង្កើនផលិតកម្មក្នុងស្រុក ដូចជា បន្លែ ផ្លែឈើ ត្រី គ្រឿងសង្ហារឹម និងការផ្តល់នូវការងារ សេវាកម្ម និងជំនាញ អាចជួយស្រូបយកចំណូលបន្ថែមទៀតសម្រាប់ប្រទេសកម្ពុជា។

ការសម្របសម្រួលល្អ និងធ្វើឲ្យប្រសើរឡើងនូវខ្សែចង្វាក់ផលិតកម្ម អាចជួយពង្រឹង និងពង្រីកផលិតកម្មក្នុង ស្រុក (Ballard 2005)។ ជាឧទាហរណ៍ ចុងភៅសណ្ឋាគារអាចជួបជាមួយក្រុម

កសិករដោយផ្ទាល់ ដើម្បីពិភាក្សា និងធ្វើកិច្ចសន្យាឲ្យកសិករផ្តល់នូវផលិតផលបន្លែ ឬផ្លែឈើមានគុណភាពល្អ និងបានយ៉ាងទៀងទាត់ ដល់សណ្ឋាគារ។ រដ្ឋ អង្គការផ្សេងៗ អ្នកផ្តល់ជំនួយ និង សង្គមស៊ីវិល អាចផ្តល់នូវការប្រឹក្សា និងការបង្ហាត់បង្ហាញដល់សមាគមកសិករទាំងនោះ ដើម្បីឲ្យពួកគាត់មានសមត្ថភាពផលិតបានទាំងគុណភាព និងបរិមាណស្របតាមតម្រូវការ។ ដូច្នេះសណ្ឋាគារ ឬភោជនីយដ្ឋាន មិនត្រឹមតែបានជួយលើកកម្ពស់ជីវភាពប្រជាពលរដ្ឋមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានផលិតផលកសិកម្មមានគុណភាពល្អ និងស្របតាមតម្រូវការទៀតផង។

បញ្ហាប្រឈមមួយទៀតគឺ កំណើនយ៉ាងលឿននៃវិស័យទេសចរណ៍បានដាក់សម្ពាធកាន់តែខ្លាំងទៅលើ តំបន់ទេសចរណ៍ដែលគេនិយមទៅលេង ដូចជា ប្រាសាទអង្គរវត្ត ជាដើម។ ដូច្នេះ ត្រូវមានយុទ្ធសាស្ត្របង្កើតហេដ្ឋារចនាសម្ព័ន្ធ និងតំបន់ទេសចរណ៍ទាក់ទាញផ្សេងៗទៀត ដូចជា តំបន់នៅភាគនិរតី ភាគឦសាន្ត ដែលមានធនធានធម្មជាតិសម្បូរបែបដូចជា ផ្សោតទន្លេ សត្វស្លាបបឹងទន្លេសាប ឆ្នេរខ្សាច់ និងកោះ ជាដើម ( MoT 2012b )។

ដូចមានបង្ហាញពីខាងដើម អេកូទេសចរណ៍បានផ្តល់ការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ប៉ុន្តែបច្ចុប្បន្ននេះ ពុំទាន់មានច្បាប់ស្តីពីការគ្រប់គ្រងតំបន់អេកូទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍នោះទេ។ មន្ត្រី ក្រសួងទេសចរណ៍បានបញ្ជាក់ថា ក្រសួងទេសចរណ៍កំពុងស្វែងរកជំនួយថវិកាដើម្បីបង្កើតច្បាប់គ្រប់គ្រងតំបន់អេកូទេសចរណ៍។ ម្យ៉ាងទៀត មានការមិនច្បាស់លាស់ស្តីពីដែនសមត្ថកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ ដោយសារមានការគងលើគ្នា ឬស្ថាប័នផ្សេងគ្នាធ្វើការងារដូចគ្នាក្នុងអេកូទេសចរណ៍ ដូចជារវាង ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងក្រសួងកសិកម្ម ជាដើម។ ដូចនេះ ត្រូវមានវិធីសាស្ត្រសម្របសម្រួលមួយ ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់អេកូទេសចរណ៍ ដែលមានការថ្លឹងថ្លែងល្អរវាងទិសដៅខុសៗគ្នារបស់ស្ថាប័នទាំងនោះ។

មានបញ្ហាប្រឈមមួយចំនួនទៀតជុំវិញការអភិរក្សតំបន់អេកូទេសចរណ៍ ដោយសារតំបន់ទាំងនោះស្ថិតនៅក្នុងតំបន់ការពារ ដែលមានទាំងអស់ ២៣កន្លែង ស្មើនឹង ២១% នៃផ្ទៃដីប្រទេសកម្ពុជា។ ជនជាតិដើមភាគតិចបាននិងកំពុងរស់នៅក្នុងតំបន់នោះ ហើយក្រសួងបរិស្ថានបានបង្កើតតំបន់ការពារសហគមន៍ (community protected area: CPA) ដើម្បីឲ្យពួកគាត់អាចរស់នៅនិងរកផល ឬអនុផលព្រៃឈើបានតាមលក្ខណៈគ្រួសារ។ ទោះយ៉ាងនេះក្តី កំណើនប្រជាពលរដ្ឋ និងសិទ្ធិប្រើប្រាស់និងកម្មសិទ្ធិដីមិនច្បាស់លាស់ក្នុងតំបន់នោះ អាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃតំបន់អេកូទេសចរណ៍។ម៉្យាងទៀតឧទ្យាននុរក្សតំបន់ការពារមានចំនួនមិនគ្រប់គ្រាន់ និងទទួលបានប្រាក់បៀវត្សរ៍មិនសមល្មម គឺមិនអាចការពារព្រៃដែលមានទំហំរាប់សិបម៉ឺនហិកតានៅក្នុងតំបន់ការពារទាំងនោះបានទេ។ កត្តាទាំងនេះបង្កការគំរាមកំហែងដល់តំបន់អេកូទេចរណ៍ និងធ្វើឲ្យថមថយវិនិយោគទៅលើតំបន់នោះ។

តំបន់អេកូទេសចរណ៍មួយចំនួនទៀត មានទំនាស់ជាមួយដីសម្បទានសេដ្ឋកិច្ចដែលតែងមានលេចចេញនូវ ការរានដីព្រៃសម្រាប់គោលបំណងផ្សេងទៀត។ ការរេចរិលព្រៃ ការឆេះព្រៃនៅរដូវប្រាំង និងការដកហូតយកអនុផលព្រៃឈើគ្មាននិរន្តភាព បានធ្វើឲ្យអន់ថយដល់ការអភិវឌ្ឍអេកូទេសចរណ៍ ( Lonn et al. 2012 )។ ការធ្វើសម្ភាសន៍ជាមួយមន្ត្រីក្រសួងទេសចរណ៍បានបង្ហាញថា ការបំពុលទឹក ជាពិសេសដោយសារកាកសំណល់នៃការជីកយករ៉ែ ក៏បានប៉ះពាល់ដល់តំបន់អេកូទេសចរណ៍ដែរ ( ទន្លេ ឬ ស្ទឹង ) ព្រោះពុំមានការអនុវត្តច្បាប់ឬវិធានច្បាប់ឲ្យបានហ្មត់ចត់។

ម៉្យាងទៀត សព្វថ្ងៃនៅខ្វះការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍអេកូទេសចរណ៍ ជាពិសេស ទាក់ទងទៅនឹងជំនាញ និងចំណេះដឹងនានា ដូចជា ការពង្រឹងសមត្ថភាពផ្នែកភាសាបរទេស ក្នុងការទំនាក់ទំនងជាមួយភ្ញៀវ ការរៀបចំចម្អិនអាហារ បញ្ហាអនាម័យ ការធ្វើបដិសណ្ឋារកិច្ច ការគ្រប់គ្រងបរិស្ថាន និង ការគ្រប់គ្រងសំណល់និងការបំពុល ជាដើម។

## ៣.១ ការកាត់បន្ថយកាបូន និងកត្តាគំរាមកំហែងទៅលើវិស័យទេសចរណ៍កម្ពុជា

ដូចបានពិភាក្សាពីខាងដើម វិស័យទេសចរណ៍មានចំណងទាក់ទងទៅនឹងយន្តការកាត់បន្ថយការបញ្ចេញកាបូន ហើយវាអាចប៉ះពាល់ដល់ការអភិវឌ្ឍវិស័យនេះ។ ឧទាហរណ៍ ការឡើងថ្លៃការធ្វើដំណើរតាមផ្លូវអាកាស ដោយសារប្រេងឡើងថ្លៃ និងការបង់ពន្ធលើការបញ្ចេញកាបូនដោយអាកាសយាន អាចនាំឲ្យថយចុះចំនួនភ្ញៀវធ្វើដំណើរផ្លូវឆ្ងាយតាមយន្តហោះ ហើយប៉ះពាល់ដល់វិស័យទេសចរណ៍។ ប៉ុន្តែការឡើងថ្លៃនេះ ទំនងជាភាគតូចមួយនៃបន្ទុកចំណាយសរុបប៉ុណ្ណោះ ហើយមានភស្តុតាងបង្ហាញថាអ្នកទេសចរមិនសូវមានប្រតិកម្មទេ ដូច្នេះវាក៏ជះឥទ្ធិពលតិចតួចដែរទៅលើវិស័យទេសចរណ៍។ ម៉្យាងទៀតកំណើនភ្ញៀវទេសចរនៅកម្ពុជាមានប្រភពមកពីប្រទេសជិតខាង ដូច្នេះកត្តាគំរាមកំហែងនេះមិនគួរព្រួយបារម្ភពេកទេ។

## ៣.២ វិស័យទេសចរណ៍ និងការប្រែប្រួលអាកាសធាតុ

ដើម្បីវាយតម្លៃពីកត្តាសក្តានុពលផ្នែកអេកូទេសចរណ៍ គេក៏គួរគិតគូរពីបញ្ហាផ្សេងៗជុំវិញការប្រែប្រួលអាកាសធាតុដែរ។ នៅក្នុងពិភពលោក ការប្រែប្រួលអាកាសធាតុកំពុងកើនល្បឿនក្នុងសតវត្សរ៍ទី២១ នេះ (UNWTO 2008) ហើយអ្នកវិទ្យាសាស្ត្រដូចជា Fankhauser និង Tol (1997) បានប៉ាន់ស្មានថា ការប្រែប្រួលអាកាសធាតុអាចធ្វើឲ្យខូចខាតសេដ្ឋកិច្ចពិភពលោក រហូតដល់ ១,៥ ទៅ ២% នៃ ផសស ពិភពលោក ឬពី ១ ទៅ ១,៥% នៃ ផសស សម្រាប់ប្រទេស OECD និង ពី ២ ទៅ ៩ % នៃ ផសស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

នៅលើឆាកអន្តរជាតិ គេចាត់ទុកកម្ពុជាជាប្រទេសងាយរងគ្រោះខ្លាំង ដោយសារការប្រែប្រួលអាកាសធាតុ ដែលមានដូចជា ទំហំនិងភាពញឹកញាប់នៃទឹកជំនន់ និងភាពរាំងស្ងួតកាន់តែធ្ងន់ធ្ងរ និងញឹកញាប់ឡើង។ ការប្រែប្រួលបានបង្កការឡើងកំដៅ និងការប្រែប្រួលរបបទឹកភ្លៀង ហើយប៉ះពាល់ដល់ប្រជាពលរដ្ឋ ព្រោះពួកគេពឹងផ្អែកលើកសិកម្មអាស្រ័យលើទឹកភ្លៀង (World Bank 2012a)។ ការប្រែប្រួលក៏អាចបង្អាក់ ដំណើរវិស័យទេសចរណ៍ដែរ ដូចជា ការជួបប្រទះភាពរាំងស្ងួតខ្លាំង ឬព្យុះភ្លៀងខ្លាំង ឬគ្រោះធម្មជាតិ ផ្សេងទៀត ដែលអាចកាត់បន្ថយប្រភពទឹកសម្រាប់ប្រើប្រាស់ក្នុងវារីអគ្គិសនី និងធ្វើឲ្យខូចខាតដល់ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធបម្រើទេសចរណ៍ផ្សេងទៀត។វាក៏អាចនាំឲ្យអ្នកទេសចរណ៍ផ្លាស់ប្តូរទីកន្លែងធ្វើទេសចរណ៍ ដូចជា ប្រសិនបើមានព្យុះភ្លៀងនៅខេត្តសៀមរាប ឬក្រុងព្រះសីហនុ អ្នកទេសចរអាចផ្លាស់ ប្តូរទិសដៅទៅកាន់តំបន់ទាំងនោះ ហើយធ្វើដំណើរទៅតំបន់ផ្សេងជំនួសវិញ។

ការប្រែប្រួលនេះក៏អាចប៉ះពាល់ដោយប្រយោល បង្កការធ្លាក់ចុះទិន្នផលដំណាំនិងបរិមាណស្បៀងអាហារផលិតបាន ធ្វើឲ្យស្បៀងអាហារឡើងថ្លៃ និងបង្កើនការប្រជែងគ្នាប្រើប្រាស់ស្បៀងអាហារ។ ដូច្នេះត្រូវធ្វើវិភាគឲ្យស៊ីជម្រៅថែមទៀត ទៅលើភាពប្រថុយប្រថាននៃឧស្សាហកម្មទេសចរណ៍ និងវិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីពង្រឹងភាពស៊ាំ។

មន្ត្រីក្រសួងទេសចរណ៍បានលើកពីការព្រួយបារម្ភនៃការឆ្លងរាលដាលមេរោគផ្តាសាយបក្សី H5N1 ដែលគេបានផ្សារភ្ជាប់ទៅនឹងការប្រែប្រួលអាកាសធាតុ និងកំណើនប្រជាជនផងដែរ ហើយទាំងអស់នេះជាក្តីបារម្ភ និងជាការគំរាមកំហែងចំពោះវិស័យទេសចរណ៍នៅកម្ពុជា។ មេរោគផ្តាសសាយបក្សីH5N1បានសម្លាប់ប្រជាពលរដ្ឋកម្ពុជាអស់១២នាក់គិតមកដល់ខែវិច្ឆិកាឆ្នាំ២០១៣ ដែលជាករណីដ៏ធ្ងន់ធ្ងរ បើធៀបនឹងចំនួនមនុស្សស្លាប់ ៩នាក់ ដោយសារមេរោគនេះនៅប្រទេសឯទៀតទាំងអស់ក្នុងពិភពលោក (Denise 2013)។

## ៣.៣ ឥទ្ធិពលនៃការរីកចម្រើនវិស័យទេសចរណ៍ទៅលើធនធានធម្មជាតិ

ក្រៅពីផលចំណេញដល់វិស័យសេដ្ឋកិច្ច ការរីកលូតលាស់ទេសចរណ៍នាំឲ្យកើនការប្រើប្រាស់ថាមពល និងទឹក (UNEP 2011)។ ឧទាហរណ៍ នៅខេត្តសៀមរាបមានកង្វះខាតទឹកប្រើប្រាស់ ហើយធនធានទឹកកាន់តែខ្សត់ឡើងទាំងទឹកនៅលើដី និងនៅក្រោមដី។ អាជ្ញាធរបានឲ្យដឹងថា មានម៉ាស៊ីន និងកន្លែងបូមទឹកខុសច្បាប់ ប្រមាណ ៦០០០កន្លែង ក្នុងនេះមានជាច្រើនជារបស់សណ្ឋាគារ និង ១០០០អណ្តូងទៀតដែលគេបានជីកក្នុងក្រុង (Doherty 2010)។ ហេតុការណ៍នេះបានបង្កការបារម្ភថា នៅពេលណាមួយនឹងអាចកើតមានអស្ថិរភាព ដែលអាចធ្វើឲ្យប្រាសាទបុរាណនានា មានប្រាសាទអង្គរវត្តជាដើម ត្រូវស្រុតបាក់បែក។ នាយកដ្ឋាននគររូបនីយកម្មនិងអភិវឌ្ឍន៍នៃអាជ្ញាធរអប្សរា បានសហការជាមួយ ទីភ្នាក់ងារសហប្រតិបត្តិការ អន្តរជាតិ ជប៉ុន (JICA) ដើម្បីពិនិត្យបញ្ហាការផ្គត់ផ្គង់ទឹក ហើយបានសន្និដ្ឋានថា អាងស្តុកទឹកទាំងពីរ (បារាយ ខាងលិច និងមួយទៀតនៅភ្នំគូលេន) ដែលកំពុងផ្គត់ផ្គត់ទឹកដល់ខេត្តសៀមរាប នឹងមិនគ្រប់គ្រាន់ទេសម្រាប់ បំពេញតម្រូវការនៅពេលអនាគត (APSARA, 2005)។ ហេតុការណ៍នេះអាចប៉ះពាល់ដល់ការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងតំបន់ ដែលតម្រូវឲ្យមានការកំណត់ចំនួនភ្ញៀវទេសចរនៅតំបន់អង្គរវត្ត។ ឧទាហរណ៍នេះបង្ហាញពីសារៈសំខាន់នៃការយល់ដឹង និងការគ្រប់គ្រងនូវជម្រើសរវាងសេដ្ឋកិច្ច បរិស្ថាន និងការអភិវឌ្ឍទេសចរណ៍។ ជម្រើសមួយ ដើម្បីដោះស្រាយបញ្ហា គឺការតម្រូវឲ្យគម្រោងអភិវឌ្ឍទេសចរណ៍នានាធ្វើការវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាន (Environmental Impact Assessments: EIAs) ដោយមានទាំងការចូលរួមពិគ្រោះយោបល់ពីស្ថាប័ន ពាក់ព័ន្ធផង ដើម្បីវាយតម្លៃពីផលចំណេញ និងការខាតបង់ដល់សេដ្ឋកិច្ច និងបរិស្ថាន។

សម្រាមសំណល់ច្រើនៗក៏ចោទបញ្ហាដែរ។ នៅឆ្នាំ២០១០ ក្រុងភ្នំពេញមានបង្កើតសំណល់រឹងប្រមាណ ១០០០តោន/ថ្ងៃ (Derkeiler 2009; Euronet, 2012) ហើយកង្វះប្រព័ន្ធសំអាត និងគ្រប់គ្រងសំណល់រាវ នឹងនាំឲ្យមានបញ្ហាការបំពុលទឹក (Euronet 2012)។ ដូច្នេះត្រូវមានគោលការណ៍ច្បាប់ត្រឹមត្រូវក្នុងការគ្រប់គ្រងសំណល់ ប្រព័ន្ធកែច្នៃសំណល់ឡើងវិញ ប្រព័ន្ធបច្ចេកវិទ្យាបំលែងសំណល់ទៅជាថាមពលដែលមិនត្រឹមតែជួយធ្វើឲ្យបរិស្ថាននៅល្អ និងមានសុវត្ថិភាពសម្រាប់ទេសចរណ៍នោះទេ ប៉ុន្តែថែមទាំងជួយបង្កើតឱកាសការងារ និងការអភិវឌ្ឍបៃតងទៀតផង។

## ៤. គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល៖ ជម្រើសគោលនយោបាយថ្មីៗ និងគម្រោងជំនួយរបស់រដ្ឋ

តើរដ្ឋាភិបាលបានឆ្លើយតបយ៉ាងណាចំពោះកាលានុវត្តភាព និងបញ្ហាប្រឈមដូចខាងលើ? រដ្ឋាភិបាលបានចាត់ទុកវិស័យទេសចរណ៍ ជា "មាសបៃតង" និងជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចបៃតង[២] ដូចមានបញ្ជាក់ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ឆ្នាំ២០១២-២០២០ ដែលមានបង្ហាញពីចក្ខុវិស័យរយៈពេលវែង សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជាដោយផ្អែកទៅលើសក្តានុពល "វប្បធម៌ និងធនធានធម្មជាតិ"។ ទេសចរណ៍វប្បធម៌បានទទួលអាទិភាពខ្ពស់រួចជាស្រេច ប៉ុន្តែអេកូទេសចរណ៍ក៏ត្រូវអភិវឌ្ឍឡើងដែរ ដើម្បីទាក់ទាញភ្ញៀវឲ្យមកទស្សនាផង ជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុផង និងចូលរួមចំណែកដល់ការអភិវឌ្ឍបៃតងផង (MoT 2012a)។ ផែនការយុទ្ធសាស្ត្រទាំងនេះមានទិសដៅធំៗមួយចំនួន ដូចជា៖ ការអភិវឌ្ឍផលិតផលទេសចរណ៍ ការផ្សព្វផ្សាយទីផ្សារទេសចរណ៍ ការតភ្ជាប់និងសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនភ្ញៀវ ប្រព័ន្ធសុវត្ថិភាពទេសចរណ៍ ការគ្រប់គ្រងហេតុប៉ះពាល់អវិជ្ជមាន ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស។

វិធានការ និងយុទ្ធនាការមួយចំនួនបានផ្តួចផ្តើមធ្វើឡើង ដើម្បីកសាងកេរ្តិ៍ឈ្មោះប្រទេសកម្ពុជាឲ្យក្លាយជាទិសដៅទេសចរណ៍បៃតង។ ច្បាប់ទេសចរណ៍បានចែងថា ក្រុមហ៊ុនទេសចរណ៍ ឬប្រតិបត្តិករទេសចរណ៍ ណាដែលអនុវត្តទៅតាមស្តង់ដារបរិស្ថានកំណត់ឡើងដោយក្រសួងបរិស្ថាននោះ នឹងទទួលបាន "ស្លាកអេកូ" "Eco label" (MoT 2009)។ ក្រសួងទេសចរណ៍ក៏បានបង្កើតពាក្យស្លោកមួយថា "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ" ដើម្បីលើកកម្ពស់ការអនុវត្តល្អដែលរួមមាន ការកាត់បន្ថយសំណល់តាមរយៈការបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹង និងការលើកទឹកចិត្តដោយផ្តល់ជារង្វាន់ដល់បុគ្គល ឬ ស្ថាប័ន ដែលមានស្នាដៃអនុវត្តបានល្អ (MOT n.d.)។

សៀវភៅកម្មវិធី "ស្នាក់នៅមួយថ្ងៃទៀតនៅកម្ពុជា" បានបោះពុម្ពតាំងពីឆ្នាំ២០០៧ ដោយមានជំនួយហិរញ្ញវត្ថុ និងកិច្ចសហការពីអង្គការអាល្លឺម៉ង់ (GTZ) សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ឲ្យស្នាក់នៅបានកាន់តែយូរថ្ងៃនៅកម្ពុជា ដើម្បីសិក្សារៀនសូត្រអំពីជីវិត និងដើម្បីចូលរួមជួយជាសប្បុរសដោយធ្វើការស្ម័គ្រចិត្ត ដោយចំណាយពេលនិងថវិកាផ្ទាល់ខ្លួន ដើម្បីជួយសហគមន៍ (Kim and Browne 2011)។

រដ្ឋាភិបាលក៏បានអនុវត្តគំនិតផ្តួចផ្តើម "ទេសចរណ៍ម្នាក់ ដើមឈើមួយដើម" ដោយបង្កើតសួនឧទ្យាននៅ ១១ខេត្ត ដើម្បីឲ្យភ្ញៀវទេសចរណ៍ទៅដាំដើមឈើ និងជួយផ្សព្វផ្សាយពីការអភិវឌ្ឍ

[២] "កម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ United Nations Environment Program (UNEP) បានផ្តល់និយមន័យពាក្យ "សេដ្ឋកិច្ចបៃតង" ថាជា សកម្មភាពជួយឲ្យមនុស្សមានជីវភាពប្រសើរឡើង មានសមធម៌សង្គមនិងជួយកាត់បន្ថយគួរឲ្យកត់សំគាល់នូវហានិភ័យចំពោះបរិស្ថាននិងការក្រខ្សត់ធនធានអេកូឡូស៊ី។ និយាយសាមញ្ញ "សេដ្ឋកិច្ចបៃតង" ជាការអភិវឌ្ឍដែលបញ្ចេញកាបូនទាប មានការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍលើកកម្ពស់ជីវភាពដែលរួមទាំងប្រជាជនក្រីក្រផងដែរ។ និយាយតាមការអនុវត្តជាក់ស្តែង "សេដ្ឋកិច្ចបៃតង" ជាសេដ្ឋកិច្ចមួយដែលក្នុងនោះ កំណើនប្រាក់ចំណូល និងការងារគឺកើតមានឡើងតាមរយៈការវិនិយោគពីវិស័យសាធារណៈ និងឯកជន ដែលកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិក និងការបំពុល ធ្វើឲ្យការប្រើប្រាស់ថាមពលនិងធនធានមានប្រសិទ្ធភាព ហើយជួយទប់ស្កាត់ការបាត់បង់ជីវចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី" (UNEP n.d.)។

បៃតង ( Xinhua English News 2013 )។ នៅខែកុម្ភៈ ២០១៣ មន្ត្រីទេសចរណ៍បានបង្កើតអេកូក្លឹប ដើម្បីធ្វើការគ្រប់គ្រងសំណល់បានកាន់តែប្រសើរ កាត់បន្ថយការប្រើប្រាស់ថង់ផ្លាស្ទិក បង្កើនការយល់ដឹងពីបរិស្ថាន និងលើកកម្ពស់កេរ្តិ៍ឈ្មោះ និងមុខមាត់របស់ទីក្រុងភ្នំពេញ។ ក្រសួងទេសចរណ៍នឹងធ្វើការផ្សព្វផ្សាយចលនាអេកូក្លឹបនេះទៅដល់សាលារៀន សាកលវិទ្យាល័យ រោងចក្រ វិទ្យុ និងទូរទស្សន៍។ សកម្មភាពយុវជនក៏កើនឡើងដែរតាំងពីឆ្នាំ ២០១១ មក ក្នុងយុទ្ធនាការ ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ ការដាំដើមឈើ ការប្រឡងដេញដោល ឆ្លើយសំណួរទាក់ទងនឹងបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយមានការចូលរួមនិងកិច្ចសហការពីសមាជិកព្រឹទ្ធសភា សាលាក្រុងភ្នំពេញ ខេត្តសៀមរាប ក្រុងព្រះសីហនុ និងយុវសភាកម្ពុជា (JCI Cambodia)។ សកម្មភាពក្នុងគំនិតផ្តួចផ្តើមនេះមានគោលដៅ លើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តអ្នកនៅទីក្រុង ជាពិសេសយុវជន ឲ្យថែរក្សាទីក្រុង និងរមណីយដ្ឋានឲ្យបានស្អាត និងមានលក្ខណៈទាក់ទាញ (JCI Cambodia 2012)។

ទោះបីជាលទ្ធផលនៃសកម្មភាពទាំងនេះពិបាកវាស់វែងក្តី ក៏វាបង្ហាញពីការរួមផ្សំដ៏មានសក្តានុពលរវាងវិស័យទេសចរណ៍ នឹងការអភិវឌ្ឍបៃតង។

ដើម្បីលើកកម្ពស់ "គំនិតបៃតង" នៅក្នុងវិស័យសណ្ឋាគារ ប្រទេសមាជិកអាស៊ានបានបង្កើតរង្វាន់សម្រាប់ សណ្ឋាគារដែលគោរពតាមគោលការណ៍ថែរក្សាបរិស្ថាន ជួយសន្សំ និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ( Travel Daily News 2012 )។ ពិធីប្រគល់រង្វាន់មានធ្វើឡើងរៀងរាល់ពីរឆ្នាំម្តង តាំងពីឆ្នាំ ២០០៨ មក ហើយលើកចុងក្រោយនេះបានធ្វើនៅទីក្រុង South Sulawesi កាលពីខែមករា ២០១២។ លក្ខណៈវិនិច្ឆ័យដើម្បីទទួលបានរង្វាន់នេះ មានជាអាទិ៍៖

1. សកម្មភាពនិងគោលនយោបាយបរិស្ថាន ក្នុងការគ្រប់គ្រងនិងប្រតិបត្តិការសណ្ឋាគារ
2. ការប្រើប្រាស់ផលិតផលបៃតង ប្រើធនធានមានប្រសិទ្ធភាព មិនប្រើសារធាតុគីមី និងមិនបំពុលបរិស្ថាន
3. កិច្ចសហការជាមួយសហគមន៍ និងអង្គការដៃគូអភិវឌ្ឍន៍ក្នុងស្រុកនានា
4. ការអភិវឌ្ឍធនធានមនុស្ស
5. ការគ្រប់គ្រងសំណល់រឹងបានត្រឹមត្រូវ
6. ការប្រើប្រាស់ថាមពលមានប្រសិទ្ធភាព
7. ការប្រើប្រាស់ទឹកមានប្រសិទ្ធភាព
8. ការគ្រប់គ្រងគុណភាពខ្យល់ ( នៅក្នុង និង នៅក្រៅសណ្ឋាគារ )
9. ការគ្រប់គ្រងការបំពុលដោយសំឡេង
10. ការគ្រប់គ្រង និងប្រព្រឹត្តិកម្មសំណល់រាវ
11. ការគ្រប់គ្រងការទុកដាក់សំណល់គីមី ឬ សំណល់ពុល

មានសណ្ឋាគារដល់ទៅ ៥០ នៅកម្ពុជា ដែលទទួលបានស្តង់ដារសណ្ឋាគារបៃតងរបស់អាស៊ាន ( Björn 2012 )។ សណ្ឋាគារ និងរមណីយដ្ឋានអង្គរផាលេស ( The Angkor Palace Resort & Spa ) នៅខេត្តសៀមរាប ទទួលបានរង្វាន់ស្តង់ដារសណ្ឋាគារបៃតងអាស៊ានចំនួន ២ដងជាប់គ្នា

គឺនៅឆ្នាំ ២០០៨-២០០៩ និង ២០១០-២០១១។ សណ្ឋាគារនេះបានអនុវត្តយុទ្ធនាការសន្សំសំចៃទឹកក្នុងបន្ទប់ភ្ញៀវ និងធ្វើប្រព្រឹត្តិកម្មកាកសំណល់ទឹក ដើម្បីយកទៅប្រើប្រាស់ជាជីនៅក្នុងសួនច្បារ (Grand Soluxe Angkor Palace 2013)។

គំនិតផ្តួចផ្តើមទាំងនេះ បង្កើតបានជាគំរូអាជីវកម្មល្អជួយកាត់បន្ថយការចំណាយ សន្សំសំចៃធនធានកម្រ ព្រមទាំងកសាងកេរ្តិ៍ឈ្មោះ និងទាក់ទាញទីផ្សារទេសចរណ៍ទៀតផង។ ទោះយ៉ាងនេះក្តី ការលើកកម្ពស់ចំណាប់អារម្មណ៍ និងការផ្សព្វផ្សាយទូលំទូលាយអំពីសកម្មភាពទាំងនេះនៅខ្វះខាតខ្លាំងណាស់។ ក្នុងប្រទេសជាច្រើន គេមានការទទួលស្គាល់ខ្លាំងជាងពីសក្តានុពលនៃថាមពលកកើតឡើងវិញ ដូចជា ថាមពលកំដៅព្រះអាទិត្យសម្រាប់ផ្តល់ទឹកក្តៅក្នុងសណ្ឋាគារ ឬ ការកសាងអគារសំណង់ផ្សេងៗដែលសន្សំសំចៃថាមពល (ឧទាហរណ៍ ជួយកាត់បន្ថយការចំណាយទៅលើម៉ាស៊ីនត្រជាក់ក្នុងអាយុកាលរបស់អគារទាំងមូល)។

សណ្ឋាគារ ហ្វ្រាន់ជីផានីវីឡា The Frangipani Villa Hotels នៅក្រុងភ្នំពេញ បានធ្វើវិនិយោគយ៉ាងច្រើនទៅលើវិធានការប្រើប្រាស់ថាមពលមានប្រសិទ្ធភាព និងថាមពលកកើតឡើងវិញរួមមានប្រព័ន្ធទឹកក្តៅដើរដោយថាមពលព្រះអាទិត្យ អំពូលបំភ្លឺស៊ីភ្លើងតិច LED lighting ជាដើម។ ចំណាយសរុបលើប្រព័ន្ធទឹកក្តៅប្រើថាមពលព្រះអាទិត្យ មានតម្លៃពី ២០.០០០ ទៅ ៥០.០០០ដុល្លារ អាស្រ័យលើចំនួនបន្ទប់ (១៥ ទៅ ២៥បន្ទប់ ក្នុងសណ្ឋាគារមួយ) ដែលខ្ពស់ជាងការចំណាយលើប្រព័ន្ធទឹកក្តៅប្រើអគ្គិសនីធម្មតា។ ប៉ុន្តែប្រព័ន្ធទឹកក្តៅប្រើថាមពលព្រះអាទិត្យជួយសន្សំសំចៃបានច្រើនណាស់ ក្នុងអាយុកាលរបស់វា (១៥ ទៅ ២០ឆ្នាំ)។ នៅពេលតម្លៃថាមពលអគ្គិសនីក្នុងពិភពលោកកើនឡើង ការវិនិយោគទៅលើការប្រើប្រាស់ថាមពលមានប្រសិទ្ធភាព និងបច្ចេកវិទ្យាថាមពលកកើតឡើងវិញនាពេលបច្ចុប្បន្ន អាចក្លាយជាកម្លាំងប្រកួតប្រជែងធំធេងនាពេលអនាគត។ ការលើកកម្ពស់ចំណាប់អារម្មណ៍តាមការបង្ហាត់បង្ហាញពីផលប្រយោជន៍ផ្សេងៗ ការផ្តល់រង្វាន់ដោយមានការផ្សព្វផ្សាយជាសាធារណៈ និងការទទួលស្គាល់ជាសាធារណៈកាន់តែច្រើនឡើង នឹងជួយជំរុញវិនិយោគបែបនេះ។ នៅប្រទេសដទៃ មានការផ្សាយពាណិជ្ជកម្មក្នុងប្រព័ន្ធផ្សព្វផ្សាយ អំពីការកាត់បន្ថយចំណាយ តាមការអនុវត្តវិធានការប្រើប្រាស់ថាមពលមានប្រសិទ្ធភាព។

ការធ្វើវិនិយោគបែបនេះ អាចជួយកសាងកេរ្តិ៍ឈ្មោះប្រទេសកម្ពុជា ឲ្យក្លាយជាទិសដៅទេសចរណ៍បៃតង ដែលអាចទាក់ទាញភ្ញៀវទេសចរ ព្រោះពួកគេកាន់តែយកចិត្តទុកដាក់ទៅលើការថែរក្សាបរិស្ថាន។ ក្រុមហ៊ុនទេសចរណ៍ ក៏ដូចជាវិនិយោគិន កំពុងជំរុញឡើងជាលំដាប់នូវការធ្វើប្រតិបត្តិការទេសចរណ៍ប្រកបដោយនិរន្តរភាព ដែលបង្ហាញផងដែរអំពីការទាមទាររបស់អតិថិជន។ ការកំណត់គោលការណ៍ណែនាំដោយខ្លួនឯង និងដោយស្ម័គ្រចិត្ត ដូចជាក្នុងប្រព័ន្ធ Travelife Award system ដែលជាគម្រោងទទួលស្គាល់ដោយអន្តរជាតិ និងកំណត់ឡើងដោយសមាជិកឧស្សាហកម្មទេសចរណ៍ ដើម្បីផ្តល់ជាមេដៃមាស មេដៃប្រាក់ និងមេដៃសំរិទ្ធ ទៅដល់សេវាកម្មសណ្ឋាគារ ឬអាគារស្នាក់នៅនានា ដែលបានចូលរួមអនុវត្តតាមលក្ខខណ្ឌផ្នែកបរិស្ថាន និងសង្គម និងដែលនាបច្ចុប្បន្នមានតំណាង ២៥ ប្រទេសចូលរួម ក្នុងនេះគេនយ៉ា ជាប្រទេសមានប្រាក់ចំណូលទាបតែមួយគត់ដែលបានចូលជាសមាជិក។

ការរីកចម្រើនគម្រោងផ្តល់រង្វាន់ និងវិញ្ញាបនបត្រទទួលស្គាល់ដោយអន្តរជាតិនេះ អាចជំរុញឲ្យមានការត្រួតពិនិត្យដោយខ្លួនឯងលើការប្រើប្រាស់ទឹកនិងថាមពល និងការបញ្ចេញឧស្ម័នកាបូនិក ដែលកាន់តែសំខាន់ខ្លាំងឡើងសម្រាប់ សណ្ឋាគារទាំងឡាយណាដែលចង់រក្សាសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារ។ ដូច្នេះ គោលនយោបាយ និងបទបញ្ញត្តិច្បាប់ដ៏ចាំបាច់ៗសម្រាប់គ្រប់គ្រងធនធានធម្មជាតិ ព្រមទាំង ការលើកទឹកចិត្តវិស័យឯកជនឲ្យគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាពនិងប្រសិទ្ធភាពអាចជួយពង្រឹងសមត្ថភាពប្រកួតប្រជែងក្នុងការធ្វើអាជីវកម្ម។ ដោយឡែក សម្រាប់បណ្តាប្រទេសមានប្រាក់ចំណូលទាបដែលបានចាប់អនុវត្តគោលការណ៍ណែនាំទាំងនេះមុនគេ គឺអាចធ្វើឲ្យក្រុមហ៊ុនអាជីវកម្ម ឬ សេវាកម្មរបស់ខ្លួន ទទួលបានការគាំទ្រកេរ្តិ៍ឈ្មោះ និងសញ្ញាសំគាល់ "brand" លំដាប់អន្តរជាតិ ជាពិសេសសម្រាប់ទេសចរណ៍បៃតង (ERD 2012)។ ប៉ុន្តែការយល់ដឹងពីបរិស្ថានក្នុងចំណោមអ្នកទេសចរក្នុងតំបន់នៅមានកម្រិតទាប ដូច្នេះការដាក់សម្ពាធឲ្យសេវាកម្មទេសចរណ៍អនុវត្តនូវវិធីសាស្ត្របៃតងនេះ ប្រហែលពុំសូវមានប្រសិទ្ធភាពទេ ពិនិត្យតាមលំនាំនៃការរីកចម្រើនវិស័យទេសចរណ៍នៅកម្ពុជានាពេលបច្ចុប្បន្ន។

## ៥. សេចក្តីសន្និដ្ឋាន

តារាង ៤ សង្ខេបពីកាលានុវត្តភាពសំខាន់ៗ និងហានិភ័យនានាដែល វិស័យទេសចរណ៍កម្ពុជាបាននិងកំពុងជួបប្រទះ ដោយសារឥទ្ធិពលនៃកត្តាទាំងបីដូចបានពិភាក្សាខាងដើម ពោលគឺ ការក្រខ្សត់ធនធានធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងគោលនយោបាយអន្តរជាតិដើម្បីកាត់បន្ថយការប្រែប្រួលនេះ។ បន្ទាប់មក មានការលើកឡើងពីដំណោះស្រាយផ្នែកគោលនយោបាយ និងអាជីវកម្មមួយចំនួន ដែលគួរធ្វើការពិភាក្សា និងសិក្សាស្រាវជ្រាវបន្ថែមទៀត៖

តារាង ៤៖ សង្ខេបអំពីកាលានុវត្តភាព និង ហានិភ័យនានា

| **កាលានុវត្តភាព/ហានិភ័យ** | **លទ្ធផល/ចម្លើយតប** |
|---|---|
| **ការក្រខ្សត់ធនធានធម្មជាតិ** | |
| ការរីកចម្រើនទេសចរណ៍អាចដាក់សម្ពាធខ្លាំងទៅលើធនធានធម្មជាតិ (ទឹក និងថាមពល) និងគំរាមកំហែងដល់តម្លៃនៃតំបន់ទាក់ទាញទេសចរណ៍ ដូចជា ប្រាសាទអង្គរវត្ត ជាដើម។ | ធ្វើការសិក្សាពីហេតុប៉ះពាល់បរិស្ថានសង្គម (EIA) សម្រាប់គម្រោងអភិវឌ្ឍទេសចរណ៍ដែលបានស្នើឡើង ដោយមានស្រង់ទាំងយោបល់ពិគ្រោះរបស់អ្នកពាក់ព័ន្ធទាំងអស់<br>ធ្វើការវិនិយោគបង្កើតតំបន់ទេសចរណ៍ឲ្យបានកាន់តែច្រើន ដើម្បីកាត់បន្ថយសម្ពាធលើតំបន់ទេសចរណ៍មួយចំនួន និងបែងចែកប្រាក់ចំណូលឲ្យបានទូលំទូលាយ។<br>ធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម (ឧទាហរណ៍ ទឹក និងអនាម័យ) ដែលចាំបាច់សម្រាប់ការពង្រីកទេសចរណ៍ប្រកបដោយនិរន្តភាព។<br>បង្កើតក្របខ័ណ្ឌច្បាប់សមស្រប, លើកកម្ពស់ការយល់ដឹងពីការគ្រប់គ្រងធនធានធម្មជាតិ និងទេសចរណ៍បៃតងដែលមាននិរន្តភាព នៅក្នុងសហគមន៍ និងជាមួយអ្នកទេសចរ។<br>ពិនិត្យពីចំណាយ និងចំណូល លើការគ្រប់គ្រងចំនួនភ្ញៀវទេសចរ។ |

| | |
|---|---|
| ការគ្រប់គ្រងសំណល់មិនបានល្អជាកត្តាគំរាមកំហែងដល់ការរីកចម្រើនទេសចរណ៍និងការអភិវឌ្ឍជាទូទៅ ប៉ុន្តែមានកាលានុវត្តភាពជាច្រើនក្នុងការកែច្នៃសំណល់ឲ្យទៅជាថាមពលអគ្គិសនី។ | ដាក់អនុវត្តក្របខ័ណ្ឌច្បាប់សមស្រប និងសិក្សាស្វែងរកជម្រើសនានា ដើម្បីបង្កើតទីផ្សារថ្មីៗ ក្នុងគម្រោងកែច្នៃសំណល់ឲ្យទៅជាថាមពល។<br>ណែនាំឲ្យអនុវត្ត និងពង្រឹងយុទ្ធសាស្ត្រ 3 R: កាត់បន្ថយ (Reduce), ប្រើប្រាស់ឡើងវិញ (Reuse), និង កែច្នៃឡើងវិញ (Recycle)។<br>ណែនាំឲ្យធ្វើយុទ្ធនាការកែលំអការប្រើប្រាស់ធនធានធម្មជាតិឲ្យមានប្រសិទ្ធភាព។ |
| សក្តានុពលមានច្រើនណាស់ក្នុងការពង្រីកតំបន់អេកូទេសចរណ៍ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការលូតលាស់បៃតង | បង្កើតយុទ្ធសាស្ត្រមានការសម្របសម្រួលល្អមួយសម្រាប់ការអភិវឌ្ឍ អេកូទេសចរណ៍ ដោយមានការចូលរួមពីគ្រប់ក្រសួងនិងអ្នកពាក់ព័ន្ធ ដើម្បីឲ្យមានតុល្យភាពរវាងទិសដៅខុសៗគ្នារបស់ពួកគេ ហើយបង្កើតបាននិងអនុវត្តនូវក្របខ័ណ្ឌច្បាប់មួយដ៏សមស្រប។<br>ពង្រឹងការការពារ និងអភិរក្សតំបន់អេកូទេសចរណ៍។<br>ធ្វើការបោះបង្គោលព្រំជាផ្លូវការនៅជុំវិញតំបន់អេកូទេសចរណ៍។<br>ចាត់វិធានការនានាដើម្បីទាក់ទាញវិនិយោគឯកជនទៅក្នុងវិស័យ អេកូទេសចរណ៍ តាមរយៈកិច្ចពិភាក្សារវាងឯកជននឹងស្ថាប័នរដ្ឋ។<br>ធ្វើវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធសេវាកម្មបណ្តុះបណ្តាលជំនាញផ្សេងៗ សម្រាប់សហគមន៍ និងធ្វើការផ្សព្វផ្សាយទីផ្សារ ដើម្បីជំរុញកំណើនអេកូទេសចរណ៍។ |
| **គោលនយោបាយអន្តរជាតិកាត់បន្ថយការប្រែប្រួលអាកាសធាតុ** | |
| ការយកពន្ធលើអាកាសចរ និងតម្លៃដឹកជញ្ជូនតាមផ្លូវអាកាស អាចកើនឡើង និងប៉ះពាល់ដល់ការរីកចម្រើនវិស័យទេសចរណ៍<br>ឧស្សាហកម្មទេសចរណ៍ដែលជាអ្នកទាមទារនិងជំរុញកំណើនបៃតង ត្រូវបង្ហាញឲ្យឃើញថា គំនិតផ្តួចផ្តើមឲ្យមានកេរ្តិ៍ឈ្មោះបៃតង គឺជាប្រភពនៃឧត្តមភាពប្រកួតប្រជែង | ផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរណ៍ក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជួយសម្រួលការធ្វើដំណើរឆ្លងកាត់ព្រំដែន ដោយសហការជាមួយប្រទេសជិតខាង។<br>សហការជាមួយឧស្សាហកម្មទេសចរណ៍ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីការថែរក្សាបរិស្ថាន អនាម័យស្អាត។<br>ផ្តោតខ្លាំងទៅលើទីផ្សារអ្នកទេសចរដែលចូលចិត្តបរិស្ថាន។<br>បន្តផ្សព្វផ្សាយពាក្យស្លោក "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ" និងជំរុញការប្រកួតប្រជែងក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនក្នុងវិស័យទេសចរណ៍នៅកម្ពុជា។<br>លើកទឹកចិត្តការប្រើប្រាស់ផលិតផលធម្មជាតិក្នុងស្រុក និងបច្ចេកវិទ្យាប្រើប្រាស់ថាមពលមានប្រសិទ្ធភាព។ |
| ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុរបស់រដ្ឋ អាចយកមកវិនិយោគលើការអភិវឌ្ឍទេសចរណ៍បៃតង និងអេកូទេសចរណ៍។ | បង្កើតឲ្យមានយុទ្ធសាស្ត្រថ្មីដើម្បីទាញយកប្រភពហិរញ្ញប្បទានរបស់រដ្ឋដូចជាថវិកាវិនិយោគអាកាសធាតុ ជាដើម។ |
| កំណើនចំណាប់អារម្មណ៍ទៅលើគុណភាពបរិស្ថានពីភ្ញៀវទេសចរ និងឧស្សាហកម្មទេសចរណ៍ នឹងនាំឲ្យមានការបង្កើតតំបន់ទេសចរណ៍បៃតងកាន់តែច្រើន។ | ធ្វើឲ្យកម្ពុជាក្លាយជាទិសដៅទេសចរណ៍ធម្មជាតិបៃតង ដើម្បីពង្រឹងឧត្តមភាពប្រកួតប្រជែង។<br>បង្ហាញនិងពង្រឹងស្តង់ដារ ស្លាកសញ្ញា និងគម្រោងផ្តល់រង្វាន់ដល់ប្រតិបត្តិករទេសចរណ៍ណាដែលអនុវត្តបាននូវគុណភាពបរិស្ថានបៃតងមានជាអាទិ៍ ការប្រើថាមពលមានប្រសិទ្ធភាព និងការគ្រប់គ្រងសំណល់រាវដោយមានការទទួលខុសត្រូវខ្ពស់។<br>ផ្សព្វផ្សាយ និងពង្រីកបន្ថែមការផ្តល់រង្វាន់ សណ្ឋាគារបៃតងអាស៊ាន និងគិតគូរពីការចូលរួមក្នុងគម្រោងអន្តរជាតិ the international Travelife scheme |

ប្រទេសកម្ពុជាបានទទួលផលប្រយោជន៍យ៉ាងច្រើនពី ការរីកចម្រើនវិស័យទេសចរណ៍ក្នុង ១០ឆ្នាំចុងក្រោយនេះ ហើយក៏នៅមានសក្តានុពលជាច្រើនទៀត ដើម្បីបន្តរីកដុះដាលទៅមុខ។ ទោះជាយ៉ាងនេះក្តី ត្រូវមានការគ្រប់គ្រងធនធានធម្មជាតិឲ្យបានសមស្រប ដើម្បីជៀសវាងការអាក់ដំណើរ។ តំបន់ទេសចរណ៍កម្ពុជា ត្រូវបង្កើតឲ្យមានច្រើនកន្លែងក្រៅពីតំបន់បេតិកភណ្ឌពិភពលោកក្នុងខេត្តសៀមរាប និងព្រះវិហារ ដើម្បីកាត់បន្ថយសម្ពាធទៅលើបរិស្ថានក្នុងតំបន់ទាំងនោះ និងដើម្បីទាញយកផលប្រយោជន៍ពីធនធានធម្មជាតិ និង បែងចែកផលប្រយោជន៍ឲ្យបានទូលំទូលាយក្នុងប្រទេស។

កំណើនការយកចិត្តទុកដាក់ជាអន្តរជាតិទៅលើ គុណភាពបរិស្ថានក្នុងវិស័យទេសចរណ៍ នឹងបានជាប្រយោជន៍ដល់តំបន់ទេសចរណ៍ណាដែលយកចិត្តទុកដាក់លើ ការថែរក្សាធនធានបរិស្ថាន។ ដូច្នេះ ការកសាងកេរ្តិ៍ឈ្មោះប្រទេសកម្ពុជាឲ្យក្លាយជាគោលដៅទេសចរណ៍បៃតង អាចសំខាន់ខ្លាំងសម្រាប់ការកសាងឧត្តមភាពប្រកួតប្រជែងនាពេលអនាគត។ ការបង្កើតបទបញ្ញត្តិច្បាប់ ឬការលើកទឹកចិត្តឲ្យលើកកម្ពស់របៀបប្រើប្រាស់ថាមពលមានប្រសិទ្ធភាពខ្ពស់ និងមិនប៉ះពាល់ដល់បរិស្ថានក្នុងវិស័យទេសចរណ៍ នឹងជួយឲ្យសម្រេចបាននូវគោលបំណងនេះ។

ការវិនិយោគទៅលើថាមពលកកើតឡើងវិញ និងវិធានការប្រើប្រាស់ថាមពលមានប្រសិទ្ធភាពនៅតាមសណ្ឋាគារ និងកន្លែងស្នាក់នៅផ្សេងៗ អាចជួយកាត់បន្ថយចំណាយ និងទទួលបានកេរ្តិ៍ឈ្មោះល្អ។ ប៉ុន្តែនៅកម្ពុជា ហាក់ពុំទាន់មានការផ្សព្វផ្សាយទូលំទូលាយអំពីបញ្ហាទាំងនេះទេ បើធៀបទៅនឹងប្រទេសដទៃទៀត។ ដូចនេះ ការផ្សព្វផ្សាយជាសាធារណៈ និងការផ្តល់ការលើកទឹកចិត្តឲ្យធ្វើវិនិយោគទៅលើគម្រោងក្នុងផ្នែកនេះ អាចជួយរក្សាសមត្ថភាពប្រកួតប្រជែងក្នុងវិស័យទេសចរណ៍។ ការគាំទ្រឲ្យមានការធ្វើសវនកម្មថាមពល ឬ ការណែនាំឲ្យប្រើថាមពលកកើតឡើងវិញនៅតាមសណ្ឋាគារ និងការគាំទ្រដល់គម្រោងទេសចរណ៍ធម្មជាតិ អាចជួយចូលរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាព។

អេកូទេសចរណ៍មានសក្តានុពលច្រើនណាស់ដើម្បីអភិវឌ្ឍឡើង និងក្លាយជាប្រភពអភិវឌ្ឍ និងចំណូលថ្មីៗ ដែលនឹងជួយដល់ការការពារសម្បត្តិធម្មជាតិ (ឧទាហរណ៍ ព្រៃឈើ) និងការគ្រប់គ្រងធនធានធម្មជាតិដទៃទៀត។ ប៉ុន្តែវិស័យនេះមិនទាន់អភិវឌ្ឍបានល្អទេ ដូច្នេះត្រូវធ្វើការងារច្រើនទៀត ដើម្បីជំនះលើឧបសគ្គទាំងឡាយ។

ឧស្សាហកម្មទេសចរណ៍ មានផលប្រយោជន៍ និងធ្វើការអភិវឌ្ឍដោយគិតគូរពីបរិស្ថាន និងនិរន្តរភាព ហើយតាមការការពារធនធានបរិស្ថានធម្មជាតិ វាអាចដើរតួរជាអ្នកតស៊ូមតិគាំទ្រដល់គោលនយោបាយអភិវឌ្ឍបៃតង។ ការសិក្សានេះបង្ហាញថា មានការគួបកម្លាំងគ្នាច្រើនណាស់ រវាងការអភិវឌ្ឍវិស័យទេសចរណ៍ឲ្យមាននិរន្តរភាព និងមានចំណេញច្រើន និងការជំរុញការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងសម្រាប់គ្រប់គ្នា។

## ឯកសារយោង


Apsara Authority (2005), “Water Supply”, http://www.autoriteapsara.org/en/apsara/urban_development/city/water_supply.html (accessed 22 March 2013)

Ballard, B. (2005),“Linking Tourism to Poverty Reduction: A Siem Reap Case Study”, *Annual Development Review 2004-05*(Phnom Penh: CDRI) 78-96

Björn, A. (2012),“Cambodia Hotel Gets ASEAN Award”, http://phnom-penh.info/cambodian-hotels-get-asean-award/(accessed 5 August 2013)

CDRI, Cambodia Development Resource Institute (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities*(Phnom Penh: CDRI)

Derkeiler (2009), “Stung Meanchey Waste to Become Methane Gas, Electricity: City Hall”, http://newsgroups.derkeiler.com/Archive/Soc/soc.culture.cambodia/200904/msg00346.html (accessed 26 March 2013)

Doherty, Ben (2010),”Private Water Raiding Threatens Angkor's Temples Built on Sand”, 27 February 2010, *The Guardian,* http://www.theguardian.com/world/2010/sep/27/water-raiding-threatens-angkor-wat (accessed 2 January 2014)

Ellis, Karen, Jodie Keane, Alberto Lemma and Lonn Pichdara (2013), *Low Carbon Competitiveness in Cambodia* (London: Overseas Development Institute)

Ellis, K. (2013), *Low Carbon Competitiveness: Analysing Opportunities and Threats for Low-Income Countries, and the Business Case for Low Carbon Investment*, ODI Working Paper 368 (London: ODI)

Euronet (2012), “Country Environment Profile: Royal Kingdom of Cambodia”, http://eeas.europa.eu/delegations/cambodia/documents/publications/country_env_profile_cam_april_2012_en.pdf (accessed 14 June 2013)

EU, European Union (2012), *European Report on Development 2012 Confronting Scarcity: Managing Water, Energy and Land for Inclusive and Sustainable Growth* (London: Overseas Development Institute)

Fankhauser, S. and R.S. Tol (1997),“The Social Costs of Climate Change: The IPCC Second Assessment Report and Beyond”, *Mitigation and Adaptation Strategies for Global Change,* 1(4), 385-403

Grand Soluxe Angkor Palace (2013), “ASEAN Green Hotel Standard Award 2010-2011”, http://www.angkorpalaceresort.com/award/Award.aspx (accessed 22 March 2013)

Hem Socheat (2013), *Impact of the Global Financial Crisis on Cambodian Economy at Macro and Sectoral Levels*, Working Paper Series No. 72 (Phnom Penh: CDRI)

Hruby, Denise (2013), “Home Farming, No Compensation to Blame for H5N1 Rate”,*Cambodia Daily,* 6 November 2013, http://www.cambodiadaily.com/news/home-farming-no-compensation-to-blame-for-h5n1-rate-46685/ (accessed 31 December 2013)

ILO, International Labour Organization (2010), “Final Report of the Discussion”, Global Dialogue Forum on New Development and Challenges in the Hospitality and Tourism Sector and their impact on Employment, Human Resources Development and Industrial Relations. Sectoral Activities Department, Geneva, 23-24 November 2010 http://www.ilo.org/wcmsp5/groups/public/---ed_dialogue/---sector/documents/meetingdocument/wcms_163430.pdf (accessed 2 January 2014)

Junior Chamber International Cambodia (2011), “JCI Newsletter 2011-2012”, http://www.jcicambodia.com/index.php?option=com_content&view=article&id=87:jci-newsletter-2011-2012&catid=50:jci-cambodia&Itemid=28 (accessed 2 January 2014)

Karantzavelou, Vicky (2012), “ASEAN Green Hotel Recognition Award 2012”, *Travel Daily News,* 12 January 2012, http://www.traveldailynews.asia/news/article/47180/asean-green-hotel-recognitionaward

Kim, N. and M. Browne (eds.) (2011), *Stay Another Day Cambodia 2011-12: Cambodia's Guide to Responsible Travel,* Fourth Edition (Phnom Penh: Economics Today)

Leksakundilok, A. (2004), *Ecotourism and Community-based Ecotourism in the Mekong Region,* Working Paper No. 10, Australian Mekong Resource Centre, University of Sydney
Lonn P., M. Nobuya, K. Tsuyoshi and Y. Shigejiro (2012), "Effectiveness of Community-Based Ecotourism in Forest Conservation and Livelihood Improvement: A Case Study in Chambok Community-Based Ecotourism", proceedings of the conference on Sustainable Forest Ecosystem Management in Rapidly Changing World, 12-14 September 2012, Taiwan
Men, P. (2007), "Tourism Impact: Incomes Distribution Case of Angkor Heritage Site, Siem Reap Province"(Phnom Penh: Department of Tourism, Royal University of Phnom Penh)
MOT, Ministry of Tourism (2009), "Law on Tourism", http://www.tourismcambodia.org/camtourismlaw/index.php (accessed 14 August 2013)
MOT (2012a), *2012-2020 Tourism Strategic Development Plan* (Phnom Penh: MOT)
MOT(2012b), *Tourism Statistics Annual Report 2011* (Phnom Penh: Statistics and Tourism Information Department, MOT)
MOT (n.d.),"Cambodia Tourism Marketing Strategy Post Global Economic Crisis 2011-2013",: http://ampilvillages.webs.com/documents/Tourism%20Marketing%20Strategy%202011-2013.pdf (accessed 2 January 2014)
NIS, National Institute of Statistics (2012), *Statistical Year Book of Cambodia 2011*(Phnom Penh: Ministry of Planning)
Pollock, A. (2007),"The Climate Change Challenge: Implications for the Tourism Industry", http://icarusfoundation.typepad.com/icarusblog/files/Icarus_Report_Final2.pdf (accessed 2 January 2014)
Rann Reuy (2013), "Ecotourism in Cambodia up 9.7 per cent" *Phnom Penh Post*, 14 February 2013 http://www.phnompenhpost.com/business/ecotourism-cambodia-97-cent (accessed 18 August 2013)
Reimer, J.K.and P.Walter(2012),"How do You Know It When You See It? Community-based Ecotourism in the Cardamom Mountains of Southwestern Cambodia", *Tourism Management,* 34, 122-132
RGC, Royal Government of Cambodia (2012), "Mid-Term Review 2011 on National Strategic Development Plan Update 2009-2013" (Phnom Penh: Ministry of Planning)
Shoko, Mitani (n.d,),"Green Tourism, Environmentally Sound Rural Tourism in Japan: Recommendations for Improvement of Japanese Green Tourism Practices", master thesis, Maastricht Graduate School of Governance, http://arno.unimaas.nl/show.cgi?fid=15252 (accessed 2 January 2014)
SNV World (2010), "Mekong Discovery Trail: Explore River Life in Northeast Cambodia" YouTube video, 6:23, 11 February 2010, http://www.youtube.com/watch?v=96Vzulj97go (accessed 27 March 2013)
TIES, The International Ecotourism Society (2012), "How is Ecotourism Different from Nature Tourism, Sustainable Tourism, Responsible tourism?", http://www.ecotourism.org/book/how-ecotourism-different-nature-tourism-sustainable-tourismresponsible-tourism (accessed 2 April 2012)
Tourism of Cambodia (2013), "Mekong Discovery Trail – Stung Treng", http://www.tourismcambodia.com/travelguides/provinces/stung-treng/what-to-see/429_mekongdiscovery-trail.htm (accessed 27 March 2013)
UNDESA, United Nations Department of Economic and Social Affairs (2002),"Guidance in Preparing a National Sustainable Development Strategy: Managing Sustainable Development in the New Millennium", Background paper No. 13, Outcome of the International Forum on National Development Strategies, Accra, Ghana, 7-9 November 2001
UNEP, United Nations Environment Programme (2011), *Towards a Green Economy: Pathways to Sustainable Development and Poverty Eradication* (Nairobi: UNEP)
UNEP (2013), "Green Economy and Trade – Trends, Challenges, and Opportunities", http://www.unep.org/greeneconomy/GreenEconomyandTrade

UNEP (n.d.), "What is the 'Green Economy'?" http://www.unep.org/greeneconomy/AboutGEI/WhatisGEI/tabid/29784/language/en-US/Default.aspx (accessed 2 January 2014)
UNEP and UNWTO (2005), *Making Tourism more Sustainable: A Guide for Policy Makers*
http://www.unep.fr/scp/publications/details.asp?id=DTI/0592/PA
UNWTO, United Nations World Tourism Organization (2008), "Climate Change and Tourism –Responding to Global Challenges" (Madrid: UNWTO and UNEP)
VISA (2010),"Visa and PATA Survey: Mainland Chinese Most Frequent Outbound Travelers from Greater China", Hong Kong, 7 July 2010, http://www.visa-asia.com/ap/hk/en_US/mediacenter/pressrelease/hk_07072010PATASurvey.shtml
World Bank (2012), *World Development Indicators 2012* (Washington, DC: World Bank)
World Economic Forum (2013), *Global Competitiveness Report 2013-2014* (Geneva: WEF)
World Travel & Tourism Council (2013), "Travel and Tourism –Economic Impact Cambodia 2013" (London: World Travel & Tourism Council)
Xinhua English News (2013), "Cambodia Launches 'One Tourist, One Tree' Campaign to Promote Green Tourism", 27 February 2013, http://news.xinhuanet.com/english/travel/201302/27/c_132196175.htm (accessed 22 March 2013)

-១១-

# ឥទ្ធិពលនៃកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ទៅលើលទ្ធិប្រជាធិបតេយ្យថ្នាក់ មូលដ្ឋាន៖ ទស្សនៈពីភូមិវិទ្យានយោបាយផ្អែកលើ ការសិក្សាពីគម្រោងបោះព្រំទន្លេសាប

*ដោយបណ្ឌិត គឹមស៊ាន ស៊ុំម៉ាត្រា និង ហ៊ត ណារី*

ជាង ២ទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានធ្វើកំណែទម្រង់យ៉ាងច្រើនគួរឲ្យកត់សម្គាល់ ដើម្បីសម្រេចបានលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ កំណែទម្រង់ទាំងនោះ រួមមានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សម្រាប់លើកកម្ពស់គណនេយ្យភាព ការតំណាង និងការឆ្លើយតបចំពោះតម្រូវការថ្នាក់មូលដ្ឋាន។

កន្លងមកមានការពិភាក្សាជាច្រើនស្តីពី សមត្ថភាពរបស់រដ្ឋក្នុងការផ្តល់នូវគណនេយ្យភាព ការតំណាង និងការឆ្លើយតបចំពោះតម្រូវការនៅថ្នាក់មូលដ្ឋាន។ ក្រុមអ្នកស្រាវជ្រាវដែល វិភាគពីកំណែទម្រង់ដោយផ្អែកលើទស្សនៈរបស់ថ្នាក់មូលដ្ឋាន យល់ឃើញថា កំណែទម្រង់នេះបានជះឥទ្ធិពលជាវិជ្ជមាន។ចំណែកក្រុមអ្នកស្រាវជ្រាវដែលផ្អែកលើបទដ្ឋាននៃកំណែទម្រង់ យល់ឃើញថា កំណែទម្រង់នេះមិនបានផ្តល់ផលជាវិជ្ជមានគួរឲ្យកត់សម្គាល់ទេ។ ដើម្បីរួមចំណែកក្នុងការស្វែងយល់បន្ថែមពីឥទ្ធិពលនៃកំណែទម្រង់ ការសិក្សានេះមានពិភាក្សាពីស្ថានភាពប្រជាធិបតេយ្យរបស់រដ្ឋ ដូចជា គណនេយ្យភាព ការតំណាង និងការឆ្លើយតប តាមរយៈករណីសិក្សាពីការបោះបង្គោលព្រំព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប។

## ១. ក្របខ័ណ្ឌនៃការវិភាគ

ការសិក្សានេះធ្វើការវាយតម្លៃ ពីស្ថានភាពប្រជាធិបតេយ្យដោយផ្អែកលើគណនេយ្យភាព ការតំណាង និងការឆ្លើយតប។ គណនេយ្យភាព សំដៅលើសមត្ថភាពទទួលខុសត្រូវ និងពន្យល់បកស្រាយពីសកម្មភាពរបស់ខ្លួន។ ការតំណាង សំដៅលើឱកាសដែលប្រជាជនអាចបង្ហាញពីតម្រូវការរបស់ខ្លួនទៅដល់រដ្ឋាភិបាល ហើយការឆ្លើយតប សំដៅលើ ល្បឿន គុណភាព និងបរិមាណនៃការឆ្លើយតបរបស់រដ្ឋចំពោះតម្រូវការរបស់ប្រជាជន។

ការសិក្សានេះបានយក ទ្រឹស្តីការបែងចែកតំបន់គ្រប់គ្រង មកធ្វើជាគោលនៃការវិភាគ។ ទ្រឹស្តីនេះផ្តោតលើ ការកំណត់របបគ្រប់គ្រងធម្មជាតិ ការធ្វើផែនទីធនធានធម្មជាតិ ការបោះព្រំ និងការអនុម័តព្រំ។ ដោយការគ្រប់គ្រងធនធានបែបនេះ នាំឲ្យមានការកំណត់ភូមិសាស្ត្រឡើងវិញ ហើយអាចនាំឲ្យមានការហ៊ុមព័ទ្ធ ឬ ការរាំងដល់ការប្រើប្រាស់ដីរបស់ប្រជាជន ដូច្នេះការសិក្សារបស់យើង អាចជួយបំភ្លឺពី កម្រិតឆ្លើយតបរបស់រដ្ឋចំពោះតម្រូវការរបស់ប្រជាជន។ ការកំណត់ក្របខ័ណ្ឌវិភាគបែបនេះ អាចឲ្យយើងធ្វើការសន្និដ្ឋានពី ស្ថានភាពប្រជាធិបតេយ្យដែលជាលទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## ២. វិធីសាស្ត្រស្រាវជ្រាវ និងករណីសិក្សា

ដោយឃើញការបាត់បង់ព្រៃលិចទឹកបានកើនឡើងយ៉ាងខ្លាំងពី ៧៩៥.០០០ហិកតាក្នុងឆ្នាំ ១៩៨៥ ដល់ ២០.០០០ហិកតាក្នុងឆ្នាំ១៩៩៧ សម្តេចនាយករដ្ឋមន្ត្រីក៏ប្រកាសឲ្យមាន ការបោះព្រំបែងចែកតំបន់ព្រៃលិចទឹក និងដីស្រែស្រូវឡើងទឹក ដោយសង្កត់ធ្ងន់លើការគោរពដីស្រែមានស្រាប់របស់ប្រជាជន។ គម្រោងនេះបានចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ២០១០ ដល់ ២០១១។ ការសិក្សានេះបានប្រមូលព័ត៌មានតាមរយៈ ការវិភាគលើឯកសារមានស្រាប់ ការធ្វើសម្ភាសន៍ជាផ្លូវការនិងក្រៅផ្លូវការ និង ការធ្វើអង្កេតដល់កន្លែង។

## ៣. លទ្ធផលរកឃើញ

លទ្ធផលរកឃើញ ចែកចេញជា ៣ផ្នែក។ ផ្នែកទី១ និងទី២ ផ្តោតលើយុទ្ធសាស្ត្ររបស់រដ្ឋពីថ្នាក់លើមកថ្នាក់ក្រោម ក្នុងការធ្វើផែនទី និងបោះព្រំ ហើយផ្នែកទី៣ផ្តោតលើ ចលនារបស់ប្រជាជននៅមូលដ្ឋានក្នុងការទាមទារដីស្រែរបស់ខ្លួន។ ការសិក្សាពីដំណើរការទាំងនេះ សំខាន់ខ្លាំងណាស់សម្រាប់ការស្វែងយល់ពី គណនេយ្យភាព ការតំណាង និង ការឆ្លើយតបរបស់រដ្ឋចំពោះតម្រូវការរបស់ប្រជាជន។

### ៣.១ ការបង្កើតផែនទី និងគណនេយ្យភាព

ការបង្កើតផែនទីថ្មីសម្រាប់បឹងទន្លេសាបបង្ហាញថា រដ្ឋមិនមានគណនេយ្យភាពគ្រប់គ្រាន់ចំពោះប្រជាជនមូលដ្ឋានឡើយ។ ករណីសិក្សានេះបង្ហាញថា ប្រជាជនមូលដ្ឋានមិនបានដឹងថា មានការប្រមូលទិន្នន័យសម្រាប់បង្កើតផែនទីនោះទេដូច្នេះពួកគាត់មិនបានចូលរួមក្នុងការងារបង្កើតផែនទីឡើយ។ ទន្ទឹមគ្នានោះ អាជ្ញាធរមូលដ្ឋានក៏មិនមានតួនាទីសមស្របដែរ ក្នុងការប្រមូលទិន្នន័យ និងការបង្កើតផែនទី ហើយអាជ្ញាធរមូលដ្ឋានខ្លះមិនបានដឹងសូម្បីតែអំពី ការកែប្រែគោលនយោបាយក្នុងការបោះបង្គោលព្រំនេះផង។ ដោយសារមិនមានការចូលរួមពីថ្នាក់មូលដ្ឋាន ការបង្កើតផែនទីនេះមិនបានគោរពតាមការប្រើប្រាស់ដីជាក់ស្តែង តាំងពីដើមមករបស់ប្រជាជនឡើយ។

ក្នុងការអនុវត្តជាក់ស្តែង ការប្រមូលទិន្នន័យ និងការបង្កើតផែនទី គឺគោរពទៅតាមការណែនាំរបស់ក្រសួង ដែលបានកំណត់ទំហំព្រៃលិចទឹកចំនួន ៦៤៥.០០០ហិកតា ដើម្បីអភិរក្សព្រៃលិចទឹក តែមិនបានគិតពីការប្រើប្រាស់ដីរបស់ប្រជាជនក្នុងពេលបច្ចុប្បន្នឡើយ។ ករណីសិក្សានេះបង្ហាញថា គណនេយ្យភាពទៅថ្នាក់លើមានកម្រិតខ្ពស់ ជាពិសេសនៅក្នុងក្រសួងជំនាញ។

ជារួមមក ការធ្វើផែនទីមិនបានផ្តល់ឱកាសឲ្យអាជ្ញាធរមូលដ្ឋានបង្ហាញនូវគណនេយ្យភាពរបស់ខ្លួនចំពោះប្រជាជនមូលដ្ឋានទេ ព្រោះរាល់អំណាចក្នុងការគ្រប់គ្រង និងការសម្រេចចិត្តស្ថិតនៅលើមន្ត្រីថ្នាក់ជាតិ។ គេក៏មិនឃើញមានគណនេយ្យភាពអ្វីរវាងមន្ត្រីថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋានដែរ ព្រោះមន្ត្រីថ្នាក់ជាតិមិនបានពន្យល់ពីសកម្មភាពរបស់ខ្លួន ហើយក៏មិនទទួលយកយោបល់ពីអាជ្ញាធរមូលដ្ឋានក្នុងការប្រមូលទិន្នន័យសម្រាប់ធ្វើផែនទីដែរ។

## ៣.២ ការបោះបង្គោលព្រំ និងគណនេយ្យភាព

*ការបោះបង្គោលព្រំ និងគណនេយ្យភាពទៅថ្នាក់ក្រោម*

ការបោះបង្គោលព្រំនៅតំបន់ទន្លេសាបនេះ មិនបានបង្ហាញពីគណនេយ្យភាពពេញលេញនៅថ្នាក់មូលដ្ឋានឡើយ។ អាជ្ញាធរមូលដ្ឋានមិនបានចូលរួមក្នុងការសម្រេចចិត្ត និងការងារបោះបង្គោលព្រំទេ ដូច្នេះក៏មិនអាចធ្វើសកម្មភាពដើម្បីការពារផលប្រយោជន៍របស់ប្រជាជនមូលដ្ឋានដែរ។អាជ្ញាធរមូលដ្ឋានត្រូវបានគេចាត់ទុកត្រឹមជាសេនាធិការ ដែលត្រូវស្តាប់តាមមន្ត្រីថ្នាក់ជាតិ និងគ្រាន់តែជួយសម្របសម្រួលការងារទូទៅប៉ុណ្ណោះ។

មន្ត្រីថ្នាក់ជាតិក៏មិនបានបង្ហាញ គណនេយ្យភាពចំពោះប្រជាជនមូលដ្ឋានដែរ។ ប្រជាជនមូលដ្ឋានមិនបានបោះឆ្នោតតែងតាំងមន្ត្រីថ្នាក់ជាតិទេ ដូច្នេះពួកគេក៏មិនមានតួនាទីនិងការទទួលខុសត្រូវជាផ្លូវការ ដើម្បីឆ្លើយតបចំពោះប្រជាជនមូលដ្ឋានដែរ។ ពួកគេគោរពតាមតែបញ្ជាថ្នាក់ដឹកនាំនៅក្រសួងជំនាញប៉ុណ្ណោះ ដូច្នេះក៏ធ្វើការបោះបង្គោលព្រំទៅតាមការកំណត់ទំហំស្រាប់របស់ក្រសួង ដែលមិនបានគោរពតាមការប្រើប្រាស់ដីជាក់ស្តែងរបស់ប្រជាជនឡើយ។

*ការបោះបង្គោលព្រំ និងគណនេយ្យភាពទៅថ្នាក់លើ*

ជាទូទៅ បើសិនពុំមានគណនេយ្យភាពទៅថ្នាក់ក្រោមទេ គឺតែងតែមានគណនេយ្យភាពទៅថ្នាក់លើ ប៉ុន្តែករណីសិក្សានេះបង្ហាញថា គណនេយ្យភាពទៅថ្នាក់លើក៏មិនសូវច្បាស់លាស់ដែរ។ គណនេយ្យភាពទៅថ្នាក់លើក្នុងករណីសិក្សានេះ គឺអាស្រ័យទៅលើអ្នកគ្រប់គ្រងផ្ទាល់។ នាយករដ្ឋមន្ត្រីបានប្រកាសឲ្យមានការបោះបង្គោលព្រំច្បាស់លាស់រវាងព្រៃលិចទឹក និងដីស្រែស្រូវឡើងទឹក ប៉ុន្តែក៏ត្រូវគោរពតាមការប្រើប្រាស់ដីជាក់ស្តែងរបស់ប្រជាពលរដ្ឋដែរ។ មន្ត្រីថ្នាក់ជាតិទទួលបន្ទុកលើការងារបោះព្រំ បានគោរពតាមគោលនយោបាយរបស់នាយករដ្ឋមន្ត្រីក្នុងការបោះបង្គោលព្រំឲ្យច្បាស់លាស់ ប៉ុន្តែមិនបានប្រតិបត្តិតាមគោលនយោបាយឲ្យគោរពដីស្រែរបស់ប្រជាជននោះទេ។ ពួកគេបោះព្រំដោយគោរពតាមផែនទីដែលកំណត់ទំហំស្រាប់ពីក្រសួង។

ការបោះបង្គោលព្រំនៅតំបន់ទន្លេសាប មានការបត់បែនខ្លះអាស្រ័យលើការលំបាកក្នុងពេលអនុវត្តការងារ។ ដោយសារការបោះបង្គោលព្រំវគ្គទី១ ប៉ះចំរដូវភ្លៀង តំបន់ធ្វើប្រតិបត្តិការក៏មានទឹកជន់លិច និងពិបាកក្នុងការធ្វើដំណើរ ដូច្នេះភ្នាក់ងារនានាក៏បោះបង្គោលព្រំ ដោយមិនបានគោរពទាំងស្រុងតាមគោលនយោបាយឬផែនទីកំណត់ឡើងដោយថ្នាក់លើនោះទេ ព្រោះជួបបញ្ហា និងការពិបាកក្នុងការធ្វើដំណើរ។

ការអនុវត្តការងារជាក់ស្តែងក៏អាស្រ័យលើ លទ្ធភាពដែលភ្នាក់ងារទាំងនោះអាចស្វែងរកផលចំណេញផ្ទាល់ខ្លួនដែរ។ ផ្អែកលើការចុះអង្កេតផ្ទាល់ កសិករតូចតាចភាគច្រើនរងការប៉ះពាល់ ប៉ុន្តែកសិករធំៗមានអំណាច ជាពិសេសនៅខេត្តកំពង់ធំ មិនសូវរងការប៉ះពាល់ទេ។

ជារួម ការបោះបង្គោលព្រំមិនបានបង្ហាញពីគណនេយ្យភាពនៅថ្នាក់មូលដ្ឋានឡើយ ហើយគណនេយ្យភាពទៅថ្នាក់លើក៏មិនសូវច្បាស់លាស់ដែរ ព្រោះអាស្រ័យទៅលើការយល់ឃើញរបស់អ្នកបញ្ជាផ្ទាល់ ការលំបាកក្នុងការធ្វើដំណើរ និងឱកាសស្វែងរកផលចំណេញផ្ទាល់ខ្លួន។

### ៣.៣ តម្រូវការរបស់ប្រជាជន ការតំណាង និងការឆ្លើយតប

ការវិភាគបង្ហាញថា មន្ត្រីនៅមូលដ្ឋានមិនអាចធ្វើជាតំណាងដើម្បីបម្រើផលប្រយោជន៍របស់ប្រជាជនបានទេ គឺផ្ទុយពីគោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការបោះព្រំធ្វើឲ្យប្រជាជនមូលដ្ឋានមួយចំនួនបាត់បង់ដីស្រែឡើងទឹក ហើយពួកគេក៏នាំគ្នាត៉វ៉ា ប៉ុន្តែមិនមានអាជ្ញាធរមូលដ្ឋានណាមួយហ៊ានចេញមុខតំណាងឲ្យពួកគេឡើយ។ មេភូមិ និងមេឃុំ មិនហ៊ានធ្វើជាតំណាងឲ្យប្រជាជនទេ ទោះបីពួកគេមិនគាំទ្រសកម្មភាពមន្ត្រីថ្នាក់ជាតិក៏ដោយ ពីព្រោះអាជ្ញាធរមូលដ្ឋានមិនមានតួនាទីច្បាស់លាស់នៅក្នុងការងារបោះព្រំនេះ។ ដោយសារអាជ្ញាធរមូលដ្ឋានមិនហ៊ានធ្វើជាតំណាងឲ្យប្រជាជន ទើបមានកសិករមួយក្រុមចេញមុខធ្វើជាតំណាងប្រមូលផ្តុំកសិករដទៃទៀតដែលរងផលប៉ះពាល់ ដើម្បីដាក់ពាក្យត៉វ៉ា។

ដំណើរការដាក់ពាក្យត៉វ៉ាដោយផ្ទាល់បែបនេះ បង្ហាញថា អាជ្ញាធរមូលដ្ឋានខ្វះការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាជន។មេឃុំមិនហ៊ានទទួលយកពាក្យបណ្តឹងពីប្រជាជនទេដោយហេតុថាត្រូវរង់ចាំការណែនាំពីអភិបាលស្រុក ហើយអភិបាលស្រុកក៏ត្រូវរង់ចាំការណែនាំពីអភិបាលខេត្តដែរ។ ជាលទ្ធផល ក្រុមអភិបាលមិនហ៊ានទទួល ឬអនុម័តលើពាក្យបណ្តឹងទេ។ ការរង់ចាំការណែនាំពីថ្នាក់លើបែបនេះ គឺផ្ទុយពីគោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងបានរារាំងដល់ការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋានចំពោះតម្រូវការរបស់ប្រជាជន។ អាជ្ញាធរមូលដ្ឋានមិនហ៊ានឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនបែបនេះ គឺដោយសារពួកគាត់ខ្លាច មន្ត្រីមកពីថ្នាក់ជាតិចោទប្រកាន់ថា ចូលដៃជាមួយពួកឈ្មួញ និងការគម្រាមដាក់ខ្នោះ។

## ៤. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន

ករណីសិក្សាពីការបោះព្រំនៅតំបន់បឹងទន្លេសាបបង្ហាញថា រដ្ឋមិនបានបង្ហាញគណនេយ្យភាពចំពោះថ្នាក់មូលដ្ឋានទេ ដោយសារមានការបែងចែកការងារមិនច្បាស់លាស់រវាងមន្ត្រីថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន។ ចំណែកឯគណនេយ្យភាពទៅថ្នាក់លើវិញ ក៏មិនច្បាស់លាស់ដែរ ព្រោះអាស្រ័យលើឥទ្ធិពលរបស់អ្នកបញ្ជាផ្ទាល់ ការលំបាកក្នុងពេលអនុវត្តការងារ និង ការស្វែងរកផលចំណេញផ្ទាល់ខ្លួន។

ម្យ៉ាងវិញទៀត តួនាទីមិនច្បាស់លាស់របស់អជ្ញាធរមូលដ្ឋាននៅក្នុងការងារនេះ និងការគោរពតាមការប្រមូលផ្តុំអំណាចនៅថ្នាក់លើនិងមន្ត្រីថ្នាក់ជាតិ ធ្វើឲ្យអាជ្ញាធរមូលដ្ឋានមិនអាចធ្វើជាតំណាងជូនប្រជាជនដែលបានបោះឆ្នោតឲ្យពួកខ្លួន។

ការសិក្សាបានបង្ហាញទៀតថា ការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននៅមានកម្រិតទាប។ រដ្ឋបាលមូលដ្ឋានមិនត្រឹមតែមិនបានផ្តួចផ្តើមសកម្មភាពដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជននោះទេ ប៉ុន្តែថែមទាំងមិនហ៊ានគាំទ្រដល់ចលនាប្រជាជនក្នុងការត៉វ៉ាទៀតផង ដោយសារមានវប្បធម៌ភ័យខ្លាចដែលមន្ត្រីថ្នាក់ជាតិបានបង្កើតឡើង។

ផ្អែកលើទស្សនៈភូមិវិទ្យានយោបាយ ការសិក្សានេះបង្ហាញថា កំណែទម្រង់អភិបាលកិច្ចមិនមានឥទ្ធិពលល្អគួរឲ្យកត់សម្គាល់ទេក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ហើយគណនេយ្យភាព ការតំណាង និងការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាជន គឺត្រូវបានជំនួសដោយ ការគោរពតាមបញ្ជាពីថ្នាក់លើមកថ្នាក់ក្រោម។

# បញ្ជីគន្ថនិទ្ទេស

ADB, Asian Development Bank (2005), The Tonle Sap and Its Fisheries (M. Department, Trans.) *The Future Solutions Now: The Tonle Sap Initiative* (Manila, Philippines: Asian Development Bank)

CDRI, Cambodia Development Resource Institute (2013), *Cambodia's Development Dynamics: Past Performance and Emerging Priorities* (Phnom Penh: CDRI)

Chheat S., Lun P., Kim S., Heng S., Sok S. and Chhoun N. (2011), A Baseline Survey of Sub-national Government: Towards a Better Understanding of Decentralisation and Deconcentration in Cambodia (Phnom Penh: CDRI)

Craig, D. and Pak K. (2011), "Party Financing of Local Investment Projects: Elite and Mass Patronge", in C. Hughes and K. Un (eds.), *Cambodia's Economic Transformation.* (Copenhagen, Denmark: Nordic Institute of Asian Studies)

Diamond, L. (1999), *Developing Democracy: Towards Consolidation* (London: Johns Hopkins University Press)

Heng S., Kim S and So S. (2011), *Decentralised Governance in a Hybrid Polity: Localisation of Decentralisation Reform in Cambodia,* Working Paper Series No 63 (Phnom Penh: CDRI)

Hughes, C. (2009), "Reconstructing Legitimate Political Authority through Elections? In J. Ojendal and M. Lilja (eds.), *Beyond Democracy in Cambodia: Political Reconstruction in a Post-conflict Society* (Copenhagen: Nordic Institute of Asian Studies)

Kim, S.S. (2013), "Territoriality and State Power in Cambodia: The Case of Demarcation in Tonle Sap", PhD thesis, University of Sydney

Ledgerwood, J. and J. Vijghen (2002), "Decision Making in Rural Cambodian Vllages", in J. Ledgerwood (Ed.), *Cambodia Emerges from the Past: Eight Essays* (Dekalb, Illinios: Northern Illinois University)

Lefebvre, H. (1991), *The Production of Space* (B. Nicholson-Smith, Trans.) (Oxford: Blackwell)

Lipsky, M. (1980). *Street level bureaucrats*. Nova York: Russel Sage.

Manor, J. (1999), *The Political Economy of Democratic Decentralization* (Washington, DC: World Bank)

Niazi, T.H. (2011), "Deconcentration and Decentralization Reforms in Cambodia: Recomemdations for an Institutional Framework" (Mandaluyong City, Philippines: Asian Development Bank)

Ojendal, J. and Kim S. (2006),"'Korob, Kaud, Klach': In Search of Agency in Rural Cambodia", *Journal of Southeast Asian Studies, 37*, 507-526

RGC, Royal Government of Cambodia (2005), *Strategic Framework for Decentralization and Deconcentration Reforms* (RGC: Phnom Penh)

RGC (2008), *Law on Aadministrative Management of the Capital, Provinces, Municipalities, Districts and Khans* (RGC: Phom Penh)

Rusten, C., Sedara K., Netra E.and P. Kimchoeun (2004), *The Challenges of Decentralization Design in Cambodia* (Phnom Penh: CDRI)

Un K. (2006), "State, Society and Democratic Consolidation: The Case of Cambodia", *Pacific Affairs,* 79(2), 225-245

Un K. (2009), "The Judicial System and Democratization in Post-conflict Cambodia", in J. Ojendal and M. Lilja (eds.), *Beyond Democracy in Cambodia: Political Reconstruction inPpost-conflict Society* (Copenhagen: NIAS Press)

Un K. (2011), "Cambodia: Moving Away from Democracy?" *International Political Science Review, 32*(5), 546-562

Un K. and J. Ledgerwood (2003), "Cambodia in 2002: Decentralization and Its Effects on Party Politics", *Asian Survey, 43*(1), 113-119

Un K. and So S. (2009), "The Politics of Natural Resource Use in Cambodia", *Asian Affairs: An American Review,* 36(3), 123-138

Un, K., & So, S. (2011), Land rights in Cambodia: How neo-patrimonial politics restricts land policy reform. *Pacific Affairs,* 84(2), 289-308

Yishai, Y. (1984)," Responsiveness to Ethnic Demands: The Case of Israel", *Ethnic and Racial Studies, 7*(2), 283-300

-១២-

# ទំនាក់ទំនងរវាងក្រុមប្រឹក្សា ស្រុក/ក្រុង/ខណ្ឌ និងឃុំ/សង្កាត់៖ ភាពតំណាង និងគណនេយ្យភាព ក្នុងអភិបាលកិច្ចមូលដ្ឋាន

*ដោយ ឈាត ស្រ៊ាង[១]*

## ១. សេចក្តីផ្តើម

គម្រោងនេះស្រាវជ្រាវពីទំនាក់ទំនងរវាងកម្រិតពីរនៃ "រដ្ឋបាលមូលដ្ឋាន" ក្នុងប្រព័ន្ធវិមជ្ឈការនៅកម្ពុជា ដោយពិនិត្យពីអន្តរកម្មរវាង ឃុំ/សង្កាត់ (CS) ដែលស្ថិតនៅកម្រិតទាបបំផុតនៃរដ្ឋបាល និង ស្រុក/ក្រុង/ខណ្ឌ (DMK)។ រដ្ឋអំណាចទាំងពីរថ្នាក់នេះ គឺជាលទ្ធផលនៃកំណែទម្រង់វិមជ្ឈការ ដោយបានចាប់ដំណើរការនៅឆ្នាំ២០០២ ពេលការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សា CS ជាលើកដំបូង។ ឆ្នាំ២០០៩ ជាកាលបរិច្ឆេទដ៏សំខាន់បំផុត នៅពេលដែល CS បោះឆ្នោតជ្រើសតាំង DMK និង ក្រុមប្រឹក្សាខេត្តនិងរាជធានី ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនយោបាយនៅកម្ពុជា។ យោងតាមទ្រឹស្តី កំណែទម្រង់គួរតែញ៉ាំងឲ្យរដ្ឋាភិបាល ខិតទៅជិតប្រជាជនមូលដ្ឋាន ហើយឆ្លងតាមការចូលរួមជាលក្ខណៈប្រជាធិបតេយ្យ គួរតែបង្កើនភាពជាម្ចាស់របស់ប្រជាជនលើកម្មវិធីអភិវឌ្ឍផ្សេងៗក្នុងមូលដ្ឋាន ជួយលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវា និង ការកាត់បន្ថយភាពក្រីក្រ (Cheema and Rondinelli 2007; öjendaland 2008)។

ការអនុវត្តកំណែទម្រង់វិមជ្ឈការទូទាំងប្រទេសជួយបង្កើន សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងនយោបាយ របស់ប្រជាជនតាមមូលដ្ឋាន ដោយពួកគាត់អាចបញ្ចេញមតិពីការព្រួយបារម្ភ និងចំណង់ចំណូលចិត្តលើ អ្នកដឹកនាំ និងគម្រោងអភិវឌ្ឍន៍នានាក្នុងមូលដ្ឋាន។ សរុបមក កំណែទម្រង់បានផ្លាស់ប្តូរឥរិយាបទប្រជាជនក្នុងទំនាក់ទំនងជាមួយរដ្ឋអំណាចមូលដ្ឋាន និងបានធ្វើឲ្យប្រែប្រួលដល់បែបបទអនុវត្តនយោបាយក្នុងមូលដ្ឋាន (Ann 2008; Kim and Öjendal 2009; Öjendal and Kim 2006; Öjendal and Kim 2008)។ សព្វថ្ងៃ ប្រជាជនបានយល់ដឹងច្រើនហើយពីតួនាទីរបស់គាត់ ក្នុងការធ្វើអន្តរកម្មជាមួយរដ្ឋ (Heng and So 2012)។ ដោយមានសិទ្ធិសម្រេចលើការប្រើប្រាស់មូលនិធិឃុំ CS ឥឡូវនេះចូលរួមចំណែកក្នុងការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា ផ្លូវថ្នល់ និងប្រឡាយទឹក ដើម្បីឲ្យទ្រព្យសាធារណៈទាំងអស់នេះផ្តល់ប្រយោជន៍បានច្រើនបំផុតដល់ប្រជាជនក្នុងមូលដ្ឋាន (Plummer and Tritt 2012; RGC 2010a)។ CS មានសិទ្ធិអំណាចធំទូលាយក្នុងការលើកកម្ពស់របបប្រជាធិបតេយ្យ និងការអភិវឌ្ឍក្នុងមូលដ្ឋាន ដែលជួយរួមចំណែកកែលំអអភិបាលកិច្ច និងការចិញ្ចឹមជីវិតក្នុងភូមិស្រុក។ គួរកត់សំគាល់ថា មុខងាររដ្ឋបាលរបស់ រដ្ឋអំណាចមូលដ្ឋានមានជាសំខាន់ ការចុះបញ្ជីអត្រានុកូលដ្ឋាន រីឯតួនាទីក្នុងការផ្តល់សេវា ដូចជា ទឹក ការអប់រំ និងការគ្រប់គ្រងធនធានធម្មជាតិ គឺមានតិចតួច ឬក៏ទទួលយកអ្វីដែលមានស្រាប់ (Chea 2010; Öjendal and Kim 2011)។

---

[១] ឈាត ស្រ៊ាង ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI

គោលនយោបាយដែលបានផ្តោតការយកចិត្តទុកដាក់នាពេលថ្មីៗទៅលើ ការពង្រឹងតួនាទីរបស់ DMK ក្នុងការផ្តល់សេវានៅមូលដ្ឋាន (RGC 2010a,b) ជាការវិវឌ្ឍមួយល្អ ប៉ុន្តែគេប្រមើលឃើញថា នឹងមានបញ្ហាប្រឈមថ្មីៗផុសឡើងទៀត ជាពិសេសនៅពេលអ្នកគ្រប់គ្រងរដ្ឋបាលប្រឹងអនុវត្តតាមគោលការណ៍ជាមូលដ្ឋាននៃគណនេយ្យភាព ដែលរួមមាន ការពង្រឹងគណនេយ្យភាពពីលើចុះក្រោមនៃក្រុមប្រឹក្សាខេត្តនិងស្រុក ចំពោះសមាជិកក្រុមប្រឹក្សា CS ដែលបានបោះឆ្នោតឲ្យខ្លួន, អនុវត្តតាមគ្រប់លទ្ធភាពនូវគណនេយ្យភាពដោយផ្ទាល់របស់ក្រុមប្រឹក្សាស្រុក និងខេត្ត ចំពោះប្រជាពលរដ្ឋ, ពង្រឹងគណនេយ្យភាពនៃគណៈអភិបាលចំពោះក្រុមប្រឹក្សារបស់ខ្លួន ដោយមានការបែងចែកច្បាស់នូវអំណាចនិងមុខងារ និងបន្តផ្តោតលើគណនេយ្យភាព របស់ក្រុមប្រឹក្សា CS ចំពោះប្រជាពលរដ្ឋ (UNDP 2012) ។

ការស្រាវជ្រាវនេះមានគោលដៅ ពិនិត្យបញ្ហាគណនេយ្យភាពនៃរដ្ឋបាលមូលដ្ឋាន និងទំនាក់ទំនងរវាង ឃុំ (CS) នឹង ស្រុក (DMK) ដោយប្រើលទ្ធផលអង្កេតគោលធ្វើឡើងដោយ CDRI ក្នុងឆ្នាំ២០១១ (Chheat *et al.* 2011)។ អង្កេតនេះសំដៅស្វែងយល់ពីការយល់ឃើញអំពីកំណែទម្រង់វិមជ្ឈការ និងទំនាក់ទំនងរវាង CS និង DMK ក្នុងចំណោម សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈអភិបាល និងក្រុមប្រឹក្សា DMK ។ អង្កេតមានអ្នកឆ្លើយសម្ភាសន៍ ៩៥៤នាក់ក្នុងទូទាំងកម្ពុជា (៥៣១នាក់ ជាសមាជិក ក្រុមប្រឹក្សា CS និង ៤២៣នាក់ជាសមាជិកក្រុមប្រឹក្សា និងគណៈអភិបាល DMK)។ អង្កេតនេះមានបំពេញ បន្ថែមដោយ សម្ភាសន៍ស៊ីជម្រៅបែបគុណវិស័យនៅដើមឆ្នាំ ២០១២ ដើមឆ្នាំ២០១២ និងចុងឆ្នាំ២០១៣ លើជនបង្គោល (KIIs) ៥៧នាក់ ជា គណៈអភិបាល និងក្រុមប្រឹក្សា DMK និង សមាជិកក្រុមប្រឹក្សា CS ។

## ២. ទិដ្ឋភាពទូទៅនៃកំណែទម្រង់នៅកម្ពុជា

ដើម្បីសម្រេចគោលដៅក្នុងរយៈពេលវែងនៃការអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចពិតៗ និងការកាត់បន្ថយភាពក្រីក្រ កំណែទម្រង់វិមជ្ឈការនៅកម្ពុជាត្រូវរក្សាតុល្យភាពរវាងខ្សែរយៈផ្សេងៗនៃគណនេយ្យភាព (ឡើងលើ ចុះក្រោម ឬតាមខ្សែដេក)។ រចនាសម្ព័ន្ធរដ្ឋបាលមានបួនថ្នាក់នេះ ត្រូវបានបែងចែករដ្ឋបាល ឬរដ្ឋអំណាចបីកម្រិតខុសៗ គ្នា ដូចមានបង្ហាញក្នុង រូបភាព ១ ដែលក្នុងនោះ CS និង DMK គេហៅថា រដ្ឋបាលមូលដ្ឋាន (RGC 2010a) ។

កំណែទម្រង់បានប៉ះពាល់ដល់របៀបរបបនៃទំនាក់ទំនងថ្នាក់ជាតិ-ថ្នាក់មូលដ្ឋាន ហើយលទ្ធផលរំពឹងទុកនៃវិមជ្ឈការអាចមើលឃើញច្បាស់នៅក្នុងដំណើរការអនុវត្ត។ គោលនយោបាយកំណែទម្រង់របស់រដ្ឋាភិបាល បានកំណត់ឲ្យសម្រេចគោលដៅរយៈពេលវែងចំនួន ៣ គឺមានការពង្រឹងរបបប្រជាធិបតេយ្យក្នុងមូលដ្ឋាន ការលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ សម្រាប់គោលដៅទី១ គោលការណ៍ប្រជាធិបតេយ្យ រួមមាន ការតំណាងឲ្យការចូលរួម តម្លាភាពនិងគណនេយ្យភាព គឺមានអាទិភាពខ្ពស់ក្នុងរបៀបវារៈនៃកំណែទម្រង់ (RGC 2005)។ ក្របខ័ណ្ឌយុទ្ធសាស្ត្រក៏មានគ្រោងពី កំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងទាំងនៅកម្រិត DMK និង កម្រិតខេត្ត/រាជធានី ដើម្បីសម្រេចបានរដ្ឋបាលឯកភាពមួយសម្រាប់ ដោះស្រាយជាសំខាន់ លើបញ្ហាចោទជាយូរមកហើយក្នុងការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ និងដំណើរការធ្វើមជ្ឈការ (RGC 2005, 2010a)។

តារាង ១៖ គំនូរបង្ហាញរចនាសម្ព័ន្ធរដ្ឋបាលរបស់រដ្ឋាភិបាល




ចំណាំ: ព្រួញបង្ហាញពីខ្សែគណនេយ្យភាពរវាងអង្គភាពថ្នាក់ក្រោមជាតិដូចមានចែងនៅក្នុងឆ្នាំ២០០៨ នៃច្បាប់អង្គការ ។

ដូចមានបង្ហាញច្បាស់ក្នុងការងារស្រាវជ្រាវអន្តរជាតិកន្លងមក កំណែទម្រង់វិមជ្ឈការតែងជាដំណើរការ នយោបាយដ៏ស្មុគស្មាញ (Turner 1999; Manor 2011; Cheema and Rondinelli 2007) ហើយនៅកម្ពុជាក៏ដូច្នោះដែរ។ ដូចបានកំណត់ចេញតាំងពីដំបូង មានគោលគំនិតសំខាន់ៗ ដូចគ្នាពីរគឺ "វិមជ្ឈការ" និង "វិសហមជ្ឈការ" នៅក្នុងកំណែទម្រង់ដូចមានបញ្ជាក់ក្នុងឈ្មោះកំណែទម្រង់ស្រាប់។ តាមអត្ថន័យជាផ្លូវការ វិមជ្ឈការសំដៅជាសំខាន់ការផ្តល់សិទ្ធិអំណាចនិង ធនធានដល់ថ្នាក់ក្រោមជាតិ ក្នុងនេះមានទាំង CS ផង រីឯវិសហមជ្ឈការគេតែងសំគាល់ថា ជាការធ្វើប្រតិភូកម្មនូវធនធាន និងមុខងារទៅឲ្យថ្នាក់ក្រោមជាតិ ហើយពាក់ព័ន្ធជាសំខាន់ដល់ការផ្តល់សេវា (RGC ២០០៩)។ DMK ដែលមានលក្ខណៈពហុគណបក្ស គឺជាកម្រិតដែលទំនួលខុសត្រូវសម្រាប់ការផ្តល់សេវា ត្រូវបានធ្វើប្រតិភូកម្មទៅឲ្យអាជ្ញាធរបានធ្វើវិសហមជ្ឈការ និងជាថ្នាក់ទាបបំផុតក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ប្រទេសកម្ពុជា ដែលការចាត់តាំងបញ្ជូនមន្ត្រីបច្ចេកទេស និងមន្ត្រីការិយាល័យឲ្យទៅបម្រើការ ប៉ុន្តែមិនមែនគ្រប់ក្រសួងជំនាញសុទ្ធតែមានអ្នកតំណាងនៅកម្រិតនេះទេ។

គោលគំនិតបង្កើតរដ្ឋបាលឯកភាព គឺជាសមាសភាគសំខាន់បំផុតមួយនៃកំណែទម្រង់ ជាពិសេសក្នុងការបង្កើតស្ថាប័នរដ្ឋបាល DMK។ ក្នុងបញ្ហាទាក់ទងនឹងការធ្វើផែនការអភិវឌ្ឍន៍ជាច់ដោយដុំនៅកម្រិតនេះ ជាពិសេសរវាង ការិយាល័យជំនាញតាមវិស័យខុសៗគ្នា គឺគួរដោះស្រាយដោយដាក់ការិយាល័យជំនាញទាំងអស់ឲ្យស្ថិតក្រោមការដឹកនាំ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា DMK។ ម៉្យាងទៀត គណៈអភិបាល ទោះបីតែងតាំងឡើងដោយរដ្ឋាភិបាលកណ្តាលក្តី គឺត្រូវមានគណនេយ្យភាពតាមផ្លូវច្បាប់ចំពោះក្រុមប្រឹក្សានេះ។

ក្រុមប្រឹក្សា CS គេនៅតែចាត់ទុកជាតំណាងពេញច្បាប់ថ្នាក់មូលដ្ឋាន ក្នុងការជះឥទ្ធិពលនយោបាយទៅលើរដ្ឋអំណាចកម្រិតខ្ពស់ៗ ជាពិសេសនៅកម្រិត DMK។ គណនេយ្យភាពទាំង

នៅក្នុងរដ្ឋបាល DMK និងរវាងក្រុមប្រឹក្សា DMK និង CS នៅតែសំខាន់បំផុត។ ច្បាប់រៀបចំអង្គការឆ្នាំ២០០៨ ជំពូក៧ មានចែងជាសំខាន់ពីទំនាក់ទំនងរវាង DMK និង CS។ មាត្រា៩៨ ចែងថា "ក្រុមប្រឹក្សាស្រុក ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកអំពីជម្រើស សេចក្ដីសម្រេច ការអនុវត្តការងារ ព្រមទាំង ផលប៉ះពាល់នៃជម្រើស សេចក្ដីសម្រេច និងការអនុវត្តទាំងនោះ"។ មាត្រានេះ បំពេញបន្ថែមលើមាត្រា ៣៤ ដែលចែងថា "ក្រុមប្រឹក្សា (នៃរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ) ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្ដីសម្រេចធានាបានការអនុវត្ត តាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន"។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍរបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅកម្ពុជា (NP-SNDD) សម្រាប់ ១០ឆ្នាំខាងមុខ បានបញ្ជាក់ជាថ្មីថា ឃុំ/សង្កាត់ ដែលជាអង្គភាពរដ្ឋបាលទទួលបានការបោះឆ្នោតតែងតាំងដោយផ្ទាល់ ត្រូវក្លាយជាសំឡេងរបស់ប្រជាពលរដ្ឋ។ ដូច្នេះឃុំ/សង្កាត់ត្រូវធានាថា តម្រូវការអភិវឌ្ឍន៍ក្នុងដែនដីរបស់ខ្លួន ត្រូវបានដោះស្រាយដោយផ្ទាល់តាមអាចធ្វើបាន ឬតាមរយៈរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតខ្ពស់ៗ ដូចមានចែងក្នុងមុខងារដែលត្រូវផ្ទេរ។ ឃុំ/សង្កាត់ ក៏ត្រូវចាប់ឲ្យ ស្រុក ខណ្ឌ ក្រុង ខេត្ត និង រាជធានី មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ តាមរយៈការចូលរួមក្នុងយន្តការធ្វើសេចក្ដីសម្រេចចិត្តនានា ដូចជា មានអ្នកតំណាងក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងតាមរយៈសិទ្ធិទទួលបានព័ត៌មានសិទ្ធិពិនិត្យតាមដាន និងសិទ្ធិទទួលបានរបាយការណ៍ពីក្រុមប្រឹក្សាថ្នាក់ខ្ពស់ជាង និងតាមរយៈយន្តការនៃគណនេយ្យភាព រួមមាន ការដាក់ទណ្ឌកម្មចំពោះលទ្ធផលអនុវត្តបានអន់ខ្សោយនៃរដ្ឋអំណាចថ្នាក់ក្រោមជាតិនៅកម្រិតខ្ពស់ជាង (RGC 2010:4)។ ការងារទាំងនេះផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងគោលដៅនៃគោលនយោបាយពង្រឹងតួនាទីរបស់ CS ដើម្បីអាចជំរុញឲ្យ DMK មានគណនេយ្យភាពលើសកម្មភាពរបស់ខ្លួន។ គម្រោងបែបនេះមានមហិច្ឆតាខ្ពស់ ដូចជា ការតម្រង់ទិសឡើងវិញនូវវប្បធម៌នយោបាយបច្ចុប្បន្ននៅកម្ពុជា ដែលទាមទារឲ្យមានការប្រឹងប្រែងរួមគ្នា និងជាប់រហូត។ ការផ្ដល់សិទ្ធិអំណាចដល់ CS ដើម្បីចាប់ឲ្យរដ្ឋអំណាចថ្នាក់ខ្ពស់ជាង (ក្នុងករណីនេះ គឺ DMK) មានគណនេយ្យភាពលើការសម្រេចចិត្តរបស់ខ្លួន វាប្រទាំងប្រទើសជាខ្លាំងទៅនឹងវប្បធម៌ដែលតែងគោរពប្រណិប័តន៍អាជ្ញាធរថ្នាក់លើ ជាចៅហ្វាយនាយ។ ជាក់ស្ដែង សមាជិកក្រុមប្រឹក្សា CS ភាគច្រើនចាត់ទុក រដ្ឋបាលថ្នាក់ស្រុក/ខណ្ឌ និងរដ្ឋាភិបាលថ្នាក់ជាតិ ថាជាចៅហ្វាយរបស់ខ្លួន (Chheat *et al.* 2011; Kim and Öjendal 2009) ។

## ៣. លទ្ធផលស្រាវជ្រាវ

### ៣.១ គណនេយ្យភាពនៅក្នុង DMK

លទ្ធផលរំពឹងទុកដ៏ធំមួយនៃកំណែទម្រង់ គឺ រដ្ឋបាលឯកភាពនៅកម្រិត DMK និងដែលតាមនោះ កំណែទម្រង់ព្យាយាមញ៉ាំងឲ្យគោលនយោបាយមានភាពរលូនគ្នាល្អនៅថ្នាក់ក្រោមជាតិ ដោយដាក់ផែនការសកម្មភាពរបស់ការិយាល័យជំនាញខុសៗគ្នា ក៏ដូចជាគម្រោង និងធនធានផ្សេងៗ ឲ្យនៅក្រោមផែនការតែមួយ។ ក្រុមប្រឹក្សា DMK នឹងទទួលបានអំណាចផ្នែកនីតិប្រតិបត្តិ និងនីតិបញ្ញត្តិនៅកម្រិតនេះ និងមានសិទ្ធិអំណាចចាប់ឲ្យគណៈអភិបាល និងការិយាល័យជំនាញនានាមានគណនេយ្យភាព។ ការផ្លាស់ប្ដូរពីរនេះរួមមាន (i) ពង្រឹងការត្រួតមើលនិងថ្លឹងអំណាច

(Checks and balances) និងការបង្កើតស្ថាប័នថ្មី ដើម្បីការពារភាពពេញច្បាប់នៃក្រុមប្រឹក្សា និង (ii) ពង្រឹងគណនេយ្យភាពតាមខ្សែដេកនៃការិយាល័យជំនាញ (ដែលខុសពីបែបបទកន្លងមកនៃការពឹងផ្អែកលើ និងទទួលខុសត្រូវតែចំពោះមុខក្រសួងជំនាញថ្នាក់ជាតិ។ គេជឿថា វិធានការរដ្ឋបាលថ្មីៗទាំងនេះ នឹងជួយដោះស្រាយចំណុចខ្វះខាតជាលក្ខណៈរចនាសម្ព័ន្ធនៃគោលនយោបាយមិនរលូនគ្នា ហើយនាំឲ្យមានការសម្របសម្រួលកាន់តែប្រសើរផ្នែកគោលនយោបាយ ។

ទី១ កំណែទម្រង់បានបង្កើតនូវយន្តការតាមច្បាប់មួយសម្រាប់ ការត្រួតមើលនិងថ្លឹងអំណាចនៅថ្នាក់ក្រោមជាតិ។ក្រុមប្រឹក្សាDMKបានជួបប្រជុំគ្នាជារៀងរាល់ខែនិងបានបង្កើតគណៈកម្មាធិការផ្សេងៗតាមការតម្រូវក្នុងច្បាប់ ដើម្បីជួយដល់ការងាររបស់ខ្លួន មានជាអាទិ៍ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និង គណៈកម្មាធិការសម្រាប់កិច្ចការនារី និងកុមារ។ នៅខែតុលា ២០១៣ នាពេលថវិការបស់ពួកគេចាប់ផ្ដើមហូរចូល ក្រុមប្រឹក្សា DMK ក៏មានលទ្ធភាពបង្កើតគណៈកម្មាធិការលទ្ធកម្មផ្សេងៗបាន។ នៅពេលកំណែទម្រង់កំពុងដំណើរការទៅមុខ ការអនុវត្តយន្តការត្រួតមើលនិងថ្លឹងអំណាចដោយរដ្ឋអំណាចនៅកម្រិតនេះ កាន់តែមានលក្ខណៈស្វ័យតឡើង។ ផ្នែកនីតិប្រតិបត្តិ (គណៈអភិបាល) បានដឹងច្បាស់ថា ខ្លួនត្រូវមានគណនេយ្យភាពចំពោះ DMK។ លោក អភិបាល ឬអភិបាលរង (មានករណីលើកលែងតិចតួចណាស់) តែងចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សា DKM ប្រចាំខែ ដើម្បីរាយការណ៍ពីសកម្មភាពរបស់គណៈអភិបាលក្នុងខែកន្លងទៅ។

ទោះបីកំណែទម្រង់បានជួយពន្លឿនកំណើនក្ដី ក៏បច្ចុប្បន្នមិនមែនជាឱកាសល្អដើម្បីអបអរសាទរជោគជ័យនោះទេ។ ប្រព័ន្ធត្រួតមើលនិងថ្លឹងអំណាចដែលបង្កប់ក្នុងរចនាសម្ព័ន្ធតាមផ្លូវច្បាប់នៃ DMK គឺជាការឈានមួយជំហានចេញពីបែបបទចាស់ (ការិយាធិបតេយ្យពីលើចុះក្រោម) នៃការសម្រេចចិត្ត ដែលទម្រង់សព្វថ្ងៃនៃអភិបាលកិច្ចនៅកម្រិតនេះ។ ម្យ៉ាងទៀត "ឥរិយាបទចាស់" (ដែលក្នុងនោះ របៀបរបបផ្នែកនីតិប្រតិបត្តិ ពោលគឺ ការងារនយោបាយក្នុងមូលដ្ឋាន វាស្ថិតក្រោមការដឹកនាំនៃអាជ្ញាធរតែងតាំងឡើងដោយថ្នាក់មជ្ឈិម ព្រោះក្នុងមូលដ្ឋានពុំទាន់មានការបោះឆ្នោតជ្រើសតាំងអ្នកតំណាង) រំពឹងថា នឹងផ្លាស់ប្ដូរ។ ការផ្លាស់ប្ដូរកំពុងតែកើតឡើងទោះបីនៅយឺតៗក្ដី ហើយនៅតែជាបញ្ហាប្រឈម ជាពិសេស ការផ្លាស់ប្ដូរក្នុងរចនាសម្ព័ន្ធ និងឥរិយាបទ។ ឧទាហរណ៍ជាក់ស្ដែងមួយ គឺសមាជិកក្រុមប្រឹក្សាភាគច្រើនជាមន្ត្រីចូលនិវត្តន៍ដែលធ្លាប់បម្រើការយូរឆ្នាំនិងមានបទពិសោធន៍ហើយអ្នកតំណាងបែបនេះមានគេទិទានថាជាវិធានការនយោបាយមួយដីម្បីបង្កើតតួនាទីសម្រាប់ពួកអ្នកមានភក្ដីភាពចំពោះគណបក្ស។[២] យើងស្រាវជ្រាវឃើញទៀតថាក្រុមប្រឹក្សាDMKពុំមានសកម្មភាពកំណត់ដោយច្បាប់ឬក៏ថវិកាគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃទេ ហើយការចូលរួមក្នុងការប្រជុំប្រចាំខែនេះ គឺជាសកម្មភាពចម្បងតែមួយគត់។

គណនេយ្យភាពនៃគណៈអភិបាលចំពោះក្រុមប្រឹក្សា DMK មានចោទជាបញ្ហា និងមិនបានស្មើគ្នាល្អទេ។ គណៈអភិបាល និងក្រុមប្រឹក្សា ត្រូវការពេលវេលាច្រើនទៀតដើម្បីស្វែងយល់ពីគោលគំនិតនៃកំណែទម្រង់ និងរៀនធ្វើការជាមួយគ្នា ហើយឈានទៅកែលំអយន្តការត្រួតមើលនិងថ្លឹងអំណាចនៅថ្នាក់ក្រោមជាតិ។ ឥរិយាបថមិនសូវចង់ផ្លាស់ប្ដូរនេះ អាចមកពីអ្នកនយោបាយនៅតាមមូលដ្ឋានមានចំណេះដឹងតិចអំពីកំណែទម្រង់ និង នយោបាយរបស់គណបក្ស។ ក្របខ័ណ្ឌច្បាប់និងគោលនយោបាយបានកំណត់ឲ្យ គណៈអភិបាលត្រូវ រាយការណ៍ និងមាន

---

២ សម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សា DMK នៅខេត្តកំពង់ធំ, ថ្ងៃ២៥ មករា ២០១៣

គណនេយ្យភាពចំពោះក្រុមប្រឹក្សា DMK ក៏ពិតមែន ប៉ុន្តែនៅថ្នាក់មូលដ្ឋានមិនសូវមានការចាប់អារម្មណ៍ពីការផ្លាស់ប្តូរក្នុងច្បាប់នេះទេ។ អង្កេតរបស់ CDRI ក្នុងឆ្នាំ២០១១ បង្ហាញថា ជាង ៥០% នៃសមាជិកក្រុមប្រឹក្សាស្រុក និងឃុំយល់ថា គណៈអភិបាលស្រុកត្រូវរាយការណ៍ទៅជូនគណៈអភិបាលខេត្តរបស់ខ្លួន និងមានតែប្រមាណ ៣០% ប៉ុណ្ណោះដែលយល់ឃើញថា ខ្លួនត្រូវរាយការណ៍ទៅក្រុមប្រឹក្សា DKM របស់ខ្លួន (Chheat *et al.* ២០១១)។ តាមនេះ គណៈអភិបាលតែងចាត់ទុក ក្រុមប្រឹក្សាស្រុក ជាថ្នាក់ទី២ រីឯគណៈអភិបាលខេត្តជាថ្នាក់ទី១ ដែលខ្លួនត្រូវមានគណនេយ្យភាព (Chheat *et al.* 2011)។ កង្វះខាតការយល់ដឹងពីគោលដៅនៃកំណែទម្រង់បែបនេះ ត្រូវតែមានវិធានការដោះស្រាយ ដើម្បីពង្រឹងការត្រួតមើលនិងថ្លឹងអំណាចនៅកម្រិត DMK។

ទី២ កំណែទម្រង់ក៏មានគោលដៅញុំាំឲ្យមាន សេចក្តីសម្រេចចិត្តប្រកបដោយការសម្របសម្រួលគ្នាល្អនៅថ្នាក់មូលដ្ឋានដែរ អាចសម្រេចទៅបានលុះត្រាតែមានការពង្រឹងគណនេយ្យភាពតាមខ្សែដេក របស់មន្ត្រីរាជការនៅថ្នាក់នេះ។ ដើម្បីឲ្យកំណែទម្រង់នយោបាយហុចផលជាផ្លែផ្កា យន្តការទាំងនេះត្រូវតែរៀបចំឡើងដោយប្រយ័ត្នប្រយែង ហើយសម្រេចបានតុល្យភាពល្អរវាងគណនេយ្យភាពទាំងពីរបែប គឺ តាមខ្សែដេក និងតាមខ្សែបញ្ឈរព្រោះ៖

បើសិនអ្នកដឹកនាំដែលជាប់ឆ្នោតទទួលបានអំណាចធំធេង ត្រួតត្រាលើបុគ្គលិករបស់ក្រសួងជំនាញដែលពួកគេត្រូវពាក់ព័ន្ធការងារ (គ្រូបង្រៀនអ្នកជំនាញផ្នែកសុខភាព ភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម...) គឺពួកគេច្រើនតែប្រើអំណាចដោយទំនោរ។ ប៉ុន្តែ (គិតតាមបញ្ហាតែងជួបជាទូទៅ) បើសិនថ្នាក់ដឹកនាំដែលជាប់ឆ្នោតមានឥទ្ធិពលតិចតួចទៅលើអ្នកទាំងនោះវិញ បុគ្គលិករបស់ក្រសួងជំនាញក៏ច្រើនធ្វើទៅតាមអំពើចិត្តដែរ (Manor 2011: 11)។ មកទល់សព្វថ្ងៃ មានការរីកចម្រើនតិចតួចនៅឡើយនៅក្នុងគណនេយ្យភាពតាមខ្សែដេក។ ការិយាល័យជំនាញ គឺជាអ្នកផ្តល់សេវាដ៏សំខាន់នៅកម្រិត DMK ហើយចូលរួមជាទៀងទាត់ក្នុងកិច្ចប្រជុំ និងព្រឹត្តិការណ៍ផ្សេងៗ។ ប៉ុន្តែពួកគេក៏ត្រូវអនុវត្តផែនការ ក្នុងឋានៈជាភ្នាក់ងារនៃមន្ទីរជំនាញខេត្ត ឬក្រសួងជំនាញរៀងៗខ្លួនដែរ ដូច្នេះត្រូវមានគណនេយ្យភាពចំពោះមន្ទីរក្រសួងទាំងនោះ។ អាជ្ញាធរមូលដ្ឋាន និងអ្នកនយោបាយជឿថា ការផ្លាស់ប្តូរអាចកើតមានឡើងបាន លុះត្រាតែមានការប្រគល់មុខងារ និងធនធានសមស្របទៅឲ្យថ្នាក់ក្រោមជាតិ និងការដាក់អនុវត្តបទបញ្ញត្តិច្បាប់ផ្សេងៗ ដូចជាសេចក្តីព្រាងច្បាប់ស្តីពីមន្ត្រីរាជការថ្នាក់ក្រោមជាតិ ជាដើម។ ម្យ៉ាងទៀត កង្វះការយល់ដឹងពីខ្សែរយៈគណនេយ្យភាព របស់មន្ត្រីថ្នាក់ក្រោមជាតិនៅតែជាបញ្ហាមួយនៅក្នុងកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅកម្ពុជា។ ការស្ទង់មតិនៅឆ្នាំ២០១១ របស់ CDRI បង្ហាញថា សមាជិកក្រុមប្រឹក្សាឃុំរំពឹងថា បុគ្គលិកការិយាល័យជំនាញគឺមានគណនេយ្យភាពចំពោះ CS ជាទី១ និងក្រសួងជំនាញរបស់ខ្លួនជាទី២ រីឯស្រុក/ក្រុង ចាប់ឲ្យការិយាល័យជំនាញមានគណនេយ្យភាពចំពោះគណៈអភិបាល DMK ជាទី១ និង មន្ទីរក្រសួងជំនាញ ជាទី២ (Chheat *et al.* 2011)។

### ៣.២ ឃុំ/សង្កាត់ និង ស្រុក/ខណ្ឌ/ក្រុងៈ អ្នកតំណាងមានគណនេយ្យភាពឬទេ?

កំណែទម្រង់មានឥទ្ធិពលយ៉ាងខ្លាំងក្លា និងបានកែលំអការយល់ដឹងពីទំនាក់ទំនងរវាង ថ្នាក់រដ្ឋបាលទាំងពីរ ជាពិសេស ជំហរមានគណនេយ្យភាព។ អង្កេតនៅឆ្នាំ២០១១ បានរកឃើញថា អន្តរកម្មរបស់ពួកគេ បានជួបឧបសគ្គនៃកង្វះខាតការយល់ដឹងអំពីខ្សែគណនេយ្យភាពរវាងពួកគេ។ ខណៈដែល DMK តែងចាត់ទុកប្រជាជនថាជាខ្សែគណនេយ្យភាពដ៏ចម្បងរបស់ខ្លួន ខាងសមាជិកក្រុមប្រឹក្សា CS រំពឹងថា រដ្ឋបាលស្រុក/ក្រុង ត្រូវមានគណនេយ្យចំពោះខ្លួនជាចម្បង ពីព្រោះក្រុមប្រឹក្សា CS មានទំនុកចិត្តថា យ៉ាងហោចណាស់ក៏ការបោះឆ្នោត ជំរុញឲ្យ DMK មានគណនេយ្យភាពដែរ (Chheat *et al.* 2011)។ អង្កេតរកឃើញទៀតថា រដ្ឋបាល CS និង DMK មានទំនាក់ទំនងតែនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាស្រុក និងភាគច្រើនពីបញ្ហាសន្តិសុខ។ ម៉្យាងទៀត អ្នកតំណាងជាប់ឆ្នោតនៅតាមមូលដ្ឋាន ដោយសារគាត់មានចំណេះដឹងតិចអំពីច្បាប់រៀបចំអង្គការឆ្នាំ២០០៨ នោះគាត់ក៏ច្រើនតែមានការយល់ខុសអំពីខ្លឹមសារនៃទំនាក់ទំនងខាងលើ។ បញ្ហាប្រឈមធំៗផ្សេងទៀតរបស់ CS និង DMK ក្នុងការអនុវត្តតួនាទីធ្វើអភិវឌ្ឍន៍ក្នុងមូលដ្ឋាន គឺ កង្វះសមត្ថភាព កង្វះមូលនិធិ និងការរើសអើងផ្នែកនយោបាយ (Chheat *et al.* 2011) ។

ការយល់ខុសផ្សេងៗ ការច្រណែន និងការដណ្តើមអំណាចគ្នា ធ្វើឲ្យទំនាក់ទំនងរវាង CS និង DMK មានភាពតឹងតែង។ ការផ្តល់ការងារ និងថវិកាបន្ថែមទៅឲ្យកម្រិតណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើឲ្យបញ្ហាជាន់តួនាទីគ្នាអាចចោទកាន់តែខ្លាំងឡើង។ សមាជិកក្រុមប្រឹក្សា CS ភាគច្រើនត្អូញត្អែរថា ទោះបីខំធ្វើការខ្លាំងដូច្នេះក្តី ក៏នៅតែបានប្រាក់ខែតិច (ការលើកទឹកចិត្ត) បើធៀបនឹងសមាជិកក្រុមប្រឹក្សា DMK ដែលគ្រាន់តែមកចូលរួម ក្នុងកិច្ចប្រជុំប្រចាំខែ ហើយក្រៅពីនោះទំនេរស្រួលក្នុងការិយាល័យ។ ប៉ុន្តែពេល "ទំនេរ" របស់ DMK នេះ អាចបណ្តាលមួយចំណែកមកពីកង្វះធនធាន និងការយឺតយ៉ាវក្នុងការប្រគល់មុខងារ។ ភស្តុតាងជាក់ស្តែង បង្ហាញថា រដ្ឋអំណាចថ្នាក់មូលដ្ឋានមានការរំពឹងសង្ឃឹមយ៉ាងខ្ពស់ទៅលើ កំណែទម្រង់វិមជ្ឈការ ដែលនឹងមានការផ្ទេរមុខងាររដ្ឋទៅឲ្យកម្រិតផ្សេងៗនៃរដ្ឋអំណាចថ្នាក់ក្រោមជាតិ។

ទំនាក់ទំនងខាងលើ ឥឡូវនេះបានវិវត្តដល់ដំណាក់កាលថ្មីមួយ ដែលក្នុងនោះ CS និង DKM មានទំនួលខុសត្រូវរួមគ្នាក្នុងការជួយដោះស្រាយបញ្ហាប្រឈម និងក្តីកង្វល់របស់ប្រជាជនជាម្ចាស់ឆ្នោត ក្នុងឃុំ/ស្រុក របស់ខ្លួន។ ក្នុងអាណត្តិដំបូងនៃរដ្ឋបាល DMK គេឃើញថ្នាក់ឃុំ/សង្កាត់ មានអ្នកតំណាងយ៉ាងល្អនៅក្នុងការប្រជុំប្រចាំខែនៅថ្នាក់ស្រុក/ក្រុង។ ការរីកចម្រើនថ្មីៗនេះទៀត បង្ហាញថា ពួកគេមានការយល់ដឹងពីគ្នាកាន់តែប្រសើរ។ ដំណើរការនេះចាប់ផ្តើមពីឆ្នាំ២០១០ នៅពេលដែល DMK បានទៅចូលរួមជាផ្លូវការនិងជាទៀងទាត់ក្នុងកិច្ចប្រជុំប្រចាំខែរបស់ CS។ សមាជិក DMK ម្នាក់ៗមានភារកិច្ចចូលរួមក្នុងកិច្ចប្រជុំទាំងនោះ ដើម្បីរាយការណ៍អំពីសកម្មភាពនៅថ្នាក់ DMK និងស្តាប់របាយការណ៍អំពីសកម្មភាពនៅថ្នាក់មូលដ្ឋាន និងកត់ត្រានូវក្តីបារម្ភ និងបញ្ហាផ្សេងៗដែល CS ត្រូវប្រឈមមុខ ក្នុងពេលចាត់ចែងការងារនៅក្នុងមូលដ្ឋាន។

## ៤. សេចក្តីសន្និដ្ឋាន

ការសិក្សាបានបង្ហាញថានៅកម្រិត DMK រចនាសម្ព័ន្ធផ្នែកស្ថាប័នបានរឹងប៉ឹងឡើងក្លាយជាប្រព័ន្ធអាចដំណើរការបានពីការត្រួតមើលនិងថ្លឹងថ្លែងអំណាច។ ប៉ុន្តែការផ្លាស់ប្តូរនេះមិនបានស្មើភាព

គ្នាល្អទេ ព្រោះកំណែទម្រង់នៅក្មេងខ្ចី ហើយចំណេះដឹងអំពីកំណែទម្រង់របស់អ្នកនយោបាយ និងអាជ្ញាធរក្នុងមូលដ្ឋានក៏នៅមានកម្រិត។ បញ្ហាប្រឈមខាងសមត្ថភាពនេះ បានជះឥទ្ធិពលដល់គោលនយោបាយជាតិទាំងមូល។

នៅដំណាក់កាលដំបូងនៃកំណែទម្រង់នេះ ទំនាក់ទំនងរវាង CS និង DMK គួរមានលក្ខណៈជាប្រព័ន្ធ និងបំពេញឲ្យគ្នាទៅវិញទៅមក ជាជាងមិនបានស្មើគ្នាល្អ និងប្រកួតប្រជែងគ្នាដូច្នេះ។ ក្រៅពីនេះយើងអាចនិយាយបានថា ពុំមានការផ្លាស់ប្តូរអ្វីច្រើនផុសចេញពីកំណែទម្រង់នៅកម្រិត DMK នោះទេ។ ទន្ទឹមនឹងនេះ ចំណុចគួរកត់សម្គាល់នោះ គឺ ក្នុងចំណោម CS និង DMK នៅមានការយល់ដឹងតិចតួចអំពីតួនាទី និងការរំពឹងទុករបស់ខ្លួន។ ដោយឡែក គណនេយ្យភាពរបស់ DMK ចំពោះ CS នៅតែមិនទាន់ច្បាស់លាស់ និងមិនទាន់បានអនុវត្តនៅឡើយ។ បញ្ហានេះអាចបណ្តាលមួយចំណែកមកពី ការយល់ដឹង អំពីស្មារតីនៃកំណែទម្រង់នៅមានកម្រិត ហើយបំណងប្រាថ្នាចង់កែប្រែវប្បធម៌នយោបាយនៅកម្ពុជា ដែលផ្តល់អំណាចសម្រេចចិត្តដល់ អាជ្ញាធរថ្នាក់លើ និងអ្នកចាស់ទុំ គឺជាបំណងពោពេញដោយមហិច្ឆតាមួយខ្ពស់ហួសពេក។

ដើម្បីពង្រឹងតួនាទីរបស់អ្នកតំណាង CS នៅតាមមូលដ្ឋាន និងសម្រេចបាននូវរដ្ឋបាលឯកភាពមួយនៅថ្នាក់ DKM យើងគួរពិចារណាពីវិធានការផ្នែកគោលនយោបាយមួយចំនួនដូចតទៅ៖

- ផ្តល់មុខងារច្បាស់លាស់ដល់ CS និង DMK ដោយមានផ្តល់ធនធានសមស្រប ដើម្បីឲ្យពួកគេអាចឆ្លើយតបទៅនឹងតម្រូវការក្នុងមូលដ្ឋាន
- បញ្ជាក់បំភ្លឺអំពីគណនេយ្យភាពនៃ DMK ចំពោះ CS ដើម្បីរក្សាស្មារតីនៃគោលដៅកំណែទម្រង់ ក្នុងការពង្រឹងតួនាទីរបស់អ្នកតំណាងនៅថ្នាក់មូលដ្ឋាន ក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ
- លើកកម្ពស់ចំណេះដឹងអំពីកំណែទម្រង់ តាមរយៈការអភិវឌ្ឍសមត្ថភាពរបស់អ្នកនយោបាយ និងបុគ្គលិកការិយាល័យនៅតាមមូលដ្ឋាន ដែលអាចជួយកែលំអដំណើរមានគណនេយ្យភាពរបស់តួអង្គផ្សេងៗនៅក្នុងរដ្ឋបាលនៃ DMK និងនៅក្នុងទំនាក់ទំនងរវាង DMK និង CS ។

## ឯកសារយោង


Ann, S. (2008), *"Parton-Clientelism and Decentralisation: An Emerging Local Political Culture in Rural Cambodia"*, Master's thesis, Northern Illinois University, Dekalb

Chea C. (2010), *The Local Governance of the Common Pool Resources: The Case of Irrigation Water in Cambodia,* Working Paper Series No. 47 (Phnom Penh: CDRI)

Cheema, Shabir G. and Dennis A. Rondinelli (eds.) (2007), *Decentralizing Governance: Emerging Concepts and Practices* (Washington, DC: Brookings Institution Press)

Chheat S., Lun P., Kim S., Heng S., Sok S. and Chhoun N. (2011), *"A Baseline Survey of Sub-national Government: Towards a Better Understanding of Decentralisation and Deconcentration in Cambodia"*, Special Report 12 (Phnom Penh: CDRI)

Heng S. and So S. (2012),*"Citizens' Perceptions of Their Responsibilities: Preliminary Analysis of D&D's Contribution to Reciprocal State-Society Relations in Battambang Province"*, Annual Development Review 2012-2013 (Phnom Penh: CDRI) 8-21

Hughes, C.and N. Devas (2008), *"Review of the Draft Law on Administration and Management of the Capital, Province, Municipality, District, Khan"* (unpublished paper)

Kim S. and J. öjendal (2009),*"Decentralisation as a Strategy for State Reconstruction in Cambodia"*, in J. öjendal and M. Lilja (eds.), Beyond Democracy in Cambodia: Political Reconstruction in a Post-Conflict Society (Copenhagen: NIAS) 101-135

Manor, J. (2011), *Perspectives on Decentralisation*, Working Paper No. 3 (Visby, Sweden: International Centre for Local Democracy)

Meas, S. (2009),*"Comfrel Report Blasts Council Elections Scheduled for May"*, Phnom Penh Post,http://www.phnompenhpost.com/national/comfrel-report-blasts-council-elections-scheduled-may (accessed 17 October 2013)

NCDD, National Committee for Sub-National Democractic Development (2011), *"Situational Analysis 3: Capital/Provincial amd District/ Municipal/Khan Administration Management"* (Phnom Penh: NCDD)

Neth P. and G. Vilkins (2008), *"Monitoring Group to Boycott 'Predictable' Local Elections"*, http://newsgroups.derkeiler.com/Archive/Soc/soc.culture.cambodia/2008-12/msg00317.html (accessed 17 October 2013)

öjendal, J. and Kim S. (2006),*"'Korob, Kaud, Klach': In Search of Agency in Rural Cambodia)"*, Journal of Southeast Asian Studies, 37(3), 507

öjendal, J. and Kim S. (2008), *A Background Study on the District Office's Role and Potential Facing the Deconcentration and Decentralisation Reform* (G'teborg; Phnom Penh)

öjendal, J. and Kim S. (2011), Real Democratization in Cambodia? *An Empirical Review of the Potential of a Decentralization Reform*, Working Paper No.9. (Visby, Sweden: International Centre for Local Democracy)

Pak K. and Kruy V. (2011), *"Accountability in Cambodia: Relevant Concepts and their Application"*, Cambodia Development Review, Vol. 15 (Phnom Penh: CDRI)

Plummer, J. and G. Tritt (2012), *Voice, Choice and Decision: A Study of Local Governance Progress in Cambodia* (Phnom Penh: World Bank)

RGC, Royal Government of Cambodia (2005), *Strategic Framework for Decentralisation and Deconcentration Reforms*

RGC (2009), *Guidelines on Fundamental Principles for Sub-national Management and Administration* (Phnom Penh: NCDDS) (Khmer)

RGC (2010a), *First Implementing Plan (IP3) 2011-2013* (Phnom Penh: NCDD)

RGC (2010b), *National Program for Sub-National Democratic Development 2010-2019* (Phnom Penh: NCDD)

Turner, M. (ed.) (1999), *Central-Local Relations in Asia-Pacific: Convergence or Divergence?* (New York: St. Martin Press)

UNCDF, United Nations Capital Development Fund (2010), *"Local Development Outlook: Cambodia"* (Phnom Penh: UNCDF)

UNDP, United Nations Development Programme (2012), *"Project to Support Democratic Development through Decentralization and Deconcentration (PSDD)"*, Final Report (unpublished)

# បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន វបសអ

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន វបសអ-CDRI
អាចយកប្រើបាន ដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh


២៧. យឹម ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្មអភិបាលកិច្ចនិងបរិយាកាសសម្រាប់ការលូតលាស់* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

២៨. ព្រុំ តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជ័រទឹក* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

២៩. យឹម ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹង ទន្លេសាបទៅក្រុងភ្នំពេញ* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣០. Caroline Hughes និង គឹម សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រង ទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣២. K. A. S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣៣. Hansen, Kasper K. និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* ជាភាសាអង់គ្លេស

៣៤. ប៉ក់ គឹមជឿន, ហ៊ាង វុទ្ធី, អេង នេត្រា, អាន សុវត្ថា, គឹម សេតារា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* ជាភាសាអង់គ្លេស។

៣៥. គឹម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* ជាភាសាអង់គ្លេស

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅប្រទេសកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣៧. ចែម ផល្លា និងអ្នកឯទៀត (ឧសភា ២០០៨), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស

៣៨. ប៉ក់ គឹមជឿន និង David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* ជាភាសាអង់គ្លេស

៣៩. ហ៊ាង វុទ្ធី និង David Craig, *Accountability and Planning in Decentralised Cambodia* ជាភាសាអង់គ្លេស

៤០. អេង នេត្រា និង David Craig, *Accountability and Human Resource Management in Decentralised Cambodia* ជាភាសាអង់គ្លេស

៤១. ហ៊ីង វុត្ថា និង Hossein Jalilian ( មេសា ២០០៩ ) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាន នៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៤២. ធន់ វិមាលា, អ៊ូ ស៊ីវហួច, អេង នេត្រា និង លី តឹម ( តុលា ២០០៩ ), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces* ជាភាសាអង់គ្លេស
៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា ( ធ្នូ ២០០៩ ) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៤៤. ច័ន្ទ សុផល ( ធ្នូ ២០០៩ ) *ផលប្រយោជន៍និងចំណាយនៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៤៥. CDRI Publication ( December 2009 ), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam*
៤៦. CDRI Publication ( December 2009 ), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries*
៤៧. ជា ជូ ( សីហា ២០១០ ) *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia*
៤៨. CDRI Publication ( August 2010 ), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*
៤៩. ចែម ផល្លា និង សុមេធ ប៉ារ៉ាឌី (មីនា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួម ស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៥០. ប៉ក់ គឹមជឿន ( ឧសភា ២០១១ ) *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់។*
៥១. Christopher Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths ( June 2011 ), *Irrigation Water Productivity in Cambodian Rice System* ជាភាសាអង់គ្លេស
៥២. អ៊ូច ច័ន្ទតារ៉ានី, សាំង ច័ន្ទហង្ស និង ផាន់ ដាលីស (មិថុនា ២០១១), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៥៣. ច័ន្ទ សុភក្តិ, Nathan Wales and Tim Frewer ( សីហា ២០១១ ), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស
៥៤. ណាំង ភិរុណ, ខៀវ ដារ៉ាវី, Philip HIRSCH និង Isabelle WHITEHEAD (កក្កដា ២០១១) *លើកកម្ពស់អភិបាលកិច្ចធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៥៥. គឹម សុធន, ឈឹម ឈន់, ថេង វុទ្ធី និង សូ សុវណ្ណារិទ្ធ (កក្កដា ២០១១) *Policy Coherence in Agricultural and Rural Development: Cambodia* ជាភាសាអង់គ្លេស
៥៦. តុង គឹមស៊ុន, ហែម សុចិត្រ និង Paulos Santos (កក្កដា ២០១១), *What Limits Agricultural Intensification in Cambodia? The role of emigration, agricultural extension services and credit constraints* ជាភាសាអង់គ្លេស
៥៧. Tong Kimsun, Hem Socheth and Paulos Santos (August 2011), *The Impact of Irrigation on Household Assets* ជាភាសាអង់គ្លេស
៥៨. ហ៊ីង វុត្ថា, លន់ ពិដេ និង ផាន់ ដាលីស (សីហា ២០០១) *ទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៥៩. ចែម ផល្លា, Philip Hirsch និង សុមេធ ប៉ាភាឌី (កញ្ញា ២០០១), *Hydrological Analysis in Support of Irrigation Management: A Case Study of Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស
៦០. សាំង ច័ន្ទហង្ស, ហែម សុចិត្រ និង អ៊ួច ច័ន្ទតារានី ជាមួយ ផាន់ ដាលីស និង ប៊ុន ដូរីណា (កញ្ញា ២០១១) *Foreign Investment in Agriculture in Cambodia* ជាភាសាអង់គ្លេស
៦១. រស់ បណ្ដែត, លី តឹម និង Anna Thompson (កញ្ញា ២០០១), *Catchment Governance and Cooperation Dilemmas: A Case Study from Cambodia* ជាភាសាអង់គ្លេស
៦២. ជា ជូ, ណាំង ភិរុណ, Isabelle Whitehead, Phillip Hirsch and Anna Thompson (តុលា ២០១១), *Decentralised Governance of Irrigation Water in Cambodia: Matching Principles to Local Realities* ជាភាសាអង់គ្លេស និងខ្មែរ
៦៣. ហេង សីហា, គឹម សេដារា និង សូ សុខប៊ុនធឿន (តុលា ២០១១), *Decentralised Governance in Hybrid Polity: Localisation of Decentralisation Reform in Cambodia* ជាភាសាអង់គ្លេស
៦៤. តុង គឹមស៊ុន និង ស្រ៊ី បុប្ផារ័ត្ន (វិច្ឆិកា ២០១១), *Poverty and Evironment Links: The Case of Rural Cambodia* ជាភាសាអង់គ្លេស
៦៥. រស់ បានសុខ, ណាំង ភិរុណ និង ឈឹម ឈន់(ធ្នូ ២០១១), *Agricultural Development and Climate Change: The Case of Cambodia* ជាភាសាអង់គ្លេស
៦៦. តុង គឹមស៊ុន (កុម្ភៈ ២០១២), *Analysing Chronic Poverty in Rural Cambodia Evidence from Panel Data* ជាភាសាអង់គ្លេស
៦៧. Keith Carpenter ដោយមានជំនួយពី ប៊ុន ដូរីណា (កុម្ភៈ ២០១២), *A Basic Consumer Price Index for Cambodia 1993–2009* ជាភាសាអង់គ្លេស
៦៨. រ័ត្ន វឌ្ឍនា (មីនា ២០១២), *Sectoral Composition of China's Economic Growth, Poverty Reduction and Inequality: Development and Policy Implications for Cambodia* ជាភាសាអង់គ្លេស
៦៩. CDRI Publication (March 2012), *Understanding Poverty Dynamics: Evidence from Nine Villages in Cambodia* ជាភាសាអង់គ្លេស
៧០. ហ៊ីង វុត្ថា, សាំង ច័ន្ទហង្ស និង យាង សុធី (សីហា ២០១២), *Baseline Survey for Socioeconomic Impact Assessment: Greater Mekong Sub-region Transmission Project* ជាភាសាអង់គ្លេស

៧១. គឹម សេដារា និង Joakim Öjendal ជាមួយ ឈួន ណារ៉េត និង លី តឹម (ធ្នូ ២០១២), *A Gendered Analysis of Decentralisation Reform in Cambodia* ជាភាសាអង់គ្លេស
៧២. ហែម សុចិត្រ (មីនា ២០១៣), *Impact of the Global Financial Crisis on Cambodian Economy at Macro and Sectoral Levels*
៧៣. ហៃ សុវុទ្ធា (មីនា ២០១៣), *Government Response to Inflation Crisis and Global Financial Crisis*
៧៤. ងិន ច័ន្ទរិទ្ធ (មីនា ២០១៣), *Impact of the Global Financial Crisis on Employment in SMEs in Cambodia*
៧៥. តុង គឹមស៊ុន (មីនា ២០១៣), *Impact of the Global Financial Crisis on Poverty: Evidence from Nine Villages in Cambodia*
៧៦. ហ៊ីង វុត្ថា (មីនា ២០១៣), *Impact of the Global Financial Crisis on the Rural Labour Market: Evidence from Nine Villages in Cambodia*
៧៧. សាំង ច័ន្ទហង្ស (មីនា ២០១៣), *Household Vulnerability to Global Financial Crisis and Their Risk Coping Strategies: Evidence from Nine Rural Villages in Cambodia*
៧៨. តុង គឹមស៊ុន និង ផៃ សុខចេង (មីនា ២០១៣), *The Role of Income Diversification during the Global Financial Crisis: Evidence from Nine Villages in Cambodia*
៧៩. លន់ ពិដេ (មីនា ២០១៣), *The Role of Rural Credit during the Global Financial Crisis: Evidence From Nine Villages in Cambodia*
៨០. សាំង ច័ន្ទហង្ស (មីនា ២០១៣), *Binding Constraints on Economic Growth in Cambodia: A Growth Diagnostic Approach*
៨១. ហ៊ីង វុត្ថា (មិថុនា ២០១៣), *Leveraging Trade for Economic Growth in Cambodia*
៨២. ណាំង ភិរុណ (មិថុនា ២០១៣), *Climate Change Adaptation and Livelihoods in Inclusive Growth: A Review of Climate Change Impacts and Adaptive Capacity in Cambodia*
៨៣. តុង គឹមស៊ុន, លន់ ពិដេ និង ស្រ៊ី បុប្ផារ័ត្ន ជាមួយ ប៊ុន ដូរីណា (សីហា ២០១៣), *Levels and Sources of Household Income in Rural Cambodia 2012*
៨៤. អ៊ូ ស៊ីវហ្វួច (សីហា ២០១៣), *Sub-National Civil Society in Cambodia: A Gramscian Perspective*
៨៥. អ៊ូ ស៊ីវហ្វួច និង គឹម សេដារា (សីហា ២០១៣), *20 Years' Strengthening of Cambodian Civil Society: Time for Reflection*
៨៦. សែន វិចិត្រ និង រស់ សុវិជ្ជា ជាមួយ ហៀង ធីរ៉ាភមរី (តុលា ២០១៣), *Anatomy of Higher Education Governance in Cambodia*
៨៧. គឹម សេដារា និង Joakim Öjendal ជាមួយ ឈួន ណារ៉េត (វិច្ឆិកា ២០១៣), *Gatekeepers in Local Politics: Political Parties in Cambodia and their Gender Policy*
៨៨. ឈាត ស្រ៊ាង (ធ្នូ ២០១៣), *Impact of Decentralisation on Cambodia's Urban Governance*
៨៩. ណាំង ភិរុណ និង អ៊ួច ឈួង (មករា ២០១៤), *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change*
៩០. A CDRI Publication (មករា ២០១៤), *ASEAN 2030: Growing Together for Economic Prosperity – the Challenges*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ ទូរស័ព្ទ៖ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣

🖷 ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ www.cdri.org.kh





តម្លៃ ៨០០០៛

9 789996 352898